ទីស្តីការគណៈរដ្ឋមន្ត្រី
គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់

# កម្រងវិសោធនកម្មរដ្ឋធម្មនុញ្ញ
# នៃព្រះរាជាណាចក្រកម្ពុជា

ប្រមូលចងក្រង និងរៀបរៀងដោយ
គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់

មីនា ២០២៦

# បុព្វកថា

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ គឺជាច្បាប់កំពូលដែលកំណត់គោលការណ៍មូលដ្ឋាននៃប្រជាធិបតេយ្យ សេរីពហុបក្ស ការគោរពសិទ្ធិមនុស្ស នីតិរដ្ឋ និងការបែងចែកអំណាចដោយឡែកពីគ្នា។ រាប់ចាប់តាំងពីការប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ មក កម្ពុជាបានអនុវត្តនូវការកែទម្រង់ជាបន្តបន្ទាប់ដើម្បីធានាថារដ្ឋធម្មនុញ្ញអាចឆ្លើយតបនឹងការវិវត្តសង្គមនយោបាយ សេដ្ឋកិច្ច និងទំនាក់ទំនងអន្តរជាតិ។

ឯកសារនេះគឺជាការស្រាវជ្រាវ និងប្រមូលផ្តុំវិសោធនកម្មរដ្ឋធម្មនុញ្ញចំនួន ១១លើក ដែលបានអនុម័តនិងពិនិត្យដោយស្ថាប័ននីតិប្បញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជា និងប្រកាសឱ្យប្រើដោយ **អង្គព្រះមហាក្សត្រ** ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត។ វិសោធនកម្មទាំងនេះ មិនត្រឹមតែបង្ហាញពីការរីកចម្រើននៃប្រព័ន្ធច្បាប់កម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់ព្រះរាជាណាចក្រកម្ពុជាក្នុងការការពារបូរណភាពនិងអធិបតេយ្យភាពរបស់ជាតិ ភាពខ្លាំងនិងរឹងមាំរបស់ជាតិ សុខុមាលភាពរបស់ប្រជាជន ការពង្រឹងនីតិរដ្ឋ ប្រសិទ្ធភាពស្ថាប័នសាធារណៈ និងសន្តិសុខគតិយុត្ត។

ក្នុងបរិបទនៃការអនុវត្តក្របខ័ណ្ឌយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់ច្បាប់របស់រាជរដ្ឋាភិបាល ដែលបានប្រកាសដាក់ឱ្យអនុវត្តកាលពីថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៥ ដោយ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ការរៀបចំ វិភាគនិងបោះពុម្ពផ្សាយឯកសារវិសោធនកម្មរដ្ឋធម្មនុញ្ញនេះ គឺដើម្បីរួមចំណែកក្នុងការអនុវត្តយុទ្ធសាស្ត្រគន្លឹះនៃកម្មវិធីកែទម្រង់ច្បាប់ ជាពិសេសនៅដំណាក់កាលទី១ ដែលត្រូវផ្សព្វផ្សាយច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានាជាសាធារណៈតាមបែបប្រពៃណីជាឯកសារ និងបែបទំនើបឬឌីជីថលជាលិខិតទន់ (ពិនិត្យានុភាវូបនីយកម្មគតិយុត្ត)។ សៀវភៅនេះ ក៏ជាផ្នែកមួយនៃការពង្រឹងវប្បធម៌នៃការគោរពច្បាប់ នីត្យានុកូលភាព ការលើកកម្ពស់ភាពច្បាស់លាស់នៃច្បាប់ និងភាពអាចព្យាករណ៍បាននៃប្រព័ន្ធច្បាប់ ព្រមទាំងការជំរុញការចូលរួមរបស់សាធារណជន និងអ្នកស្រាវជ្រាវក្នុងការយល់ដឹងអំពីការវិវត្តនៃរដ្ឋធម្មនុញ្ញ ដែលជាច្បាប់កំពូលរបស់កម្ពុជា។

វិសោធនកម្មរដ្ឋធម្មនុញ្ញត្រូវបានអនុវត្តដោយគោរពយ៉ាងតឹងរ៉ឹងតាមនីតិវិធី និងគោលការណ៍ដែលបានកំណត់ក្នុងរដ្ឋធម្មនុញ្ញផ្ទាល់។ នេះបង្ហាញថា ការកែទម្រង់ត្រូវបានធ្វើឡើងក្នុងក្របខ័ណ្ឌនៃច្បាប់ និងដោយគោរពដល់គោលការណ៍នីតិរដ្ឋ។ វិសោធនកម្មទាំង១១លើក មានបំណងធ្វើឱ្យប្រព័ន្ធស្ថាប័នរដ្ឋមានភាពច្បាស់លាស់ ប្រសិទ្ធភាព និងសមស្របទៅនឹងតម្រូវការអភិវឌ្ឍជាតិ និងសមាហរណកម្មជាមួយសហគមន៍អន្តរជាតិ។

ខ្ញុំសូមកោតសរសើរ និងថ្លែងអំណរគុណដល់អគ្គលេខាធិការដ្ឋាន **គ.ក.ច.** ក្រោមការដឹកនាំរបស់ **ឯកឧត្តម លី ច័ន្ទតុលា** ជាពិសេស ថ្នាក់ដឹកនាំនិងមន្ត្រីរាជការ អ្នកជំនាញការច្បាប់ និងក្រុមស្រាវជ្រាវទាំងអស់ ដែលបានខិតខំប្រឹងប្រែងក្នុងការប្រមូលផ្តុំ រៀបចំ និងវិភាគវិសោធនកម្មទាំងនេះប្រកបដោយវិជ្ជាជីវៈ។ ខ្ញុំជឿជាក់ថា ឯកសារនេះនឹងក្លាយជាឯកសារយោងដ៏មានតម្លៃសម្រាប់មន្ត្រីរាជការ អ្នកសិក្សា អ្នកស្រាវជ្រាវ និងសាធារណជនទូទៅ ក្នុងការយល់ដឹងអំពីដំណើរនៃការធ្វើវិសោធនកម្មនិងការវិវត្តនៃរដ្ឋធម្មនុញ្ញ និងការអភិវឌ្ឍនីតិរដ្ឋនៅកម្ពុជា។

សូមឱ្យការបោះពុម្ពផ្សាយនេះរួមចំណែកជំរុញការយល់ដឹងជាសាធារណៈ ការពង្រឹងវប្បធម៌គោរពច្បាប់ និងការអភិវឌ្ឍប្រព័ន្ធច្បាប់កម្ពុជាឱ្យកាន់តែរឹងមាំនិងប្រសើរឡើងជាបន្តបន្ទាប់ ស្របតាមចក្ខុវិស័យដែលបានកំណត់ក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់ច្បាប់ ក៏ដូចជាយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលកម្ពុជា។

ថ្ងៃសុក្រ ២កើត ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៦

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធាន គ.ក.ច.**

**វង្សី វិស្សុត**

## អារម្ភកថា

ការរៀបចំនិងបោះពុម្ពផ្សាយសៀវភៅ «**កម្រងវិសោធនកម្មរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា**» គឺជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងជាបន្តបន្ទាប់របស់គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ (គ.ក.ច.) ក្នុងការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃប្រព័ន្ធច្បាប់កម្ពុជា។ សៀវភៅនេះមានគោលបំណងប្រមូលផ្តុំ រៀបចំ និងវិភាគវិសោធនកម្មរដ្ឋធម្មនុញ្ញដែលបានប្រកាសឱ្យប្រើតាំងពីឆ្នាំ១៩៩៣មក ដើម្បីផ្តល់ជាឯកសារយោងដ៏ទូលំទូលាយ និងមានលក្ខណៈជាប្រព័ន្ធសម្រាប់ការសិក្សាស្រាវជ្រាវ និងការអនុវត្ត។

ក្នុងនាមជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ ខ្ញុំសូមគោរពសម្តែងនូវការដឹងគុណដ៏ខ្ពង់ខ្ពស់ចំពោះ **ឯកឧត្តម វង្សី វិស្សុត ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធាន** គ.ក.ច. ដែលបានដឹកនាំ ត្រួតពិនិត្យ និងផ្តល់អនុសាសន៍ដឹកនាំជាប្រចាំលើការអនុវត្តកម្មវិធីកែទម្រង់ច្បាប់របស់រាជរដ្ឋាភិបាល។ ការដឹកនាំប្រកបដោយចក្ខុវិស័យ យុទ្ធសាស្ត្រ និងការយកចិត្តទុកដាក់ខ្ពស់របស់**ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ** បានផ្តល់ទិសដៅច្បាស់លាស់ និងជំរុញឱ្យការងារកែទម្រង់ច្បាប់នៅកម្ពុជាទទួលបានលទ្ធផលជាក់ស្តែងជាច្រើន និងមានប្រសិទ្ធភាពខ្ពស់។

ក្នុងន័យនេះ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ បានអនុវត្តតួនាទីភារកិច្ចស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន និងក្របខ័ណ្ឌយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់ច្បាប់របស់រាជរដ្ឋាភិបាលកម្ពុជា ដោយផ្តោតលើការពិនិត្យ កែលម្អ និងធានាឱ្យមានធម្មនុញ្ញភាពរវាងច្បាប់នានាជាមួយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលជាច្បាប់គ្រឹះនិងជាច្បាប់កំពូលរបស់ជាតិ។ សៀវភៅនេះបង្ហាញពីវិសោធនកម្មរដ្ឋធម្មនុញ្ញ ដែលត្រូវបានអនុវត្តតាមនីតិវិធី និងគោលការណ៍នីតិរដ្ឋយ៉ាងតឹងរ៉ឹង ក្រោមគំនិតផ្តួចផ្តើមរបស់ឥស្សរជនជាថ្នាក់ដឹកនាំកំពូលៗរបស់ប្រទេសជាតិយើង។

ខ្ញុំសូមកោតសរសើរនិងវាយតម្លៃខ្ពស់ចំពោះថ្នាក់ដឹកនាំនិងមន្ត្រីទាំងអស់ ដែលបានចូលរួមចំណែកយ៉ាងសកម្មក្នុងការស្រាវជ្រាវ ប្រមូលផ្តុំ វិភាគនិងរៀបចំឯកសារនេះឱ្យមានលក្ខណៈពេញលេញគ្រប់ជ្រុងជ្រោយ និងត្រឹមត្រូវ។ កិច្ចខិតខំរបស់ក្រុមការងារនេះពិតជាបានរួមចំណែកយ៉ាងសំខាន់ក្នុងការពង្រឹងមូលដ្ឋានចំណេះដឹងផ្នែកច្បាប់ និងលើកកម្ពស់វប្បធម៌នៃការគោរពច្បាប់នៅកម្ពុជា។

ខ្ញុំមានសេចក្តីសង្ឃឹមថា សៀវភៅនេះនឹងក្លាយជាឯកសារយោងដ៏មានតម្លៃសម្រាប់មន្ត្រីរាជការ អ្នកសិក្សា អ្នកស្រាវជ្រាវ សិស្ស និស្សិត និងសាធារណជនទូទៅ ក្នុងការយល់ដឹងអំពីវិសោធនកម្មរដ្ឋធម្មនុញ្ញ និងការអភិវឌ្ឍនីតិរដ្ឋនៅកម្ពុជា។ សូមឱ្យសៀវភៅនេះបានរួមចំណែកគាំទ្រដល់ការអនុវត្ត

ក្របខ័ណ្ឌយុទ្ធសាស្ត្រ នៃកម្មវិធីកែទម្រង់ច្បាប់របស់រាជរដ្ឋាភិបាល និងបានរួមចំណែកក្នុងការកសាង ប្រព័ន្ធច្បាប់កម្ពុជាឱ្យកាន់តែរឹងមាំស្របតាមចក្ខុវិស័យអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាលកម្ពុជា។

ថ្ងៃ សុក្រ ២កើត ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែមីនា ឆ្នាំ២០២៦

**រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី**

**អនុប្រធាន និងជាអគ្គលេខាធិការ**

**លី ច័ន្ទតុលា**

# មាតិកា

**ផ្នែកទី១ ប្រវត្តិនៃការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា.. ១**

វិសោធនកម្មលើកទី១ (១៩៩៤) ........ ២

វិសោធនកម្មលើកទី២ (១៩៩៩) ........ ៤

វិសោធនកម្មលើកទី៣ (២០០១) ........ ៣១

វិសោធនកម្មលើកទី៤ (២០០៥) ........ ៣៣

វិសោធនកម្មលើកទី៥ (២០០៦) ........ ៣៥

វិសោធនកម្មលើកទី៦ (២០០៨) ........ ៤១

វិសោធនកម្មលើកទី៧ (២០១៤) ........ ៤២

វិសោធនកម្មលើកទី៨ (២០១៨) ........ ៥០

វិសោធនកម្មលើកទី៩ (២០២១) ........ ៥៤

វិសោធនកម្មលើកទី១០ (២០២២) ........ ៦០

វិសោធនកម្មលើកទី១១ (២០២៥) ........ ៦៧

**ផ្នែកទី២ ព្រះរាជក្រមប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា........ ៧០**

វិសោធនកម្មលើកទី១ ........ ៧១

វិសោធនកម្មលើកទី២ ........ ៧៤

វិសោធនកម្មលើកទី៣ ........ ៩២

វិសោធនកម្មលើកទី៤ ........ ៩៥

វិសោធនកម្មលើកទី៥ ........ ៩៩

វិសោធនកម្មលើកទី៦ ........ ១០៦

វិសោធនកម្មលើកទី៧ ........ ១០៩

វិសោធនកម្មលើកទី៨ ........ ១១៦

វិសោធនកម្មលើកទី៩ ........ ១២១

វិសោធនកម្មលើកទី១០ ...................................................................................... ១២៧

វិសោធនកម្មលើកទី១១ ......................................................................................១៣៤

**ឧបសម្ព័ន្ធ១ សេចក្ដីថ្លែងហេតុនៃវិសោធនកម្ម រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ........................................................................................................១៣៧**

សេចក្ដីថ្លែងហេតុនៃវិសោធនកម្ម លើកទី១ (គ្មាន)..................................................១៣៨

សេចក្ដីថ្លែងហេតុនៃវិសោធនកម្មលើកទី២ ............................................................១៣៩

សេចក្ដីថ្លែងហេតុនៃវិសោធនកម្មលើកទី៣ ............................................................១៤២

សេចក្ដីថ្លែងហេតុនៃវិសោធនកម្មលើកទី៤............................................................ ១៤៥

សេចក្ដីថ្លែងហេតុនៃវិសោធនកម្មលើកទី៥............................................................ ១៤៨

សេចក្ដីថ្លែងហេតុនៃវិសោធនកម្មលើកទី៦............................................................ ១៥១

សេចក្ដីថ្លែងហេតុនៃវិសោធនកម្មលើកទី៧ ............................................................ ១៥៤

សេចក្ដីថ្លែងហេតុនៃវិសោធនកម្មលើកទី៨............................................................ ១៥៦

សេចក្ដីថ្លែងហេតុនៃវិសោធនកម្មលើកទី៩............................................................ ១៥៨

សេចក្ដីថ្លែងហេតុនៃវិសោធនកម្មលើកទី១០ .......................................................... ១៦៤

សេចក្ដីថ្លែងហេតុនៃវិសោធនកម្មលើកទី១១ .......................................................... ១៧៧

**ឧបសម្ព័ន្ធ២ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ ១៩៩៣ ............................................................................................................ ១៨៣**

**ឧបសម្ព័ន្ធ៣ ច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤..........................................................................២៣៣**

**ឧបសម្ព័ន្ធ៤ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (គិតត្រឹមថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៦)................................................................................................... ២៣៩**

# ផ្នែកទី១
# ប្រវត្តិនៃការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ
# នៃព្រះរាជាណាចក្រកម្ពុជា

# ប្រវត្តិនៃការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ
# នៃព្រះរាជាណាចក្រកម្ពុជា

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានសភាធម្មនុញ្ញអនុម័តនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ ហើយត្រូវបានព្រះមហាក្សត្រឡាយព្រះហស្តលេខាលើព្រះរាជក្រមប្រកាសឱ្យប្រើនៅថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ១៩៩៣។ គិតត្រឹមឆ្នាំ២០២៥ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ ត្រូវបានធ្វើវិសោធនកម្មចំនួន១១លើក ក្នុងគោលបំណងដើម្បីធានានូវនិរន្តរភាពជាតិ ក៏ដូចជាការធានាការពារនូវឧត្តមប្រយោជន៍ជាតិ និងប្រជាជនកម្ពុជា ដូចខាងក្រោម៖

## វិសោធនកម្មលើកទី១ (១៩៩៤)

ច្បាប់ស្តីពីការកែប្រែ មាត្រា២៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាអនុម័តនៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៩៤ នាសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញនីតិកាលទី១។ ច្បាប់ស្តីពីការកែប្រែមាត្រា២៨នេះ ត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមចុះថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ១៩៩៤។ វិសោធនកម្មនេះធ្វើឡើងដើម្បីធ្វើប្រតិភូកម្មព្រះហស្តលេខាព្រះមហាក្សត្រជូនទៅប្រមុខរដ្ឋស្តីទី។

វិសោធនកម្មរដ្ឋធម្មនុញ្ញលើកទី១នេះ កើតឡើងដោយសារតម្រូវការជាក់ស្តែងក្នុងអំឡុងពេលដែល **ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ** ស្តេចយាងជាញឹកញាប់ទៅកាន់ប្រទេសចិនដើម្បីពិនិត្យព្រះរាជសុខភាព។ ក្នុងស្ថានភាពនេះ មានសំណួរថា តើព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រម ឬព្រះរាជក្រឹត្យ ដើម្បីប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញ ឬច្បាប់ផ្សេងៗ ខណៈពេលដែលព្រះអង្គស្ថិតនៅក្រៅប្រទេសកម្ពុជាបានដែរឬទេ?

បន្ថែមពីលើនេះ ក៏មានសំណួរលើកឡើងថា តាមមាត្រា៣០ នៃរដ្ឋធម្មនុញ្ញ ដែលកំណត់ថា នៅពេលព្រះមហាក្សត្រទ្រង់អវត្តមាន ប្រធានរដ្ឋសភាត្រូវបំពេញភារកិច្ចជាប្រមុខរដ្ឋស្តីទី តើប្រធានរដ្ឋសភាមានសិទ្ធិប្រកាសឱ្យប្រើច្បាប់ដែរឬទេ? ដោយសារនៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៩៤ ក្រុមប្រឹក្សាធម្មនុញ្ញមិនទាន់ដំណើរការនៅឡើយ សំណើសម្រាប់វិសោធនកម្មលើកទី១នេះ ត្រូវបានដំណើរការដោយរដ្ឋសភាខ្លួនឯង ដោយគ្មានការពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាធម្មនុញ្ញទេ។

ដោយសារតែគ្មានមាត្រាណាមួយក្នុងរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ (ច្បាប់ដើម) កំណត់អំពីអំណាចក្នុងការចុះហត្ថលេខាលើព្រះរាជក្រម ឬព្រះរាជក្រឹត្យ នៅពេលដែលព្រះមហាក្សត្រទ្រង់

គង់នៅក្រៅប្រទេសនោះ គេបានសន្និដ្ឋានថា មានតែការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញប៉ុណ្ណោះ ទើបអាចបំពេញចន្លោះនេះ ដើម្បីកុំឱ្យមានផលប៉ះពាល់អវិជ្ជមានចំពោះកិច្ចការរដ្ឋបាលរបស់រដ្ឋ។[9]

ក្រៅពីនេះ ក៏មានការព្រួយបារម្ភផងដែរថា កង្វះខាតនីតិវិធីច្បាស់លាស់អាចបង្កើតបន្ទុកដល់ព្រះមហាក្សត្រ ព្រោះព្រះអង្គប្រហែលជាពុំមានព្រះទ័យងាយស្រួលក្នុងការស្នាក់នៅក្រៅប្រទេសរយៈពេលយូរដើម្បីពិនិត្យនិងព្យាបាលព្រះរាជសុខភាពឡើយ ប្រសិនបើតាមទម្លាប់រដ្ឋបាលព្រះអង្គទ្រង់ឡាយព្រះហស្តលេខាប្រកាសឱ្យប្រើច្បាប់តែនៅក្នុងដែនដីនៃប្រទេសរបស់ព្រះអង្គប៉ុណ្ណោះ។

សរុបមក វិសោធនកម្មលើកទី១នេះ មានគោលបំណងដោះស្រាយចន្លោះផ្នែកនីតិវិធីដែលកើតមានក្នុងការអនុវត្តអំណាចរបស់ព្រះមហាក្សត្រ នៅពេលព្រះអង្គគង់នៅក្រៅប្រទេស។ ការកែប្រែមាត្រា២៨ បានអនុញ្ញាតឱ្យមានការធ្វើប្រតិភូកម្មព្រះហស្តលេខារបស់ព្រះមហាក្សត្រ ទៅប្រមុខរដ្ឋស្តីទី ដើម្បីធានាថាការប្រកាសឱ្យប្រើច្បាប់ និងដំណើរការរដ្ឋបាលរបស់រដ្ឋអាចបន្តបានដោយរលូន។ វិសោធនកម្មនេះបានរួមចំណែកធានាប្រសិទ្ធភាពនៃការគ្រប់គ្រងរដ្ឋ និងបំពេញចន្លោះនៃបទប្បញ្ញត្តិរដ្ឋធម្មនុញ្ញដែលមិនទាន់មានភាពច្បាស់លាស់នៅពេលនោះ។

## ខ្លឹមសារមាត្រាចាស់ និងមាត្រាថ្មី

| មាត្រាចាស់ | មាត្រាថ្មី |
|---|---|
| **មាត្រា ២៨.-**<br>ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រមប្រកាសឱ្យ ប្រើរដ្ឋធម្មនុញ្ញ ច្បាប់ដែលរដ្ឋសភាបានអនុម័ត និងទ្រង់ឡាយព្រះហស្តលេខាលើ ព្រះរាជក្រឹត្យតាមសេចក្តីស្នើសុំពីគណៈរដ្ឋមន្ត្រី។ | **មាត្រា ២៨ ថ្មី.-**<br>ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រមប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញ ច្បាប់ដែលរដ្ឋសភាបានអនុម័ត និងទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រឹត្យ តាមសេចក្តីស្នើសុំពីគណៈរដ្ឋមន្ត្រី។ ក្នុងពេលដែលព្រះមហាក្សត្រប្រឈួន ហើយត្រូវព្យាបាលព្រះរោគនៅបរទេស ក្នុងពេលនោះ ព្រះមហាក្សត្រមានសិទ្ធិផ្ទេរអំណាចព្រះហស្តលេខា នៅលើព្រះរាជក្រម ឬព្រះរាជក្រឹត្យខាងលើនេះទៅប្រមុខរដ្ឋស្តីទីចុះហត្ថលេខាជំនួសដោយព្រះរាជសារប្រគល់សិទ្ធិ។ |

[9] Taing Ratana. (2019). *Constitutional change and amendment in Cambodia.* Journal of Comparative Law, 14(1), 94–118.

## វិសោធនកម្មលើកទី២ (១៩៩៩)

ច្បាប់ធម្មនុញ្ញស្ដីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយ នៃជំពូកទី៨ ដល់ ជំពូកទី១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាអនុម័តនៅថ្ងៃទី៤ ខែមីនា ឆ្នាំ១៩៩៩។ ច្បាប់ធម្មនុញ្ញស្ដីពីវិសោធនកម្មនេះ ត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៩៩។ វិសោធនកម្មលើកទី២នេះ ត្រូវបានធ្វើឡើងដើម្បីបង្កើតស្ថាប័នព្រឹទ្ធសភា។

យោងតាមរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ (ច្បាប់ដើម) កម្ពុជាមានប្រព័ន្ធរដ្ឋាភិបាលដែលមានសភាតែមួយ (unicameral) ដែលអំណាចនីតិប្បញ្ញត្តិត្រូវបានផ្ដល់ឱ្យតែមួយគត់ដល់រដ្ឋសភា។ បន្ទាប់ពីការបោះឆ្នោតសាកលឆ្នាំ១៩៩៣ កម្ពុជាត្រូវបានដឹកនាំដោយនាយករដ្ឋមន្ត្រីពីររូប ក្នុងរដ្ឋាភិបាលចម្រុះ ដែលបង្កើតឡើងដោយគណបក្សនយោបាយពីរដែលឈ្នះការបោះឆ្នោត គឺ គណបក្សហ៊្វុនស៊ិនប៉ិច (FUNCINPEC) និង គណបក្សប្រជាជនកម្ពុជា (CPP)។

កិច្ចព្រមព្រៀងនយោបាយរវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សហ៊្វុនស៊ិនប៉ិច ឆ្នាំ១៩៩៨ បាននាំឱ្យមានការកែសម្រួល និងវិសោធនកម្មរដ្ឋធម្មនុញ្ញជាលើកទីពីរ។ តាមកិច្ចព្រមព្រៀងនយោបាយនេះ គណបក្សប្រជាជនកម្ពុជា និងគណបក្សហ៊្វុនស៊ិនប៉ិច បានយល់ព្រមបង្កើតរដ្ឋាភិបាលចម្រុះ។ ក្នុងការរៀបចំថ្មីនេះ មិនមាននាយករដ្ឋមន្ត្រីពីររូបដូចមុនទៀតឡើយ។ ផ្ទុយទៅវិញ គណបក្សទាំងពីរបានបែងចែកតួនាទីដឹកនាំដូចតទៅ៖ **ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ** ពីគណបក្សហ៊្វុនស៊ិនប៉ិច នឹងដឹកនាំរដ្ឋសភា ជាប្រធាននៃស្ថាប័ននីតិប្បញ្ញត្តិ ខណៈដែល **សម្ដេច ហ៊ុន សែន** ពីគណបក្សប្រជាជនកម្ពុជា នឹងដឹកនាំស្ថាប័ននីតិប្រតិបត្តិ ក្នុងតួនាទីជានាយករដ្ឋមន្ត្រី។ កិច្ចព្រមព្រៀងនេះ មានគោលបំណងធានាស្ថិរភាពផ្ទៃក្នុងរបស់ប្រទេស ដោយបង្កើតយន្តការដើម្បីឱ្យតួអង្គនយោបាយសំខាន់ៗអាចរស់នៅ និងធ្វើការរួមគ្នាបាន។[២]

យោងតាមសេចក្ដីថ្លែងហេតុនៃសេចក្ដីស្នើច្បាប់ធម្មនុញ្ញ ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ១៩៩៨ **ឯកឧត្តម ស ខេង** តំណាងក្រុមតំណាងរាស្ត្រហត្ថលេខី បានគូសបញ្ជាក់ថា *"ជោគជ័យនៃកិច្ចប្រជុំកំពូលថ្ងៃទី១២-១៣ ខែវិច្ឆកា ឆ្នាំ១៩៩៨ ជាជោគជ័យនៃស្មារតីស្នេហាជាតិនិងបង្រួបបង្រួមផ្សះផ្សាជាតិក្រោមព្រះរាជអធិបតីភាពនៃព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។ ជោគជ័យនេះ ជាកូនសោដែលបើកឱ្យមានការដោះស្រាយប្រកបដោយវិចារណញ្ញាណ នូវវិបត្តិនយោបាយជាតិនិងទប់ស្កាត់បាននូវគ្រោះមហន្តរាយដែលអាចនឹងកើតមានដោយសារវិបត្តិនេះ។ ដោយជោគជ័យនេះបំរើមូលហេតុដ៏ឧត្តុង្គឧត្តមរបស់ជាតិយើង ការអនុវត្តឱ្យល្អនូវសេចក្ដីប្រកាសរួមអំពីគោលការណ៍សហ*

---

[២] Ibid.

*ប្រតិបត្តិការ ដែលបានសំរេចក្នុងកិច្ចប្រជុំកំពូល ថ្ងៃទី១២-១៣ ខែវិច្ឆិកា ឆ្នាំ១៩៩៨ គឺជាការចាំបាច់ខានមិនបាន។ ការបង្កើតឱ្យមានព្រឹទ្ធសភា ដោយធ្វើវិសោធនកម្មលើរដ្ឋធម្មនុញ្ញបច្ចុប្បន្ន ស្ថិតក្នុងការចាំបាច់ខានមិនបាននេះ"។*[៣]

សំណើបង្កើតស្ថាប័នព្រឹទ្ធសភា បានកើតឡើងក្នុងបរិបទនៃការព្រួយបារម្ភអំពីជម្លោះនយោបាយ និងការជាប់គាំងនយោបាយ។ គំនិតនេះបានកើតចេញពីកិច្ចប្រជុំកំពូលរវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សហ៊្វុនស៊ិនប៉ិចនៅថ្ងៃទី ១២–១៣ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ដែលបានធ្វើឡើងក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ព្រះករុណា ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**។ វិធានការដើម្បីកែសម្រួល និងធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ បានកើតចេញពីសំណើរបស់សមាជិករដ្ឋសភាចំនួន៤៦ រូប ដែលតំណាងដោយ **ឯកឧត្តម ស ខេង** ពីគណបក្សប្រជាជនកម្ពុជា។ សំណើនេះត្រូវបានដាក់ជូនប្រធានរដ្ឋសភា នៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ១៩៩៨ តាមរយៈលិខិតមួយ ដែលស្នើសុំឱ្យមានការកែសម្រួល និងវិសោធនកម្មរដ្ឋធម្មនុញ្ញ។ បន្ទាប់ពីបានទទួលលិខិតនេះហើយ ប្រធានស្តីទីរដ្ឋសភា **សម្តេច ហេង សំរិន** បានថ្វាយលិខិតមួយច្បាប់ចុះថ្ងៃទី១ ខែធ្នូ ឆ្នាំ១៩៩៨ ទូលថ្វាយ **ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ** ដូចខាងក្រោម៖

*«ទូលព្រះបង្គំបានទទួលសេចក្តីស្នើច្បាប់ពីសមាជិករដ្ឋសភាចំនួន ៤៦ រូប ដែលស្នើសុំឱ្យធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ដើម្បីបង្កើតព្រឹទ្ធសភា។ សំណើនេះត្រូវបានធ្វើឡើងស្របតាមសេចក្តីសម្រេចនៃកិច្ចប្រជុំកំពូល នៅថ្ងៃទី ១២–១៣ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង។ សំណើនេះក៏ត្រូវបានធ្វើឡើងស្របតាមបទប្បញ្ញត្តិនៃមាត្រា ១៣២ នៃរដ្ឋធម្មនុញ្ញ។ ដោយយោងតាមមាត្រា ១២៤ នៃរដ្ឋធម្មនុញ្ញ ទូលព្រះបង្គំសូមក្រាបបង្គំទូលថ្វាយសេចក្តីស្នើច្បាប់នេះ ជាមួយឯកសារពាក់ព័ន្ធផ្សេងទៀតថ្វាយព្រះករុណា ដើម្បីព្រះអង្គពិនិត្យពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាធម្មនុញ្ញ»*។

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ **ឯកឧត្តម ចាន់ សុខ** បានថ្វាយលិខិតមួយចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៩៨ ទូលថ្វាយ **ព្រះករុណា ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**។ តាមខ្លឹមសារលិខិតនេះបង្ហាញថា ក្រុមប្រឹក្សាធម្មនុញ្ញបានក្រាបបង្គំស្នើអង្គព្រះមហាក្សត្រ ពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាធម្មនុញ្ញ ឬស្នើទ្រង់ពិចារណាលើមាត្រា១២៤ និង ១៣២ នៃរដ្ឋធម្មនុញ្ញ។ ខ្លឹមសារសង្ខេបនៃលិខិតនេះមានដូចខាងក្រោម៖

*«ក្រុមប្រឹក្សាធម្មនុញ្ញបានទទួលលិខិតចំនួនពីរច្បាប់ពីប្រធានស្តីទីរដ្ឋសភា ដែលភ្ជាប់ជាមួយលិខិតនេះពាក់ព័ន្ធនឹងសំណើធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ដើម្បីបង្កើតព្រឹទ្ធសភា។ ក្រុមប្រឹក្សា*

---

[៣] សេចក្តីថ្លែងហេតុនៃសេចក្តីស្នើច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្ម មាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ និង ជំពូក៧ ដល់ទី១៤ នៃរដ្ឋធម្មនុញ្ញ ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ១៩៩៨

*ធម្មនុញ្ញមានការព្រួយបារម្ភអំពីនីតិវិធីដូចដែលបានកំណត់ក្នុងមាត្រា១២៤ នៃរដ្ឋធម្មនុញ្ញ ដែលចែងថា៖ "ព្រះមហាក្សត្រ ត្រូវពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាធម្មនុញ្ញលើសំណើណាមួយ ដែលមានគោលបំណងធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ"។ ក្នុងករណីដែលមិនមានការជូនដំណឹងទៅក្រុមប្រឹក្សាធម្មនុញ្ញ អាចបង្កឱ្យមានការសង្ស័យអំពីសុពលភាពតាមរដ្ឋធម្មនុញ្ញនៃច្បាប់នេះ ដែលត្រូវអនុម័តដោយរដ្ឋសភា។ ក្រុមប្រឹក្សាធម្មនុញ្ញកំពុងរង់ចាំដើម្បីបំពេញភារកិច្ចថ្វាយសេវាផ្នែករដ្ឋធម្មនុញ្ញដល់ព្រះករុណា ដោយគារវកិច្ចដ៏ខ្ពង់ខ្ពស់»។*

ឆ្លើយតបទៅនឹងលិខិតរបស់ក្រុមប្រឹក្សាធម្មនុញ្ញ **ព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម សីហនុ** បានចេញព្រះរាជសារមួយចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩៩៨ ជូនក្រុមប្រឹក្សាធម្មនុញ្ញ ដោយបានបញ្ជាក់ថា៖

*«ក្រុមប្រឹក្សាធម្មនុញ្ញមានកាតព្វកិច្ចពិនិត្យ និងជូនដំណឹងទៅកាន់រដ្ឋសភារបស់យើង អំពីការកែលម្អសេចក្តីស្នើច្បាប់ស្តីពីការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ដើម្បីបង្កើតព្រឹទ្ធសភា។ ឧទាហរណ៍ដូចជា ការបន្ថែម ការលុបចេញ ឬការកែប្រែចំណុចផ្សេងៗ ដើម្បីជាប្រយោជន៍ដល់ជាតិ និងប្រជាជន»។*

ព្រះរាជសារនេះត្រូវបានប្រើប្រាស់ជាមូលដ្ឋានសម្រាប់ក្រុមប្រឹក្សាធម្មនុញ្ញ ចាប់ផ្តើមនីតិវិធីរបស់ខ្លួន ដោយស្នើឱ្យរដ្ឋសភាផ្តល់ឯកសារបន្ថែម តាមរយៈលិខិតមួយច្បាប់ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩៨។ ក្នុងអំឡុងពេលនៃនីតិវិធីនេះ ត្រូវបានបញ្ជាក់ថា សំណើនេះត្រូវបានធ្វើឡើងស្របតាមសេចក្តីសម្រេចនយោបាយ ដែលមានគោលបំណងទប់ស្កាត់ការជាប់គាំងនយោបាយណាមួយ ដែលអាចកើតឡើងពីជម្លោះនយោបាយអូសបន្លាយយូរ។ ក្រោយពីបានពិនិត្យហើយ ក្រុមប្រឹក្សាធម្មនុញ្ញបានសម្រេចថា ការបង្កើតព្រឹទ្ធសភាតម្រូវឱ្យធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ។

ការបង្កើតព្រឹទ្ធសភាបានធានាស្ថិរភាពនយោបាយ ព្រមទាំងលើកកម្ពស់គុណភាពនៃដំណើរការនីតិកម្មនៅកម្ពុជា។ ស្ថាប័ននេះមានតួនាទីសំខាន់ក្នុងការសម្របសម្រួលការងាររវាងរដ្ឋសភា និងរាជរដ្ឋាភិបាលកម្ពុជា។ ដូច្នេះ ការបង្កើតនេះអាចត្រូវបានចាត់ទុកថា ជាផ្នែកមួយនៃការកែទម្រង់ ស្ថាប័នធម្មនុញ្ញនៅកម្ពុជា។ តួនាទីរបស់ព្រឹទ្ធសភា ក៏បានបង្ហាញយ៉ាងច្បាស់អំពីនីតិវិធីនៃការកសាងច្បាប់ផងដែរ។ ការណ៍នេះជាវិធីដ៏ល្អមួយក្នុងការធានាភាពច្បាស់លាស់នៃច្បាប់ (legal certainty) នៅកម្ពុជា ពីព្រោះច្បាប់ត្រូវតែ (១) មានភាពច្បាស់លាស់និងងាយយល់ (២)អាចរកបានដោយងាយ និង (៣) អាចអនុវត្តបាន។[៤]

សរុបមក វិសោធនកម្មលើកទី២នេះ មានគោលបំណងសំខាន់ក្នុងការបង្កើតស្ថាប័នព្រឹទ្ធសភា ដើម្បីបន្ថែមរចនាសម្ព័ន្ធនីតិប្បញ្ញត្តិពីប្រព័ន្ធសភាតែមួយទៅជាប្រព័ន្ធសភាពីរថ្នាក់គឺរដ្ឋសភា និងព្រឹទ្ធសភា។ វិសោធនកម្មនេះកើតឡើងក្នុងបរិបទនៃការព្រមព្រៀងនយោបាយរវាងគណបក្សនយោបាយធំៗ បន្ទាប់ពីវិបត្តិ

[៤] Taing (n 1).

នយោបាយឆ្នាំ១៩៩៨ ដោយមានគោលបំណងធានាស្ថិរភាពនយោបាយ និងការសហការរវាងគួអង្គនយោបាយសំខាន់ៗ។ ការបង្កើតព្រឹទ្ធសភា ក៏បានរួមចំណែកលើកកម្ពស់គុណភាពនៃដំណើរការនីតិកម្ម និងពង្រឹងប្រព័ន្ធធម្មនុញ្ញនៅកម្ពុជា ដោយបង្កើតយន្តការត្រួតពិនិត្យ និងពិភាក្សាច្បាប់បន្ថែម មុនពេលច្បាប់ត្រូវបានអនុម័តជាផ្លូវការ។

## ខ្លឹមសារមាត្រាចាស់ និងមាត្រាថ្មី

| មាត្រាចាស់ | មាត្រាថ្មី |
|---|---|
| **មាត្រា ១១.-**<br>ក្នុងករណីដែលព្រះមហាក្សត្រពុំអាចបំពេញព្រះរាជភារៈជាព្រះប្រមុខរដ្ឋបានដូចធម្មតាដោយព្រះអង្គប្រឈួនជាទម្ងន់ មានការបញ្ជាក់ដោយក្រុមគ្រូពេទ្យជំនាញជ្រើសរើសដោយប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រីនោះប្រធានរដ្ឋសភាបំពេញភារកិច្ចប្រមុខរដ្ឋជំនួសព្រះអង្គ ក្នុងឋានៈជា "ព្រះរាជានុសិទ្ធិ"។ | **មាត្រា ១១.- ថ្មី**<br>ក្នុងករណីដែលព្រះមហាក្សត្រពុំអាចបំពេញព្រះរាជភារៈ ជាព្រះប្រមុខរដ្ឋបានដូចធម្មតាដោយព្រះអង្គប្រឈួនជាទម្ងន់ មានការបញ្ជាក់ដោយក្រុមគ្រូពេទ្យជំនាញជ្រើសរើសដោយប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រី នោះប្រធានព្រឹទ្ធសភាបំពេញភារកិច្ចប្រមុខរដ្ឋជំនួសព្រះអង្គ ក្នុងឋានៈជាព្រះរាជានុសិទ្ធិ។<br>ក្នុងករណីដែលប្រធានព្រឹទ្ធសភាពុំមានលទ្ធភាពបំពេញភារកិច្ចជាប្រមុខរដ្ឋជំនួសព្រះមហាក្សត្រ ក្នុងឋានៈជាព្រះរាជានុសិទ្ធិ ពេលព្រះអង្គទ្រង់ប្រឈួនជាទម្ងន់ ដូចមានចែងក្នុងវាក្យខ័ណ្ឌខាងលើ ប្រធានរដ្ឋសភាជាអ្នកបំពេញភារកិច្ចនេះ ។<br>តំណែងជាប្រមុខរដ្ឋជំនួសព្រះមហាក្សត្រ ក្នុងឋានៈជាព្រះរាជានុសិទ្ធិនេះ អាចនឹងដូរឥស្សរជនផ្សេងទៀត ក្នុងករណីដូចដែលបានចែងក្នុងវាក្យខ័ណ្ឌខាងលើ តាមឋានានុក្រមដូចតទៅៈ<br>ក. អនុប្រធានទី១ ព្រឹទ្ធសភា<br>ខ. អនុប្រធានទី១ រដ្ឋសភា<br>គ. អនុប្រធានទី២ ព្រឹទ្ធសភា<br>ឃ. អនុប្រធានទី២ រដ្ឋសភា |

| | |
|---|---|
| **មាត្រា ១២.-**<br>នៅពេលព្រះមហាក្សត្រទ្រង់ចូលទិវង្គត ប្រធានរដ្ឋសភាទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទី ក្នុងឋានៈជាព្រះរាជានុសិទ្ធិ នៃព្រះរាជាណាចក្រកម្ពុជា។ | **មាត្រា ១២.- ថ្មី**<br>នៅពេលព្រះមហាក្សត្រទ្រង់ចូលទិវង្គត ប្រធានព្រឹទ្ធសភាទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទី ក្នុងឋានៈជាព្រះរាជានុសិទ្ធិ នៃព្រះរាជាណាចក្រកម្ពុជា។<br>ក្នុងករណីដែលប្រធានព្រឹទ្ធសភាពុំមានលទ្ធភាពបំពេញភារកិច្ចជាប្រមុខរដ្ឋស្តីទីជំនួសព្រះមហាក្សត្រ ក្នុងពេលព្រះអង្គចូលទិវង្គត ការទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទី ក្នុងឋានៈជាព្រះរាជានុសិទ្ធិ ត្រូវអនុវត្តតាមវាក្យខ័ណ្ឌទី២ និងទី៣ នៃមាត្រា១១ថ្មី។ |
| **មាត្រា ១៣.-**<br>ក្នុងរយៈពេលប្រាំពីរថ្ងៃយ៉ាងយូរ ព្រះមហាក្សត្រថ្មីនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានជ្រើសរើសដោយក្រុមប្រឹក្សារាជសម្បត្តិ។<br>សមាសភាពនៃក្រុមប្រឹក្សារាជសម្បត្តិមាន :<br>-ប្រធានរដ្ឋសភា<br>-នាយករដ្ឋមន្ត្រី<br>-សម្តេចព្រះសង្ឃរាជគណមហានិកាយ និងគណៈធម្មយុត្តិកនិកាយ<br>-អនុប្រធានទីមួយ និងអនុប្រធានទីពីរ នៃរដ្ឋសភា។<br>ការរៀបចំនិងការប្រព្រឹត្តិទៅនៃក្រុមប្រឹក្សារាជសម្បត្តិនឹងមានកំណត់ក្នុងច្បាប់មួយ។ | **មាត្រា ១៣.- ថ្មី**<br>ក្នុងរយៈពេល៧ថ្ងៃយ៉ាងយូរ ព្រះមហាក្សត្រថ្មីនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានជ្រើសរើសដោយក្រុមប្រឹក្សារាជសម្បត្តិ ។<br>សមាសភាពនៃក្រុមប្រឹក្សារាជសម្បត្តិមាន :<br>-ប្រធានព្រឹទ្ធសភា<br>-ប្រធានរដ្ឋសភា<br>-នាយករដ្ឋមន្ត្រី<br>-សម្តេចព្រះសង្ឃរាជគណមហានិកាយ និងគណៈធម្មយុត្តិកនិកាយ<br>-អនុប្រធានទី១ និងអនុប្រធានទី២ ព្រឹទ្ធសភា<br>-អនុប្រធានទី១ និងអនុប្រធានទី២ រដ្ឋសភា<br>ការរៀបចំនិងការប្រព្រឹត្តិទៅនៃក្រុមប្រឹក្សារាជសម្បត្តិនឹងមានកំណត់ក្នុងច្បាប់មួយ។ |

| | |
|---|---|
| **មាត្រា ១៨.-**<br>ព្រះមហាក្សត្រព្រះអង្គទ្រង់ទាក់ទងជាមួយរដ្ឋសភាដោយព្រះរាជសារ។ ព្រះរាជសារនេះ រដ្ឋសភាមិនអាចយកទៅជជែកពិភាក្សាឡើយ។ | **មាត្រា ១៨.- ថ្មី**<br>ព្រះមហាក្សត្រ ព្រះអង្គទ្រង់ទាក់ទងជាមួយព្រឹទ្ធសភា និងរដ្ឋសភាដោយព្រះរាជសារ។<br>ព្រះរាជសារនេះ ព្រឹទ្ធសភានិងរដ្ឋសភាមិនអាចយកទៅជជែកពិភាក្សាឡើយ។ |
| **មាត្រា ២២.-**<br>នៅពេលប្រជាជាតិប្រឈមមុខនឹងគ្រោះថ្នាក់ ព្រះមហាក្សត្រទ្រង់ប្រកាសប្រទានដំណឹងជាសាធារណៈដាក់ប្រទេសជាតិឋិតក្នុងភាពអាសន្នក្រោយពីបានមតិឯកភាពពីនាយករដ្ឋមន្ត្រី និងប្រធានរដ្ឋសភា។ | **មាត្រា ២២.- ថ្មី**<br>នៅពេលប្រជាជាតិប្រឈមមុខនឹងគ្រោះថ្នាក់ ព្រះមហាក្សត្រទ្រង់ប្រកាសប្រទានដំណឹងជាសាធារណៈដាក់ប្រទេសជាតិស្ថិតនៅក្នុងភាពអាសន្ន ក្រោយពីបានមតិឯកភាពពីនាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា និងប្រធានព្រឹទ្ធសភា។ |
| **មាត្រា ២៤.-**<br>ព្រះមហាក្សត្រទ្រង់គង់ជាព្រះអធិបតីនៃឧត្តមក្រុមប្រឹក្សាការពារជាតិ ដែលនឹងត្រូវបង្កើតឡើងដោយច្បាប់មួយ។<br>ព្រះមហាក្សត្រទ្រង់ប្រកាសសង្គ្រាមក្រោយការអនុម័តរបស់រដ្ឋសភា។ | **មាត្រា ២៤.- ថ្មី**<br>ព្រះមហាក្សត្រទ្រង់គង់ជាព្រះអធិបតីនៃឧត្តមក្រុមប្រឹក្សាការពារជាតិ ដែលនឹងត្រូវបង្កើតឡើងដោយច្បាប់មួយ។<br>ព្រះមហាក្សត្រទ្រង់ប្រកាសសង្គ្រាមក្រោយការអនុម័តរបស់រដ្ឋសភា និងព្រឹទ្ធសភា។ |
| **មាត្រា ២៦.-**<br>ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាលើសន្ធិសញ្ញា និងអនុសញ្ញាអន្តរជាតិ ហើយទ្រង់ប្រទានសច្ចាប័នលើសន្ធិសញ្ញានិងអនុសញ្ញាទាំងនេះ ក្រោយបានទទួលការអនុម័តយល់ព្រមពីរដ្ឋសភា។ | **មាត្រា ២៦.- ថ្មី**<br>ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាលើសន្ធិសញ្ញា និងអនុសញ្ញាអន្តរជាតិ ហើយទ្រង់ប្រទានសច្ចាប័នលើសន្ធិសញ្ញានិងអនុសញ្ញាទាំងនេះ ក្រោយបានទទួលការអនុម័តយល់ព្រមពីរដ្ឋសភា និងព្រឹទ្ធសភា។ |
| **មាត្រា ២៨.-**<br>ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រមប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញ ច្បាប់ដែលរដ្ឋសភាបានអនុម័ត និងទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រឹត្យតាមសេចក្តីស្នើសុំពីគណៈរដ្ឋមន្ត្រី។ | **មាត្រា ២៨.- ថ្មី**<br>ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រមប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញ ច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់រួចហើយ និងទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រឹត្យ តាមសេចក្តីស្នើសុំពីគណៈរដ្ឋមន្ត្រី។ |

| | |
|---|---|
| | ក្នុងពេលដែលព្រះមហាក្សត្រប្រឈួន ហើយត្រូវព្យាបាលព្រះរោគនៅបរទេស ក្នុងពេលនោះ ព្រះមកហាក្សត្រមានសិទ្ធិផ្ទេរអំណាច ឡាយព្រះហស្តលេខានៅលើព្រះរាជក្រម ឬព្រះរាជក្រឹត្យខាងលើនេះ ទៅប្រមុខរដ្ឋស្តីទីចុះហត្ថលេខាជំនួសដោយព្រះរាជសារប្រគល់សិទ្ធិ។ |
| **មាត្រា ៣០.-**<br>ក្នុងរយៈពេលព្រះមហាក្សត្រទ្រង់អវត្តមាន ប្រធានរដ្ឋសភាទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទី។ | **មាត្រា ៣០.- ថ្មី**<br>ក្នុងរយៈពេលព្រះមហាក្សត្រអវត្តមាន ប្រធានព្រឹទ្ធសភាទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទី។<br>ក្នុងករណីដែលប្រធានព្រឹទ្ធសភា ពុំមានលទ្ធភាពបំពេញភារកិច្ចជាប្រមុខរដ្ឋស្តីទីជំនួសព្រះមហាក្សត្រ ពេលព្រះអង្គទ្រង់អវត្តមាន ការទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទី ត្រូវអនុវត្តតាមវាក្យខ័ណ្ឌទី២ និងទី៣ នៃមាត្រា ១១ថ្មី។ |
| **មាត្រា ៣៤.-**<br>ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិបោះឆ្នោតនិងអាចឈរឈ្មោះឱ្យគេបោះឆ្នោត។<br>ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានអាយុយ៉ាងតិច១៨ឆ្នាំមានសិទ្ធិបោះឆ្នោត។<br>ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានអាយុយ៉ាងតិច២៥ឆ្នាំ អាចឈរឈ្មោះឱ្យគេបោះឆ្នោត។<br>បទប្បញ្ញត្តិបន្ថយសិទ្ធិបោះឆ្នោត និងសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតត្រូវចែងក្នុងច្បាប់បោះឆ្នោត។ | **មាត្រា ៣៤.- ថ្មី**<br>ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិបោះឆ្នោត និងអាចឈរឈ្មោះអោយគេបោះឆ្នោត។<br>ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច១៨ឆ្នាំ មានសិទ្ធិបោះឆ្នោត។<br>ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានអាយុយ៉ាងតិច២៥ឆ្នាំ អាចឈរឈ្មោះអោយគេបោះឆ្នោតជ្រើសតាំងជាតំណាងរាស្ត្រ។<br>ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច៤០ឆ្នាំ អាចឈរឈ្មោះអោយគេបោះឆ្នោតជ្រើសតាំងជាសមាជិកព្រឹទ្ធសភា។<br>បទប្បញ្ញត្តិបន្ថយសិទ្ធិបោះឆ្នោត និងសិទ្ធិឈរឈ្មោះអោយគេបោះឆ្នោត ត្រូវចែងក្នុងច្បាប់បោះឆ្នោត។ |

| មាត្រា ៥១.- | មាត្រា ៥១.- ថ្មី |
|---|---|
| ព្រះរាជាណាចក្រកម្ពុជាអនុវត្តរបបនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស។<br>ប្រជាពលរដ្ឋខ្មែរជាម្ចាស់វាសនានៃប្រទេសជាតិរបស់ខ្លួន។<br>អំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ។ ប្រជាពលរដ្ឋប្រើអំណាចរបស់ខ្លួនតាមរយៈរដ្ឋសភា រាជរដ្ឋាភិបាល និងសាលាជំរះក្តី។<br>អំណាចបែងចែកដាច់ពីគ្នា រវាងអំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ។ | ព្រះរាជាណាចក្រកម្ពុជាអនុវត្តនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស។<br>ប្រជាពលរដ្ឋខ្មែរជាម្ចាស់វាសនានៃប្រទេសជាតិរបស់ខ្លួន។<br>អំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ។ ប្រជាពលរដ្ឋប្រើអំណាចរបស់ខ្លួនតាមរយៈរដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាលនិងសាលាជំរះក្តី។<br>អំណាចបែងចែកដាច់ពីគ្នារវាងអំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ។ |
| **មាត្រា ៩០.-** | **មាត្រា ៩០.- ថ្មី** |
| រដ្ឋសភាជាអង្គការតែមួយគត់ដែលមានអំណាចនីតិប្បញ្ញត្តិ។ អំណាចនេះ រដ្ឋសភាមិនអាចប្រគល់ឱ្យទៅអង្គការ ឬបុគ្គលណាមួយបានឡើយ។<br>រដ្ឋសភាអនុម័តថវិកាជាតិ ផែនការរដ្ឋ ការឱ្យរដ្ឋខ្ចីប្រាក់ពីគេ ការឱ្យរដ្ឋឱ្យប្រាក់គេខ្ចី ការសន្យានានាផ្នែកហិរញ្ញវត្ថុ និងការបង្កើត កែប្រែ ឬ លុបចោលពន្ធដារ។<br>រដ្ឋសភាឱ្យសេចក្តីយល់ព្រមចំពោះគណនីរដ្ឋបាល។<br>រដ្ឋសភាអនុម័តច្បាប់ស្តីពីការលើកលែងទោសជាទូទៅ។<br>រដ្ឋសភាអនុម័តយល់ព្រម ឬលុបចោលសន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិ។<br>រដ្ឋសភាអនុម័តច្បាប់ស្តីពីការប្រកាសសង្គ្រាម។ | រដ្ឋសភាជាអង្គការដែលមានអំណាចនីតិប្បញ្ញត្តិ ហើយបំពេញភារកិច្ចរបស់ខ្លួន ដូចបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន។<br>រដ្ឋសភាអនុម័តថវិកាជាតិ ផែនការរដ្ឋ ការអោយរដ្ឋខ្ចីប្រាក់ពីគេ ការអោយរដ្ឋអោយប្រាក់គេខ្ចី ការសន្យានានាផ្នែកហិរញ្ញវត្ថុ និងការបង្កើត កែប្រែ ឬ លុបចោលពន្ធដារ។<br>រដ្ឋសភាអោយសេចក្តីយល់ព្រមចំពោះគណនីរដ្ឋបាល។<br>រដ្ឋសភាអនុម័តច្បាប់ ស្តីពីការលើកលែងទោសជាទូទៅ។<br>រដ្ឋសភាអនុម័តយល់ព្រម ឬលុបចោលសន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិ។<br>រដ្ឋសភាអនុម័តច្បាប់ស្តីពីការប្រកាសសង្គ្រាម។<br>ការអនុម័តខាងលើនេះប្រព្រឹត្តទៅដោយមតិភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល។ |

| | |
|---|---|
| ការអនុម័តខាងលើនេះប្រព្រឹត្តទៅដោយមតិភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល។<br>រដ្ឋសភាបោះឆ្នោតទុកចិត្តដល់រាជរដ្ឋាភិបាល តាមមតិភាគច្រើនពីរភាគបីនៃសមាជិករដ្ឋសភាទាំងមូល។ | រដ្ឋសភាបោះឆ្នោតទុកចិត្តដល់រាជរដ្ឋាភិបាល តាមមតិភាគច្រើនពីរភាគបីនៃសមាជិករដ្ឋសភាទាំងមូល។ |
| **មាត្រា ៩១.-**<br>តំណាងរាស្ត្រ និងនាយករដ្ឋមន្ត្រីមានសិទ្ធិផ្តួចផ្តើមគំនិតធ្វើច្បាប់។<br>តំណាងរាស្ត្រមានសិទ្ធិស្នើធ្វើវិសោធនកម្មច្បាប់ ប៉ុន្តែសំណើនេះមិនអាចទទួលយកបានទេ បើវិសោធនកម្មនោះសំដៅបន្ថយប្រាក់ចំណូលសាធារណៈ ឬបន្ថែមបន្ទុកទៅលើប្រជាពលរដ្ឋ។ | **មាត្រា ៩១.- ថ្មី**<br>សមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា និងនាយករដ្ឋមន្ត្រីមានសិទ្ធិផ្តួចផ្តើមគំនិតធ្វើច្បាប់។<br>តំណាងរាស្ត្រមានសិទ្ធិស្នើធ្វើវិសោធនកម្មច្បាប់ ប៉ុន្តែសំណើនេះមិនអាចទទួលយកបានទេ បើវិសោធនកម្មនោះសំដៅបន្ថយប្រាក់ចំណូលសាធារណៈ ឬបន្ថែមបន្ទុកទៅលើប្រជាពលរដ្ឋ។ |
| **មាត្រា ៩៣.-**<br>ច្បាប់ដែលរដ្ឋសភាបានអនុម័តរួចហើយ ហើយត្រូវបានព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាប្រកាសឱ្យប្រើ ត្រូវចូលជាធរមាននៅរាជធានីភ្នំពេញក្នុងរយៈពេល ១០ ថ្ងៃគត់ ក្រោយពីថ្ងៃប្រកាសឱ្យប្រើ និងនៅទូទាំងប្រទេសក្នុងរយៈពេល ២០ ថ្ងៃគត់ ក្រោយពីថ្ងៃប្រកាសឱ្យប្រើ។<br>ប៉ុន្តែបើច្បាប់នេះបានចែងថាជាការប្រញាប់ ច្បាប់នេះត្រូវចូលជាធរមានភ្លាមនៅទូទាំងប្រទេសក្រោយថ្ងៃប្រកាសឱ្យប្រើ។<br>ច្បាប់ដែលព្រះមហាក្សត្រទ្រង់បានឡាយព្រះហស្តលេខាប្រកាសឱ្យប្រើ ត្រូវចុះក្នុងរាជកិច្ច និងផ្សព្វផ្សាយនៅទូទាំងប្រទេស ឱ្យទាន់តាមពេលកំណត់ខាងលើ។ | **មាត្រា ៩៣.- ថ្មី**<br>ច្បាប់ដែលរដ្ឋសភាបានអនុម័តនិងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់រួចហើយ ហើយត្រូវបានព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាប្រកាសអោយប្រើ ត្រូវចូលជាធរមាននៅរាជធានីភ្នំពេញក្នុងរយៈពេលដប់ថ្ងៃគត់ ក្រោយពីថ្ងៃប្រកាសអោយប្រើ និងនៅទូទាំងប្រទេសក្នុងរយៈពេលម្ភៃថ្ងៃគត់ ក្រោយពីថ្ងៃប្រកាសអោយប្រើ។<br>ប៉ុន្តែបើច្បាប់នេះបានចែងថាជាការប្រញាប់ ច្បាប់នេះត្រូវចូលជាធរមានភ្លាមនៅទូទាំងប្រទេសក្រោយថ្ងៃប្រកាសអោយប្រើ។<br>ច្បាប់ដែលព្រះមហាក្សត្រទ្រង់បានឡាយព្រះហស្តលេខាប្រកាសអោយប្រើ ត្រូវចុះក្នុងរាជកិច្ច និងផ្សព្វផ្សាយនៅទូទាំងប្រទេស អោយទាន់តាមពេលកំណត់ខាងលើ។ |

| "រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ (ច្បាប់ដើម) ពុំមានបទប្បញ្ញត្តិស្តីពីព្រឹទ្ធសភាទេ" | **ជំពូកទី៨ ថ្មី<br>អំពី<br>ព្រឹទ្ធសភា** |
|---|---|
| | **មាត្រា ៩៩.- ថ្មី**<br>ព្រឹទ្ធសភាជាអង្គការដែលមានអំណាចនីតិបញ្ញត្តិ ហើយបំពេញភារកិច្ចរបស់ខ្លួន ដូចមានកំណត់ក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ធរមាន។<br>ព្រឹទ្ធសភាមានចំនួនសមាជិកយ៉ាងច្រើនស្មើនឹងពាក់កណ្តាលនៃចំនួនសមាជិករដ្ឋសភាទាំងមូល។<br>សមាជិកព្រឹទ្ធសភាត្រូវចាត់តាំងខ្លះនិងត្រូវជ្រើសតាំងដោយការបោះឆ្នោតអសកលខ្លះ។<br>សមាជិកព្រឹទ្ធសភាអាចត្រូវបានចាត់តាំង និងជ្រើសតាំងសាជាថ្មីបាន។ អ្នកដែលមានសិទ្ធិឈរឈ្មោះជាបេក្ខជនព្រឹទ្ធសភា គឺជាប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានសិទ្ធិបោះឆ្នោតមានអាយុយ៉ាងតិច ៤០ឆ្នាំ មានសញ្ជាតិខ្មែរតាំងពីកំណើត។ |
| | **មាត្រា ១០០.- ថ្មី**<br>សមាជិកព្រឹទ្ធសភាចំនួន ២រូប ត្រូវបានចាត់តាំងដោយព្រះមហាក្សត្រ។<br>សមាជិកព្រឹទ្ធសភាចំនួន ២រូប ត្រូវបានរដ្ឋសភាជ្រើសតាំងតាមមតិភាគច្រើនដោយប្រៀប។<br>រីឯសមាជិកព្រឹទ្ធសភាឯទៀត ត្រូវបានជ្រើសតាំងដោយការបោះឆ្នោតអសកល។ |
| | **មាត្រា ១០១.- ថ្មី**<br>ការរៀបចំ បែបបទ និងការប្រព្រឹត្តិទៅនៃការចាត់តាំង និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ព្រមទាំងការកំណត់អំពីអ្នកបោះឆ្នោត |

| | |
|---|---|
| | អង្គបោះឆ្នោត និងមណ្ឌលបោះឆ្នោត ត្រូវចែងក្នុងច្បាប់មួយ។ |
| | **មាត្រា ១០២.- ថ្មី**<br><br>នីតិកាលរបស់ព្រឹទ្ធសភាមានកំណត់ ៦ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលដែលព្រឹទ្ធសភាថ្មីចូលកាន់តំណែង។<br>ក្នុងពេលមានសង្គ្រាម ឬ ក្នុងកាលៈទេសៈពិសេសដទៃទៀត ដែលមិនអាចធ្វើការបោះឆ្នោតកើត ព្រឹទ្ធសភាអាចប្រកាសបន្តនីតិកាលរបស់ខ្លួនមួយដងបានមួយឆ្នាំ តាមសំណើរបស់ព្រះមហាក្សត្រ។<br>ការប្រកាសបន្តនីតិកាលរបស់ព្រឹទ្ធសភា ត្រូវសំរេចដោយមតិយល់ព្រមពីរភាគបីយ៉ាងតិចនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។<br>ក្នុងកាលៈទេសៈដូចបានរៀបរាប់ខាងលើ ព្រឹទ្ធសភាប្រជុំរាល់ថ្ងៃជាប់ជាប្រចាំ។ ព្រឹទ្ធសភាមានសិទ្ធិសំរេចបញ្ចប់កាលៈទេសៈពិសេសខាងលើនេះ កាលបើសភាពការណ៍អនុញ្ញាត។<br>បើព្រឹទ្ធសភាមិនអាចប្រជុំបានទេ ដោយមូលហេតុចាំបាច់ ជាអាទិ៍នៅពេលដែលកំលាំងបរទេសចូលមកកាន់កាប់ទឹកដី ការប្រកាសភាពអាសន្នត្រូវបន្តទៅមុខជាស្វ័យប្រវត្តិ។ |
| | **មាត្រា ១០៣.- ថ្មី**<br><br>អាណត្តិនៃសមាជិកព្រឹទ្ធសភាមានវិសមិតភាពជាមួយការបំពេញមុខងារសាធារណៈជាសកម្ម ជាមួយមុខងារជាតំណាងរាស្ត្រនិង ជាមួយមុខងារជាសមាជិកស្ថាប័នដទៃទៀត ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ។ |

| | |
|---|---|
| | **មាត្រា ១០៤.- ថ្មី**<br>សមាជិកព្រឹទ្ធសភា មានអភ័យឯកសិទ្ធិសភា។<br>សមាជិកព្រឹទ្ធសភារូបណាក៏ដោយមិនអាចត្រូវបានចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួនដោយហេតុពីបានសំដែងយោបល់ ឬបញ្ចេញមតិក្នុងការបំពេញមុខងាររបស់ខ្លួនសោះឡើយ។<br>ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួន សមាជិកណាមួយនៃព្រឹទ្ធសភានឹងអាចធ្វើទៅកើត លុះត្រាតែមានការយល់ព្រមពីព្រឹទ្ធសភា ឬពីគណៈកម្មាធិការអចិន្ត្រៃយ៍របស់ព្រឹទ្ធសភា ក្នុងចន្លោះសម័យប្រជុំនៃព្រឹទ្ធសភា វៀរលែងតែក្នុងករណីបទល្មើសព្រហ្មទណ្ឌជាក់ស្តែង។ ក្នុងករណីចុងក្រោយនេះ ក្រសួងមានសមត្ថកិច្ច ត្រូវធ្វើសេចក្តីរាយការណ៍ជូនព្រឹទ្ធសភា ឬជូនគណៈកម្មាធិការអចិន្ត្រៃយ៍របស់ព្រឹទ្ធសភាជាបន្ទាន់ដើម្បីសំរេច។<br>សេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍របស់ព្រឹទ្ធសភាត្រូវដាក់ជូនសម័យប្រជុំព្រឹទ្ធសភាខាងមុខ ដើម្បីអនុម័តតាមមតិភាគច្រើនពីរភាគបីនៃសមាជិកសភាទាំងមូល។<br>ក្នុងករណីទាំងអស់ខាងលើនេះ ការឃុំខ្លួន ការចោទប្រកាន់សមាជិកព្រឹទ្ធសភាណាមួយត្រូវផ្អាក ប្រសិនបើព្រឹទ្ធសភាបានបញ្ចេញមតិអោយផ្អាកតាមមតិភាគច្រើន បីភាគបួននៃសមាជិកព្រឹទ្ធសភាទាំងមូល។ |
| | **មាត្រា១០៥.- ថ្មី**<br>ព្រឹទ្ធសភាមានថវិកាស្វ័យ័តសំរាប់ដំណើរការ។ |

| | |
|---|---|
| | សមាជិកព្រឹទ្ធសភាត្រូវទទួលប្រាក់បំណាច់។ |
| | **មាត្រា ១០៦.- ថ្មី**<br>ព្រឹទ្ធសភាបើកសម័យប្រជុំដំបូង ហុកសិបថ្ងៃយ៉ាងយូរ ក្រោយពេលបោះឆ្នោត តាមការកោះប្រជុំរបស់ព្រះមហាក្សត្រ ។<br>មុនចាប់ផ្តើមការងាររបស់ខ្លួន ព្រឹទ្ធសភាត្រូវប្រកាសសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗ និងត្រូវបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នានូវប្រធាន អនុប្រធានព្រឹទ្ធសភា និងសមាជិកទាំងអស់នៃគណៈកម្មការនានារបស់ព្រឹទ្ធសភា ដោយមតិភាគច្រើនពីរភាគបីនៃសមាជិកព្រឹទ្ធសភាទាំងមូល។<br>សមាជិកព្រឹទ្ធសភាទាំងអស់ត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់តំណែងដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធទី៧ នៃរដ្ឋធម្មនុញ្ញ។ |
| | **មាត្រា ១០៧.- ថ្មី**<br>ព្រឹទ្ធសភាប្រជុំជាសាមញ្ញពីរដងក្នុងមួយឆ្នាំ។<br>សម័យប្រជុំនីមួយៗមានថេរៈវេលាយ៉ាងតិចបីខែ។ បើមានសំណូមពរពីព្រះមហាក្សត្រ ឬសេចក្តីស្នើសុំពីនាយករដ្ឋមន្ត្រី ឬពីសមាជិកព្រឹទ្ធសភាចំនួនមួយភាគបីយ៉ាងតិច ព្រឹទ្ធសភាកោះប្រជុំជាវិសាមញ្ញ។ |
| | **មាត្រា ១០៨.- ថ្មី**<br>នៅចន្លោះសម័យប្រជុំរបស់ព្រឹទ្ធសភា គណៈកម្មាធិការអចិន្ត្រៃយ៍របស់ព្រឹទ្ធសភាទទួលភារកិច្ចចាត់ចែងការងារ។ |

| | |
|---|---|
| | គណៈកម្មាធិការអចិន្ត្រៃយ៍របស់ព្រឹទ្ធសភារួមមានៈ ប្រធានព្រឹទ្ធសភា អនុប្រធានព្រឹទ្ធសភា និងប្រធានគណៈកម្មការទាំងអស់របស់ព្រឹទ្ធសភា។ |
| | **មាត្រា ១០៩.- ថ្មី** <br> សម័យប្រជុំព្រឹទ្ធសភាត្រូវធ្វើនៅរាជធានីនៃព្រះរាជាណាចក្រកម្ពុជាក្នុងសាលប្រជុំរបស់ព្រឹទ្ធសភា លើកលែងតែមានការសំរេចផ្សេងចុះក្នុងលិខិតកោះប្រជុំ ដោយកាលៈទេសៈតម្រូវ។ <br> ក្រៅពីករណីខាងលើនិងក្រៅពីកន្លែង និងកាលបរិច្ឆេទដែលកំណត់ក្នុងសេចក្តីអញ្ជើញ ការប្រជុំណាក៏ដោយរបស់ព្រឹទ្ធសភាត្រូវទុកជាខុសច្បាប់ ហើយអសារសូន្យពេញលក្ខណៈ។ |
| | **មាត្រា ១១០.- ថ្មី** <br> ប្រធានព្រឹទ្ធសភាដឹកនាំអង្គប្រជុំរបស់ព្រឹទ្ធសភា ទទួលអាញត្តិច្បាប់ និងសេចក្តីសំរេចចិត្តទាំងឡាយដែលព្រឹទ្ធសភាបានអនុម័តរ៉ាប់រងការអនុវត្តន៍បទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភា និងចាត់ចែងការទាក់ទងអន្តរជាតិទាំងឡាយរបស់ព្រឹទ្ធសភា។ <br> ក្នុងករណីដែលប្រធានព្រឹទ្ធសភាមានធុរៈមិនអាចបំពេញមុខងារបាន ដោយហេតុមកពីមានជម្ងឺ ឬបំពេញមុខងារជាប្រមុខរដ្ឋស្តីទី ឬជាព្រះរាជានុសិទ្ធិ ឬបំពេញបេសកកម្មនៅបរទេសអនុប្រធានព្រឹទ្ធសភាមួយរូបត្រូវទទួលភារកិច្ចចាត់ចែងការងារជំនួស។ <br> ក្នុងករណីដែលប្រធាន ឬអនុប្រធានព្រឹទ្ធសភាលាលែងពីមុខតំណែង ឬទទួលអនិច្ចកម្ម ព្រឹទ្ធសភាត្រូវបោះឆ្នោតជ្រើសតាំងប្រធាន ឬអនុប្រធានថ្មី។ |

| | |
|---|---|
| | **មាត្រា ១១១.- ថ្មី**<br>ការប្រជុំព្រឹទ្ធសភា ត្រូវធ្វើជាសាធារណៈ។<br>ព្រឹទ្ធសភាអាចប្រជុំជាសំងាត់បានតាមការសុំពីប្រធាន ឬពីសមាជិកចំនួនមួយភាគដប់យ៉ាងតិចពីព្រះមហាក្សត្រ ពីនាយករដ្ឋមន្ត្រី ឬពីប្រធានរដ្ឋសភា។<br>ការប្រជុំព្រឹទ្ធសភានឹងយកជាការបាន លុះត្រាតែមានកូរ៉ុមប្រាំពីរភាគដប់ នៃសមាជិកព្រឹទ្ធសភាទាំងមូល។<br>ចំនួនសំឡេងដែលតម្រូវសំរាប់រដ្ឋសភាអនុម័តយល់ព្រម ហើយដែលបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ ត្រូវយកមកប្រើសំរាប់ព្រឹទ្ធសភាផងដែរ។ |
| | **មាត្រា ១១២.- ថ្មី**<br>ព្រឹទ្ធសភាមានភារកិច្ចសំរបសំរួលការងាររវាងរដ្ឋសភា និងរដ្ឋាភិបាល។ |
| | **មាត្រា ១១៣.- ថ្មី**<br>ព្រឹទ្ធសភាពិនិត្យហើយអោយយោបល់ក្នុងរយៈពេលមួយខែយ៉ាងយូរ លើសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ដែលរដ្ឋសភាបានអនុម័តយល់ព្រមលើកដំបូងរួចហើយ ព្រមទាំងលើបញ្ហាទាំងពួងដែលរដ្ឋសភាបានដាក់អោយពិនិត្យ។ បើជាការប្រញាប់ រយៈពេលនោះត្រូវបន្ថយមកនៅត្រឹមតែប្រាំថ្ងៃ។<br>បើព្រឹទ្ធសភាបានអោយយោបល់យល់ព្រម ឬពុំបានអោយយោបល់សោះក្នុងរយៈពេលដែលមានកំណត់ទុកហើយនោះទេ ច្បាប់ដែលរដ្ឋសភាបានអនុម័តយល់ព្រមហើយនោះនឹងត្រូវបានយកទៅប្រកាសអោយប្រើ។<br>បើព្រឹទ្ធសភាសុំអោយកែសំរួលសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់នោះ រដ្ឋសភាត្រូវយក |

| | |
|---|---|
| | មកពិចារណាភ្លាមជាលើកទី២។ រដ្ឋសភាត្រូវពិនិត្យ និងសំរេចតែត្រង់បទប្បញ្ញត្តិ ឬចំណុចណាដែលព្រឹទ្ធសភាសុំអោយកែសំរួល ដោយបដិសេធចោលទាំងមូល ឬទុកជាបានការខ្លះ។<br>ការបង្វិលទៅបង្វិលមករវាងព្រឹទ្ធសភានិងរដ្ឋសភា ត្រូវធ្វើតែក្នុងរយៈពេលមួយខែ។ រយៈពេលនេះត្រូវបន្ថយមកត្រឹមដប់ថ្ងៃ បើត្រូវពិនិត្យសំរេចពីថវិកាជាតិ និងហិរញ្ញវត្ថុ ហើយមកត្រឹមតែពីរថ្ងៃ បើជាការប្រញាប់។<br>បើរដ្ឋសភាទុកអោយហួសរយៈពេលកំណត់ ឬពន្យារពេលដែលកំណត់ទុកសំរាប់ពិនិត្យនោះ រយៈពេលជាគោលការណ៍សំរាប់រដ្ឋសភា និងព្រឹទ្ធសភាត្រូវបន្ថែមអោយស្មើគ្នាដែរ។<br>បើព្រឹទ្ធសភាបដិសេធសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នោះជាអសារបង់ រដ្ឋសភាមិនអាចនឹងយកមកពិចារណាជាលើកទីពីរបាន មុនរយៈពេលមួយខែទេ។ រយៈពេលនេះត្រូវបន្ថយ មកត្រឹមដប់ប្រាំថ្ងៃ បើពិនិត្យពីថវិកាជាតិ និងហិរញ្ញវត្ថុ ហើយមកត្រឹមតែបួនថ្ងៃបើជាការប្រញាប់។<br>ក្នុងការពិនិត្យសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ជាលើកទី២នេះ រដ្ឋសភាត្រូវអនុម័តដោយវិធីបោះឆ្នោតចំហ និងយកតាមមតិភាគច្រើនដាច់ខាត។<br>សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ណាដែលបានសំរេចដូចខាងលើនេះហើយនោះនឹងត្រូវបានយកទៅប្រកាសអោយប្រើ។ |
| | **មាត្រា ១១៤.- ថ្មី**<br>ព្រឹទ្ធសភាបង្កើតគណៈកម្មការផ្សេងៗដែលចាំបាច់។ ការរៀបចំនិងការប្រព្រឹត្តិទៅនៃព្រឹទ្ធសភានឹងមានកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភា។ បទបញ្ជាផ្ទៃក្នុងនេះ ត្រូវអនុម័ត |

| | |
|---|---|
| | យល់ព្រមដោយសំឡេងភាគច្រើនពីរភាគបីនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។ |
| | **មាត្រា ១១៥.- ថ្មី**<br>ក្នុងករណីមានសមាជិកព្រឹទ្ធសភាទទួលអនិច្ចកម្ម លាលែង ឬប្រាសចាកសមាជិកភាព ដែលកើតមានឡើងប្រាំមួយខែយ៉ាងតិចមុនចប់នីតិកាល ត្រូវចាត់តាំងឬជ្រើសតាំងជំនួសសមាជិកនោះតាមល័ក្ខខ័ណ្ឌកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងនៃព្រឹទ្ធសភា និងក្នុងច្បាប់ស្តីពីការចាត់តាំង និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។ |
| | **ជំពូកទី៩ ថ្មី**<br>**អំពី**<br>**សមាជរដ្ឋសភា និងព្រឹទ្ធសភា** |
| | **មាត្រា ១១៦.- ថ្មី**<br>ក្នុងករណីចាំបាច់ រដ្ឋសភា និងព្រឹទ្ធសភា អាចប្រជុំរួមគ្នាជាសមាជ ដើម្បីដោះស្រាយបញ្ហាសំខាន់ៗរបស់ប្រទេសជាតិ។ |
| | **មាត្រា ១១៧.- ថ្មី**<br>បញ្ហាសំខាន់ៗរបស់ប្រទេសជាតិដូចមានចែងក្នុងមាត្រា ១១៦ថ្មី ខាងលើ ព្រមទាំងការរៀបចំ និងការប្រព្រឹត្តិទៅនៃសមាជនឹងត្រូវកំណត់ក្នុងច្បាប់មួយ។ |
| **ជំពូកទី៨**<br>**អំពី**<br>**រាជរដ្ឋាភិបាល** | **ជំពូកទី១០ ថ្មី**<br>**អំពី**<br>**រាជរដ្ឋាភិបាល** |
| **មាត្រា ៩៩.-**<br>គណៈរដ្ឋមន្ត្រីជារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។ | **មាត្រា ១១៨.- ថ្មី (មាត្រា៩៩ ចាស់)**<br>គណៈរដ្ឋមន្ត្រីជារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។ |

| | |
|---|---|
| គណៈរដ្ឋមន្ត្រី ត្រូវបានដឹកនាំដោយនាយករដ្ឋមន្ត្រីមួយរូប អមដោយឧបនាយករដ្ឋមន្ត្រី ព្រមទាំងមានទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការជាសមាជិក។ | គណៈរដ្ឋមន្ត្រីត្រូវបានដឹកនាំដោយនាយករដ្ឋមន្ត្រីមួយរូប អមដោយឧបនាយករដ្ឋមន្ត្រី ព្រមទាំងមានទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការជាសមាជិក។ |
| **មាត្រា ១០០.-**<br>តាមសេចក្តីស្នើពីប្រធាន ដោយមានមតិឯកភាពពីអនុប្រធានទាំងពីរនៃរដ្ឋសភា ព្រះមហាក្សត្រទ្រង់ចាត់តាំងវរជនមួយរូប ក្នុងចំណោមតំណាងរាស្ត្រនៃគណៈបក្សដែលឈ្នះឆ្នោតអោយបង្កើតរាជរដ្ឋាភិបាល។ វរជនដែលត្រូវបានចាត់តាំងនេះ នាំសហការីដែលជាតំណាងរាស្ត្រ ឬជាសមាជិកគណៈបក្សតំណាងនៅក្នុងរដ្ឋសភា ដែលផ្តូវផ្តងអោយកាន់តំណែងផ្សេងៗក្នុងរាជរដ្ឋាភិបាល ទៅសុំសេចក្តីទុកចិត្តពីរដ្ឋសភា។<br>កាលបើរដ្ឋសភាបានបោះឆ្នោតទុកចិត្តហើយនោះ ព្រះមហាក្សត្រទ្រង់ចេញព្រះរាជក្រឹត្យតែងតាំងគណៈរដ្ឋមន្ត្រីទាំងមូល។<br>មុនចូលកាន់តំណែងគណៈរដ្ឋមន្ត្រីត្រូវធ្វើសច្ចាប្រណិធាន ដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធ៦។ | **មាត្រា ១១៩.- ថ្មី (មាត្រា ១០០ ចាស់)**<br>តាមសេចក្តីស្នើពីប្រធាន ដោយមានមតិឯកភាពពីអនុប្រធានទាំងពីរនៃរដ្ឋសភា ព្រះមហាក្សត្រទ្រង់ចាត់តាំងវរជនមួយរូប ក្នុងចំណោមតំណាងរាស្ត្រ នៃគណបក្សដែលឈ្នះឆ្នោតអោយបង្កើតរាជរដ្ឋាភិបាល។ វរជនដែលត្រូវបានចាត់តាំងនេះ នាំសហការីដែលជាតំណាងរាស្ត្រ ឬជាសមាជិកគណបក្សតំណាងនៅក្នុងរដ្ឋសភា ដែលផ្តូវផ្តងអោយកាន់តំណែងផ្សេងៗក្នុងរាជរដ្ឋាភិបាល ទៅសុំសេចក្តីទុកចិត្តពីរដ្ឋសភា។<br>កាលបើរដ្ឋសភាបានបោះឆ្នោតទុកចិត្តហើយនោះ ព្រះមហាក្សត្រទ្រង់ចេញព្រះរាជក្រឹត្យតែងតាំងគណៈរដ្ឋមន្ត្រីទាំងមូល។<br>មុនចូលកាន់តំណែងគណៈរដ្ឋមន្ត្រីត្រូវធ្វើសច្ចាប្រណិធាន ដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធ៦។ |
| **មាត្រា ១០១.-**<br>មុខងារនៃសមាជិករាជរដ្ឋាភិបាល មានវិសមិតភាពនិងសកម្មភាពខាងវិជ្ជាជីវៈផ្នែកពាណិជ្ជកម្ម ឬឧស្សាហកម្ម ហើយនិងកាន់តំណែងណាមួយក្នុងមុខងារសាធារណៈ។ | **មាត្រា ១២០.- ថ្មី (មាត្រា ១០១ ចាស់)**<br>មុខងារនៃសមាជិករាជរដ្ឋាភិបាល មានវិសមិតភាពនិងសកម្មភាពខាងវិជ្ជាជីវៈផ្នែកពាណិជ្ជកម្ម ឬឧស្សាហកម្ម ហើយនិងកាន់តំណែងណាមួយក្នុងមុខងារសាធារណៈ។ |
| **មាត្រា ១០២.-**<br>សមាជិកទាំងឡាយនៃរាជរដ្ឋាភិបាលទទួលខុសត្រូវរួមគ្នាចំពោះរដ្ឋសភា អំពីនយោបាយទូទៅរបស់រាជរដ្ឋាភិបាល។ | **មាត្រា ១២១.- ថ្មី (មាត្រា ១០២ ចាស់)**<br>សមាជិកទាំងឡាយនៃរាជរដ្ឋាភិបាលទទួលខុសត្រូវរួមគ្នាចំពោះរដ្ឋសភា អំពីនយោបាយទូទៅរបស់រាជរដ្ឋាភិបាល។ |

| | |
|---|---|
| សមាជិកមួយរូបៗនៃរាជរដ្ឋាភិបាល ទទួលខុសត្រូវរៀងខ្លួនចំពោះនាយករដ្ឋមន្ត្រី និងចំពោះរដ្ឋសភាអំពីការដែលខ្លួនបានប្រព្រឹត្ត។ | សមាជិកមួយរូបៗនៃរាជរដ្ឋាភិបាល ទទួលខុសត្រូវរៀងខ្លួនចំពោះនាយករដ្ឋមន្ត្រី និងចំពោះរដ្ឋសភាអំពីការដែលខ្លួនបានប្រព្រឹត្ត។ |
| **មាត្រា ១០៣.-**<br>សមាជិកទាំងឡាយនៃរាជរដ្ឋាភិបាល មិនអាចយកសំអាងនៃសេចក្ដីបង្គាប់ដោយលាយល័ក្ខអក្សរ ឬដោយវាចា អំពីនរណាមួយ ដើម្បីដោះសារឱ្យរួចខ្លួនពីការទទួលខុសត្រូវរបស់ខ្លួនបានឡើយ។ | **មាត្រា ១២២.- ថ្មី (មាត្រា ១០៣ ចាស់)**<br>សមាជិកទាំងឡាយនៃរាជរដ្ឋាភិបាល មិនអាចយកសំអាងនៃសេចក្ដីបង្គាប់ដោយលាយលក្ខអក្សរ ឬដោយវាចាអំពីនរណាមួយ ដើម្បីដោះសាអោយរួចខ្លួនពីការទទួលខុសត្រូវរបស់ខ្លួនឡើយ។ |
| **មាត្រា ១០៤.-**<br>គណៈរដ្ឋមន្ត្រីត្រូវប្រជុំរាល់សប្ដាហ៍ ជាប្រជុំធំឬជាប្រជុំពិនិត្យស្រាវជ្រាវ។<br>អង្គប្រជុំធំត្រូវដឹកនាំដោយនាយករដ្ឋមន្ត្រី។ នាយករដ្ឋមន្ត្រីអាចប្រគល់ភារកិច្ចជូនឧបនាយករដ្ឋមន្ត្រីដឹកនាំអង្គប្រជុំពិនិត្យស្រាវជ្រាវបាន។<br>កំណត់ហេតុនៃអង្គប្រជុំទាំងអស់របស់គណៈរដ្ឋមន្ត្រី ត្រូវធ្វើថ្វាយព្រះមហាក្សត្រទ្រង់ជ្រាប។ | **មាត្រា ១២៣.- ថ្មី (មាត្រា ១០៤ ចាស់)**<br>គណៈរដ្ឋមន្ត្រីត្រូវប្រជុំរាល់សប្ដាហ៍ ជាប្រជុំធំឬជាប្រជុំពិនិត្យស្រាវជ្រាវ។<br>អង្គប្រជុំធំត្រូវដឹកនាំដោយនាយករដ្ឋមន្ត្រី។ នាយករដ្ឋមន្ត្រីអាចប្រគល់ភារកិច្ចជូនឧបនាយករដ្ឋមន្ត្រីដឹកនាំអង្គប្រជុំពិនិត្យស្រាវជ្រាវបាន។<br>កំណត់ហេតុនៃអង្គប្រជុំទាំងអស់របស់គណៈរដ្ឋមន្ត្រី ត្រូវធ្វើថ្វាយព្រះមហាក្សត្រទ្រង់ជ្រាប។ |
| **មាត្រា ១០៥.-**<br>នាយករដ្ឋមន្ត្រីអាចរំលែកអំណាចរបស់ខ្លួនឱ្យទៅឧបនាយករដ្ឋមន្ត្រីឬសមាជិកណាមួយនៃរាជរដ្ឋាភិបាលបាន។ | **មាត្រា ១២៤.- ថ្មី (មាត្រា១០៥ ចាស់)**<br>នាយករដ្ឋមន្ត្រីអាចរំលែកអំណាចរបស់ខ្លួនអោយទៅឧបនាយករដ្ឋមន្ត្រីឬសមាជិកណាមួយនៃរាជរដ្ឋាភិបាលបាន។ |
| **មាត្រា ១០៦.-**<br>បើតំណែងនាយករដ្ឋមន្ត្រីនៅទំនេរជាស្ថាពរនោះ ត្រូវតែងតាំងគណៈរដ្ឋមន្ត្រីមួយជាថ្មី ក្នុងល័ក្ខខ័ណ្ឌដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនេះ។ បើការទំនេរនេះ ជាការទំនេរមួយកាលមួយគ្រាទេ ត្រូវចាត់តាំងនាយករដ្ឋមន្ត្រីស្ដីទីជាបណ្ដោះអាសន្ន។ | **មាត្រា ១២៥.- ថ្មី (មាត្រា ១០៦ ចាស់)**<br>បើតំណែងនាយករដ្ឋមន្ត្រីនៅទំនេរជាស្ថាពរនោះ ត្រូវតែងតាំងគណៈរដ្ឋមន្ត្រីមួយជាថ្មី ក្នុងលក្ខខ័ណ្ឌដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនេះ។ បើការទំនេរនេះ ជាការទំនេរមួយកាលមួយគ្រាទេ ត្រូវចាត់តាំងនាយករដ្ឋមន្ត្រីស្ដីទីជាបណ្ដោះអាសន្ន។ |

| | |
|---|---|
| **មាត្រា ១០៧.-**<br>សមាជិកមួយរូបៗនៃរាជរដ្ឋាភិបាល ត្រូវទទួលទណ្ឌកម្មពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ដែលខ្លួនបានប្រព្រឹត្តក្នុងការបំពេញការងាររបស់ខ្លួន។<br>ក្នុងករណីនេះនិងក្នុងករណីធ្វើខុសជាទម្ងន់ ក្នុងការបំពេញការងាររបស់ខ្លួន រដ្ឋសភាអាចសំរេចប្តឹងទៅតុលាការមានសមត្ថកិច្ច។<br>រដ្ឋសភាសំរេចក្នុងរឿងនេះដោយវិធីបោះឆ្នោតជាសម្ងាត់ តាមមតិភាគច្រើនដាច់ខាត នៃសមាជិករដ្ឋសភាទាំងមូល។ | **មាត្រា ១២៦.- ថ្មី (មាត្រា ១០៧ ចាស់)**<br>សមាជិកមួយរូបៗនៃរាជរដ្ឋាភិបាល ត្រូវទទួលទណ្ឌកម្មពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ដែលខ្លួនបានប្រព្រឹត្តក្នុងការបំពេញការងាររបស់ខ្លួន។<br>ក្នុងករណីនេះនិងក្នុងករណីធ្វើខុសជាទម្ងន់ ក្នុងការបំពេញការងាររបស់ខ្លួន រដ្ឋសភាអាចសំរេចប្តឹងទៅតុលាការមានសមត្ថកិច្ច។<br>រដ្ឋសភាសំរេចក្នុងរឿងនេះដោយវិធីបោះឆ្នោតជាសំងាត់ តាមមតិភាគច្រើនដាច់ខាត នៃសមាជិករដ្ឋសភាទាំងមូល។ |
| **មាត្រា ១០៨.-**<br>ការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីនឹងត្រូវកំណត់ក្នុងច្បាប់មួយ។ | **មាត្រា ១២៧.- ថ្មី (មាត្រា ១០៨ ចាស់)**<br>ការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីនឹងត្រូវកំណត់ក្នុងច្បាប់មួយ។ |
| **ជំពូកទី៩**<br>**អំពី**<br>**អំណាចតុលាការ** | **ជំពូកទី១១ ថ្មី**<br>**អំពី**<br>**អំណាចតុលាការ** |
| **មាត្រា ១០៩.-**<br>អំណាចតុលាការជាអំណាចឯករាជ្យ។<br>អំណាចតុលាការ ជានារក្សាអនាគតិ និងការពារសិទ្ធិ សេរីភាពរបស់ប្រជាពលរដ្ឋ។<br>អំណាចតុលាការគ្របដណ្តប់ទៅលើរឿងក្តីទាំងអស់រួមទាំងរឿងក្តីរដ្ឋបាលផង។<br>អំណាចនេះ ត្រូវប្រគល់ឱ្យតុលាការកំពូល និងសាលាជំរះក្តីគ្រប់ផ្នែក និងគ្រប់ជាន់ថ្នាក់។ | **មាត្រា ១២៨.- ថ្មី (មាត្រា ១០៩ ចាស់)**<br>អំណាចតុលាការជាអំណាចឯករាជ្យ។<br>អំណាចតុលាការ ជានារក្សាអនាគតិ និងការពារសិទ្ធិ សេរីភាពរបស់ប្រជាពលរដ្ឋ។<br>អំណាចតុលាការគ្របដណ្តប់ទៅលើរឿងក្តីទាំងអស់រួមទាំងរឿងក្តីរដ្ឋបាលផង។<br>អំណាចនេះ ត្រូវប្រគល់អោយតុលាការកំពូល និងសាលាជំរះក្តីគ្រប់ផ្នែក និងគ្រប់ជាន់ថ្នាក់។ |
| **មាត្រា ១១០.-**<br>ការជំរះក្តីផ្តល់យុត្តិធម៌ ត្រូវធ្វើក្នុងនាមប្រជារាស្ត្រខ្មែរ តាមនីតិវិធីនិងច្បាប់ជាធរមាន។<br>មានតែចៅក្រមទេដែលមានសិទ្ធិជំរះក្តី។<br>ចៅក្រមត្រូវបំពេញភារកិច្ចនេះ ដោយគោរពច្បាប់ | **មាត្រា ១២៩.- ថ្មី (មាត្រា ១១០ ចាស់)**<br>ការជំរះក្តីផ្តល់យុត្តិធម៌ ត្រូវធ្វើក្នុងនាមប្រជារាស្ត្រខ្មែរ តាមនីតិវិធីនិងច្បាប់ជាធរមាន។<br>មានតែចៅក្រមទេដែលមានសិទ្ធិជំរះក្តី។<br>ចៅក្រមត្រូវបំពេញភារកិច្ចនេះ ដោយគោរព |

| | |
|---|---|
| យ៉ាងម៉ឺងម៉ាត់ និងឱ្យអស់ពីដួងចិត្ត និងសម្បជញ្ញៈរបស់ខ្លួន។ | ច្បាប់យ៉ាងម៉ឺងម៉ាត់ និងអោយអស់ពីដួងចិត្ត និងសម្បជញ្ញៈរបស់ខ្លួន។ |
| **មាត្រា ១១១.-**<br>គ្មានអង្គការណាមួយនៃអំណាចនីតិប្បញ្ញត្តិ ឬនីតិប្រតិបត្តិអាចទទួលអំណាចតុលាការអ្វីបានឡើយ។ | **មាត្រា ១៣០.- ថ្មី (មាត្រា ១១១ ចាស់)**<br>គ្មានអង្គការណាមួយនៃអំណាចនីតិប្បញ្ញត្តិ ឬនីតិប្រតិបត្តិអាចទទួលអំណាចតុលាការអ្វីបានឡើយ។ |
| **មាត្រា ១១២.-**<br>មានតែអង្គការអយ្យការទេ ដែលមានសិទ្ធិធ្វើបណ្ដឹងអាជ្ញា។ | **មាត្រា ១៣១.- ថ្មី (មាត្រា ១១២ ចាស់)**<br>មានតែអង្គការអយ្យការទេ ដែលមានសិទ្ធិធ្វើបណ្ដឹងអាជ្ញា។ |
| **មាត្រា ១១៣.-**<br>ព្រះមហាក្សត្រទ្រង់ជាអ្នកធានាឯករាជ្យនៃអំណាចតុលាការ។<br>ឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រមជួយព្រះមហាក្សត្រក្នុងកិច្ចការនេះ។ | **មាត្រា ១៣២.- ថ្មី (មាត្រា ១១៣ ចាស់)**<br>ព្រះមហាក្សត្រទ្រង់ជាអ្នកធានាឯករាជ្យនៃអំណាចតុលាការ។<br>ឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រមជួយព្រះមហាក្សត្រក្នុងកិច្ចការនេះ។ |
| **មាត្រា ១១៤.-**<br>ចៅក្រមមិនអាចត្រូវគេដកពីមុខងារបានទេ។ ប៉ុន្តែឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រមសំរេចដាក់វិន័យលើចៅក្រមដែលបានប្រព្រឹត្តខុស។ | **មាត្រា ១៣៣.- ថ្មី (មាត្រា ១១៤ ចាស់)**<br>ចៅក្រមមិនអាចត្រូវគេដកពីមុខងារបានទេ។ ប៉ុន្តែឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រមសំរេចដាក់វិន័យលើចៅក្រមដែលបានប្រព្រឹត្តខុស។ |
| **មាត្រា ១១៥.-**<br>ឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រមនឹងត្រូវបង្កើតដោយច្បាប់រៀបចំអង្គការមួយដែលនឹងកំណត់សមាសភាព និងមុខងារ។<br>ឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រមស្ថិតក្រោមព្រះរាជាធិបតីភាពនៃព្រះមហាក្សត្រ។ ព្រះមហាក្សត្រព្រះអង្គអាចចាត់តាំងព្រះរាជតំណាងម្នាក់របស់ព្រះអង្គឱ្យធ្វើអធិបតីនៃឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រមនេះ។ | **មាត្រា ១៣៤.- ថ្មី (មាត្រា ១១៥ ចាស់)**<br>ឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រមនឹងត្រូវបង្កើតដោយច្បាប់រៀបចំអង្គការមួយដែលនឹងកំណត់សមាសភាព និងមុខងារ។<br>ឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រមស្ថិតក្រោមព្រះរាជាធិបតីភាពនៃព្រះមហាក្សត្រ។ ព្រះមហាក្សត្រព្រះអង្គអាចចាត់តាំងព្រះរាជតំណាងម្នាក់របស់ព្រះអង្គអោយធ្វើអធិបតីនៃឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រមនេះ។ |

| | |
|---|---|
| ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម លើកសេចក្តីស្នើថ្វាយព្រះមហាក្សត្រអំពីការតែងតាំងចៅក្រម និងព្រះរាជអាជ្ញាអមសាលាជំរះក្តីទាំងអស់។<br>ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្នុងមុខការដាក់វិន័យចំពោះចៅក្រម និងព្រះរាជអាជ្ញាត្រូវប្រជុំក្រោមអធិបតីភាពនៃប្រធានតុលាការកំពូល ឬអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល អាស្រ័យដោយករណីទាក់ទងនឹងចៅក្រម ឬព្រះរាជអាជ្ញា។ | ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម លើកសេចក្តីស្នើថ្វាយព្រះមហាក្សត្រអំពីការតែងតាំងចៅក្រម និងព្រះរាជអាជ្ញាអមសាលាជំរះក្តីទាំងអស់។<br>ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្នុងមុខការដាក់វិន័យចំពោះចៅក្រម និងព្រះរាជអាជ្ញាត្រូវប្រជុំក្រោមអធិបតីភាពនៃប្រធានតុលាការកំពូល ឬអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល អាស្រ័យដោយករណីទាក់ទងនឹងចៅក្រម ឬព្រះរាជអាជ្ញា។ |
| **មាត្រា ១១៦.-** | **មាត្រា ១៣៥.- ថ្មី (មាត្រា ១១៦ ចាស់)** |
| លក្ខន្តិកៈនៃចៅក្រមនិងព្រះរាជអាជ្ញា និងការរៀបចំអង្គការតុលាការនឹងត្រូវកំណត់ក្នុងច្បាប់ដោយឡែកពីគ្នា។ | លក្ខន្តិកៈនៃចៅក្រមនិងព្រះរាជអាជ្ញា និងការរៀបចំអង្គការតុលាការនឹងត្រូវកំណត់ក្នុងច្បាប់ដោយឡែកពីគ្នា។ |
| **ជំពូកទី១០<br>អំពី<br>ក្រុមប្រឹក្សាធម្មនុញ្ញ** | **ជំពូកទី១២ ថ្មី<br>អំពី<br>ក្រុមប្រឹក្សាធម្មនុញ្ញ** |
| **មាត្រា ១១៧.-** | **មាត្រា ១៣៦.- ថ្មី (មាត្រា ១១៧ ចាស់)** |
| ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចធានាការពារការគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ដែលអនុម័តដោយរដ្ឋសភា។<br>ក្រុមប្រឹក្សាធម្មនុញ្ញមានសិទ្ធិពិនិត្យ និងសំរេចអំពីករណីវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ។ | ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចធានាការពារការគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និង ច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ។<br>ក្រុមប្រឹក្សាធម្មនុញ្ញមានសិទ្ធិពិនិត្យ និងសំរេចអំពីករណីវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។ |
| **មាត្រា ១១៨.-** | **មាត្រា ១៣៧.- ថ្មី (មាត្រា ១១៨ ចាស់)** |
| ក្រុមប្រឹក្សាធម្មនុញ្ញមានសមាជិកប្រាំបួនរូប ដែលទទួលអាណត្តិប្រាំបួនឆ្នាំ។ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញចំនួនមួយភាគបីត្រូវផ្លាស់ថ្មីក្នុងរយៈពេលបីឆ្នាំម្តង បីឆ្នាំម្តង។ សមាជិកបីរូបត្រូវតែងតាំងដោយព្រះមហាក្សត្រ បីរូបត្រូវ | ក្រុមប្រឹក្សាធម្មនុញ្ញមានសមាជិកប្រាំបួនរូប ដែលទទួលអាណត្តិប្រាំបួនឆ្នាំ។ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញចំនួនមួយភាគបីត្រូវផ្លាស់ថ្មីក្នុងរយៈពេលបីឆ្នាំម្តង បីឆ្នាំម្តង។ សមាជិកបីរូបត្រូវតែងតាំងដោយព្រះមហាក្សត្រ បីរូបត្រូវ |

| | |
|---|---|
| ជ្រើសតាំងដោយរដ្ឋសភា ហើយបីរូបទៀតត្រូវតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។<br>ប្រធានត្រូវបានជ្រើសតាំងដោយសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ។ ប្រធានមានសម្លេងឧត្តមានុភាពក្នុងករណីបែកសម្លេងជាពីរស្មើគ្នា។ | ជ្រើសតាំងដោយរដ្ឋសភា ហើយបីរូបទៀតត្រូវតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។<br>ប្រធានត្រូវបានជ្រើសតាំងដោយសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ។ ប្រធានមានសំឡេងឧត្តមានុភាពក្នុងករណីបែកសំឡេងជាពីរស្មើគ្នា។ |
| **មាត្រា ១១៩.-**<br>សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវជ្រើសរើសក្នុងចំណោមឥស្សរជនដែលមានសញ្ញាប័ត្រ ចាប់ពីឧត្តមសិក្សាទៅខាងច្បាប់ ខាងរដ្ឋបាល ខាងការទូត ឬខាងសេដ្ឋកិច្ច ហើយមានពិសោធន៍ច្រើនក្នុងការងារ។ | **មាត្រា ១៣៨.- ថ្មី (មាត្រា ១១៩ ចាស់)**<br>សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវជ្រើសរើសក្នុងចំណោមឥស្សរជនដែលមានសញ្ញាបត្រ ចាប់ពីឧត្តមសិក្សាទៅខាងច្បាប់ ខាងរដ្ឋបាល ខាងការទូត ឬខាងសេដ្ឋកិច្ច ហើយមានពិសោធន៍ច្រើនក្នុងការងារ។ |
| **មាត្រា ១២០.-**<br>មុខងារសមាជិកក្រុមប្រឹក្សាធម្មនុញ្ញមានវិសមិតភាពនឹងមុខងារសមាជិករដ្ឋាភិបាល សមាជិករដ្ឋសភា ប្រធាន ឬអនុប្រធានគណបក្សនយោបាយ ប្រធាន ឬអនុប្រធានសហជីពចៅក្រមក្នុងតំណែង។ | **មាត្រា ១៣៩.- ថ្មី (មាត្រា ១២០ ចាស់)**<br>មុខងារសមាជិកក្រុមប្រឹក្សាធម្មនុញ្ញមានវិសមិតភាពនឹងមុខងារសមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា សមាជិករាជរដ្ឋាភិបាល ចៅក្រមក្នុងតំណែង ការកាន់តំណែងណាមួយក្នុងមុខងារសាធារណៈ ប្រធាន ឬអនុប្រធានគណបក្សនយោបាយ ប្រធាន ឬអនុប្រធានសហជីព។ |
| **មាត្រា ១២១.-**<br>ព្រះមហាក្សត្រ នាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា ឬតំណាងរាស្ត្រ ចំនួនមួយភាគដប់អាចបញ្ជូនសេចក្ដីព្រាងច្បាប់ទៅឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុននឹងសេចក្ដីព្រាងច្បាប់នោះត្រូវបានប្រកាសឱ្យប្រើ។<br>បទបញ្ជាផ្ទៃក្នុងរដ្ឋសភា និងច្បាប់រៀបចំអង្គការទាំងឡាយ ត្រូវតែបញ្ជូនទៅក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ មុននឹងត្រូវបានប្រកាសឱ្យប្រើ។<br>ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសំរេចក្នុងរយៈពេលសាមសិបថ្ងៃយ៉ាងយូរថាតើច្បាប់ បទបញ្ជាផ្ទៃក្នុងរដ្ឋសភាខាងលើស្រប ឬមិនស្របនឹងរដ្ឋធម្មនុញ្ញ។ | **មាត្រា ១៤០.- ថ្មី (មាត្រា ១២១ ចាស់)**<br>ព្រះមហាក្សត្រ នាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា តំណាងរាស្ត្រ ចំនួនមួយភាគដប់ ប្រធានព្រឹទ្ធសភា ឬសមាជិកព្រឹទ្ធសភាចំនួនមួយភាគបួន អាចបញ្ជូនច្បាប់ដែលរដ្ឋសភាបានអនុម័តទៅអោយក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុននឹងច្បាប់នោះត្រូវប្រកាសអោយប្រើ។<br>បទបញ្ជាផ្ទៃក្នុងរដ្ឋសភា បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា និងច្បាប់រៀបចំអង្គការទាំងឡាយ ត្រូវតែបញ្ជូនទៅក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ មុននឹងប្រកាសអោយប្រើ។ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសំរេចក្នុងរយៈពេលសាមសិប (៣០) ថ្ងៃយ៉ាងយូរ ថាតើ |

| | |
|---|---|
| | ច្បាប់ បទបញ្ជាផ្ទៃក្នុងរដ្ឋសភា និងបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភាខាងលើស្រប ឬមិនស្របនឹងរដ្ឋធម្មនុញ្ញ។ |
| **មាត្រា ១២២.-**<br>ក្រោយពីច្បាប់ណាមួយត្រូវបានប្រកាសឱ្យប្រើ ព្រះមហាក្សត្រ នាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា តំណាងរាស្ត្រចំនួនមួយភាគដប់ ឬតុលាការអាចសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យអំពីធម្មនុញ្ញភាពនៃច្បាប់នោះ។<br>ប្រជារាស្ត្រមានសិទ្ធិប្ដឹងអំពីធម្មនុញ្ញភាពនៃច្បាប់បាន តាមរយៈតំណាងរាស្ត្រ ឬប្រធានរដ្ឋសភាដូចមានចែងក្នុងវាក្យខ័ណ្ឌខាងលើ។ | **មាត្រា ១៤១.- ថ្មី (មាត្រា ១២២ ចាស់)**<br>ក្រោយពីច្បាប់ណាមួយត្រូវបានប្រកាសអោយប្រើ ព្រះមហាក្សត្រ ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី សមាជិកព្រឹទ្ធសភាចំនួនមួយភាគបួន តំណាងរាស្ត្រចំនួនមួយភាគដប់ ឬតុលាការអាចសុំអោយក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យអំពីធម្មនុញ្ញភាពនៃច្បាប់នោះ។<br>ប្រជារាស្ត្រមានសិទ្ធិប្ដឹងអំពីធម្មនុញ្ញភាពនៃច្បាប់បាន តាមរយៈតំណាងរាស្ត្រ ឬប្រធានរដ្ឋសភា ឬសមាជិកព្រឹទ្ធសភា ឬប្រធានព្រឹទ្ធសភាដូចមានចែងក្នុងវាក្យខ័ណ្ឌខាងលើ។ |
| **មាត្រា ១២៣.-**<br>បទប្បញ្ញត្តិក្នុងមាត្រាណាដែលក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាមិនស្របនឹងរដ្ឋធម្មនុញ្ញ មិនអាច យកទៅប្រកាសឱ្យប្រើ ឬយកទៅអនុវត្តបានឡើយ។<br>សេចក្ដីសំរេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញជាសេចក្ដីសំរេចបិទផ្លូវតវ៉ា។ | **មាត្រា ១៤២.- ថ្មី (មាត្រា ១២៣ ចាស់)**<br>បទប្បញ្ញត្តិក្នុងមាត្រាណាដែលក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាមិនស្របនឹងរដ្ឋធម្មនុញ្ញ មិនអាច យកទៅប្រកាសអោយប្រើ ឬយកទៅអនុវត្តបានឡើយ។<br>សេចក្ដីសំរេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញជាសេចក្ដីសំរេចបិទផ្លូវតវ៉ា។ |
| **មាត្រា ១២៤.-**<br>ព្រះមហាក្សត្រទ្រង់ពិគ្រោះមតិក្រុមប្រឹក្សាធម្មនុញ្ញចំពោះសេចក្ដីស្នើទាំងឡាយ ដែលសុំធ្វើវិសោធនកម្មលើរដ្ឋធម្មនុញ្ញ។ | **មាត្រា ១៤៣.- ថ្មី (មាត្រា ១២៤ ចាស់)**<br>ព្រះមហាក្សត្រទ្រង់ពិគ្រោះមតិក្រុមប្រឹក្សាធម្មនុញ្ញចំពោះសេចក្ដីស្នើទាំងឡាយ ដែលសុំធ្វើវិសោធនកម្មលើរដ្ឋធម្មនុញ្ញ។ |
| **មាត្រា ១២៥.-**<br>ច្បាប់រៀបចំអង្គការមួយនឹងកំណត់ការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។ | **មាត្រា ១៤៤.- ថ្មី (មាត្រា ១២៥ ចាស់)**<br>ច្បាប់រៀបចំអង្គការមួយនឹងកំណត់ការរៀបចំនិងការប្រព្រឹត្តិទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។ |
| **ជំពូកទី១១**<br>**អំពី**<br>**ការគ្រប់គ្រងរដ្ឋបាល** | **ជំពូកទី១៣ ថ្មី**<br>**អំពី**<br>**ការគ្រប់គ្រងរដ្ឋបាល** |

| | |
|---|---|
| **មាត្រា ១២៦.-**<br>ទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ចែកជាខេត្ត និងក្រុង។<br>ខេត្ត ចែកជាស្រុក ស្រុកចែកជា ឃុំ។<br>ក្រុង ចែកជាខ័ណ្ឌ ខ័ណ្ឌចែកជាសង្កាត់។ | **មាត្រា ១៤៥.- ថ្មី (មាត្រា ១២៦ ចាស់)**<br>ទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ចែកជាខេត្ត និងក្រុង។<br>ខេត្ត ចែកជាស្រុក ស្រុកចែកជា ឃុំ។<br>ក្រុង ចែកជាខ័ណ្ឌ ខ័ណ្ឌចែកជាសង្កាត់។ |
| **មាត្រា ១២៧.-**<br>ខេត្ត ក្រុង ស្រុក ខ័ណ្ឌ ឃុំ និង សង្កាត់ត្រូវគ្រប់គ្រងតាមល័ក្ខខ័ណ្ឌ ដែលមានចែងក្នុងច្បាប់រៀបចំអង្គការមួយ។ | **មាត្រា ១៤៦.- ថ្មី (មាត្រា ១២៧ ចាស់)**<br>ខេត្ត ក្រុង ស្រុក ខ័ណ្ឌ ឃុំ និង សង្កាត់ត្រូវគ្រប់គ្រងតាមល័ក្ខខ័ណ្ឌ ដែលមានចែងក្នុងច្បាប់រៀបចំអង្គការមួយ។ |
| **ជំពូកទី១២**<br>**អំពី**<br>**សមាជជាតិ** | **ជំពូកទី១៤ ថ្មី**<br>**អំពី**<br>**សមាជជាតិ** |
| **មាត្រា ១២៨.-**<br>សមាជជាតិបើកឱ្យប្រជារាស្ត្រជ្រាបដោយផ្ទាល់ អំពីកិច្ចការផ្សេងៗ ដែលជាប្រយោជន៍ជាតិ និងលើកបញ្ហា និងសំណូមពរជូនរដ្ឋអំណាចដោះស្រាយ។<br>ប្រជារាស្ត្រខ្មែរទាំងពីរភេទ មានសិទ្ធិទៅចូលរួមក្នុងសមាជជាតិ។ | **មាត្រា ១៤៧.- ថ្មី (មាត្រា ១២៨ ចាស់)**<br>សមាជជាតិបើកអោយប្រជារាស្ត្រជ្រាបដោយផ្ទាល់ អំពីកិច្ចការផ្សេងៗ ដែលជាប្រយោជន៍ជាតិ និងលើកបញ្ហា និងសំណូមពរជូនរដ្ឋអំណាចដោះស្រាយ។<br>ប្រជារាស្ត្រខ្មែរទាំងពីរភេទ មានសិទ្ធិទៅចូលរួមក្នុងសមាជជាតិ។ |
| **មាត្រា ១២៩.-**<br>សមាជជាតិប្រជុំមួយដងក្នុងមួយឆ្នាំនៅដើមខែធ្នូ តាមការកោះអញ្ជើញរបស់នាយករដ្ឋមន្ត្រី។<br>សមាជជាតិប្រព្រឹត្តទៅក្រោមព្រះរាជាធិបតីភាពនៃព្រះមហាក្សត្រ។ | **មាត្រា ១៤៨.- ថ្មី (មាត្រា ១២៩ ចាស់)**<br>សមាជជាតិប្រជុំមួយដងក្នុងមួយឆ្នាំនៅដើមខែធ្នូ តាមការកោះអញ្ជើញរបស់នាយករដ្ឋមន្ត្រី។<br>សមាជជាតិប្រព្រឹត្តទៅក្រោមព្រះរាជាធិបតីភាពនៃព្រះមហាក្សត្រ។ |
| **មាត្រា ១៣០.-**<br>សមាជជាតិអនុម័តសំណូមពរជូនរដ្ឋអំណាច និងជូនរដ្ឋសភាពិចារណា។<br>ការរៀបចំ និងការប្រព្រឹត្តទៅនៃសមាជជាតិនឹងត្រូវកំណត់ក្នុងច្បាប់មួយ។ | **មាត្រា ១៤៩.- ថ្មី (មាត្រា ១៣០ ចាស់)**<br>សមាជជាតិអនុម័តសំណូមពរជូនព្រឹទ្ធសភា ជូនរដ្ឋសភា និងជូនរដ្ឋអំណាចពិចារណា។<br>ការរៀបចំ និងការប្រព្រឹត្តទៅនៃសមាជជាតិនឹងត្រូវកំណត់ក្នុងច្បាប់មួយ។ |

| ជំពូកទី១៣<br>អំពី<br>អានុភាព ការសើរើ និងវិសោធនកម្ម<br>រដ្ឋធម្មនុញ្ញ | ជំពូកទី១៥ ថ្មី<br>អំពី<br>អានុភាព ការសើរើ និងវិសោធនកម្ម<br>រដ្ឋធម្មនុញ្ញ |
|---|---|
| **មាត្រា ១៣១.-**<br>រដ្ឋធម្មនុញ្ញនេះជាច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជា។<br>ច្បាប់ និងសេចក្តីសម្រេចទាំងឡាយនៃស្ថាប័ននានារបស់រដ្ឋត្រូវស្របនឹងរដ្ឋធម្មនុញ្ញជាដាច់ខាត។ | **មាត្រា ១៥០.- ថ្មី (មាត្រា ១៣១ ចាស់)**<br>រដ្ឋធម្មនុញ្ញនេះជាច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជា។<br>ច្បាប់ និងសេចក្តីសំរេចទាំងឡាយនៃស្ថាប័ននានា របស់រដ្ឋត្រូវស្របនឹងរដ្ឋធម្មនុញ្ញជាដាច់ខាត។ |
| **មាត្រា ១៣២.-**<br>ការផ្តើមគំនិតសើរើ ឬការផ្តើមគំនិតធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ជាសិទ្ធិរបស់ព្រះមហាក្សត្រ របស់នាយករដ្ឋមន្ត្រី និងរបស់ប្រធានរដ្ឋសភា តាមសេចក្តីស្នើរបស់ តំណាងរាស្ត្រមួយភាគបួន នៃចំនួនសមាជិករដ្ឋសភាទាំងមូល។<br>ការសើរើ ឬវិសោធនកម្មរដ្ឋធម្មនុញ្ញត្រូវធ្វើឡើងដោយច្បាប់ធម្មនុញ្ញ មួយដែលអនុម័តដោយរដ្ឋសភាតាមមតិភាគច្រើនពីរភាគបី នៃចំនួនសមាជិករដ្ឋសភាទាំងមូល។ | **មាត្រា ១៥១.- ថ្មី (មាត្រា ១៣២ ចាស់)**<br>ការផ្តើមគំនិតសើរើឬការផ្តើមគំនិតធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ជាសិទ្ធិរបស់ព្រះមហាក្សត្រ របស់នាយករដ្ឋមន្ត្រី និងរបស់ប្រធានរដ្ឋសភា តាមសេចក្តីស្នើរបស់តំណាងរាស្ត្រ មួយភាគបួននៃចំនួនសមាជិករដ្ឋសភាទាំងមូល។<br>ការសើរើឬវិសោធនកម្មរដ្ឋធម្មនុញ្ញត្រូវធ្វើឡើងដោយច្បាប់ធម្មនុញ្ញមួយដែលអនុម័តដោយរដ្ឋសភាតាមមតិភាគច្រើនពីរភាគបី នៃចំនួនសមាជិករដ្ឋសភាទាំងមូល។ |
| **មាត្រា ១៣៣.-**<br>ការសើរើ ឬវិសោធនកម្មរដ្ឋធម្មនុញ្ញត្រូវហាមឃាត់មិនឱ្យធ្វើ នៅពេលប្រទេសជាតិឋិតក្នុងភាពអាសន្ន ដូចមានចែងក្នុងមាត្រា ៨៦។ | **មាត្រា ១៥២.- ថ្មី (មាត្រា ១៣៣ ចាស់)**<br>ការសើរើ ឬវិសោធនកម្មរដ្ឋធម្មនុញ្ញ ត្រូវហាមឃាត់មិនអោយធ្វើ នៅពេលប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ដូចមានចែងក្នុងមាត្រា ៨៦។ |
| **មាត្រា ១៣៤.-**<br>ការសើរើ ឬវិសោធនកម្មរដ្ឋធម្មនុញ្ញមិនអាចធ្វើបានឡើយ កាលបើប៉ះពាល់ដល់ប្រព័ន្ធប្រជាធិបតេយ្យ សេរីពហុបក្ស និងរបបរាជានិយមអាស្រ័យដោយរដ្ឋធម្មនុញ្ញ។ | **មាត្រា ១៥៣.- ថ្មី (មាត្រា ១៣៤ ចាស់)**<br>ការសើរើ ឬវិសោធនកម្មរដ្ឋធម្មនុញ្ញមិនអាចធ្វើបានឡើយ កាលបើប៉ះពាល់ដល់ប្រព័ន្ធប្រជាធិបតេយ្យ សេរីពហុបក្ស និងរបបរាជានិយមអាស្រ័យដោយរដ្ឋធម្មនុញ្ញ។ |

| ជំពូកទី១៤<br>អំពី<br>អន្តរប្បញ្ញត្តិ | ជំពូកទី១៦ ថ្មី<br>អំពី<br>អន្តរប្បញ្ញត្តិ |
|---|---|
| **មាត្រា ១៣៥.-**<br>រដ្ឋធម្មនុញ្ញនេះ ក្រោយពីបានទទួលការអនុម័ត ត្រូវបានប្រកាសឱ្យចូលជាធរមានភ្លាមដោយព្រះប្រមុខរដ្ឋកម្ពុជា។ | **មាត្រា ១៥៤.- ថ្មី (មាត្រា ១៣៥ ចាស់)**<br>រដ្ឋធម្មនុញ្ញនេះ ក្រោយពីបានទទួលការអនុម័ត ត្រូវបានប្រកាសអោយចូលជាធរមានភ្លាមដោយព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។ |
| **មាត្រា ១៣៦.-**<br>ក្រោយពេលរដ្ឋធម្មនុញ្ញនេះចូលជាធរមាន សភាធម្មនុញ្ញត្រូវក្លាយទៅជារដ្ឋសភា។<br>បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភាត្រូវចូលជាធរមាន ក្រោយទទួលបានការអនុម័តពីរដ្ឋសភា។<br>ក្នុងករណីដែលរដ្ឋសភាមិនទាន់ចាប់ដំណើរការបាន ប្រធាន អនុប្រធានទីមួយ និងអនុប្រធានទីពីរនៃសភាធម្មនុញ្ញនឹងចូលរួមបំពេញភារកិច្ចក្នុងក្រុមប្រឹក្សារាជសម្បត្តិ បើសភាពការណ៍ក្នុងប្រទេសទាមទារ។ | **មាត្រា ១៥៥.- ថ្មី (មាត្រា ១៣៦ ចាស់)**<br>ក្រោយពេលរដ្ឋធម្មនុញ្ញនេះចូលជាធរមាន សភាធម្មនុញ្ញត្រូវក្លាយទៅជារដ្ឋសភា។<br>បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភាត្រូវចូលជាធរមាន ក្រោយទទួលបានការអនុម័តពីរដ្ឋសភា។<br>ក្នុងករណីដែលរដ្ឋសភាមិនទាន់ចាប់ដំណើរការបាន ប្រធាន អនុប្រធានទីមួយ និងអនុប្រធានទីពីរនៃសភាធម្មនុញ្ញនឹងចូលរួមបំពេញភារកិច្ចក្នុងក្រុមប្រឹក្សារាជសម្បត្តិបើសភាពការណ៍ក្នុងប្រទេសទាមទារ។ |
| **មាត្រា ១៣៧.-**<br>ក្រោយរដ្ឋធម្មនុញ្ញនេះចូលជាធរមាន ព្រះមហាក្សត្រជ្រើសតាំងតាមលក្ខខ័ណ្ឌ ដែលមានចែងក្នុងមាត្រា ១៣ និង ១៤។ | **មាត្រា ១៥៦.- ថ្មី (មាត្រា ១៣៧ ចាស់)**<br>ក្រោយរដ្ឋធម្មនុញ្ញនេះចូលជាធរមាន ព្រះមហាក្សត្រជ្រើសតាំងតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ១៣ថ្មី និង១៤។ |
| **មាត្រា ១៣៨.-**<br>ក្រោយពេលរដ្ឋធម្មនុញ្ញនេះចូលជាធរមាន ហើយក្នុងនីតិកាលទី១ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ព្រះអង្គចាត់តាំងនាយករដ្ឋមន្ត្រីទីមួយមួយរូប និងនាយករដ្ឋមន្ត្រីទីពីរ ឱ្យបង្កើតរាជរដ្ឋាភិបាលក្រោយបានមតិឯកភាពពីប្រធានរដ្ឋសភា និងអនុប្រធានទាំងពីរនៃរដ្ឋសភា។ | **មាត្រា ១៥៧.- ថ្មី (មាត្រា ១៣៨ ចាស់)**<br>នីតិកាលទី១ នៃព្រឹទ្ធសភាមានកំណត់ ៥ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលព្រឹទ្ធសភាថ្មីចូលកាន់តំណែង។<br>សំរាប់នីតិកាលទី១ នៃព្រឹទ្ធសភា៖<br>- សមាជិកព្រឹទ្ធសភា មានចំនួនសរុបហុកសិបមួយរូប។<br>- ព្រះមហាក្សត្រទ្រង់តែងតាំងសមាជិកព្រឹទ្ធសភាពីររូប ព្រមទាំងប្រធាន អនុ |

| | |
|---|---|
| សហនាយករដ្ឋមន្ត្រី ដែលមានមុនការអនុម័តរដ្ឋធម្មនុញ្ញនេះ ត្រូវចូលជាសមាជិកនៃគណៈកម្មការ និងក្រុមប្រឹក្សារាជសម្បត្តិដែលមានចែងក្នុងមាត្រា១១ និង១៣ ខាងលើ។ | ប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា។<br>- សមាជិកដទៃទៀតនៃព្រឹទ្ធសភាត្រូវបានតែងតាំងដោយព្រះមហាក្សត្រ តាមសំណើរបស់ព្រឹទ្ធសភា និងប្រធានរដ្ឋសភា ក្នុងចំណោមសមាជិកនៃគណបក្សដែកមានអាសនៈនៅក្នុងរដ្ឋសភា។<br>- កិច្ចប្រជុំជាសមាជិករដ្ឋសភា និងព្រឹទ្ធសភា ត្រូវដឹកនាំដោយសហប្រធាន។ |
| **មាត្រា ១៣៩.-**<br>ច្បាប់និងលិខិតបទដ្ឋានទាំងអស់នៅកម្ពុជា ដែលធានាការពារបាននូវទ្រព្យសម្បត្តិរដ្ឋ សិទ្ធិ សេរីភាព និងទ្រព្យសម្បត្តិត្រឹមត្រូវតាមច្បាប់របស់បុគ្គលនិងដែលសមស្របនឹងប្រយោជន៍ជាតិ ត្រូវមានអានុភាពអនុវត្តបន្តទៅមុខទៀត រហូតដល់មានអត្ថបទថ្មីមកកែប្រែ ឬលុបចោលលើកលែងតែបទប្បញ្ញត្តិណា ដែលផ្ទុយនឹងស្មារតីនៃរដ្ឋធម្មនុញ្ញនេះ។ | **មាត្រា ១៥៨.- ថ្មី (មាត្រា ១៣៩ ចាស់)**<br>ច្បាប់ និងលិខិតបទដ្ឋានទាំងអស់នៅកម្ពុជា ដែលធានាការពារបាននូវទ្រព្យសម្បត្តិរដ្ឋ សិទ្ធិ សេរីភាព និងទ្រព្យសម្បត្តិត្រឹមត្រូវតាមច្បាប់របស់បុគ្គល និងដែលសមស្របនឹងប្រយោជន៍ជាតិ ត្រូវមានអានុភាពអនុវត្តបន្តទៅមុខទៀត រហូតដល់មានអត្ថបទថ្មីមកកែប្រែ ឬលុបចោលលើកលែង តែបទប្បញ្ញត្តិណាដែលផ្ទុយនឹងស្មារតីនៃរដ្ឋធម្មនុញ្ញនេះ។<br>ច្បាប់ធម្មនុញ្ញនេះ ត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា អនុម័តនៅថ្ងៃទី ៤ ខែ មីនា ឆ្នាំ ១៩៩៩ ក្នុងសម័យប្រជុំវិសាមញ្ញ នីតិកាលទី២។ |

## វិសោធនកម្មលើកទី៣ (២០០១)

ច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា១៩ និងមាត្រា២៩ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាអនុម័តនៅថ្ងៃទី២ ខែកក្កដា ឆ្នាំ២០០១ ហើយដែលព្រឹទ្ធសភាបានអនុម័តស្របលើទម្រង់ និងគតិច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០១។ ច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា១៩ និងមាត្រា២៩ នៃរដ្ឋធម្មនុញ្ញនេះ ត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០១/១១ ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០១។ វិសោធនកម្មលើកទី៣នេះត្រូវបានធ្វើឡើងដើម្បីថ្វាយព្រះរាជសិទ្ធិដល់ព្រះមហាក្សត្រក្នុងការបង្កើត និងប្រទានគ្រឿងឥស្សរិយយសជាតិ។

យោងលិខិតមួយច្បាប់ក្រាបបង្គំទូលថ្វាយ **ព្រះករុណាព្រះបាទសម្ដេចព្រះនរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០០១ ដោយសម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ព្រះប្រធានរដ្ឋសភាបានទូលថ្វាយថា *"ទូលព្រះបង្គំជាខ្ញុំបានទទួលនូវពាក្យស្នើសុំធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញពីសមាជិកតំណាងរាស្ត្រនៃគណបក្សទាំងបី ដែលបានចុះហត្ថលេខាស្នើសុំធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ លើមាត្រា ១៩ និងមាត្រា ២៩ ដើម្បីញ៉ាំងឱ្យរដ្ឋធម្មនុញ្ញកាន់តែមានភាពសុក្រិតឡើង"។*[៥]

យោងតាមលិខិតខាងលើនេះ សេចក្តីស្នើច្បាប់ធម្មនុញ្ញនេះ សំដៅកែប្រែមាត្រា១៩ ដែលចែងថា *"ព្រះមហាក្សត្រទ្រង់បង្កើត និងប្រទានគ្រឿងឥស្សរិយយសជាតិ តាមសេចក្តីស្នើពីគណៈរដ្ឋមន្ត្រី"* ការស្នើសុំកែប្រែមាត្រានេះគឺសុំលុបចោល *"តាមសេចក្តីស្នើពីគណៈរដ្ឋមន្ត្រី"* ដើម្បីថ្វាយព្រះមហាក្សត្រនូវព្រះរាជសិទ្ធិទូលំទូលាយ ក្នុងការបង្កើត និងប្រទានគ្រឿងឥស្សរិយយសជាតិដល់មន្ត្រីរាជការស៊ីវិល យោធា សប្បុរសជន និងឥស្សរជនដទៃទៀត។ ដោយសារការធ្វើវិសោធកម្មនៃមាត្រានេះ មានការទាក់ទងជាមួយសិទ្ធិរបស់គណៈរដ្ឋមន្ត្រី **សម្តេចព្រះប្រធានរដ្ឋសភា** ក៏បានធ្វើការពិភាក្សាជាមួយ **សម្តេច ហ៊ុន សែន** នាយករដ្ឋមន្ត្រី ហើយបានឯកភាពគ្នាចំពោះសេចក្តីស្នើសុំធ្វើវិសោធនកម្មនេះ។

សរុបមក វិសោធនកម្មលើកទី៣នេះ មានគោលបំណងកែសម្រួលមាត្រា១៩ និងមាត្រា ២៩ ដើម្បីពង្រឹង និងពង្រីកព្រះរាជសិទ្ធិរបស់ព្រះមហាក្សត្រ ក្នុងការបង្កើត និងប្រទានគ្រឿងឥស្សរិយយសជាតិ។ ការកែប្រែនេះបានលុបចោលលក្ខខណ្ឌដែលតម្រូវឱ្យមានសេចក្តីស្នើពីគណៈរដ្ឋមន្ត្រី ដោយមានគោលបំណងថ្វាយព្រះមហាក្សត្រនូវព្រះរាជសិទ្ធិទូលំទូលាយជាងមុនក្នុងការប្រទានគ្រឿងឥស្សរិយយសជាតិដល់បុគ្គលដែលមានគុណូបការៈចំពោះជាតិ។ វិសោធនកម្មនេះក៏បង្ហាញពីការព្រមព្រៀងរួមគ្នារវាងស្ថាប័នពាក់ព័ន្ធ ដើម្បីធ្វើឱ្យរដ្ឋធម្មនុញ្ញមានភាពសុក្រឹត និងសមស្របតាមបរិបទនយោបាយ និងរដ្ឋបាលរបស់ប្រទេស។

## ខ្លឹមសារមាត្រាចាស់ និងមាត្រាថ្មី

| មាត្រាចាស់ | មាត្រាថ្មី |
|---|---|
| **មាត្រា ១៩.-** ព្រះមហាក្សត្រទ្រង់តែងតាំងនាយករដ្ឋមន្ត្រីនិងទ្រង់តែងតាំងគណៈរដ្ឋមន្ត្រី តាមបែបបទដែលមានចែងក្នុងមាត្រា ១០០។ | **មាត្រា.- ១៩ ថ្មី** ព្រះមហាក្សត្រទ្រង់តែងតាំងនាយករដ្ឋមន្ត្រីនិងទ្រង់តែងតាំងគណៈរដ្ឋមន្ត្រីតាមបែបបទដែលមានចែងក្នុងមាត្រា ១១៩ ថ្មី។ |

[៥] លិខិតថ្វាយព្រះមហាក្សត្រ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០០១ ដោយ សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ព្រះប្រធានរដ្ឋសភា

| **មាត្រា ២៩.–** | **មាត្រា ២៩.– ថ្មី** |
| --- | --- |
| ព្រះមហាក្សត្រទ្រង់បង្កើតនិងប្រទានគ្រឿងឥស្សរិយសជាតិតាមសេចក្តីស្នើសុំពីគណៈរដ្ឋមន្ត្រី។<br>ព្រះមហាក្សត្រទ្រង់សំរេចប្រទានឋានន្តរសក្តិ ឋានៈ យោធា និងស៊ីវិល តាមច្បាប់កំណត់។ | ព្រះមហាក្សត្រទ្រង់បង្កើតនិងប្រទានគ្រឿងឥស្សរិយយសជាតិ។<br>ព្រះមហាក្សត្រទ្រង់សំរេចប្រទានឋានន្តរសក្តិ ឋានៈ យោធានិងស៊ីវិល តាមច្បាប់កំណត់។ |

## វិសោធនកម្មលើកទី៤ (២០០៥)

ច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា៨៨ និងមាត្រា១១១ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាអនុម័ត នៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៥ នាសម័យប្រជុំរដ្ឋសភាលើកទី២ នីតិកាលទី៣ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៥ នាសម័យប្រជុំពេញអង្គលើកទី៩ នីតិកាលទី១។ ច្បាប់ធម្មនុញ្ញនេះត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦០៥/០១៨ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥។ វិសោធនកម្មលើកទី៤នេះត្រូវបានធ្វើឡើងដើម្បីកែសម្រួលកូរ៉ុមប្រជុំរបស់រដ្ឋសភា និងព្រឹទ្ធសភាដើម្បីសម្រួលដល់ដំណើរការរដ្ឋបាលរបស់ស្ថាប័នទាំងពីរ។

យោងតាមសេចក្តីថ្លែងហេតុនៃសេចក្តីស្នើច្បាប់ធម្មនុញ្ញ តំណាងក្រុមតំណាងរាស្ត្រហត្ថលេខីបានគូសបញ្ជាក់ថា *"អនុលោមតាមការព្រមព្រៀងកំពូលរវាងសម្តេចក្រុមព្រះ* ***នរោត្តម រណឫទ្ធិ*** *ព្រះប្រធានរដ្ឋសភា និង សម្តេច* ***ហ៊ុន សែន*** *នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា កាលពីព្រឹកថ្ងៃព្រហស្បតិ៍ទី១៧ ខែមីនា ឆ្នាំ២០០៥ និងដោយពិនិត្យឃើញថា កូរ៉ុមសម្រាប់ប្រជុំរដ្ឋសភា និងព្រឹទ្ធសភាដែលមានចែងក្នុងរដ្ឋធម្មនុញ្ញចំនួនប្រាំពីរភាគដប់ គឺជាកូរ៉ុមមួយខ្ពស់មានលក្ខណៈសមស្របទៅនឹងកាលៈទេសៈផ្សះផ្សាបង្រួបបង្រួមជាតិ។ ឆ្លងតាមការវិវត្តន៍របស់ព្រះរាជាណាចក្រកម្ពុជាមកដល់ពេលសព្វថ្ងៃនេះ ការប្រជុំរដ្ឋសភា និងព្រឹទ្ធសភាច្រើនជួបការអោក់អេ្ញលដោយមូលហេតុខ្វះកូរ៉ុម"*។[៦]

សេចក្តីថ្លែងហេតុខាងលើបានបញ្ជាក់បន្ថែមថា *"សេចក្តីស្នើច្បាប់ធម្មនុញ្ញនេះ សំដៅកែប្រែមាត្រា៨៨ និងមាត្រា១១១ថ្មី នៃរដ្ឋធម្មនុញ្ញ ដើម្បីសម្រួលកូរ៉ុមសម្រាប់ប្រជុំរដ្ឋសភា និងព្រឹទ្ធសភា ដូចមានចែងក្នុងខ្លឹមសារថា កូរ៉ុមប្រាំពីរភាគដប់ត្រូវយកមកប្រើ សម្រាប់ការអនុម័តយកសម្លេងពីរភាគបី និង*

[៦] សេចក្តីថ្លែងហេតុនៃសេចក្តីស្នើច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា ៨៨ និងមាត្រា ១១១ ថ្មី នៃរដ្ឋធម្មនុញ្ញ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០០៥

*កូរ៉ុមប្រាំមួយភាគដប់ត្រូវយកប្រើសម្រាប់ការអនុម័តយកសម្លេងភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភា និងសមាជិកព្រឹទ្ធសភាទាំងមូល"។*

សរុបមក វិសោធនកម្មលើកទី៤នេះ មានគោលបំណងកែសម្រួលកូរ៉ុមសម្រាប់ការប្រជុំរបស់រដ្ឋសភា និងព្រឹទ្ធសភា ដើម្បីដោះស្រាយបញ្ហាការអាក់រអួលក្នុងដំណើរការប្រជុំដោយសារខ្វះកូរ៉ុម។ ការកែប្រែនេះបានកំណត់ឱ្យកូរ៉ុមប្រាំពីរភាគដប់ត្រូវអនុវត្តសម្រាប់ការអនុម័តសេចក្ដីសម្រេចដែលត្រូវការមតិពីរភាគបី និងកូរ៉ុមប្រាំមួយភាគដប់សម្រាប់ការអនុម័តដោយមតិភាគច្រើនដាច់ខាត។ វិសោធនកម្មនេះមានគោលបំណងធានាឱ្យស្ថាប័ននីតិប្បញ្ញត្តិអាចដំណើរការបានប្រក្រតី និងមានប្រសិទ្ធភាពស្របតាមការវិវត្តនយោបាយ និងប្រជាធិបតេយ្យរបស់កម្ពុជា។

## ខ្លឹមសារមាត្រាចាស់ និងមាត្រាថ្មី

| មាត្រាចាស់ | មាត្រាថ្មី |
|---|---|
| **មាត្រា ៨៨.-**<br>ការប្រជុំរដ្ឋសភាត្រូវធ្វើជាសាធារណៈ។<br>រដ្ឋសភាអាចប្រជុំជាសម្ងាត់បាន តាមការសុំពីប្រធាន ឬពីសមាជិកចំនួនមួយភាគដប់យ៉ាងតិច ពីព្រះមហាក្សត្រ ឬពីនាយករដ្ឋមន្ត្រី។<br>ការប្រជុំរដ្ឋសភានឹងយកជាការបានលុះត្រាតែមានកូរ៉ុមប្រាំពីរភាគដប់ នៃសមាជិករដ្ឋសភាទាំងមូល។ | **មាត្រា ៨៨.- ថ្មី**<br>ការប្រជុំរដ្ឋសភាត្រូវធ្វើជាសាធារណៈ។<br>រដ្ឋសភាអាចប្រជុំជាសម្ងាត់បានតាមការស្នើសុំពីប្រធាន ឬពីសមាជិកចំនួនមួយភាគដប់យ៉ាងតិច ពីព្រះមហាក្សត្រ ឬ ពីនាយករដ្ឋមន្ត្រី។<br>ការប្រជុំរដ្ឋសភានឹងយកជាការបាន លុះត្រាតែមាន:<br>ក-កូរ៉ុមប្រាំពីរភាគដប់នៃសមាជិករដ្ឋសភាទាំងមូល សម្រាប់ការអនុម័ត ទាំងឡាយណាដែលតម្រូវឱ្យយកមតិភាគច្រើនពីរភាគបី ឬយកមតិភាគច្រើនបីភាគបួននៃសមាជិករដ្ឋសភាទាំងមូល។<br>ខ-កូរ៉ុមប្រាំមួយភាគដប់នៃសមាជិករដ្ឋសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឱ្យយកមតិភាគច្រើនដោយប្រៀប ឬយកមតិភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល។ |
| **មាត្រា ១១១.- ថ្មី**<br>ការប្រជុំព្រឹទ្ធសភា ត្រូវធ្វើជាសាធារណៈ។ | **មាត្រា ១១១.- ថ្មី(មួយ)**<br>ការប្រជុំព្រឹទ្ធសភាត្រូវធ្វើជាសាធារណៈ។ |

| | |
|---|---|
| ព្រឹទ្ធសភាអាចប្រជុំជាសំងាត់បានតាមការសុំពីប្រធាន ឬពីសមាជិកចំនួនមួយភាគដប់យ៉ាងតិចពីព្រះមហាក្សត្រ ពីនាយករដ្ឋមន្ត្រី ឬពីប្រធានរដ្ឋសភា។<br>ការប្រជុំព្រឹទ្ធសភានឹងយកជាការបានលុះត្រាតែមានកូរ៉ុមប្រាំពីរភាគដប់ នៃសមាជិកព្រឹទ្ធសភាទាំងមូល។<br>ចំនួនសំឡេងដែលតម្រូវសំរាប់រដ្ឋសភាអនុម័តយល់ព្រម ហើយដែលបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ ត្រូវយកមកប្រើសំរាប់ព្រឹទ្ធសភាផងដែរ។ | ព្រឹទ្ធសភាអាចប្រជុំជាសម្ងាត់បាន តាមការស្នើសុំពីប្រធាន ឬពីសមាជិកចំនួនមួយភាគដប់យ៉ាងតិច ពីព្រះមហាក្សត្រ ពីនាយករដ្ឋមន្ត្រី ឬពីប្រធានរដ្ឋសភា។<br>ការប្រជុំព្រឹទ្ធសភានឹងយកជាការបានលុះត្រាតែមានៈ<br>ក-កូរ៉ុមប្រាំពីរភាគដប់នៃសមាជិកព្រឹទ្ធសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឱ្យ យកមតិភាគច្រើនពីរភាគបី ឬយកមតិភាគច្រើនបីភាគបួននៃសមាជិកព្រឹទ្ធសភាទាំងមូល។<br>ខ-កូរ៉ុមប្រាំមួយភាគដប់នៃសមាជិកព្រឹទ្ធសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឱ្យយកមតិភាគច្រើនដោយប្រៀប ឬយកមតិភាគច្រើនដាច់ខាតនៃសមាជិកព្រឹទ្ធសភាទាំងមូល។<br>ចំនួនសំឡេងដែលតម្រូវសម្រាប់រដ្ឋសភាអនុម័តយល់ព្រម ហើយដែលបានកំណត់ក្នុងរដ្ឋធម្មនុញ្ញត្រូវយកមកប្រើសម្រាប់ព្រឹទ្ធសភាផងដែរ។ |

## វិសោធនកម្មលើកទី៥ (២០០៦)

ច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា៨២ មាត្រា៨៨ ថ្មី មាត្រា៩០ ថ្មី មាត្រា៩៨ មាត្រា១០៦ ថ្មី មាត្រា១១១ ថ្មី(មួយ) មាត្រា១១៤ ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា៦ នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ ត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាអនុម័តនៅថ្ងៃទី២ ខែមីនា ឆ្នាំ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាលទី៣ និងដែលព្រឹទ្ធសភាពុំមានពេលវេលាគ្រប់គ្រាន់ដើម្បីពិនិត្យច្បាប់នេះឱ្យទាន់តាមការកំណត់របស់មាត្រា១១៣ ថ្មីនៃរដ្ឋធម្មនុញ្ញ។ ច្បាប់ធម្មនុញ្ញនេះ ត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣០៦/០០៦ ចុះថ្ងៃទី ០៩ ខែមីនា ឆ្នាំ២០០៦។

យោងសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងច្បាប់ធម្មនុញ្ញ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០៦ **សម្តេច ហ៊ុន សែន** បានគូសបញ្ជាក់ថា *"អនុលោមតាមការព្រមព្រៀងកំពូលរវាងគណបក្សនយោបាយ*

*ទាំងបី ដែលមានអាសនៈនៅក្នុងរដ្ឋសភា នីតិកាលទី៣ និងដោយពិនិត្យឃើញថា បណ្តាការអនុម័តរបស់រដ្ឋសភា និងរបស់ព្រឹទ្ធសភា ដោយមតិភាគច្រើនពីរភាគ៣ និងបីភាគបួន ដែលមានកំណត់ក្នុងមាត្រា៨០ មាត្រា៨២ មាត្រា៩០ថ្មី មាត្រា៩៨ មាត្រា១០៤ថ្មី មាត្រា១០៦ថ្មី មាត្រា១១៤ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា ៦ នៃច្បាប់ធម្មនុញ្ញបន្ថែម មានកំរិតខ្ពស់ណាស់បើប្រៀបធៀបទៅនឹងប្រទេសប្រជាធិបតេយ្យនានានៅលើពិភពលោក។ ម្យ៉ាងទៀត ដោយពិនិត្យឃើញថា កូរ៉ុមសម្រាប់ប្រជុំរដ្ឋសភា និងប្រជុំព្រឹទ្ធសភា ដែលមានចែងក្នុងមាត្រា៨៨ថ្មី និងមាត្រា១១១ថ្មី (មួយ) តម្រូវឱ្យមានវត្តមានតំណាងរាស្ត្រ និងសមាជិកព្រឹទ្ធសភាច្រើនលើសលប់ បើប្រៀបធៀបទៅសភានៃប្រទេសប្រជាធិបតេយ្យសេរី។ ឆ្លងតាមការវិវត្តន៍របស់ព្រះរាជាណាចក្រកម្ពុជាពីឆ្នាំ១៩៩៣ មកដល់សព្វថ្ងៃនេះ យើងដកស្រង់មេរៀន និងពិសោធន៍ជាច្រើន ដែលទាមទារឱ្យមានការផ្តើមគំនិតធ្វើវិសោធនកម្មមាត្រាមួយចំនួននៃរដ្ឋធម្មនុញ្ញ និងមាត្រា៦នៃច្បាប់ធម្មនុញ្ញបន្ថែម សំដៅលើកកំពស់ប្រសិទ្ធភាពការដឹកនាំរបស់ស្ថាប័ននីតិប្បញ្ញត្តិ និងនីតិប្រតិបត្តិនៃយើង និងសំដៅអភិវឌ្ឍន៍លទ្ធិប្រជាធិបតេយ្យសេរីពហុបក្សឱ្យកាន់តែរីកចំរើនថែមទៀត។ ប្រជាធិបតេយ្យកាន់តែរីកចំរើន សម្លេងអនុម័ត និងកូរ៉ុមកាន់តែថយចុះតិច"*។[7]

នៅក្នុងសេចក្តីថ្លែងហេតុខាងលើ **សម្តេច ហ៊ុន សែន** បានបន្ថែមថា *"សេចក្តីស្នើច្បាប់ធម្មនុញ្ញនេះ សំដៅកែប្រែខ្លឹមសារមាត្រា៨០ ៨២ ៩០ថ្មី ៩៨ថ្មី ១០៤ថ្មី ១០៦ថ្មី ១១៤ថ្មី នៃរដ្ឋធម្មនុញ្ញ និងខ្លឹមសារមាត្រា ៦ នៃច្បាប់ធម្មនុញ្ញបន្ថែម ដោយសម្រុតមតិភាគច្រើនពីរភាគបី ឱ្យចុះមកត្រឹមមតិភាគច្រើនដាច់ខាត និងសម្រុតមតិភាគច្រើនបីភាគបួនក្នុងមាត្រា៨០ វាក្យខ័ណ្ឌទី៥ និងមាត្រា១០៤ថ្មី វាក្យខ័ណ្ឌទី៤ ឱ្យចុះមកត្រឹមមតិភាគច្រើនពីរភាគបី។ ព្រមជាមួយនេះ ក៏បានកែសម្រួលកូរ៉ុមសម្រាប់ប្រជុំរដ្ឋសភាចែងក្នុងមាត្រា ៨៨ថ្មី និងសម្រាប់ប្រជុំព្រឹទ្ធសភាចែងក្នុងមាត្រា១១១ថ្មី (មួយ) ដូចមានខ្លឹមសារថា:*

- *កូរ៉ុមលើសពី ពីរភាគបី សម្រាប់ការអនុម័តយកសម្លេងពីរភាគបី និង*
- *កូរ៉ុមលើសពីពាក់កណ្តាល សម្រាប់ការអនុម័តយកសម្លេងភាគច្រើនដាច់ខាត នៃសមាជិករដ្ឋសភា ឬ សមាជិកព្រឹទ្ធសភាទាំងមូល"*។

សរុបមក វិសោធនកម្មលើកទី៥នេះ មានគោលបំណងសំខាន់ក្នុងការកែសម្រួលលក្ខខណ្ឌសម្រាប់ការអនុម័តសេចក្តីសម្រេច និងកូរ៉ុមប្រជុំរបស់រដ្ឋសភា និងព្រឹទ្ធសភា ដើម្បីធានាឱ្យដំណើរការរបស់ស្ថាប័ននីតិប្បញ្ញត្តិ និងនីតិប្រតិបត្តិមានប្រសិទ្ធភាព និងភាពរលូនជាងមុន។ ការកាត់បន្ថយកម្រិតសំឡេងអនុម័តពីមតិភាគច្រើនពីរភាគបី ឬបីភាគបួន មកជាមតិភាគច្រើនដាច់ខាត ឬពីរភាគបី ត្រូវបានចាត់ទុកថា ជាវិធានការសមស្របមួយស្របតាមបទពិសោធនយោបាយ និងការវិវត្តប្រជាធិបតេយ្យរបស់កម្ពុជា។ វិសោធនកម្មនេះ ក៏មាន

[7] សេចក្តីថ្លែងហេតុនៃសេចក្តីព្រាងច្បាប់ធម្មនុញ្ញ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០៦

គោលបំណងលើកកម្ពស់ប្រសិទ្ធភាពនៃការដឹកនាំ និងធានាឱ្យស្ថាប័នជាតិសំខាន់ៗអាចដំណើរការបានជាប្រក្រតី ស្របតាមគោលការណ៍ប្រជាធិបតេយ្យសេរីពហុបក្ស។

## ខ្លឹមសារមាត្រាចាស់ និងមាត្រាថ្មី

❖ មាត្រា ៨២ មាត្រា ៨៨ថ្មី មាត្រា ៩០ថ្មី មាត្រា ៩៨ មាត្រា ១០៦ថ្មី មាត្រា ១១១ថ្មី (មួយ) មាត្រា ១១៤ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា ៦ នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅ ធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ ត្រូវបានកែប្រែដូចតទៅ៖

| មាត្រាចាស់ | មាត្រាថ្មី |
|---|---|
| **មាត្រា ៨២.-**<br>រដ្ឋសភាបើកសម័យប្រជុំដំបូង ហុកសិបថ្ងៃយ៉ាងយូរក្រោយពេលបោះឆ្នោត តាមការកោះប្រជុំរបស់ព្រះមហាក្សត្រ។<br>មុនចាប់ផ្ដើមការងាររបស់ខ្លួន រដ្ឋសភាត្រូវអនុម័តបទបញ្ជាផ្ទៃក្នុង សម្រេចអំពីសុពលភាពនៃអាណត្តិរបស់សមាជិកនិមួយៗ និងត្រូវបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នានូវប្រធាន អនុប្រធានរដ្ឋសភា និងសមាជិកទាំងអស់នៃគណៈកម្មការនានារបស់រដ្ឋសភា ដោយមតិភាគច្រើនពីរភាគបី នៃសមាជិករដ្ឋសភាទាំងមូល។<br>តំណាងរាស្ត្រទាំងអស់ត្រូវធ្វើសច្ចាប្រណិធាន មុនចូលកាន់តំណែងដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធ ៥។ | **មាត្រា ៨២.- ថ្មី**<br>រដ្ឋសភាបើកសម័យប្រជុំដំបូង ហុកសិបថ្ងៃយ៉ាងយូរ ក្រោយពេលបោះឆ្នោតតាមការកោះប្រជុំរបស់ព្រះមហាក្សត្រ។<br>មុនចាប់ផ្ដើមការងាររបស់ខ្លួន រដ្ឋសភាត្រូវប្រកាសសុពលភាព នៃអាណត្តិរបស់សមាជិកនីមួយៗត្រូវបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នា នូវប្រធាន អនុប្រធាន រដ្ឋសភា និង សមាជិកទាំងអស់នៃគណៈកម្មការនានារបស់រដ្ឋសភា ដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល។<br>រដ្ឋសភាត្រូវអនុម័តបទបញ្ជាផ្ទៃក្នុង ដោយមតិភាគច្រើនដាច់ខាត នៃចំនួនសមាជិករដ្ឋសភាទាំងមូល។<br>តំណាងរាស្ត្រទាំងអស់ ត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់តំណែង ដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធទី៥ នៃរដ្ឋធម្មនុញ្ញ។ |
| **មាត្រា ៨៨.- ថ្មី**<br>ការប្រជុំរដ្ឋសភាត្រូវធ្វើជាសាធារណៈ។<br>រដ្ឋសភាអាចប្រជុំជាសម្ងាត់បានតាមការស្នើសុំពីប្រធាន ឬពីសមាជិកចំនួនមួយភាគដប់យ៉ាងតិច ពីព្រះមហាក្សត្រ ឬ ពីនាយករដ្ឋមន្ត្រី។ | **មាត្រា ៨៨.- ថ្មី(ពីរ)**<br>ការប្រជុំរដ្ឋសភាត្រូវធ្វើជាសាធារណៈ។<br>រដ្ឋសភាអាចប្រជុំជាសម្ងាត់បាន តាមការសុំពីប្រធាន ឬ ពីសមាជិកចំនួនមួយភាគដប់យ៉ាងតិច ពីព្រះមហាក្សត្រ ឬ ពីនាយករដ្ឋមន្ត្រី។ |

| | |
|---|---|
| ការប្រជុំរដ្ឋសភានឹងយកជាការបាន លុះត្រាតែមានៈ<br>ក-កូរ៉ុមប្រាំពីរភាគដប់នៃសមាជិករដ្ឋសភាទាំងមូល សម្រាប់ការអនុម័ត ទាំងឡាយណាដែលតម្រូវឱ្យយកមតិភាគច្រើនពីរភាគបី ឬយកមតិភាគច្រើនបីភាគបួននៃសមាជិករដ្ឋសភាទាំងមូល។<br>ខ-កូរ៉ុមប្រាំមួយភាគដប់នៃសមាជិករដ្ឋសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឱ្យយកមតិភាគច្រើនដោយប្រៀប ឬយកមតិភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល។ | ការប្រជុំរដ្ឋសភា នឹងយកជាការបាន លុះត្រាតែមាន :<br>ក- កូរ៉ុមលើសពី ពីរភាគបី នៃចំនួនសមាជិករដ្ឋសភាទាំងមូលសម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឱ្យយកមតិភាគច្រើនពីរភាគបី នៃចំនួនសមាជិករដ្ឋសភាទាំងមូល។<br>ខ- កូរ៉ុមលើសពីពាក់កណ្ដាល នៃចំនួនសមាជិករដ្ឋសភាទាំងមូលសម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឱ្យយកមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល។ |
| **មាត្រា ៩០.- ថ្មី**<br>រដ្ឋសភាជាអង្គការដែលមានអំណាចនីតិប្បញ្ញត្តិ ហើយបំពេញភារកិច្ចរបស់ខ្លួន ដូចបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន។<br>រដ្ឋសភាអនុម័តថវិកាជាតិ ផែនការរដ្ឋ ការអោយរដ្ឋខ្ចីប្រាក់ពីគេ ការអោយរដ្ឋអោយប្រាក់គេខ្ចី ការសន្យានានាផ្នែកហិរញ្ញវត្ថុ និងការបង្កើត កែប្រែ ឬ លុបចោលពន្ធដារ។<br>រដ្ឋសភាអោយសេចក្ដីយល់ព្រមចំពោះគណនីរដ្ឋបាល។<br>រដ្ឋសភាអនុម័តច្បាប់ ស្ដីពីការលើកលែងទោសជាទូទៅ។<br>រដ្ឋសភាអនុម័តយល់ព្រម ឬលុបចោលសន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិ។<br>រដ្ឋសភាអនុម័តច្បាប់ស្ដីពីការប្រកាសសង្គ្រាម។<br>ការអនុម័តខាងលើនេះប្រព្រឹត្តទៅដោយមតិភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល។ | **មាត្រា ៩០.- ថ្មី(ពីរ)**<br>រដ្ឋសភាជាអង្គការ ដែលមានអំណាចនីតិប្បញ្ញត្តិ ហើយបំពេញភារកិច្ចរបស់ខ្លួន ដូចបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន។<br>រដ្ឋសភាអនុម័តថវិកាជាតិ ផែនការរដ្ឋ ការអោយរដ្ឋខ្ចីប្រាក់ពីគេ ការអោយរដ្ឋអោយប្រាក់គេខ្ចី ការសន្យានានាផ្នែកហិរញ្ញវត្ថុ និងការបង្កើត កែប្រែ ឬ លុបចោលពន្ធដារ។<br>រដ្ឋសភាអោយសេចក្ដីយល់ព្រមចំពោះគណនីរដ្ឋបាល។<br>រដ្ឋសភាអនុម័តច្បាប់ស្ដីពីការលើកលែងទោសជាទូទៅ។<br>រដ្ឋសភាអនុម័តយល់ព្រម ឬ លុបចោលសន្ធិសញ្ញា ឬ អនុសញ្ញាអន្តរជាតិ។<br>រដ្ឋសភាអនុម័តច្បាប់ស្ដីពីការប្រកាសសង្គ្រាម។<br>ការអនុម័តខាងលើនេះប្រព្រឹត្តទៅដោយមតិភាគច្រើនដាច់ខាត នៃចំនួនសមាជិករដ្ឋសភាទាំងមូល។ |

| | |
|---|---|
| រដ្ឋសភាបោះឆ្នោតទុកចិត្តដល់រាជរដ្ឋាភិបាល តាមមតិភាគច្រើនពីរភាគបីនៃសមាជិករដ្ឋសភាទាំងមូល។ | រដ្ឋសភាបោះឆ្នោតទុកចិត្តដល់រាជរដ្ឋាភិបាលតាមមតិភាគច្រើនដាច់ខាត នៃចំនួនសមាជិករដ្ឋសភាទាំងមូល។ |
| **មាត្រា ៩៨.-**<br>រដ្ឋសភាអាចទំលាក់សមាជិកគណៈរដ្ឋមន្ត្រីឬទំលាក់រាជរដ្ឋាភិបាលពីតំណែងដោយអនុម័តញត្តិបន្ទោសតាមសម្លេងឆ្នោតពីភាគបីនៃចំនួនសមាជិករដ្ឋសភាទាំងមូល។<br>ញត្តិបន្ទោសរាជរដ្ឋាភិបាលត្រូវបានលើកឡើងជូនរដ្ឋសភាដោយតំណាងរាស្ត្រចំនួនសាមសិបនាក់ ទើបរដ្ឋសភាអាចលើកមកពិភាក្សាបាន។ | **មាត្រា ៩៨.- ថ្មី**<br>រដ្ឋសភាអាចទម្លាក់សមាជិកគណៈរដ្ឋមន្ត្រី ឬទម្លាក់រាជរដ្ឋាភិបាលពីតំណែងដោយអនុម័តញត្តិបន្ទោស តាមសំឡេងឆ្នោតភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល។<br>ញត្តិបន្ទោសរាជរដ្ឋាភិបាល ត្រូវបានលើកឡើងជូនរដ្ឋសភាដោយតំណាងរាស្ត្រចំនួនសាមសិបនាក់ ទើបរដ្ឋសភាអាចលើកមកពិភាក្សា បាន។ |
| **មាត្រា ១០៦.- ថ្មី**<br>ព្រឹទ្ធសភាបើកសម័យប្រជុំដំបូង ហុកសិបថ្ងៃយ៉ាងយូរ ក្រោយពេលបោះឆ្នោត តាមការកោះប្រជុំរបស់ព្រះមហាក្សត្រ។<br>មុនចាប់ផ្តើមការងាររបស់ខ្លួន ព្រឹទ្ធសភាត្រូវប្រកាសសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗ និងត្រូវបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នានូវប្រធាន អនុប្រធានព្រឹទ្ធសភា និងសមាជិកទាំងអស់នៃគណៈកម្មការនានារបស់ព្រឹទ្ធសភា ដោយមតិភាគច្រើនពីរភាគបីនៃសមាជិកព្រឹទ្ធសភាទាំងមូល។<br>សមាជិកព្រឹទ្ធសភាទាំងអស់ត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់តំណែងដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធទី៧ នៃរដ្ឋធម្មនុញ្ញ។ | **មាត្រា ១០៦.- ថ្មី(មួយ)**<br>ព្រឹទ្ធសភាបើកសម័យប្រជុំដំបូង ហុកសិបថ្ងៃយ៉ាងយូរក្រោយពេលបោះឆ្នោតតាមការកោះប្រជុំរបស់ព្រះមហាក្សត្រ។<br>មុនចាប់ផ្តើមការងាររបស់ខ្លួន ព្រឹទ្ធសភាត្រូវប្រកាសសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗ និងត្រូវបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នា នូវប្រធាន អនុប្រធានព្រឹទ្ធសភា និងសមាជិកទាំងអស់នៃគណៈកម្មការនានារបស់ព្រឹទ្ធសភា ដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិក ព្រឹទ្ធសភាទាំងមូល។<br>សមាជិកព្រឹទ្ធសភាទាំងអស់ ត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់ដំណែង ដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធទី ៧ នៃរដ្ឋធម្មនុញ្ញ។ |
| **មាត្រា ១១១.- ថ្មី(មួយ)**<br>ការប្រជុំព្រឹទ្ធសភាត្រូវធ្វើជាសាធារណៈ។<br>ព្រឹទ្ធសភាអាចប្រជុំជាសម្ងាត់បាន តាមការស្នើសុំពីប្រធាន ឬពីសមាជិកចំនួនមួយភាគដប់យ៉ាងតិច ពីព្រះមហាក្សត្រ ពីនាយករដ្ឋមន្ត្រី ឬពីប្រធានរដ្ឋសភា។ | **មាត្រា ១១១.- ថ្មី(ពីរ)**<br>ការប្រជុំព្រឹទ្ធសភាត្រូវធ្វើជាសាធារណៈ។<br>ព្រឹទ្ធសភាអាចប្រជុំជាសម្ងាត់បានតាមការស្នើសុំពីប្រធាន ឬពីសមាជិកចំនួនមួយភាគដប់យ៉ាងតិច ពីព្រះមហាក្សត្រ ពីនាយករដ្ឋមន្ត្រី ឬ ពីប្រធានរដ្ឋសភា។ |

| | |
|---|---|
| ការប្រជុំព្រឹទ្ធសភានឹងយកជាការបាន លុះត្រាតែមាន:<br>ក-កូរ៉ុមប្រាំពីរភាគដប់នៃសមាជិកព្រឹទ្ធសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឱ្យ យកមតិភាគច្រើនពីរភាគបី ឬ យកមតិភាគច្រើនបីភាគបួននៃសមាជិកព្រឹទ្ធសភាទាំងមូល។<br>ខ-កូរ៉ុមប្រាំមួយភាគដប់នៃសមាជិកព្រឹទ្ធសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឱ្យយកមតិភាគច្រើនដោយប្រៀប ឬយកមតិភាគច្រើនដាច់ខាតនៃសមាជិកព្រឹទ្ធសភាទាំងមូល។<br>ចំនួនសំឡេងដែលតម្រូវសម្រាប់រដ្ឋសភាអនុម័តយល់ព្រម ហើយដែលបានកំណត់ក្នុង រដ្ឋធម្មនុញ្ញត្រូវយកមកប្រើសម្រាប់ព្រឹទ្ធសភាផងដែរ។ | ការប្រជុំព្រឹទ្ធសភានឹងយកជាការបាន លុះត្រាតែមាន :<br>ក-កូរ៉ុមលើសពី ពីរភាគបី នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឱ្យយកមតិភាគច្រើនពីរភាគបី នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។<br>ខ-កូរ៉ុមលើសពីពាក់កណ្ដាលនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឱ្យយកមតិភាគច្រើនដោយប្រៀប ឬ យកមតិភាគច្រើនដាច់ខាត នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។<br>ចំនួនសំឡេងដែលតម្រូវសម្រាប់រដ្ឋសភាអនុម័តយល់ព្រម ហើយដែលមានកំណត់ក្នុងរដ្ឋធម្មនុញ្ញត្រូវយកមកប្រើសម្រាប់ព្រឹទ្ធសភាផងដែរ។ |
| **មាត្រា ១១៤.- ថ្មី**<br>ព្រឹទ្ធសភាបង្កើតគណៈកម្មការផ្សេងៗដែលចាំបាច់។ ការរៀបចំនិងការប្រព្រឹត្តិទៅនៃព្រឹទ្ធសភានឹងមានកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភា។ បទបញ្ជាផ្ទៃក្នុងនេះ ត្រូវអនុម័តយល់ព្រមដោយសំឡេងភាគច្រើនពីរភាគបីនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។ | **មាត្រា ១១៤.- ថ្មី(មួយ)**<br>ព្រឹទ្ធសភាបង្កើតគណៈកម្មការផ្សេងៗដែលចាំបាច់។ ការរៀបចំនិងការប្រព្រឹត្តទៅនៃព្រឹទ្ធសភានឹងកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភា។ បទបញ្ជាផ្ទៃក្នុងនេះ ត្រូវអនុម័តយល់ព្រម ដោយសំឡេងភាគច្រើនដាច់ខាត នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។ |

❖ មាត្រា ៦ នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ ត្រូវបានធ្វើវិសោធនកម្មដូចតទៅ៖

| មាត្រាចាស់ | មាត្រាថ្មី |
|---|---|
| **មាត្រា ៦.-**<br>ការបោះឆ្នោតជាកញ្ចប់ខាងលើនេះ ត្រូវយកតាមមតិភាគច្រើន ពីរភាគបី នៃសមាជិករដ្ឋសភាទាំងមូល។ | **មាត្រា ៦.- ថ្មី**<br>ការបោះឆ្នោតជាកញ្ចប់ខាងលើនេះ ត្រូវយកតាមមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល។ |

| | |
|---|---|
| ក្នុងករណី ការបោះឆ្នោតជុំទីមួយមិនបានសំរេច នីតិវិធីដដែលនេះ នឹងត្រូវអនុវត្តចំពោះការបោះឆ្នោតជុំក្រោយៗទៀត។ | ក្នុងករណីការបោះឆ្នោតជុំទីមួយមិនបានសម្រេច នីតិវិធីដដែលនេះនឹងត្រូវអនុវត្តចំពោះការបោះឆ្នោតជុំក្រោយៗទៀត។ |

## **វិសោធនកម្មលើកទី៦** (២០០៨)

ច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា១៤៥ ថ្មី និងមាត្រា១៤៦ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាអនុម័តនៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៨ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៣ និងដែលព្រឹទ្ធសភាពុំមានពេលវេលាគ្រប់គ្រាន់អាចពិនិត្យ និងឱ្យយោបល់តាមលក្ខខណ្ឌកំណត់ ក្នុងមាត្រា១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញបានឡើយ។ ច្បាប់ធម្មនុញ្ញនេះត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០៨/០០៨ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ។ វិសោធនកម្មលើកទី៦នេះ ត្រូវបានធ្វើឡើងដើម្បីរៀបចំនូវប្រព័ន្ធគ្រប់គ្រងរដ្ឋបាលនៅថ្នាក់ក្រោមជាតិ សំដៅធានាឱ្យបាននូវការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់រដ្ឋបាលទាំងនោះ។

យោងសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា១៤៥ថ្មី និងមាត្រា១៤៦ថ្មី នៃរដ្ឋធម្មនុញ្ញ ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០៧ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** បានគូសបញ្ជាក់ថា *"អនុវត្តតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៣ នៃរដ្ឋសភា រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តនូវក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ នាខែមិថុនា ឆ្នាំ២០០៥។ ផ្អែកតាមក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិឆ្នាំ២០០៦-២០១០ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបាននឹងកំពុងរៀបចំនូវប្រព័ន្ធគ្រប់គ្រងរដ្ឋបាលនៅថ្នាក់ក្រោមជាតិ សំដៅធានាឱ្យបាននូវការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់រដ្ឋបាលទាំងនោះ។ ដើម្បីសម្រេចបាននូវទិសដៅទាំងនេះ រាជរដ្ឋាភិបាលកម្ពុជាបាននឹងកំពុងរៀបចំសេចក្តីព្រាងច្បាប់រៀបចំអង្គការ ដូចដែលបានកំណត់ក្នុងមាត្រា ១៤៦ថ្មី នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា"*។[៨]

នៅក្នុងសេចក្តីថ្លែងហេតុខាងលើ **សម្តេចតេជោ** បានបន្ថែមថា *"ការតាក់តែងសេចក្តីព្រាងច្បាប់ខាងលើនេះ មានការប៉ះពាល់ជាមួយបទប្បញ្ញត្តិមាត្រា១៤៥ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលចាំបាច់ត្រូវមានការកែសម្រួលឱ្យបានសមស្របជាមួយការរីកចម្រើន*

[៨] សេចក្តីថ្លែងហេតុនៃសេចក្តីព្រាងច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា១៤៥ថ្មី និងមាត្រា១៤៦ថ្មី នៃរដ្ឋធម្មនុញ្ញ ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០៧

*ខាងវិស័យនយោបាយ រដ្ឋបាល សង្គមនិងសេដ្ឋកិច្ចរបស់ជាតិ ទាំងក្នុងពេលចំពោះមុខ និងក្នុងពេលអនាគត"។*

សរុបមក វិសោធនកម្មលើកទី៦នេះ មានគោលបំណងកែសម្រួលមាត្រា១៤៥ ថ្មី និងមាត្រា១៤៦ ថ្មី ដើម្បីបង្កើតមូលដ្ឋានធម្មនុញ្ញសម្រាប់ការរៀបចំប្រព័ន្ធគ្រប់គ្រងរដ្ឋបាលនៅថ្នាក់ក្រោមជាតិ។ វិសោធនកម្មនេះស្របតាមគោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល ដែលមានគោលបំណងពង្រឹងការគ្រប់គ្រងមូលដ្ឋាន និងលើកកម្ពស់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ការកែសម្រួលនេះក៏បានបង្កើតមូលដ្ឋានសម្រាប់ការតាក់តែងច្បាប់រៀបចំអង្គការរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាឱ្យការគ្រប់គ្រងរដ្ឋមានប្រសិទ្ធភាព និងឆ្លើយតបនឹងការវិវត្តនយោបាយ សង្គម និងសេដ្ឋកិច្ចរបស់ប្រទេស។

## ខ្លឹមសារមាត្រាចាស់ និងមាត្រាថ្មី

| **មាត្រាចាស់** | **មាត្រាថ្មី** |
|---|---|
| **មាត្រា ១៤៥.- ថ្មី (មាត្រា ១២៦ ចាស់)**<br>ទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ចែកជាខេត្ត និង ក្រុង។<br>ខេត្ត ចែកជាស្រុក ស្រុកចែកជា ឃុំ។<br>ក្រុង ចែកជាខ័ណ្ឌ ខ័ណ្ឌចែកជាសង្កាត់។ | **មាត្រា ១៤៥.- ថ្មី(មួយ)**<br>ទឹកដីនៃព្រះរាជាណាចក្រកម្ពុជាចែកជារាជធានី ខេត្ត ក្រុង ស្រុក-ខណ្ឌ ឃុំ សង្កាត់។ |
| **មាត្រា ១៤៦.- ថ្មី (មាត្រា ១២៧ ចាស់)**<br>ខេត្ត ក្រុង ស្រុក ខ័ណ្ឌ ឃុំ និងសង្កាត់ ត្រូវគ្រប់គ្រងតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងច្បាប់រៀបចំអង្គការមួយ។ | **មាត្រា ១៤៦.- ថ្មី(មួយ)**<br>រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ត្រូវគ្រប់គ្រងតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងច្បាប់រៀបចំអង្គការ។ |

## វិសោធនកម្មលើកទី៧ (២០១៤)

ច្បាប់ធម្មនុញ្ញស្ដីពីវិសោធនកម្មមាត្រា៧៦ និងមាត្រាទាំងឡាយពីជំពូកទី១៥ ថ្មី ដល់ជំពូកទី១៦ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានរដ្ឋសភាអនុម័តនៅថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៤ នាសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៤។ ច្បាប់ធម្មនុញ្ញនេះត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១០១៤/០២២ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤។ វិសោធនកម្មលើកទី៧នេះ ត្រូវបានធ្វើឡើងដើម្បីបង្កើតអង្គការរៀបចំការបោះឆ្នោតឱ្យជាស្ថាប័នដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ដែលជួយបង្កើនការជឿទុកចិត្តរបស់សាធារណជនចំពោះស្ថាប័ន។

ការបោះឆ្នោតសាកលលើកទី៥ ត្រូវបានរៀបចំឡើងនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។ គណបក្សប្រជាជនកម្ពុជាបានឈ្នះ ៦៨ អាសនៈ ខណៈ គណបក្សសង្គ្រោះជាតិ (CNRP) បានឈ្នះ ៥៥ អាសនៈ។ គណបក្សសង្គ្រោះជាតិមិនពេញចិត្តចំពោះលទ្ធផលនេះទេ ហើយបានបដិសេធលទ្ធផលឆ្នោត។ គណបក្សនេះ បានធ្វើពហិការសម័យប្រជុំដំបូងរបស់រដ្ឋសភា ដែលត្រូវបានកោះហៅដោយព្រះមហាក្សត្រ ហើយបានអះអាងថា មានភាពមិនប្រក្រតីកើតឡើងក្នុងដំណើរការបោះឆ្នោត។ បន្ទាប់មក គណបក្សសង្គ្រោះជាតិបានរៀបចំបាតុកម្មធំៗនៅរាជធានីភ្នំពេញ ក្នុងខែធ្នូ ឆ្នាំ ២០១៣។ រដ្ឋាភិបាលបានចាត់ទុកបាតុកម្មទាំងនេះថាជាបាតុកម្មខុសច្បាប់។

ជាចុងក្រោយ គណបក្សប្រឆាំងបានយល់ព្រមចូលរួមក្នុងរដ្ឋសភា បន្ទាប់ពីមានកិច្ចសន្ទនានៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ នៅវិមានរដ្ឋចំការមន ទីស្នាក់ការរបស់ព្រឹទ្ធសភា។ គណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ បានយល់ព្រមបែងចែកតួនាទីដឹកនាំក្នុងរដ្ឋសភា ដូចដែលបានបញ្ជាក់ក្នុងកិច្ចព្រមព្រៀងដែលបានចុះហត្ថលេខា។

កិច្ចព្រមព្រៀងនេះ ត្រូវបានប្រើប្រាស់ជាមធ្យោបាយសម្រាប់ដោះស្រាយវិបត្តិនយោបាយជាចុងក្រោយ និងបានបញ្ចប់ភាពជាប់គាំងនយោបាយនៅកម្ពុជា ដែលបានបន្តអស់រយៈពេលជិតមួយឆ្នាំ។ ស្របតាមកិច្ចព្រមព្រៀងនេះ តំណែងអនុប្រធានទី១ នៃរដ្ឋសភា ត្រូវបានបម្រុងទុកសម្រាប់សមាជិកមកពីគណបក្សសង្គ្រោះជាតិ ហើយតំណែងអនុប្រធានទី២ នៃរដ្ឋសភា ត្រូវបានបម្រុងទុកសម្រាប់សមាជិកមកពីគណបក្សប្រជាជនកម្ពុជា។ គណបក្សសង្គ្រោះជាតិ ក៏ត្រូវបានផ្តល់តំណែងជាប្រធានគណៈកម្មការចំនួន ៥ ក្នុងចំណោមគណៈកម្មការទាំង ១០ របស់រដ្ឋសភា រួមទាំងគណៈកម្មការប្រឆាំងអំពើពុករលួយ ដែលទើបត្រូវបានបង្កើតឡើងថ្មីផងដែរ។ កិច្ចព្រមព្រៀងខាងលើនេះ មានសរុប ៧ មាត្រា។ មាត្រា ២ បានកំណត់ថា៖ "*អនុលោមតាមសេចក្តីប្រកាសរួមនៃកិច្ចប្រជុំកំពូលរវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ កាលពីថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៣ គណបក្សទាំងពីរបានយល់ព្រមអនុវត្ត ការកែទម្រង់ការបោះឆ្នោត ដោយបង្កើតស្ថាប័នឯករាជ្យពេញលេញមួយសម្រាប់រៀបចំ និងគ្រប់គ្រងការបោះឆ្នោត។ ដូច្នេះ ស្ថាប័ននេះត្រូវបានកំណត់បញ្ចូលក្នុងជំពូកដាក់លាក់មួយនៃរដ្ឋធម្មនុញ្ញ ហើយសមាជិករបស់ស្ថាប័ននេះត្រូវបានជ្រើសរើសដោយរដ្ឋសភា តាមរយៈការបោះឆ្នោតដោយសំឡេងភាគច្រើនដាច់ខាតនៃសមាជិកទាំងអស់របស់រដ្ឋសភា។ ស្ថាប័នបោះឆ្នោតថ្មីនេះ ត្រូវមានសមាសភាពសមាជិកចំនួន ៩ រូប ដែលក្នុងនោះ សមាជិក ៤ រូប ត្រូវបានជ្រើសរើសដោយគណបក្ស ដែលដឹកនាំរាជរដ្ឋាភិបាល សមាជិក ៤រូប ត្រូវបានជ្រើសរើសដោយគណបក្សដែលមានអាសនៈក្នុងរដ្ឋសភា និងបានចូលរួមក្នុងរដ្ឋាភិបាលចម្រុះ ហើយសមាជិក១រូបទៀត ត្រូវបានជ្រើសរើសដោយការព្រមព្រៀងរវាងគណបក្សដែលមានអាសនៈក្នុងរដ្ឋសភា* [...]"។[៩]

[៩] Taing (n 1).

យោងលិខិតលេខ ៣៣១ រ.ស. របស់រដ្ឋសភា ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ សូមក្រាបបង្គំទូលថ្វាយ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** ចុះថ្ងៃទី០៧ ខែសីហាឆ្នាំ២០១៤ **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** បានទូលថ្វាយថា *"ទូលព្រះបង្គំជាខ្ញុំ ក្នុងនាមជាប្រធានរដ្ឋសភា បានទទួលនូវសេចក្តីស្នើច្បាប់ធម្មនុញ្ញពីតំណាងរាស្ត្រហត្ថលេខីចំនួន ៨៥ រូប បានផ្តើមគំនិតធ្វើសេចក្តីស្នើច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា៧៦ និងមាត្រាទាំងឡាយពីជំពូកទី១៥ ថ្មី ដល់ជំពូកទី១៦ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ សេចក្តីស្នើច្បាប់ធម្មនុញ្ញនេះ ធ្វើឡើងស្របនឹងមាត្រា ១៥១ ថ្មី (មាត្រា ១៣២ចាស់) នៃរដ្ឋធម្មនុញ្ញ"*។[១០]

ដូចដែលបានលើកឡើងខាងលើ គណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ បានឈានដល់កិច្ចព្រមព្រៀងនយោបាយមួយ ដើម្បីស្នើសុំការកែសម្រួល និងវិសោធនកម្មរដ្ឋធម្មនុញ្ញ។ ប្រធានរដ្ឋសភាបានថ្វាយលិខិតមួយច្បាប់ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ដើម្បីក្រាបបង្គំស្នើសុំព្រះមហាក្សត្រទ្រង់មានព្រះតម្រិះពិគ្រោះមតិជាមួយក្រុមប្រឹក្សាធម្មនុញ្ញ អំពីសំណើក្នុងការកែប្រែមាត្រា ៧៦ និងមាត្រាផ្សេងៗទៀត ចាប់ពីជំពូកទី១៥ (ថ្មី) ដល់ជំពូកទី១៦ (ថ្មី) នៃរដ្ឋធម្មនុញ្ញ។

វិសោធនកម្មលើកទី៧ នេះ មានឥទ្ធិពលវិជ្ជមានលើគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប.) ព្រោះបានជួយបង្កើនការជឿទុកចិត្តរបស់សាធារណជនចំពោះស្ថាប័ននេះ។ សមាសភាពថ្មីនៃ គ.ជ.ប. ដូចដែលបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ ត្រូវបានទទួលស្គាល់ដោយអ្នកនយោបាយ ក៏ដូចជាសហគមន៍ជាតិ និងអន្តរជាតិ។ វិសោធនកម្មនេះត្រូវបានចាត់ទុកថាជាជំហានមួយទៀតឆ្ពោះទៅរកការធ្វើឱ្យប្រព័ន្ធបោះឆ្នោតនៅកម្ពុជាមានភាពទំនើប និងមានស្តង់ដាកាន់តែស្របតាមគោលការណ៍នីតិរដ្ឋ និងលទ្ធិប្រជាធិបតេយ្យពិតប្រាកដ។[១១]

សរុបមកវិសោធនកម្មលើកទី៧នេះ មានគោលបំណងបង្កើតអង្គការរៀបចំការបោះឆ្នោតឱ្យក្លាយជាស្ថាប័នដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ ដើម្បីធានាឯករាជ្យភាព និងភាពជឿទុកចិត្តពីសាធារណជន។ វិសោធនកម្មនេះកើតឡើងក្នុងបរិបទនៃវិបត្តិនយោបាយបន្ទាប់ពីការបោះឆ្នោតឆ្នាំ២០១៣ និងជាលទ្ធផលនៃកិច្ចព្រមព្រៀងនយោបាយរវាងគណបក្សនយោបាយសំខាន់ៗ ដើម្បីដោះស្រាយភាពជាប់គាំងនយោបាយ។ ការកែប្រែនេះបានរួមចំណែកពង្រឹងប្រព័ន្ធបោះឆ្នោតនៅកម្ពុជា និងជាជំហានមួយក្នុងការលើកកម្ពស់គោលការណ៍នីតិរដ្ឋ និងលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស។

[១០] លិខិតលេខ ៣៣១ រ.ស. របស់រដ្ឋសភា សូមក្រាបបង្គំទូលថ្វាយ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** ចុះថ្ងៃទី០៧ ខែសីហាឆ្នាំ២០១៤

[១១] Taing (n 1).

# ខ្លឹមសារមាត្រាចាស់ និងមាត្រាថ្មី

| មាត្រាចាស់ | មាត្រាថ្មី |
|---|---|
| **មាត្រា ៧៦.-**<br>រដ្ឋសភាមានសមាជិកជាតំណាងរាស្ត្រយ៉ាងតិច ១២០ រូប។<br>តំណាងរាស្ត្រត្រូវជ្រើសតាំងដោយការបោះឆ្នោតជាសកល ដោយសេរី ដោយស្មើភាព ដោយចំពោះ និងតាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់ ។<br>តំណាងរាស្ត្រអាចឈរឈ្មោះបោះឆ្នោតសាជាថ្មីបាន។<br>អ្នកដែលមានសិទ្ធិឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រ គឺប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានសិទ្ធិបោះឆ្នោត មានអាយុយ៉ាងតិច ២៥ ឆ្នាំ មានសញ្ជាតិជាខ្មែរតាំងពីកំណើត។<br>អង្គការរៀបចំការបោះឆ្នោត បែបបទ និងការប្រព្រឹត្តិទៅនៃការបោះឆ្នោត ត្រូវកំណត់ក្នុងច្បាប់បោះឆ្នោត។ | **មាត្រា ៧៦.- ថ្មី**<br>រដ្ឋសភាមានសមាជិកតំណាងរាស្ត្រយ៉ាងតិច ១២០ រូប។<br>តំណាងរាស្ត្រ ត្រូវជ្រើសតាំងដោយការបោះឆ្នោតជាសកល ដោយសេរី ដោយស្មើភាព ដោយចំពោះ និងតាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់។<br>តំណាងរាស្ត្រអាចឈរឈ្មោះបោះឆ្នោតសាជាថ្មីបាន។<br>អ្នកដែលមានសិទ្ធិឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រ គឺជាប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានសិទ្ធិបោះឆ្នោត មានអាយុយ៉ាងតិច ២៥ឆ្នាំ មានសញ្ជាតិជាខ្មែរតាំងពីកំណើត។<br>បែបបទ និងការប្រព្រឹត្តទៅនៃការបោះឆ្នោត ត្រូវកំណត់ក្នុងច្បាប់បោះឆ្នោត។ |
| ***"រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ (ច្បាប់ដើម) ពុំមានបទប្បញ្ញត្តិស្តីពីអង្គការរៀបចំការបោះឆ្នោតទេ"*** | **ជំពូកទី១៥ ថ្មី (ពីរ)**<br>**អំពី**<br>**អង្គការរៀបចំការបោះឆ្នោត** |
| | **មាត្រា ១៥០.- ថ្មី(ពីរ)**<br>គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គឺជាអង្គការដែលមានសមត្ថកិច្ចរៀបចំចាត់ចែង និងគ្រប់គ្រងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ព្រមទាំងការបោះឆ្នោតផ្សេងទៀតតាមការកំណត់នៃច្បាប់។<br>គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវអនុវត្តសមត្ថកិច្ចរបស់ខ្លួន ប្រកបដោយឯករាជ្យ និងអព្យាក្រឹត ដើម្បីធានាឲ្យការបោះ |

| | |
|---|---|
| | ឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ស្របតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស។<br>មុខងារសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានវិសមតិភាពជាមួយការបំពេញមុខតំណែងក្នុងមុខងារសាធារណៈ និងជាមួយមុខងារជាសមាជិកនៃស្ថាប័នដទៃទៀតដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនេះ។ សមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមិនអាចធ្វើជាសមាជិកនៃគណបក្សនយោបាយ ឬធ្វើជាអ្នកដឹកនាំនៃអង្គការមិនមែនរដ្ឋាភិបាល សមាគម សហជីព ឬក្រុមហ៊ុនពាណិជ្ជកម្មណាមួយបានឡើយ។<br>គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានថវិកាស្វ័យតសម្រាប់ដំណើរការ។ |
| | **មាត្រា ១៥១.- ថ្មី(ពីរ)**<br>គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានសមាសភាពប្រាំបួនរូបដែលទទួលអាណត្តិប្រាំឆ្នាំ។ សមាសភាពបួនរូបត្រូវជ្រើសរើសដោយគណបក្សដឹកនាំរាជរដ្ឋាភិបាល បួនរូបត្រូវជ្រើសរើសដោយគណបក្សមានអាសនៈក្នុងរដ្ឋសភាដែលមិនចូលរួមក្នុងរាជរដ្ឋាភិបាល និងមួយរូប ត្រូវជ្រើសរើសដោយមានការព្រមព្រៀងគ្នារវាងគណបក្សទាំងអស់ដែលមានអាសនៈក្នុងរដ្ឋសភា។<br>គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ត្រូវដំណើរការរៀបចំឲ្យមានការជ្រើសរើសដោយបើកចំហ និងតម្លាភាព នូវសមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា រៀបចំបញ្ជីសមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដាក់ជូនរដ្ឋសភា |

| | |
|---|---|
| | ដើម្បីបោះឆ្នោតទុកចិត្តតាមមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល។<br>សមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវតែងតាំងដោយព្រះរាជក្រឹត្យ។<br>ក្នុងករណីសមាជិកណាមួយនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បាត់បង់សមាជិកភាពរបស់ខ្លួន គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាត្រូវចាត់នីតិវិធីជ្រើសរើស សមាសភាពថ្មីជំនួសក្នុងរយៈពេលយ៉ាងយូរ ១៥ ថ្ងៃ គិតពីថ្ងៃបាត់បង់សមាជិកភាព។ នីតិវិធីលំអិតនៃការជ្រើសរើសសមាសភាពថ្មី ជំនួសត្រូវកំណត់ដោយឡែកក្នុងច្បាប់។<br>ក្នុងករណីខកខានមិនបានរៀបចំសមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលមានស្រាប់ ត្រូវអនុវត្តការងាររបស់ខ្លួនបន្តទៀត និងមានសមត្ថកិច្ចដើម្បីចាត់ចែង រៀបចំការបោះឆ្នោតតាមច្បាប់។<br>ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត នឹងត្រូវកំណត់ក្នុងច្បាប់មួយ។ |
| **ជំពូកទី១៥ ថ្មី**<br>**អំពី**<br>**អានុភាព ការសើរើ និងវិសោធនកម្មរដ្ឋធម្មនុញ្ញ** | **ជំពូកទី១៦ ថ្មី (ពីរ)**<br>**អំពី**<br>**អានុភាព ការសើរើ និងវិសោធនកម្មរដ្ឋធម្មនុញ្ញ** |
| **មាត្រា ១៥០.- ថ្មី (មាត្រា ១៣១ ចាស់)**<br>រដ្ឋធម្មនុញ្ញនេះជាច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជា។<br>ច្បាប់ និងសេចក្ដីសំរេចទាំងឡាយនៃស្ថាប័ននានា របស់រដ្ឋត្រូវស្របនឹងរដ្ឋធម្មនុញ្ញជាដាច់ខាត។ | **មាត្រា ១៥២.- ថ្មី (ពីរ មាត្រា ១៥០ ថ្មី)**<br>រដ្ឋធម្មនុញ្ញនេះជាច្បាប់កំពូល នៃព្រះរាជាណាចក្រកម្ពុជា។<br>ច្បាប់ និងសេចក្ដីសម្រេចទាំងឡាយនៃស្ថាប័ននានារបស់រដ្ឋ ត្រូវស្របនឹងរដ្ឋធម្មនុញ្ញជាដាច់ខាត។ |

| | |
|---|---|
| **មាត្រា ១៥១.- ថ្មី (មាត្រា ១៣២ ចាស់)**<br>ការផ្តើមគំនិតសើរើឬការផ្តើមគំនិតធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ជាសិទ្ធិរបស់ព្រះមហាក្សត្រ របស់នាយករដ្ឋមន្ត្រី និងរបស់ប្រធានរដ្ឋសភា តាមសេចក្តីស្នើរបស់តំណាងរាស្ត្រ មួយភាគបួននៃចំនួនសមាជិករដ្ឋសភាទាំងមូល។<br>ការសើរើឬវិសោធនកម្មរដ្ឋធម្មនុញ្ញត្រូវធ្វើឡើងដោយច្បាប់ធម្មនុញ្ញមួយដែលអនុម័តដោយរដ្ឋសភាតាមមតិភាគច្រើនពីរភាគបី នៃចំនួនសមាជិករដ្ឋសភាទាំងមូល។ | **មាត្រា ១៥៣.- ថ្មី (ពីរ មាត្រា ១៥១.- ថ្មី)**<br>ការផ្តើមគំនិតសើរើ ឬការផ្តើមគំនិតធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញជាសិទ្ធិរបស់ព្រះមហាក្សត្រ របស់នាយករដ្ឋមន្ត្រី និងរបស់ប្រធានរដ្ឋសភាតាមសេចក្តីស្នើរបស់តំណាងរាស្ត្រមួយភាគបួននៃចំនួនសមាជិករដ្ឋសភាទាំងមូល។<br>ការសើរើ ឬវិសោធនកម្មរដ្ឋធម្មនុញ្ញ ត្រូវធ្វើឡើងដោយច្បាប់ធម្មនុញ្ញមួយ ដែលអនុម័តដោយរដ្ឋសភា តាមមតិភាគច្រើនពីរភាគបី នៃចំនួនសមាជិករដ្ឋសភាទាំងមូល។ |
| **មាត្រា ១៥២.- ថ្មី (មាត្រា ១៣៣ ចាស់)**<br>ការសើរើ ឬវិសោធនកម្មរដ្ឋធម្មនុញ្ញ ត្រូវហាមឃាត់មិនអោយធ្វើ នៅពេលប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ដូចមានចែងក្នុងមាត្រា ៨៦។ | **មាត្រា ១៥៤.- ថ្មី (ពីរ មាត្រា ១៥២ ថ្មី)**<br>ការសើរើ ឬវិសោធនកម្មរដ្ឋធម្មនុញ្ញ ត្រូវហាមឃាត់មិនឲ្យធ្វើ នៅពេលប្រទេសជាតិឋិតក្នុងភាពអាសន្ន ដូចមានចែងក្នុងមាត្រា ៨៦។ |
| **មាត្រា ១៥៣.- ថ្មី (មាត្រា ១៣៤ ចាស់)**<br>ការសើរើ ឬវិសោធនកម្មរដ្ឋធម្មនុញ្ញមិនអាចធ្វើបានឡើយ កាលបើប៉ះពាល់ដល់ប្រព័ន្ធប្រជាធិបតេយ្យ សេរីពហុបក្ស និងរបបរាជានិយមអាស្រ័យដោយរដ្ឋធម្មនុញ្ញ។ | **មាត្រា ១៥៥.- ថ្មី (ពីរ មាត្រា ១៥៣ ថ្មី)**<br>ការសើរើ ឬវិសោធនកម្មរដ្ឋធម្មនុញ្ញមិនអាចធ្វើបានឡើយ កាលបើប៉ះពាល់ដល់ប្រព័ន្ធប្រជាធិបតេយ្យ សេរីពហុបក្ស និងរបបរាជានិយមអាស្រ័យដោយរដ្ឋធម្មនុញ្ញ។ |
| **ជំពូកទី១៦ ថ្មី**<br>**អំពី**<br>**អន្តរប្បញ្ញត្តិ** | **ជំពូកទី១៧ ថ្មី**<br>**អំពី**<br>**អន្តរប្បញ្ញត្តិ** |
| **មាត្រា ១៥៤.- ថ្មី (មាត្រា ១៣៥ ចាស់)**<br>រដ្ឋធម្មនុញ្ញនេះ ក្រោយពីបានទទួលការអនុម័ត ត្រូវបានប្រកាសអោយចូលជាធរមានភ្លាមដោយព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។ | **មាត្រា ១៥៦.- ថ្មី (ពីរ មាត្រា ១៥៤ ថ្មី)**<br>រដ្ឋធម្មនុញ្ញនេះ ក្រោយពីបានទទួលការអនុម័ត ត្រូវបានប្រកាសឲ្យចូលជាធរមានភ្លាមដោយព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា។ |
| **មាត្រា ១៥៥.- ថ្មី (មាត្រា ១៣៦ ចាស់)**<br>ក្រោយពេលរដ្ឋធម្មនុញ្ញនេះចូលជាធរមាន សភាធម្មនុញ្ញត្រូវក្លាយទៅជារដ្ឋសភា។<br>បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភាត្រូវចូលជាធរមាន ក្រោយទទួលបានការអនុម័តពីរដ្ឋសភា។ | **មាត្រា ១៥៧.- ថ្មី (ពីរ មាត្រា ១៥៥ ថ្មី)**<br>ក្រោយពេលរដ្ឋធម្មនុញ្ញនេះចូលជាធរមានសភាធម្មនុញ្ញត្រូវក្លាយទៅជារដ្ឋសភា។<br>បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភាត្រូវចូលជាធរមាន ក្រោយទទួលបានការអនុម័តពីរដ្ឋសភា។ |

| | |
|---|---|
| ក្នុងករណីដែលរដ្ឋសភាមិនទាន់ចាប់ដំណើរការបាន ប្រធាន អនុប្រធានទីមួយ និងអនុប្រធានទីពីរនៃសភាធម្មនុញ្ញនឹងចូលរួមបំពេញភារកិច្ចក្នុងក្រុមប្រឹក្សារាជសម្បត្តិបើសភាពការណ៍ក្នុងប្រទេសទាមទារ។ | ក្នុងករណីដែលរដ្ឋសភាមិនទាន់ចាប់ដំណើរការបាន ប្រធាន អនុប្រធានទីមួយ និង អនុប្រធានទីពីរនៃសភាធម្មនុញ្ញ នឹងចូលរួមបំពេញភារកិច្ចក្នុងក្រុមប្រឹក្សារាជសម្បត្តិ បើសភាពការណ៍ក្នុងប្រទេសទាមទារ។ |
| **មាត្រា ១៥៦.- ថ្មី ( មាត្រា ១៣៧ ចាស់ )**<br>ក្រោយរដ្ឋធម្មនុញ្ញនេះចូលជាធរមាន ព្រះមហាក្សត្រជ្រើសតាំងតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ១៣ថ្មី និង១៤។ | **មាត្រា ១៥៨.- ថ្មី ( ពីរ មាត្រា ១៥៦ ថ្មី )**<br>ក្រោយរដ្ឋធម្មនុញ្ញនេះចូលជាធរមាន ព្រះមហាក្សត្រជ្រើសតាំងតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ១៣ ថ្មី និង ១៤។ |
| **មាត្រា ១៥៧.- ថ្មី ( មាត្រា ១៣៨ ចាស់ )**<br>នីតិកាលទី១ នៃព្រឹទ្ធសភាមានកំណត់ ៥ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលព្រឹទ្ធសភាថ្មីចូលកាន់តំណែង។<br>សំរាប់នីតិកាលទី១ នៃព្រឹទ្ធសភាៈ<br>- សមាជិកព្រឹទ្ធសភា មានចំនួនសរុបហុកសិបមួយរូប។<br>- ព្រះមហាក្សត្រទ្រង់តែងតាំងសមាជិកព្រឹទ្ធសភាពីររូប ព្រមទាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា។<br>- សមាជិកដទៃទៀតនៃព្រឹទ្ធសភាត្រូវបានតែងតាំងដោយព្រះមហាក្សត្រ តាមសំណើរបស់ព្រឹទ្ធសភា និងប្រធានរដ្ឋសភា ក្នុងចំណោមសមាជិកនៃគណបក្សដែកមានអាសនៈនៅក្នុងរដ្ឋសភា។<br>- កិច្ចប្រជុំជាសមាជិករដ្ឋសភា និងព្រឹទ្ធសភា ត្រូវដឹកនាំដោយសហប្រធាន។ | **មាត្រា ១៥៩.- ថ្មី ( ពីរ មាត្រា ១៥៧ ថ្មី )**<br>នីតិកាលទី ១ នៃព្រឹទ្ធសភាមានកំណត់ ៥ ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលព្រឹទ្ធសភាថ្មីចូលកាន់តំណែង។<br>សម្រាប់នីតិកាលទី ១ នៃព្រឹទ្ធសភាៈ<br>- សមាជិកព្រឹទ្ធសភាមានចំនួនសរុបហុកសិបមួយរូប។<br>- ព្រះមហាក្សត្រទ្រង់តែងតាំងសមាជិកព្រឹទ្ធសភាពីររូប ព្រមទាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា។<br>- សមាជិកដទៃទៀតនៃព្រឹទ្ធសភា ត្រូវបានតែងតាំងដោយព្រះមហាក្សត្រ តាមសំណើរបស់ប្រធានព្រឹទ្ធសភា និងប្រធានរដ្ឋសភា ក្នុងចំណោមសមាជិកនៃគណបក្សដែលមានអាសនៈ នៅក្នុងរដ្ឋសភា។<br>- កិច្ចប្រជុំជាសមាជរដ្ឋសភានិងព្រឹទ្ធសភាត្រូវដឹកនាំដោយសហប្រធាន។ |

| មាត្រា ១៥៨.- ថ្មី ( មាត្រា ១៣៩ ចាស់ ) | មាត្រា ១៦០.- ថ្មី ( ពីរ មាត្រា ១៥៨ ថ្មី ) |
|---|---|
| ច្បាប់ និងលិខិតបទដ្ឋានទាំងអស់នៅកម្ពុជា ដែលជានាការពារបាននូវទ្រព្យសម្បត្តិរដ្ឋ សិទ្ធិ សេរីភាព និងទ្រព្យសម្បត្តិត្រឹមត្រូវតាមច្បាប់របស់បុគ្គលនិងដែលសមស្របនឹងប្រយោជន៍ជាតិ ត្រូវមានអានុភាពអនុវត្តបន្តទៅមុខទៀត រហូតដល់មានអត្ថបទថ្មីមកកែប្រែ ឬលុបចោលលើកលែង តែបទប្បញ្ញត្តិណាដែលផ្ទុយនឹងស្មារតីនៃរដ្ឋធម្មនុញ្ញនេះ។<br>ច្បាប់ធម្មនុញ្ញនេះ ត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា អនុម័តនៅថ្ងៃទី ៤ ខែ មីនា ឆ្នាំ ១៩៩៩ ក្នុងសម័យប្រជុំវិសមញ្ញ នីតិកាលទី២។ | ច្បាប់ និងលិខិតបទដ្ឋានទាំងអស់នៅកម្ពុជា ដែលជានាការពារបាននូវទ្រព្យសម្បត្តិរដ្ឋសិទ្ធិសេរីភាព និងទ្រព្យសម្បត្តិត្រឹមត្រូវតាមច្បាប់របស់បុគ្គល និងដែលសមស្របនឹងប្រយោជន៍ជាតិត្រូវមានអានុភាពអនុវត្តបន្តទៅមុខទៀត រហូតដល់មានអត្ថបទថ្មីមកកែប្រែ ឬលុបចោល លើកលែងតែបទប្បញ្ញត្តិណាដែលផ្ទុយនឹងស្មារតីនៃរដ្ឋធម្មនុញ្ញនេះ។ |

## វិសោធនកម្មលើកទី៨ (២០១៨)

ច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា៣៤ ថ្មី មាត្រា៤២ មាត្រា៤៩ មាត្រា៥៣ និងមាត្រា ១១៨ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានរដ្ឋសភាអនុម័តកាលពីថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ ២០១៨ នាសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៨ នាសម័យប្រជុំពេញអង្គលើកទី១១ នីតិកាលទី៣។ ច្បាប់ធម្មនុញ្ញនេះត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២១៨/០០២ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៨។

វិសោធនកម្មលើកតី៨នេះ ត្រូវបានធ្វើឡើងតាមគំនិតផ្តួចផ្តើមដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ យោងតាមលិខិតលេខ៨៧ លស.កបច. ក្រាបបង្គំទូលថ្វាយ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ ២០១៨ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** បានទូលថ្វាយថា *"ទូលព្រះបង្គំជាខ្ញុំ ដោយអនុលោមតាមមាត្រា១៥៣ថ្មី (ពីរ) នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា និងក្នុងឋានៈជានាយករដ្ឋមន្ត្រី បានផ្តួចផ្តើមគំនិតធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ត្រង់មាត្រា ៣៤ ថ្មី មាត្រា៤២ មាត្រា៤៩ មាត្រា៥៣ និងមាត្រា១១៨ ថ្មី ក្នុងគោលបំណងដើម្បីបង្កើនប្រសិទ្ធភាពការងាររបស់អង្គនីតិប្រតិបត្តិ និងដើម្បីលើកស្ទួយតម្លៃជាតិខ្មែរ ក្នុងបុព្វហេតុការពារឯករាជ្យជាតិ*

*អធិបតេយ្យជាតិ និងឯកភាពជាតិ ប្រឆាំងនឹងការជ្រៀតជ្រែកពីខាងក្រៅ តាមគ្រប់រូបភាព ព្រមទាំងដើម្បីលើកស្ទួយការតម្កល់ផលប្រយោជន៍ជាតិ និងរបស់ប្រជាជនជាធំ"*។[១២]

វិសោធនកម្មលើកទី៨នេះ មានផលប៉ះពាល់ជាវិជ្ជមាន ពោលគឺបានផ្តល់ផលប្រយោជន៍ដល់ប្រទេសជាតិ និងការពារអធិបតេយ្យភាពនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងបានធ្វើឱ្យប្រសើរឡើងនូវមុខមាត់របស់រាជរដ្ឋាភិបាលផងដែរ។ ដោយសារតែការកែសម្រួលមាត្រា ១១៨ (ថ្មី) ចំនួនសមាជិកនៃរាជរដ្ឋាភិបាលត្រូវបានកាត់បន្ថយពីប្រហែល ៣០០ រូប មកនៅប្រហែល ៥០ រូប។[១៣] បន្ទាប់ពីច្បាប់ធម្មនុញ្ញនេះចូលជាធរមាន គណៈរដ្ឋមន្ត្រី ត្រូវបានដឹកនាំដោយនាយករដ្ឋមន្ត្រីមួយរូប អមដោយឧបនាយករដ្ឋមន្ត្រី ព្រមទាំងទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រី ជាសមាជិក។

សរុបមក វិសោធនកម្មលើកទី៨នេះ មានគោលបំណងកែសម្រួលមាត្រាចម្បងមួយចំនួនដើម្បីពង្រឹងប្រសិទ្ធភាពនៃការងាររបស់អង្គនីតិប្រតិបត្តិ និងលើកស្ទួយការការពារផលប្រយោជន៍ជាតិ អធិបតេយ្យភាព និងឯកភាពជាតិ។ ការកែប្រែនេះក៏បានកំណត់រចនាសម្ព័ន្ធថ្មីនៃរាជរដ្ឋាភិបាល ដោយកាត់បន្ថយចំនួនសមាជិកគណៈរដ្ឋមន្ត្រី និងកំណត់តួនាទីឱ្យមានភាពច្បាស់លាស់ជាងមុន។ វិសោធនកម្មនេះត្រូវបានចាត់ទុកថាជាជំហានមួយក្នុងការកែលម្អប្រព័ន្ធគ្រប់គ្រងរដ្ឋ និងពង្រឹងសមត្ថភាពអង្គនីតិប្រតិបត្តិឱ្យមានប្រសិទ្ធភាពកាន់តែប្រសើរ។

## ខ្លឹមសារមាត្រាចាស់ និងមាត្រាថ្មី

| មាត្រាចាស់ | មាត្រាថ្មី |
|---|---|
| **មាត្រា ៣៤.- ថ្មី**<br>ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិបោះឆ្នោត និងអាចឈរឈ្មោះអោយគេបោះឆ្នោត។<br>ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ១៨ឆ្នាំ មានសិទ្ធិបោះឆ្នោត។<br>ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានអាយុយ៉ាងតិច ២៥ឆ្នាំ អាចឈរឈ្មោះអោយគេបោះឆ្នោតជ្រើសតាំងជាតំណាងរាស្ត្រ។ | **មាត្រា ៣៤.- ថ្មី(មួយ)**<br>ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិបោះឆ្នោត និងអាចឈរឈ្មោះឱ្យគេបោះឆ្នោត។<br>ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ១៨ ឆ្នាំ មានសិទ្ធិបោះឆ្នោត។<br>ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ២៥ ឆ្នាំ អាចឈរឈ្មោះឱ្យគេបោះឆ្នោត ជ្រើសតាំងជាតំណាងរាស្ត្រ។ |

[១២] លិខិតលេខ៨៧ លស.កបច. ក្រាបបង្គំទូលថ្វាយ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៨

[១៣] Taing (n 1).

| | |
|---|---|
| ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ៤០ឆ្នាំ អាចឈរឈ្មោះអោយគេបោះឆ្នោតជ្រើសតាំងជាសមាជិកព្រឹទ្ធសភា។<br>បទប្បញ្ញត្តិបន្ថយសិទ្ធិបោះឆ្នោត និងសិទ្ធិឈរឈ្មោះអោយគេបោះឆ្នោត ត្រូវចែងក្នុងច្បាប់បោះឆ្នោត។ | ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ៤០ ឆ្នាំ អាចឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសតាំងជាសមាជិកព្រឹទ្ធសភា។<br>បទប្បញ្ញត្តិដកសិទ្ធិបោះឆ្នោត និងសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតត្រូវកំណត់ក្នុងច្បាប់។ |
| **មាត្រា ៤២.-**<br>ប្រជាពលរដ្ឋខ្មែរមានសិទ្ធិបង្កើតសមាគម និងគណៈបក្សនយោបាយ។ សិទ្ធិនេះត្រូវកំណត់ក្នុងច្បាប់។<br>ប្រជាពលរដ្ឋខ្មែរទាំងឡាយ អាចចូលរួមក្នុងអង្គការមហាជនជួយគ្នាទៅវិញទៅមក ការពារសមិទ្ធផលជាតិ និងសណ្តាប់ធ្នាប់សង្គម។ | **មាត្រា ៤២.- ថ្មី**<br>ប្រជាពលរដ្ឋខ្មែរមានសិទ្ធិបង្កើតសមាគម និងគណបក្សនយោបាយ។ សិទ្ធិនេះត្រូវកំណត់ក្នុងច្បាប់។<br>គណបក្សនយោបាយត្រូវតម្កល់ផលប្រយោជន៍ជាតិជាធំ ហើយមិនត្រូវធ្វើសកម្មភាពណាមួយ ទោះដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី នាំឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ព្រះរាជាណាចក្រកម្ពុជា និងប្រជាពលរដ្ឋខ្មែរឡើយ។<br>ប្រជាពលរដ្ឋខ្មែរទាំងឡាយ អាចចូលរួមក្នុងអង្គការមហាជន ជួយគ្នាទៅវិញទៅមក ការពារសមិទ្ធផលជាតិ និងសណ្តាប់ធ្នាប់សង្គម។ |
| **មាត្រា ៤៩.-**<br>ប្រជាពលរដ្ឋខ្មែរគ្រប់រូបត្រូវគោរពរដ្ឋធម្មនុញ្ញ និងគោរពច្បាប់។<br>ប្រជាពលរដ្ឋខ្មែរគ្រប់រូបមានកាតព្វកិច្ចរួមចំណែកកសាងប្រទេសជាតិនិងការពារមាតុភូមិ។<br>កាតព្វកិច្ចការពារមាតុភូមិត្រូវអនុវត្តតាមបញ្ញត្តិច្បាប់។ | **មាត្រា ៤៩.- ថ្មី**<br>ប្រជាពលរដ្ឋខ្មែរគ្រប់រូបត្រូវគោរពរដ្ឋធម្មនុញ្ញ និងគោរពច្បាប់។<br>ប្រជាពលរដ្ឋខ្មែរគ្រប់រូបត្រូវតម្កល់ផលប្រយោជន៍ជាតិជាធំ ហើយមិនត្រូវធ្វើសកម្មភាពណាមួយ ទោះដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី នាំឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ព្រះរាជាណាចក្រកម្ពុជា និងប្រជាពលរដ្ឋខ្មែរឡើយ។<br>ប្រជាពលរដ្ឋខ្មែរគ្រប់រូបមានកាតព្វកិច្ចរួមចំណែកកសាងប្រទេសជាតិ និងការពារមាតុភូមិ។<br>កាតព្វកិច្ចការពារមាតុភូមិត្រូវអនុវត្តតាមបញ្ញត្តិច្បាប់។ |

| មាត្រា ៥៣.- | មាត្រា ៥៣.- ថ្មី |
| --- | --- |
| ព្រះរាជាណាចក្រកម្ពុជា ប្រកាន់ខ្ជាប់ជានិច្ចនូវនយោបាយអព្យាក្រឹតអចិន្ត្រៃយ៍ និងមិនចូលបក្សសម្ព័ន្ធ។ ព្រះរាជាណាចក្រកម្ពុជារួមរស់ ដោយសន្តិសហវិជ្ជមានជាមួយប្រទេសជិតខាង និងប្រទេសដទៃទៀតទាំងអស់នៅ លើសកលលោក។<br>ព្រះរាជាណាចក្រកម្ពុជា មិនឈ្លានពានប្រទេសណាដាច់ខាត មិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងនៃប្រទេសដទៃដោយផ្ទាល់ ឬដោយប្រយោល ទោះបីក្រោមរូបភាពណាក៏ដោយ ដោះស្រាយរាល់បញ្ហាដោយសន្តិវិធី និង គោរពផលប្រយោជន៍ផងគ្នាទៅវិញទៅមក។<br>ព្រះរាជាណាចក្រកម្ពុជា មិនចងសម្ព័ន្ធយោធា ឬចូលក្នុងកិច្ចព្រមព្រៀង យោធាណាមួយដែលមិនស្របនឹងអព្យាក្រឹតភាពរបស់ខ្លួនឡើយ។<br>ព្រះរាជាណាចក្រកម្ពុជា មិនអនុញ្ញាតឱ្យមានមូលដ្ឋានយោធាបរទេសនៅលើទឹកដីរបស់ខ្លួន ហើយក៏មិនអនុញ្ញាតឱ្យមានមូលដ្ឋានយោធារបស់ខ្លួននៅបរទេសដែរ លើកលែងតែក្នុងក្របខ័ណ្ឌនៃសំណូមពររបស់អង្គការសហប្រជាជាតិ។<br>ព្រះរាជាណាចក្រកម្ពុជា រក្សាសិទ្ធិទទួលយកជំនួយបរទេសជា សម្ភារៈ យោធា អាវុធ គ្រាប់រំសេវ ការហ្វឹកហ្វឺនកងកម្លាំងប្រដាប់អាវុធនិងជំនួយផ្សេងៗទៀត ដើម្បីការពារខ្លួន និងធានាសណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈនៅផ្ទៃក្នុងប្រទេស។ | ព្រះរាជាណាចក្រកម្ពុជាប្រកាន់ខ្ជាប់ជានិច្ចនូវនយោបាយអព្យាក្រឹតអចិន្ត្រៃយ៍ និងមិនចូលបក្សសម្ព័ន្ធ។ ព្រះរាជាណាចក្រកម្ពុជារួមរស់ដោយសន្តិសហវិជ្ជមានជាមួយប្រទេសជិតខាង និងប្រទេសដទៃទៀតទាំងអស់នៅលើសកលលោក។<br>ព្រះរាជាណាចក្រកម្ពុជាមិនឈ្លានពានប្រទេសណាដាច់ខាត មិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងនៃប្រទេស ដទៃដោយផ្ទាល់ ឬដោយប្រយោល ទោះបីក្រោមរូបភាពណាក៏ដោយ ដោះស្រាយរាល់បញ្ហាដោយសន្តិវិធី និងគោរពផលប្រយោជន៍ផងគ្នាទៅវិញទៅមក។<br>ព្រះរាជាណាចក្រកម្ពុជាប្រឆាំងដាច់ខាតការជ្រៀតជ្រែកពីបរទេស ចូលក្នុងកិច្ចការផ្ទៃក្នុងរបស់ខ្លួន ទោះបីក្រោមរូបភាពណាក៏ដោយ។<br>ព្រះរាជាណាចក្រកម្ពុជាមិនចងសម្ព័ន្ធយោធា ឬចូលក្នុងកិច្ចព្រមព្រៀងយោធាណាមួយដែលមិន ស្របនឹងអព្យាក្រឹតភាពរបស់ខ្លួនឡើយ។<br>ព្រះរាជាណាចក្រកម្ពុជាមិនអនុញ្ញាតឱ្យមានមូលដ្ឋានយោធាបរទេសនៅលើទឹកដីរបស់ខ្លួន ហើយក៏មិនអនុញ្ញាតឱ្យមានមូលដ្ឋានយោធារបស់ខ្លួននៅបរទេសដែរ លើកលែងតែក្នុងក្របខ័ណ្ឌនៃសំណូមពរ របស់អង្គការសហប្រជាជាតិ។<br>ព្រះរាជាណាចក្រកម្ពុជារក្សាសិទ្ធិទទួលយកជំនួយបរទេសជាសម្ភារៈយោធា អាវុធ គ្រាប់រំសេវ ការហ្វឹកហ្វឺនកងកម្លាំងប្រដាប់អាវុធ និងជំនួយផ្សេងៗទៀត ដើម្បីការពារខ្លួន និងធានាសណ្តាប់ធ្នាប់ និង សន្តិសុខសាធារណៈនៅផ្ទៃក្នុងប្រទេស។ |

| **មាត្រា ១១៨.- ថ្មី (មាត្រា ៩៩ ចាស់)** | **មាត្រា ១១៨.- ថ្មី(មួយ)** |
|---|---|
| គណៈរដ្ឋមន្ត្រីជារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។ គណៈរដ្ឋមន្ត្រីត្រូវបានដឹកនាំដោយនាយករដ្ឋមន្ត្រីមួយរូប អមដោយឧបនាយករដ្ឋមន្ត្រីព្រមទាំងមានទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការ ជាសមាជិក។ | គណៈរដ្ឋមន្ត្រីជារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។ គណៈរដ្ឋមន្ត្រី ត្រូវបានដឹកនាំដោយនាយករដ្ឋមន្ត្រីមួយរូប អមដោយឧបនាយករដ្ឋមន្ត្រី ព្រមទាំងទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រី ជាសមាជិក។ |

## វិសោធនកម្មលើកទី៩ (២០២១)

ច្បាប់ស្តីពីវិសោធនកម្មមាត្រា១៩ ថ្មី មាត្រា៨២ ថ្មី មាត្រា១០៦ ថ្មី (មួយ) មាត្រា១១៩ ថ្មី និងមាត្រា១៣៧ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និង មាត្រា៣ និងមាត្រា៤ នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២១ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២១ នាសម័យប្រជុំវិសាមញ្ញ នីតិកាលទី៤។ ច្បាប់ធម្មនុញ្ញនេះត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១១២១/០១៦ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២១។ វិសោធនកម្មនេះត្រូវបានធ្វើឡើងសំដៅចារឹកគោលការណ៍គ្រឹះចូលទៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលជាច្បាប់គ្រឹះនិងជាច្បាប់កំពូលរបស់ជាតិ ដោយកំណត់ឱ្យប្រធានរដ្ឋសភា ប្រធានព្រឹទ្ធសភា នាយករដ្ឋមន្ត្រី និងប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវតែជាឥស្សរជនដែលមាន *"សញ្ជាតិខ្មែរតែមួយគត់"*។

យោងសេចក្តីថ្លែងហេតុលេខ ២៤សជណ.កបច ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០២១ របស់រាជរដ្ឋាភិបាលកម្ពុជា **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាបានគូសបញ្ជាក់ថា *"រដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និងក្រុមប្រឹក្សាធម្មនុញ្ញ គឺជាស្ថាប័នកំពូលរបស់ជាតិ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងមានការទទួលខុសត្រូវក្នុងការសម្រេចលើកិច្ចការសំខាន់ៗដែលជាអាយុជីវិតរបស់ប្រទេសជាតិ សំដៅធានាការពារឯករាជ្យជាតិ អធិបតេយ្យជាតិ និងបូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ឧត្តមប្រយោជន៍ជាតិនិងប្រជាជនកម្ពុជា និងការប្រឆាំងដាច់ខាតនឹងការជ្រៀតជ្រែកពីបរទេសចូលក្នុងកិច្ចការផ្ទៃក្នុងរបស់ជាតិ ឬការបង្គាប់បញ្ជាចំពោះគោលនយោបាយជាតិនិងអន្តរជាតិរបស់កម្ពុជា។ ផ្អែកលើមូលដ្ឋាននេះ ប្រធានរដ្ឋសភា ប្រធានព្រឹទ្ធសភា នាយករដ្ឋមន្ត្រី និងប្រធានក្រុមប្រឹក្សាធម្មនុញ្ញសុទ្ធតែត្រូវបានកំណត់ឱ្យមានកាតព្វកិច្ចត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់តំណែង នៅចំពោះព្រះភ័ក្ត្រ ព្រះមហា*

*ក្សត្រ ព្រះភ័ក្ត្រនៃសម្តេចព្រះសង្ឃរាជ និងទេវតារក្សាស្វេតច្ឆត្រ ដោយត្រូវសច្ចាប្តេជ្ញាដាច់ខាត ក្នុងការអនុវត្តកាតព្វកិច្ចស្មោះត្រង់ចំពោះជាតិនិងការពារឧត្តមប្រយោជន៍ដែលជាអាយុជីវិតរបស់ជាតិនិងប្រជាជនកម្ពុជា។ ទន្ទឹមនេះ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជានិងច្បាប់ដែលមានការពាក់ព័ន្ធក៏បានតម្រូវឱ្យតំណាងរាស្ត្រ សមាជិកព្រឹទ្ធសភា នាយករដ្ឋមន្ត្រី និងសមាជិកក្រុមក្រុមប្រឹក្សាធម្មនុញ្ញទាំងអស់ ត្រូវតែមានសញ្ជាតិខ្មែរតាំងពីកំណើត។ បន្ថែមពីនេះ ប្រធាន អនុប្រធាន និងសមាជិកទាំងអស់នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលជាស្ថាប័នមានចែងក្នុងរដ្ឋធម្មនុញ្ញផងដែរនោះក៏ត្រូវបានច្បាប់កំណត់ឱ្យត្រូវតែមានសញ្ជាតិខ្មែរពីកំណើតនិងមានសញ្ជាតិខ្មែរតែមួយគត់ ដើម្បីធានាឱ្យការបំពេញភារកិច្ចរបស់ខ្លួនទាក់ទងនឹងការងារបោះឆ្នោត ដែលជាស្នូលនៃដំណើរការប្រជាធិបតេយ្យសេរីពហុបក្សនៅកម្ពុជា ប្រព្រឹត្តទៅដោយឯករាជ្យ ដើម្បីធានាការពារឧត្តមប្រយោជន៍ជាតិពីការជ្រៀតជ្រែកពីខាងក្រៅចូលក្នុងកិច្ចការផ្ទៃក្នុង ទាក់ទងនឹងដំណើរការបោះឆ្នោត*” ។[១៤]

នៅក្នុងសេចក្តីថ្លែងហេតុខាងលើ សម្តេចតេជោបានបន្ថែមថា ដើម្បីធានាឱឡារិកភាពទាំងខាងផ្លូវច្បាប់ ទាំងខាងនយោបាយ ចំពោះគោលជំហរ និងការប្តេជ្ញាចិត្តស្មោះត្រង់ឥតងាករេចំពោះជាតិ មាតុភូមិ និងប្រជាជនកម្ពុជានៅគ្រប់កាលៈទេសៈទាំងអស់ និងដើម្បីធានាការពារឧត្តមប្រយោជន៍របស់ជាតិនិងប្រជាជនកម្ពុជាពីការជ្រៀតជ្រែកពីបរទេស **សម្តេចតេជោ** ក្នុងនាមជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងដោយយោងតាមមាត្រា១៥៣ ថ្មី(ពីរ) នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា សូមស្នើធ្វើវិសោធនកម្មមាត្រា១៩ ថ្មី មាត្រា៨២ ថ្មី មាត្រា១០៦ ថ្មី(មួយ) មាត្រា១១៩ ថ្មី និងមាត្រា១៣៧ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា៣ និងមាត្រា៤ នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ សំដៅចារឹកគោលការណ៍គ្រឹះទាំងនេះចូលទៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលជាច្បាប់គ្រឹះនិងជាច្បាប់កំពូលរបស់ជាតិ ដោយកំណត់ឱ្យប្រធានរដ្ឋសភា ប្រធានព្រឹទ្ធសភា នាយករដ្ឋមន្ត្រី និងប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវតែជាឥស្សរជនដែលមាន “**សញ្ជាតិខ្មែរតែមួយគត់**”។

សរុបមក វិសោធនកម្មលើកទី៩នេះ មានគោលបំណងចារឹកគោលការណ៍គ្រឹះមួយចំនួនចូលក្នុងរដ្ឋធម្មនុញ្ញ ដើម្បីធានាថា មុខតំណែងកំពូលសំខាន់ៗរបស់ជាតិ ដូចជា ប្រធានរដ្ឋសភា ប្រធានព្រឹទ្ធសភា នាយករដ្ឋមន្ត្រី និងប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវតែជាបុគ្គលដែលមាន “**សញ្ជាតិខ្មែរតែមួយគត់**”។ វិសោធនកម្មនេះមានគោលបំណងពង្រឹងការពារឯករាជ្យ អធិបតេយ្យភាព និងផលប្រយោជន៍ជាតិ ព្រមទាំងទប់ស្កាត់ការជ្រៀតជ្រែកពីបរទេសក្នុងកិច្ចការផ្ទៃក្នុងរបស់ប្រទេស។ ការកែសម្រួលនេះក៏បង្ហាញពីការប្តេជ្ញាចិត្តក្នុងការពង្រឹងស្ថិរភាពនៃស្ថាប័នកំពូលរបស់ជាតិ និងធានាការអនុវត្តភារកិច្ចដោយស្មោះត្រង់ចំពោះជាតិ និងប្រជាជនកម្ពុជា។

---

[14] សេចក្តីថ្លែងហេតុលេខ ២៤ សជណ.កបច របស់រាជរដ្ឋាភិបាលលេខ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០២១

## ខ្លឹមសារមាត្រាចាស់ និងមាត្រាថ្មី

<table>
<tr><td colspan="2">❖ ច្បាប់ស្តីពីវិសោធនកម្មមាត្រា១៩ ថ្មី មាត្រា៨២ ថ្មី មាត្រា១០៦ ថ្មី (មួយ) មាត្រា១១៩ ថ្មី និងមាត្រា១៣៧ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានធ្វើវិសោធនកម្ម ដូចតទៅះ</td></tr>
<tr><th>មាត្រាចាស់</th><th>មាត្រាថ្មី</th></tr>
<tr><td>មាត្រា១៩.- ថ្មី<br>ព្រះមហាក្សត្រទ្រង់តែងតាំងនាយករដ្ឋមន្ត្រី និងទ្រង់តែងតាំងគណៈរដ្ឋមន្ត្រីតាមបែបបទ ដែលមានចែងក្នុងមាត្រា ១១៩ ថ្មី។</td><td>មាត្រា ១៩.- ថ្មី(មួយ)<br>ព្រះមហាក្សត្រទ្រង់តែងតាំងនាយករដ្ឋមន្ត្រីនិងទ្រង់តែងតាំងគណៈរដ្ឋមន្ត្រីតាមបែបបទដែលមានចែងក្នុងមាត្រា ១១៩ ថ្មី (មួយ)។</td></tr>
<tr><td>មាត្រា ៨២.- ថ្មី<br>រដ្ឋសភាបើកសម័យប្រជុំដំបូង ហុកសិបថ្ងៃយ៉ាងយូរ ក្រោយពេលបោះឆ្នោតតាមការកោះប្រជុំរបស់ព្រះមហាក្សត្រ។<br>មុនចាប់ផ្តើមការងាររបស់ខ្លួន រដ្ឋសភាត្រូវប្រកាសសុពលភាព នៃអាណត្តិរបស់សមាជិកនីមួយៗត្រូវបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នា នូវប្រធាន អនុប្រធាន រដ្ឋសភា និង សមាជិកទាំងអស់នៃគណៈកម្មការនានារបស់រដ្ឋសភា ដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល។<br>រដ្ឋសភាត្រូវអនុម័តបទបញ្ជាផ្ទៃក្នុង ដោយមតិភាគច្រើនដាច់ខាត នៃចំនួនសមាជិករដ្ឋសភាទាំងមូល។<br>តំណាងរាស្ត្រទាំងអស់ ត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់តំណែង ដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធទី៥ នៃរដ្ឋធម្មនុញ្ញ។</td><td>មាត្រា ៨២.- ថ្មី(មួយ)<br>រដ្ឋសភាបើកសម័យប្រជុំដំបូង ហុកសិបថ្ងៃយ៉ាងយូរ ក្រោយពេលបោះឆ្នោតតាមការកោះប្រជុំរបស់ព្រះមហាក្សត្រ។<br>មុនចាប់ផ្តើមការងាររបស់ខ្លួន រដ្ឋសភាត្រូវប្រកាសសុពលភាព នៃអាណត្តិរបស់សមាជិកនីមួយៗ និងត្រូវបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នានូវប្រធាន អនុប្រធានរដ្ឋសភា និងសមាជិកទាំងអស់នៃគណៈកម្មការនានារបស់រដ្ឋសភា ដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល។<br>ប្រធានរដ្ឋសភាត្រូវបោះឆ្នោតជ្រើសរើសចេញពីសមាជិករដ្ឋសភា ដែលមានសញ្ជាតិខ្មែរតែមួយគត់។<br>រដ្ឋសភាត្រូវអនុម័តបទបញ្ជាផ្ទៃក្នុង ដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល។<br>តំណាងរាស្ត្រទាំងអស់ ត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់តំណែង ដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធទី៥ នៃរដ្ឋធម្មនុញ្ញ។</td></tr>
</table>

| | |
|---|---|
| **មាត្រា ១០៦.- ថ្មី(មួយ)**<br>ព្រឹទ្ធសភាបើកសម័យប្រជុំដំបូង ហុកសិបថ្ងៃយ៉ាងយូរក្រោយពេលបោះឆ្នោតតាមការកោះប្រជុំរបស់ព្រះមហាក្សត្រ។<br>មុនចាប់ផ្តើមការងាររបស់ខ្លួន ព្រឹទ្ធសភាត្រូវប្រកាសសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗ និងត្រូវបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នា នូវប្រធាន អនុប្រធានព្រឹទ្ធសភា និងសមាជិកទាំងអស់នៃគណៈកម្មការនានារបស់ព្រឹទ្ធសភា ដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិក ព្រឹទ្ធសភាទាំងមូល។<br>សមាជិកព្រឹទ្ធសភាទាំងអស់ ត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់ដំណែង ដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធទី ៧ នៃរដ្ឋធម្មនុញ្ញ។ | **មាត្រា ១០៦.- ថ្មី(ពីរ)**<br>ព្រឹទ្ធសភាបើកសម័យប្រជុំដំបូង ហុកសិបថ្ងៃយ៉ាងយូរក្រោយពេលបោះឆ្នោត តាមការកោះប្រជុំរបស់ព្រះមហាក្សត្រ។<br>មុនចាប់ផ្តើមការងាររបស់ខ្លួន ព្រឹទ្ធសភាត្រូវប្រកាសសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗ និងត្រូវបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នា នូវប្រធាន អនុប្រធានព្រឹទ្ធសភា និងសមាជិកទាំងអស់នៃគណៈកម្មការនានារបស់ព្រឹទ្ធសភា ដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។<br>ប្រធានព្រឹទ្ធសភាត្រូវជ្រើសរើសចេញពីសមាជិកព្រឹទ្ធសភា ដែលមានសញ្ជាតិខ្មែរតែមួយគត់។<br>សមាជិកព្រឹទ្ធសភាទាំងអស់ ត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់ដំណែង ដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធទី ៧ នៃរដ្ឋធម្មនុញ្ញ។ |
| **មាត្រា ១១៩.- ថ្មី (មាត្រា ១០០ ចាស់)**<br>តាមសេចក្តីស្នើពីប្រធាន ដោយមានមតិឯកភាពពីអនុប្រធានទាំងពីរនៃរដ្ឋសភា ព្រះមហាក្សត្រទ្រង់ចាត់តាំងវរជនមួយរូប ក្នុងចំណោមតំណាងរាស្ត្រនៃគណបក្សដែលឈ្នះឆ្នោត អោយបង្កើតរាជរដ្ឋាភិបាល។ វរជនដែលត្រូវបានចាត់តាំងនេះ នាំសហការីដែលជាតំណាងរាស្ត្រ ឬជាសមាជិកគណបក្សតំណាងនៅក្នុងរដ្ឋសភា ដែលផ្ទួរផ្ទងអោយកាន់តំណែងផ្សេងៗក្នុងរាជរដ្ឋាភិបាលទៅសុំសេចក្តីទុកចិត្តពីរដ្ឋសភា។ កាលបើរដ្ឋសភាបានបោះឆ្នោតទុកចិត្តហើយនោះ ព្រះមហាក្សត្រទ្រង់ចេញព្រះរាជក្រឹត្យតែងតាំងគណៈរដ្ឋមន្ត្រីទាំងមូល។ | **មាត្រា ១១៩.- ថ្មី(មួយ)**<br>តាមសេចក្តីស្នើពីប្រធាន ដោយមានមតិឯកភាពពីអនុប្រធានទាំងពីរនៃរដ្ឋសភា ព្រះមហាក្សត្រទ្រង់ចាត់តាំងវរជនមួយរូបជានាយករដ្ឋមន្ត្រី ពីក្នុងចំណោមតំណាងរាស្ត្រនៃគណបក្សដែលមានអាសនៈច្រើនជាងគេនៅក្នុងរដ្ឋសភា ឱ្យបង្កើតរាជរដ្ឋាភិបាល។ វរជនដែលនឹងត្រូវទទួលបានការចាត់តាំងជានាយករដ្ឋមន្ត្រីនេះ ត្រូវតែជាតំណាងរាស្ត្រដែលមានសញ្ជាតិខ្មែរតែមួយគត់។ វរជនដែលត្រូវបានចាត់តាំងនេះ នាំសហការីដែលជាតំណាងរាស្ត្រ ឬជាសមាជិកគណបក្សតំណាងនៅក្នុងរដ្ឋសភា ដែលផ្ទួរផ្ទងឱ្យកាន់តំណែងផ្សេងៗក្នុងរាជរដ្ឋាភិបាល ទៅសុំសេចក្តីទុកចិត្តពីរដ្ឋសភា។ កាលបើ |

| | |
|---|---|
| មុនចូលកាន់តំណែង គណៈរដ្ឋមន្ត្រីត្រូវធ្វើសច្ចាប្រណិធាន ដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធ ៦។ | រដ្ឋសភាបានបោះឆ្នោតទុកចិត្តហើយនោះ ព្រះមហាក្សត្រទ្រង់ចេញព្រះរាជក្រឹត្យ តែងតាំងគណៈរដ្ឋមន្ត្រីទាំងមូល។<br>មុនចូលកាន់តំណែង គណៈរដ្ឋមន្ត្រីត្រូវធ្វើសច្ចាប្រណិធាន ដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធទី ៦។ |
| **មាត្រា ១៣៧.- ថ្មី (មាត្រា ១១៨ ចាស់)**<br>ក្រុមប្រឹក្សាធម្មនុញ្ញមានសមាជិកប្រាំបួនរូប ដែលទទួលអាណត្តិប្រាំបួនឆ្នាំ។ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញចំនួនមួយភាគបីត្រូវផ្លាស់ថ្មីក្នុងរយៈពេលបីឆ្នាំម្តង បីឆ្នាំម្តង។ សមាជិកបីរូបត្រូវតែងតាំងដោយព្រះមហាក្សត្រ បីរូបត្រូវជ្រើសតាំងដោយរដ្ឋសភា ហើយបីរូបទៀតត្រូវតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។<br>ប្រធានត្រូវបានជ្រើសតាំងដោយសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ។ ប្រធានមានសំឡេងឧត្តមានុភាពក្នុងករណីបែកសំឡេងជាពីរស្មើគ្នា។ | **មាត្រា ១៣៧.- ថ្មី(មួយ)**<br>ក្រុមប្រឹក្សាធម្មនុញ្ញមានសមាជិកប្រាំបួនរូប ដែលទទួលអាណត្តិប្រាំបួនឆ្នាំ។ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញចំនួនមួយភាគបីត្រូវផ្លាស់ថ្មីក្នុងរយៈពេលបីឆ្នាំម្តង បីឆ្នាំម្តង។ សមាជិកបីរូបត្រូវតែងតាំងដោយព្រះមហាក្សត្រ បីរូបត្រូវជ្រើសតាំងដោយរដ្ឋសភា ហើយបីរូបទៀតត្រូវតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។<br>ប្រធានត្រូវបានជ្រើសតាំងដោយសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ពីក្នុងចំណោមសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ដែលមានសញ្ញាតិខ្មែរពីកំណើត និងមានសញ្ញាតិខ្មែរតែមួយគត់។ ប្រធានមានសំឡេងឧត្តមានុភាពក្នុងករណីបែកសំឡេងជាពីរស្មើគ្នា។ |

- ❖ មាត្រា៣និងមាត្រា៤ នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ ត្រូវបានធ្វើវិសោធនកម្ម ដូចតទៅ៖

| **មាត្រាចាស់** | **មាត្រាថ្មី** |
|---|---|
| **មាត្រា ៣.-**<br>ក្នុងករណីដែលឃើញថានីតិវិធីនៃមាត្រា ៨២ និងមាត្រា១១៩ ថ្មី នៃរដ្ឋធម្មនុញ្ញមិនអាចសំរេចបាន រដ្ឋសភា តាមសំណើររបស់គណបក្សដែលមានអាសនៈច្រើនជាងគេនៅក្នុងរដ្ឋសភាអាចដំណើរការការបោះឆ្នោតជាកញ្ចប់ ដើម្បីជ្រើសតាំងប្រធាន អនុប្រធានរដ្ឋសភា ក៏ដូចជាប្រធាន និងអនុប្រធានគណៈកម្មការក្នុង | **មាត្រា ៣.- ថ្មី**<br>ក្នុងករណីដែលឃើញថានីតិវិធីនៃមាត្រា ៨២ ថ្មី(មួយ) និងមាត្រា១១៩ ថ្មី(មួយ) នៃរដ្ឋធម្មនុញ្ញមិនអាចសម្រេចបាន រដ្ឋសភា តាមសំណើរបស់គណបក្សដែលមានអាសនៈច្រើនជាងគេនៅក្នុងរដ្ឋសភាអាចដំណើរការការបោះឆ្នោតជាកញ្ចប់ ដើម្បីជ្រើសតាំងប្រធាន អនុប្រធានរដ្ឋសភា ក៏ដូចជាប្រធាន និងអនុប្រធានគណៈកម្មការក្នុងពេល |

| | |
|---|---|
| ពេលជាមួយគ្នានឹងការផ្តល់សេចក្តីទុកចិត្ត ចំពោះរាជរដ្ឋាភិបាល។ | ជាមួយគ្នានឹងការផ្តល់សេចក្តីទុកចិត្តចំពោះរាជរដ្ឋាភិបាល។ |
| **មាត្រា ៩.-**<br>ការរៀបចំបញ្ជីរាយនាមសមាសភាព ដើម្បីបោះឆ្នោតជ្រើសតាំង និងផ្តល់សេចក្តីទុកចិត្ត ត្រូវអនុវត្តដូចតទៅ:<br>-បញ្ជីរាយនាមបេក្ខជនប្រធាន អនុប្រធាននៃរដ្ឋសភា ក៏ដូចជា ប្រធាន និងអនុប្រធានគណៈកម្មការជំនាញទាំងអស់នៃរដ្ឋសភា ត្រូវរៀបចំនិងស្នើដោយគណបក្សនយោបាយដែលព្រមព្រៀងគ្នា ដើម្បីបង្កើតរាជរដ្ឋាភិបាលចំរុះ ហើយត្រូវផ្ញើជូនព្រឹទ្ធសមាជិករដ្ឋសភា។<br>-តាមសេចក្តីស្នើពីគណបក្សនយោបាយដែលមានចំនួនអាសនៈច្រើនជាងគេ នៅក្នុងរដ្ឋសភា តាមរយៈព្រឹទ្ធសមាជិករដ្ឋសភា ព្រះមហាក្សត្រទ្រង់ចាត់តាំងវរជនមួយរូប ក្នុងចំណោមតំណាងរាស្ត្រ នៃគណបក្សនយោបាយដែលឈ្នះឆ្នោតអោយបង្កើតរាជរដ្ឋាភិបាល។<br>វរជនដែលត្រូវចាត់តាំងនេះ ត្រូវរៀបចំផ្គូរផ្គងតំណែងផ្សេងៗ ក្នុងរាជរដ្ឋាភិបាលរួចផ្ញើបញ្ជីរាយនាម សមាជិកទាំងអស់នៃរាជរដ្ឋាភិបាលជូនព្រឹទ្ធសមាជិករដ្ឋសភា។<br>-ព្រឹទ្ធសមាជិករដ្ឋសភាត្រូវរៀបចំបញ្ជីរាយនាមជាកញ្ចប់មួយនូវបេក្ខជន ប្រធាន និងអនុប្រធាននៃរដ្ឋសភា ក៏ដូចជាប្រធាន និង អនុប្រធានគណៈកម្មការជំនាញទាំងអស់នៃរដ្ឋសភា ព្រមទាំងបេក្ខជន នាយករដ្ឋមន្ត្រី និង សមាជិកទាំងអស់នៃរាជរដ្ឋាភិបាល ដើម្បីដាក់ជូនរដ្ឋសភាបោះឆ្នោត។ | **មាត្រា ៩.- ថ្មី**<br>ការរៀបចំបញ្ជីរាយនាមសមាសភាព ដើម្បីបោះឆ្នោតជ្រើសតាំង និងផ្តល់សេចក្តីទុកចិត្ត ត្រូវអនុវត្តដូចតទៅៈ<br>-បញ្ជីរាយនាមសមាសភាពប្រធាន និងអនុប្រធាននៃរដ្ឋសភា ក៏ដូចជា ប្រធាន និងអនុប្រធានគណៈកម្មការជំនាញទាំងអស់នៃរដ្ឋសភា ត្រូវរៀបចំនិងស្នើដោយគណបក្សនយោបាយដែលព្រមព្រៀងគ្នា ដើម្បីបង្កើតរាជរដ្ឋាភិបាលចម្រុះ ហើយត្រូវផ្ញើជូនព្រឹទ្ធសមាជិករដ្ឋសភា។ ប្រធានរដ្ឋសភា ត្រូវជ្រើសរើសចេញពីសមាជិករដ្ឋសភាដែលមានសញ្ជាតិខ្មែរតែមួយគត់។<br>-តាមសេចក្តីស្នើពីគណបក្សនយោបាយដែលមានចំនួនអាសនៈច្រើនជាងគេ នៅក្នុងរដ្ឋសភាតាមរយៈព្រឹទ្ធសមាជិករដ្ឋសភា ព្រះមហាក្សត្រទ្រង់ចាត់តាំងវរជនមួយរូបជានាយករដ្ឋមន្ត្រីពីក្នុងចំណោមតំណាងរាស្ត្រនៃគណបក្សនយោបាយដែលមានចំនួនអាសនៈច្រើនជាងគេនៅក្នុងរដ្ឋសភាឱ្យបង្កើតរាជរដ្ឋាភិបាល។ វរជនដែលនឹងត្រូវទទួលបានការចាត់តាំងជានាយករដ្ឋមន្ត្រីនេះ ត្រូវតែជាតំណាងរាស្ត្រ ដែលមានសញ្ជាតិខ្មែរតែមួយគត់។ វរជនដែលត្រូវបានចាត់តាំងនេះ ត្រូវរៀបចំផ្គូរផ្គងតំណែងផ្សេងៗ ក្នុងរាជរដ្ឋាភិបាល រួចផ្ញើបញ្ជីរាយនាមសមាជិកទាំងអស់នៃរាជរដ្ឋាភិបាលជូនព្រឹទ្ធសមាជិករដ្ឋសភា។<br>-ព្រឹទ្ធសមាជិករដ្ឋសភាត្រូវរៀបចំបញ្ជីរាយនាមជាកញ្ចប់មួយនូវសមាសភាពប្រធាន និងអនុប្រធាននៃរដ្ឋសភា ក៏ដូចជាប្រធាន និងអនុប្រធានគណៈកម្មការជំនាញទាំងអស់នៃរដ្ឋសភា ព្រម |

| | |
|---|---|
| | ទាំងនាយករដ្ឋមន្ត្រីដែលត្រូវបានចាត់តាំងដោយព្រះមហាក្សត្រ និងសមាជិកទាំងអស់នៃរាជរដ្ឋាភិបាល ដើម្បីដាក់ជូនរដ្ឋសភាបោះឆ្នោត។ |

## វិសោធនកម្មលើកទី១០ (២០២២)

ច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា១៩ ថ្មី (មួយ) មាត្រា៨៩ មាត្រា៩៨ ថ្មី មាត្រា១០២ ថ្មី មាត្រា១១៩ ថ្មី (មួយ) និងមាត្រា១២៥ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា៣ ថ្មី និងមាត្រា៤ ថ្មី នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ ត្រូវបានរដ្ឋសភាអនុម័តកាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២២ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់ទាំងស្រុងកាលពីថ្ងៃទី៥ ខែសីហា ឆ្នាំ២០២២ នាសម័យប្រជុំពេញអង្គលើកទី៩ នីតិកាលទី៤។ ច្បាប់ធម្មនុញ្ញនេះត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៨២២/០០៧ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០២២។ វិសោធនកម្មលើកទី១០នេះ ត្រូវបានធ្វើឡើងដើម្បីធានាឱ្យស្ថាប័ននីតិប្រតិបត្តិមានដំណើរការប្រព្រឹត្តទៅយ៉ាងរលូននិងប្រកបដោយនិរន្តរភាព និងការធានាការពារ និងថែរក្សាឱ្យបាននូវសន្តិភាព សន្តិសុខសង្គម សណ្តាប់ធ្នាប់សាធារណៈ និងស្ថិរភាពនយោបាយរបស់ប្រទេសជាតិនៅគ្រប់កាលៈទេសៈ។

យោងលិខិតលេខ៦២៥ លស របស់រាជរដ្ឋាភិបាលកម្ពុជា ក្រាបបង្គំទូលថ្វាយ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** ចុះថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០២២ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានទូលថ្វាយថា "*ទូលព្រះបង្គំជាខ្ញុំ ដោយអនុលោមតាមមាត្រា១៥៣ ថ្មី(ពីរ) នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងក្នុងឋានៈជានាយករដ្ឋមន្ត្រី បានផ្តួចផ្តើមធ្វើវិសោធនកម្មមាត្រា១៩ ថ្មី(មួយ) មាត្រា៨៩ មាត្រា៩៨ ថ្មី មាត្រា១០២ ថ្មី មាត្រា១១៩ ថ្មី(មួយ) និងមាត្រា១២៥ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា៣ ថ្មី និងមាត្រា៤ ថ្មី នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ។ ការស្នើសុំធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជានេះ គឺធ្វើឡើងក្នុងគោលបំណងធានានូវគោលដៅសំខាន់របស់ជាតិចំនួនពីរ៖ (ទី១)- ការធានាឱ្យស្ថាប័នកំពូលរបស់ជាតិ ជាពិសេសអំណាចនីតិប្រតិបត្តិដែលមានបេសកកម្មចម្បងក្នុងការដឹកនាំការងារទូទៅរបស់រដ្ឋ មានដំណើរការប្រព្រឹត្តទៅដោយរលូន និងប្រកបដោយនិរន្តរភាពនៅគ្រប់កាលៈទេសៈ និង (ទី២)- ការធានាការពារ និងថែរក្សាឱ្យបាននូវសន្តិភាព សន្តិសុខសង្គម សណ្តាប់ធ្នាប់សាធារណៈ និងស្ថិរភាពនយោបាយរបស់*

*ប្រទេសជាតិនៅគ្រប់កាលៈទេសៈដើម្បីជាគ្រឹះសម្រាប់ការអភិវឌ្ឍប្រទេសជាតិលើគ្រប់វិស័យ និងសេចក្ដីសុខសាន្តរបស់ប្រជាជនកម្ពុជា"។*[១៥]

យោងសេចក្តីថ្លែងហេតុលេខ១១ សជណ.កបច របស់រាជរដ្ឋាភិបាល ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២២ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានគូសបញ្ជាក់ថា *"បន្ថែមពីនេះ ការស្នើធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញលើកនេះ ក៏ធានាបាននូវការគោរពគោលការណ៍គ្រឹះនៃរបបរាជានិយមអាស្រ័យដោយរដ្ឋធម្មនុញ្ញ ដែលជារបបដឹកនាំប្រទេសតាមបែបសភានិយម ព្រមទាំងជាការលើកកម្ពស់នូវគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ដែលប្រជាជនកម្ពុជាបង្ហាញឆន្ទៈ និងប្រើសិទ្ធិអំណាចរបស់ខ្លួនតាមរយៈការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលប្រព្រឹត្តទៅរៀងរាល់ ៥ ឆ្នាំម្តង ប្រកបដោយលក្ខណៈសេរី ត្រឹមត្រូវ និងយុត្តិធម៌ ស្របតាមគោលការណ៍ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ព្រមទាំងច្បាប់ និងបទដ្ឋានគតិយុត្តជាធរមានរបស់ជាតិ"* ។[១៦]

សរុបមក វិសោធនកម្មលើកទី១០នេះ មានគោលបំណងធានាឱ្យស្ថាប័នកំពូលរបស់ជាតិ ជាពិសេសអំណាចនីតិប្រតិបត្តិ អាចដំណើរការបានយ៉ាងរលូន និងប្រកបដោយនិរន្តរភាពនៅគ្រប់កាលៈទេសៈ។ ការកែប្រែមាត្រាមួយចំនួននៃរដ្ឋធម្មនុញ្ញ និងច្បាប់ធម្មនុញ្ញបន្ថែមនេះ ក៏មានបំណងពង្រឹងការការពារ និងថែរក្សាសន្តិភាព សន្តិសុខសង្គម សណ្តាប់ធ្នាប់សាធារណៈ និងស្ថិរភាពនយោបាយរបស់ប្រទេសជាតិ។ លើសពីនេះ វិសោធនកម្មនេះក៏មានន័យថាជាការគោរព និងលើកកម្ពស់គោលការណ៍គ្រឹះនៃរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ និងលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ដែលប្រជាជនអនុវត្តសិទ្ធិអំណាចរបស់ខ្លួនតាមរយៈការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។

## ខ្លឹមសារមាត្រាចាស់ និងមាត្រាថ្មី

| | |
|---|---|
| ❖ មាត្រា១៩ ថ្មី(មួយ) មាត្រា៨៩ មាត្រា៩៨ ថ្មី មាត្រា១០២ ថ្មី មាត្រា១១៩ ថ្មី(មួយ) និងមាត្រា ១២៥ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានធ្វើវិសោធនកម្ម ដូចតទៅ៖ | |
| **មាត្រាចាស់** | **មាត្រាថ្មី** |
| **មាត្រា ១៩.- ថ្មី (មួយ)** | **មាត្រា ១៩.- ថ្មី (ពីរ)** |

[១៥] លិខិតលេខ៦២៥ លស របស់រាជរដ្ឋាភិបាលកម្ពុជា ក្រាបបង្គំទូលថ្វាយ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** ចុះថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០២២

[១៦] សេចក្តីថ្លែងហេតុលេខ១១ សជណ.កបច របស់រាជរដ្ឋាភិបាល ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២២

| | |
|---|---|
| ព្រះមហាក្សត្រទ្រង់តែងតាំងនាយករដ្ឋមន្ត្រីនិងទ្រង់តែងតាំងគណៈរដ្ឋមន្ត្រីតាមបែបបទដែលមានចែងក្នុងមាត្រា ១១៩ ថ្មី(មួយ)។ | ព្រះមហាក្សត្រទ្រង់តែងតាំងនាយករដ្ឋមន្ត្រី និងទ្រង់តែងតាំងគណៈរដ្ឋមន្ត្រី តាមបែបបទដែលមានចែងក្នុងមាត្រា១១៩ ថ្មី(ពីរ)។ |
| **មាត្រា ៨៩.-**<br>តាមការសុំពីសមាជិកចំនួនមួយភាគដប់យ៉ាងតិច រដ្ឋសភាអាចអញ្ជើញឥស្សរជនដ៏ឧត្តមណាមួយ មកបំភ្លឺរដ្ឋសភាអំពីបញ្ហាដែលមានសារៈសំខាន់ពិសេស។ | **មាត្រា ៨៩.- ថ្មី**<br>តាមការសុំពីសមាជិកចំនួនមួយភាគដប់យ៉ាងតិច រដ្ឋសភាអាចអញ្ជើញសមាជិករាជរដ្ឋាភិបាល មួយរូប ឬច្រើនរូប អមដោយឥស្សរជនជាអ្នកជំនាញក្នុងវិស័យណាមួយ មកបំភ្លឺរដ្ឋសភាអំពីបញ្ហាដែលមានសារៈសំខាន់ពិសេស។ |
| **មាត្រា ៩៨.- ថ្មី**<br>រដ្ឋសភាអាចទម្លាក់សមាជិកគណៈរដ្ឋមន្ត្រី ឬ ទម្លាក់រាជរដ្ឋាភិបាលពីតំណែង ដោយអនុម័តញត្តិបន្ទោស តាមសំឡេងឆ្នោតភាគច្រើនដាច់ខាត នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។<br>ញត្តិបន្ទោសរាជរដ្ឋាភិបាល ត្រូវបានលើកឡើងជូនរដ្ឋសភាដោយតំណាងរាស្ត្រចំនួនសាមសិបនាក់ ទើបរដ្ឋសភាអាចលើកមកពិភាក្សាបាន។ | **មាត្រា ៩៨.- ថ្មី(មួយ)**<br>រដ្ឋសភាអាចទម្លាក់សមាជិកគណៈរដ្ឋមន្ត្រី ឬទម្លាក់រាជរដ្ឋាភិបាលពីតំណែង ដោយអនុម័តញត្តិបន្ទោស តាមសំឡេងឆ្នោតភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល។ ក្នុងករណីដែលរាជរដ្ឋាភិបាលត្រូវបានទម្លាក់ពីមុខតំណែងដោយរដ្ឋសភា រាជរដ្ឋាភិបាលដែលត្រូវចេញពីមុខតំណែងនេះ មានតែភារកិច្ចដឹកនាំការងារប្រចាំថ្ងៃតែប៉ុណ្ណោះ រហូតដល់មានរាជរដ្ឋាភិបាលថ្មីចូលកាន់តំណែង។<br>ញត្តិបន្ទោសរាជរដ្ឋាភិបាល ត្រូវបានលើកឡើងជូនរដ្ឋសភាដោយតំណាងរាស្ត្រ ចំនួនមួយភាគបីនៃចំនួនសមាជិករដ្ឋសភាទាំងមូល ទើបរដ្ឋសភាអាចលើកមកពិភាក្សាបាន។ |
| **មាត្រា ១០២.- ថ្មី**<br>នីតិកាលរបស់ព្រឹទ្ធសភាមានកំណត់ ៦ ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលដែលព្រឹទ្ធសភាថ្មីចូលកាន់តំណែង។<br>ក្នុងពេលមានសង្គ្រាម ឬ ក្នុងកាលៈទេសៈពិសេសដទៃទៀត ដែលមិនអាចធ្វើការបោះឆ្នោតកើត ព្រឹទ្ធសភាអាចប្រកាសបន្តនីតិកាល | **មាត្រា ១០២.- ថ្មី(មួយ)**<br>នីតិកាលរបស់ព្រឹទ្ធសភាមានកំណត់ ៦ ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលដែលព្រឹទ្ធសភាថ្មីចូលកាន់តំណែង។<br>ក្នុងពេលមានសង្គ្រាម ឬក្នុងកាលៈទេសៈពិសេសដទៃទៀត ដែលមិនអាចធ្វើការបោះឆ្នោតកើត ព្រឹទ្ធសភាអាចប្រកាសបន្តនីតិកាល |

| | |
|---|---|
| របស់ខ្លួនមួយដងបានមួយឆ្នាំ តាមសំណើរបស់ព្រះមហាក្សត្រ។<br>ការប្រកាសបន្តនីតិកាលរបស់ព្រឹទ្ធសភាត្រូវសំរេចដោយមតិយល់ព្រមពីរភាគបីយ៉ាងតិចនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។<br>ក្នុងកាលៈទេសៈដូចបានរៀបរាប់ខាងលើ ព្រឹទ្ធសភាប្រជុំរាល់ថ្ងៃជាប់ជាប្រចាំ។ ព្រឹទ្ធសភាមានសិទ្ធិសំរេចបញ្ចប់កាលៈទេសៈពិសេសខាងលើនេះ កាលបើសភាពការណ៍អនុញ្ញាត ។<br>បើព្រឹទ្ធសភាមិនអាចប្រជុំបានទេ ដោយមូលហេតុចាំបាច់ ជាអាទិ៍នៅពេលដែលកំលាំងបរទេសចូលមកកាន់កាប់ទឹកដី ការប្រកាសភាពអាសន្នត្រូវបន្តទៅមុខជាស្វ័យប្រវត្តិ។ | របស់ខ្លួនមួយដងបានមួយឆ្នាំ តាមសំណើរបស់ព្រះមហាក្សត្រ។<br>ការប្រកាសបន្តនីតិកាលរបស់ព្រឹទ្ធសភាត្រូវសម្រេចដោយមតិយល់ព្រមពីរភាគបីយ៉ាងតិច នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។<br>ក្នុងកាលៈទេសៈដូចបានរៀបរាប់ខាងលើ ព្រឹទ្ធសភាប្រជុំរាល់ថ្ងៃជាប់ជាប្រចាំ។ ព្រឹទ្ធសភាមានសិទ្ធិសម្រេចបញ្ចប់កាលៈទេសៈពិសេសខាងលើនេះ កាលបើសភាពការណ៍អនុញ្ញាត។ ប៉ុន្តែការសម្រេចបញ្ចប់កាលៈទេសៈពិសេសដែលប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ព្រឹទ្ធសភាត្រូវសម្រេចរួមគ្នាជាមួយរដ្ឋសភា ក្នុងសមាជរដ្ឋសភា និងព្រឹទ្ធសភា វៀរលែងតែការអនុវត្តមាត្រា៨៦ នៃរដ្ឋធម្មនុញ្ញ។<br>បើព្រឹទ្ធសភាមិនអាចប្រជុំបានទេ ដោយមូលហេតុចាំបាច់ ជាអាទិ៍ នៅពេលដែលកម្លាំងបរទេសចូលមកកាន់កាប់ទឹកដី ការប្រកាសភាពអាសន្នត្រូវបន្តទៅមុខជាស្វ័យប្រវត្តិ។ |
| **មាត្រា ១១៩.- ថ្មី(មួយ)**<br>តាមសេចក្តីស្នើពីប្រធាន ដោយមានមតិឯកភាពពីអនុប្រធានទាំងពីរនៃរដ្ឋសភា ព្រះមហាក្សត្រទ្រង់ចាត់តាំងវរជនមួយរូបជានាយករដ្ឋមន្ត្រី ពីក្នុងចំណោមតំណាងរាស្ត្រនៃគណបក្សដែលមានអាសនៈច្រើនជាងគេនៅក្នុងរដ្ឋសភា ឱ្យបង្កើតរាជរដ្ឋាភិបាល។ វរជនដែលនឹងត្រូវទទួលបានការចាត់តាំងជានាយករដ្ឋមន្ត្រីនេះ ត្រូវតែជាតំណាងរាស្ត្រដែលមានសញ្ជាតិខ្មែរតែមួយគត់។ វរជនដែលត្រូវបានចាត់តាំងនេះ នាំសហការីដែលជាតំណាងរាស្ត្រ ឬជាសមាជិកគណបក្សតំណាងនៅក្នុងរដ្ឋសភា ដែលផ្តូរផ្តងឱ្យកាន់តំណែងផ្សេងៗក្នុងរាជរដ្ឋាភិបាល ទៅសុំ | **មាត្រា ១១៩.- ថ្មី(ពីរ)**<br>តាមសេចក្តីស្នើពីគណបក្សដែលមានអាសនៈច្រើនជាងគេក្នុងរដ្ឋសភា ព្រះមហាក្សត្រទ្រង់ចាត់តាំងវរជនមួយរូបជានាយករដ្ឋមន្ត្រី ឱ្យបង្កើតរាជរដ្ឋាភិបាល។ សេចក្តីស្នើពីគណបក្សដែលមានអាសនៈច្រើនជាងគេក្នុងរដ្ឋសភានេះត្រូវចម្លងជូនប្រធានរដ្ឋសភា។ វរជនដែលនឹងត្រូវទទួលបាន ការចាត់តាំងជានាយករដ្ឋមន្ត្រីនេះ ត្រូវតែជាតំណាងរាស្ត្រដែលមានសញ្ជាតិខ្មែរតែមួយគត់ និងដែលត្រូវបានជ្រើសរើសចេញពីគណបក្សដែលមានអាសនៈច្រើនជាងគេក្នុងរដ្ឋសភា។ វរជនដែលត្រូវបានចាត់តាំងនេះ នាំសហការីដែលជាតំណាងរាស្ត្រ ឬជាសមាជិកគណបក្សតំណាងនៅ |

| | |
|---|---|
| សេចក្ដីទុកចិត្តពីរដ្ឋសភា។ កាលបើរដ្ឋសភាបានបោះឆ្នោតទុកចិត្តហើយនោះ ព្រះមហាក្សត្រទ្រង់ចេញព្រះរាជក្រឹត្យ តែងតាំងគណៈរដ្ឋមន្ត្រីទាំងមូល។<br>មុនចូលកាន់តំណែង គណៈរដ្ឋមន្ត្រីត្រូវធ្វើសច្ចាប្រណិធាន ដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធទី ៦។ | ក្នុងរដ្ឋសភាដែលផ្ដួចផ្ដើមឱ្យកាន់តំណែងផ្សេងៗក្នុងរាជរដ្ឋាភិបាល ទៅសុំសេចក្ដីទុកចិត្តពីរដ្ឋសភា។ ការបោះឆ្នោតផ្ដល់សេចក្ដីទុកចិត្តនេះ ត្រូវធ្វើលើបញ្ជីសមាសភាពនៃគណៈរដ្ឋមន្ត្រីទាំងមូល។ កាលបើរដ្ឋសភាបានបោះឆ្នោតទុកចិត្តហើយនោះព្រះមហាក្សត្រទ្រង់ចេញព្រះរាជក្រឹត្យតែងតាំងគណៈរដ្ឋមន្ត្រីទាំងមូល។<br>មុនចូលកាន់តំណែង គណៈរដ្ឋមន្ត្រីត្រូវធ្វើសច្ចាប្រណិធានដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធទី៦។<br>នៅពេលផុតនីតិកាលនីមួយៗរបស់រដ្ឋសភា រាជរដ្ឋាភិបាលដែលត្រូវចេញពីតំណែង មានតែភារកិច្ចដឹកនាំការងារប្រចាំថ្ងៃតែប៉ុណ្ណោះ រហូតដល់មានរាជរដ្ឋាភិបាលថ្មីចូលកាន់តំណែង។ |
| **មាត្រា ១២៥.- ថ្មី (មាត្រា ១០៦ ចាស់)**<br>បើតំណែងនាយករដ្ឋមន្ត្រីនៅទំនេរជាស្ថាពរនោះ ត្រូវតែងតាំងគណៈរដ្ឋមន្ត្រីមួយជាថ្មីក្នុងលក្ខខ័ណ្ឌដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនេះ។ បើការទំនេរនេះជាការទំនេរមួយកាលមួយគ្រាទេ ត្រូវចាត់តាំងនាយករដ្ឋមន្ត្រីស្ដីទីជាបណ្ដោះអាសន្ន។ | **មាត្រា ១២៥.- ថ្មី(មួយ)**<br>ក្នុងករណីដែលនាយករដ្ឋមន្ត្រីអវត្តមានមួយកាលមួយគ្រា នាយករដ្ឋមន្ត្រីត្រូវចាត់តាំងឧបនាយករដ្ឋមន្ត្រីមួយរូប ឱ្យធ្វើជានាយករដ្ឋមន្ត្រីស្ដីទីដើម្បីទទួលភារកិច្ចដឹកនាំគណៈរដ្ឋមន្ត្រីជំនួសជាបណ្ដោះអាសន្ន។<br>បើតំណែងនាយករដ្ឋមន្ត្រីនៅទំនេរជាស្ថាពរ ដោយហេតុជាអាទិ៍មកពីការទទួលអនិច្ចកម្ម ឬការលាលែងពីមុខតំណែង គណៈរដ្ឋមន្ត្រីថ្មីមួយត្រូវតែងតាំងជាបន្ទាន់ ក្នុងលក្ខខណ្ឌដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនេះ។ ប្រធានរដ្ឋសភាត្រូវកោះប្រជុំរដ្ឋសភាជាបន្ទាន់ និងត្រូវធ្វើចំណាត់ការចាំបាច់ដទៃទៀត ដោយរួសរាន់ ក្នុងរយៈវេលា ៧ ថ្ងៃយ៉ាងយូរ បន្ទាប់ពីបានទទួលសំណើពីគណបក្សដែលមានអាសនៈច្រើនជាងគេក្នុងរដ្ឋសភា។ |

| | |
|---|---|
| | ក្នុងករណីតំណែងនាយករដ្ឋមន្ត្រីនៅទំនេរជាស្ថាពរ ដោយហេតុមកពីការទទួលអនិច្ចកម្ម គណៈរដ្ឋមន្ត្រីដែលត្រូវចេញពីតំណែង ក្រោមការដឹកនាំរបស់ឧបនាយករដ្ឋមន្ត្រីដែលទទួលបានការចាត់តាំងជានាយករដ្ឋមន្ត្រីស្ដីទី មានតែភារកិច្ចដឹកនាំការងារប្រចាំថ្ងៃតែប៉ុណ្ណោះ រហូតដល់មានគណៈរដ្ឋមន្ត្រីថ្មីចូលកាន់តំណែង។<br>ការលាលែងពីមុខតំណែងរបស់នាយករដ្ឋមន្ត្រី ត្រូវធ្វើឡើងតាមលិខិតលាលែងពីមុខតំណែងដែលត្រូវធ្វើថ្វាយព្រះមហាក្សត្រ និងចម្លងជូនប្រធានរដ្ឋសភា។ ក្នុងករណីនេះ គណៈរដ្ឋមន្ត្រីដែលត្រូវចេញពីតំណែង ត្រូវបន្តដឹកនាំការងាររបស់រាជរដ្ឋាភិបាល រហូតដល់គណៈរដ្ឋមន្ត្រីថ្មីចូលកាន់តំណែង។ |
| ❖ មាត្រា៣ ថ្មី និងមាត្រា៤ ថ្មី នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ ត្រូវបានធ្វើវិសោធនកម្ម ដូចតទៅ៖ | |
| **មាត្រា ៣.- ថ្មី**<br>ក្នុងករណីដែលឃើញថានីតិវិធីនៃមាត្រា ៨២ ថ្មី(មួយ) និងមាត្រា១១៩ ថ្មី(មួយ) នៃរដ្ឋធម្មនុញ្ញមិនអាចសម្រេចបាន រដ្ឋសភា តាមសំណើរបស់គណបក្សដែលមានអាសនៈច្រើនជាងគេនៅក្នុងរដ្ឋសភាអាចដំណើរការការបោះឆ្នោតជាកញ្ចប់ ដើម្បីជ្រើសតាំងប្រធាន អនុប្រធានរដ្ឋសភា ក៏ដូចជាប្រធាន និងអនុប្រធានគណៈកម្មការក្នុងពេលជាមួយគ្នានឹងការផ្ដល់សេចក្ដីទុកចិត្តចំពោះរាជរដ្ឋាភិបាល។ | **មាត្រា ៣.- ថ្មី(មួយ)**<br>ក្នុងករណីដែលឃើញថានីតិវិធីនៃមាត្រា ៨២ ថ្មី(មួយ) និងមាត្រា១១៩ ថ្មី(ពីរ) នៃរដ្ឋធម្មនុញ្ញ មិនអាចសម្រេចបាន រដ្ឋសភា តាមសំណើរបស់គណបក្សដែលមានអាសនៈច្រើនជាងគេក្នុងរដ្ឋសភា អាចដំណើរការការបោះឆ្នោតជាកញ្ចប់ ដើម្បីជ្រើសតាំងប្រធាន អនុប្រធានរដ្ឋសភា ក៏ដូចជាប្រធាន និងអនុប្រធានគណៈកម្មការក្នុងពេលជាមួយគ្នានឹងការផ្ដល់សេចក្ដីទុកចិត្តចំពោះរាជរដ្ឋាភិបាល។ |
| **មាត្រា ៤.- ថ្មី**<br>ការរៀបចំបញ្ជីរាយនាមសមាសភាពដើម្បីបោះឆ្នោតជ្រើសតាំង និងផ្ដល់សេចក្ដីទុកចិត្ត ត្រូវអនុវត្តដូចតទៅ៖ | **មាត្រា ៤.- ថ្មី(មួយ)**<br>ការរៀបចំបញ្ជីរាយនាមសមាសភាពដើម្បីបោះឆ្នោតជ្រើសតាំង និងផ្ដល់សេចក្ដីទុកចិត្ត ត្រូវអនុវត្តដូចតទៅ៖ |

| | |
|---|---|
| -បញ្ជីរាយនាមសមាសភាពប្រធាន និងអនុប្រធាននៃរដ្ឋសភា ក៏ដូចជា ប្រធាន និងអនុប្រធានគណៈកម្មការជំនាញទាំងអស់នៃរដ្ឋសភា ត្រូវរៀបចំនិងស្នើដោយគណបក្សនយោបាយដែលព្រមព្រៀងគ្នា ដើម្បីបង្កើតរាជរដ្ឋាភិបាលចម្រុះ ហើយត្រូវផ្ញើជូនព្រឹទ្ធសមាជិករដ្ឋសភា។ ប្រធានរដ្ឋសភា ត្រូវជ្រើសរើសចេញពីសមាជិករដ្ឋសភាដែលមានសញ្ជាតិខ្មែរតែមួយគត់។<br>-តាមសេចក្តីស្នើពីគណបក្សនយោបាយដែលមានចំនួនអាសនៈច្រើនជាងគេ នៅក្នុងរដ្ឋសភាតាមរយៈព្រឹទ្ធសមាជិករដ្ឋសភា ព្រះមហាក្សត្រទ្រង់ចាត់តាំងវរជនមួយរូបជានាយករដ្ឋមន្ត្រីពីក្នុងចំណោមតំណាងរាស្ត្រនៃគណបក្សនយោបាយដែលមានចំនួនអាសនៈច្រើនជាងគេនៅក្នុងរដ្ឋសភាឱ្យបង្កើតរាជរដ្ឋាភិបាល។ វរជនដែលនឹងត្រូវទទួលបានការចាត់តាំងជានាយករដ្ឋមន្ត្រីនេះ ត្រូវតែជាតំណាងរាស្ត្រ ដែលមានសញ្ជាតិខ្មែរតែមួយគត់។ វរជនដែលត្រូវបានចាត់តាំងនេះ ត្រូវរៀបចំផ្គូផ្គងតំណែងផ្សេងៗ ក្នុងរាជរដ្ឋាភិបាល រួចធ្វើបញ្ជីរាយនាមសមាជិកទាំងអស់នៃរាជរដ្ឋាភិបាលជូនព្រឹទ្ធសមាជិករដ្ឋសភា។<br>-ព្រឹទ្ធសមាជិករដ្ឋសភាត្រូវរៀបចំបញ្ជីរាយនាមជាកញ្ចប់មួយនូវសមាសភាពប្រធាន និងអនុប្រធាននៃរដ្ឋសភា ក៏ដូចជាប្រធាន និងអនុប្រធានគណៈកម្មការជំនាញទាំងអស់នៃរដ្ឋសភា ព្រមទាំងនាយករដ្ឋមន្ត្រីដែលត្រូវបានចាត់តាំងដោយព្រះមហាក្សត្រ និងសមាជិកទាំងអស់នៃរាជរដ្ឋាភិបាល ដើម្បីដាក់ជូនរដ្ឋសភាបោះឆ្នោត។ | -បញ្ជីរាយនាមសមាសភាពប្រធាន និងអនុប្រធាននៃរដ្ឋសភា ក៏ដូចជាប្រធាន និងអនុប្រធានគណៈកម្មការជំនាញទាំងអស់នៃរដ្ឋសភា ត្រូវរៀបចំនិងស្នើដោយគណបក្សនយោបាយដែលមានអាសនៈច្រើនជាងគេក្នុងរដ្ឋសភា ហើយត្រូវផ្ញើជូនព្រឹទ្ធសមាជិករដ្ឋសភា។ ប្រធានរដ្ឋសភាត្រូវជ្រើសរើសចេញពី សមាជិករដ្ឋសភាដែលមានសញ្ជាតិខ្មែរតែមួយគត់។<br>-តាមសេចក្តីស្នើពីគណបក្សនយោបាយដែលមានអាសនៈច្រើនជាងគេក្នុងរដ្ឋសភា ព្រះមហាក្សត្រទ្រង់ចាត់តាំងវរជនមួយរូបជានាយករដ្ឋមន្ត្រីឱ្យបង្កើតរាជរដ្ឋាភិបាល។ វរជនដែលនឹងត្រូវទទួលបានការចាត់តាំងជានាយករដ្ឋមន្ត្រីនេះ ត្រូវតែជាតំណាងរាស្ត្រដែលមានសញ្ជាតិខ្មែរតែមួយគត់ និងដែលត្រូវបានជ្រើសរើសចេញពីគណបក្សនយោបាយ ដែលមានអាសនៈច្រើនជាងគេក្នុងរដ្ឋសភា។ វរជនដែលត្រូវបានចាត់តាំងនេះ ត្រូវរៀបចំផ្គូផ្គងតំណែងផ្សេងៗក្នុងរាជរដ្ឋាភិបាល រួចធ្វើបញ្ជីរាយនាមសមាជិកទាំងអស់នៃរាជរដ្ឋាភិបាលជូនព្រឹទ្ធសមាជិករដ្ឋសភា។<br>-ព្រឹទ្ធសមាជិករដ្ឋសភាត្រូវរៀបចំជាបន្ទាន់ និងដោយឥតបង្អង់នូវបញ្ជីរាយនាមជាកញ្ចប់មួយដែលរួមមានសមាសភាពប្រធាន និងអនុប្រធាននៃរដ្ឋសភា ក៏ដូចជាប្រធាន និងអនុប្រធានគណៈកម្មការជំនាញទាំងអស់នៃរដ្ឋសភា ព្រមទាំងនាយករដ្ឋមន្ត្រីដែលត្រូវបានចាត់តាំងដោយព្រះមហាក្សត្រ និងសមាជិកទាំងអស់នៃរាជរដ្ឋាភិបាល ដើម្បីដាក់ជូនរដ្ឋសភាបោះឆ្នោត។ ព្រឹទ្ធសមាជិករដ្ឋសភាត្រូវដឹកនាំប្រជុំរដ្ឋសភាដើម្បីបោះឆ្នោតអនុម័តបញ្ជីនេះជាបន្ទាន់។ |

| | |
|---|---|
| | -ព្រឹទ្ធសមាជិករដ្ឋសភាត្រូវបានជ្រើសរើសដោយកំណត់យកសមាជិករដ្ឋសភា ដែលមានអាយុច្រើនជាងគេ ក្នុងចំណោមសមាជិករដ្ឋសភាទាំងអស់។ ក្នុងករណីដែលព្រឹទ្ធសមាជិករដ្ឋសភារូបនេះមិនអាចអនុវត្តការងាររបស់ខ្លួនបាន មុខតំណែងព្រឹទ្ធសមាជិករដ្ឋសភាត្រូវប្រគល់ទៅសមាជិករដ្ឋសភាដទៃទៀតដែលមានអាយុច្រើនក្នុងលំដាប់បន្តបន្ទាប់។ |

## វិសោធនកម្មលើកទី១១ (២០២៥)

ច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា៣៣ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានរដ្ឋសភាអនុម័តកាលពីថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២៥ នាសម័យប្រជុំសភាលើកទី៤ នីតិកាលទី៧ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២៥ នាសម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥។ ច្បាប់ធម្មនុញ្ញនេះ ត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧២៥/០២៩ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៥។ វិសោធនកម្មលើកទី១១នេះ ត្រូវបានធ្វើឡើងដើម្បីបើកផ្លូវឱ្យមានក្របខ័ណ្ឌគតិយុត្តគ្រប់គ្រាន់ ក្នុងការដកសញ្ជាតិខ្មែរពីពលរដ្ឋខ្មែរណាដែលប្រព្រឹត្តអំពើក្បត់ជាតិ។

យោងលិខិតរួមមួយច្បាប់របស់រដ្ឋសភា និងរាជរដ្ឋាភិបាល ក្រាបបង្គំទូលថ្វាយ **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៥ **សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី ប្រធានរដ្ឋសភា និងសម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានទូលថ្វាយថា *"ទូលព្រះបង្គំ យើងខ្ញុំ ក្នុងឋានៈជាប្រធានរដ្ឋសភា ដោយទទួលបានសេចក្តីស្នើពីតំណាងរាស្ត្រចំនួន១២៥រូប និងក្នុងឋានៈជានាយករដ្ឋមន្ត្រី បានសម្រេចផ្តួចផ្តើមគំនិតរួមគ្នាធ្វើវិសោធនកម្មមាត្រា៣៣ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីបើកផ្លូវអនុញ្ញាតឱ្យមានការរៀបចំក្របខ័ណ្ឌច្បាប់សម្រាប់ដកសញ្ជាតិខ្មែរ ពីពលរដ្ឋខ្មែរណាដែលបានប្រព្រឹត្តអំពើក្បត់ជាតិ ឬធ្វើសកម្មភាពប៉ះពាល់ធ្ងន់ធ្ងរដល់ផលប្រយោជន៍របស់ព្រះរាជាណាចក្រកម្ពុជា និងប្រជាពលរដ្ឋខ្មែរ ពិសេស អំពើឃុបឃិតជាមួយបរទេស។ ការស្នើសុំធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាត្រង់មាត្រា៣៣ នេះ គឺមានគោលបំណងដើម្បីលើកកម្ពស់ឧត្តមគតិជាតិ មនសិការស្នេហាជាតិ និងគោលជំហរស្មោះត្រង់ឥតងាករេរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប ចំពោះជាតិ*

*មាតុភូមិ និងប្រជាជនកម្ពុជានៅគ្រប់កាលៈទេសៈទាំងអស់ ពិសេស ការតម្កល់ផលប្រយោជន៍ជាតិជាធំ ដោយប្រជាពលរដ្ឋខ្មែរគ្រប់រូបមិនត្រូវធ្វើសកម្មភាពណាមួយ ទោះដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី នាំឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ព្រះរាជាណាចក្រកម្ពុជា ស្របតាមមាត្រា៤៩ ថ្មី វាក្យខណ្ឌទី២ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ ទន្ទឹមនេះ ការធ្វើវិសោធនកម្មនេះ ក៏នឹងរួមចំណែកយ៉ាងសំខាន់ក្នុងការប្រឆាំងនឹងការជ្រៀតជ្រែកពីខាងក្រៅចូលមកក្នុងកិច្ចការផ្ទៃក្នុងរបស់កម្ពុជា ពិសេស ការប្រឆាំងនឹងអំពើក្បត់ជាតិ និងអំពើឃុបឃិតគ្នាជាមួយបរទេស ដែលនឹងធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់វិស័យសន្តិសុខជាតិ និងឧត្តមប្រយោជន៍របស់ប្រទេសជាតិ និងប្រជាជនកម្ពុជា"*។[១៧]

ជាលើកដំបូងក្នុងប្រវត្តិនីតិកម្មកម្ពុជា ដែលត្រូវបានផ្តួចផ្តើមគំនិតរួមគ្នាពីរដ្ឋសភាដោយទទួលបានការស្នើពីសមាជិកសភាទាំងមូល និងពីរាជរដ្ឋាភិបាល។ វិសោធនកម្មរដ្ឋធម្មនុញ្ញលើកទី១១នេះ មានលក្ខណៈពិសេសចំនួន២ ដែលខុសប្លែកពីវិសោធនកម្មទាំង១០លើកមុនៗ ៖

***លក្ខណៈពិសេសទី១៖*** ជាការផ្តើមគំនិតរួមគ្នាពីរដ្ឋសភា និងនាយករដ្ឋមន្ត្រី។ កន្លងមកការធ្វើវិសោធនកម្មចំនួន ១០លើកមុន គឺជាការផ្តើមគំនិតដោយឡែកពីគ្នា ពេលខ្លះពីរដ្ឋសភា ហើយពេលខ្លះទៀតពីនាយករដ្ឋមន្ត្រី។

***លក្ខណៈពិសេសទី២៖*** ត្រូវបានស្នើសុំពីតំណាងរាស្ត្រទាំងមូល ដែលមានចំនួនសរុប ១២៥រូប មកពីគ្រប់គណបក្សនយោបាយ ដែលមានអាសនៈក្នុងរដ្ឋសភា ក្នុងនោះរួមមាន គណបក្សប្រជាជនកម្ពុជា និងគណបក្សហ៊្វុនស៊ិនប៉ិច។ កន្លងមក ការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ឬសេចក្តីស្នើច្បាប់ផ្សេងៗ មិនធ្លាប់មានការស្នើសុំពីសមាជិកសភាទាំងមូល ដែលមានន័យថាមកពីគ្រប់គណបក្សនយោបាយទាំងអស់ដែលមាននៅក្នុងសភាបែបនេះនោះទេ។

សរុបមក វិសោធនកម្មរដ្ឋធម្មនុញ្ញលើកទី១១នេះ គឺជាការធ្វើវិសោធនកម្មត្រង់មាត្រា៣៣ នៃរដ្ឋធម្មនុញ្ញ ដែលជាការបើកផ្លូវឱ្យមានការរៀបចំក្របខ័ណ្ឌច្បាប់សម្រាប់ដកសញ្ជាតិខ្មែរ ពីពលរដ្ឋខ្មែរណាដែលបានប្រព្រឹត្តអំពើក្បត់ជាតិ ឬធ្វើសកម្មភាពប៉ះពាល់ធ្ងន់ធ្ងរដល់ផលប្រយោជន៍របស់ព្រះរាជាណាចក្រកម្ពុជា និងប្រជាពលរដ្ឋខ្មែរ ពិសេស អំពើឃុបឃិតជាមួយបរទេស។

---

[១៧] លិខិតរួមមួយច្បាប់របស់រដ្ឋសភា និងរាជរដ្ឋាភិបាល ក្រាបបង្គំទូលថ្វាយ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៥ ដោយ សម្តេចមហារដ្ឋសភាធិការធិបតី **ឃួន សុដារី** ប្រធានរដ្ឋសភា និងសម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

# ខ្លឹមសារមាត្រាចាស់ និងមាត្រាថ្មី

| មាត្រាចាស់ | មាត្រាថ្មី |
|---|---|
| **មាត្រា ៣៣.-**<br>ប្រជាពលរដ្ឋខ្មែរ មិនអាចត្រូវបានដកសញ្ជាតិ និរទេស ឬ ចាប់បញ្ជូនខ្លួនទៅឱ្យប្រទេសក្រៅណាមួយឡើយ លើកលែងតែមានកិច្ចព្រមព្រៀងជាមួយគ្នាទៅវិញទៅមក។<br>ប្រជាពលរដ្ឋខ្មែរដែលកំពុងរស់នៅឯបរទេសត្រូវបានរដ្ឋគាំពារ។<br>ការទទួលសញ្ជាតិខ្មែរត្រូវកំណត់ក្នុងច្បាប់។ | **មាត្រា ៣៣.- ថ្មី**<br>ប្រជាពលរដ្ឋខ្មែរមិនអាចត្រូវបាននិរទេស ឬចាប់បញ្ជូនខ្លួនទៅឱ្យប្រទេសក្រៅណាមួយឡើយ លើកលែងតែមានកិច្ចព្រមព្រៀងជាមួយគ្នាទៅវិញទៅមក។<br>ប្រជាពលរដ្ឋខ្មែរដែលកំពុងរស់នៅឯបរទេសត្រូវបានរដ្ឋគាំពារ។<br>ការទទួលសញ្ជាតិខ្មែរ និងការបាត់សញ្ជាតិខ្មែរ ដោយរួមទាំងការដកសញ្ជាតិខ្មែរត្រូវកំណត់ក្នុងច្បាប់។ |

# ផ្នែកទី២
# ព្រះរាជក្រមប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញ
# ស្តីពីវិសោធនកម្មរដ្ឋធម្មនុញ្ញ
# នៃព្រះរាជាណាចក្រកម្ពុជា

# វិសោធនកម្មលើកទី១

## ព្រះព្រះរាជក្រម ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៩៤
## ប្រកាសឱ្យប្រើជាផ្លូវការនូវច្បាប់ស្ដីពីការកែប្រែមាត្រា២៨
## នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

# I. រដ្ឋសភា

# ច្បាប់

## ច្បាប់ ស្ដីពីការកែប្រែ មាត្រា ២៨ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

មាត្រាតែមួយៈ-មាត្រា២៨នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាត្រូវកែប្រែដូចតទៅ៖

មាត្រា ២៨ ថ្មីៈ- ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្ដលេខាលើព្រះរាជក្រមប្រកាសឲ្យប្រើរដ្ឋធម្មនុញ្ញច្បាប់ ដែលរដ្ឋសភាបានអនុម័ត និង ទ្រង់ឡាយព្រះហស្ដលេខាលើព្រះរាជក្រឹត្យតាមសេចក្ដីស្នើសុំពីគណៈរដ្ឋមន្ត្រី ។ ក្នុងពេលដែល ព្រះមហាក្សត្រប្រចួន ហើយត្រូវព្យាបាលព្រះរោគនៅបរទេសក្នុងពេលនោះ ព្រះមហាក្សត្រមានសិទ្ធិផ្ទេរអំណាចព្រះហស្ដលេខា នៅលើព្រះរាជក្រម ឬ ព្រះរាជក្រឹត្យខាងលើនេះទៅប្រមុខរដ្ឋស្ដីទីចុះហត្ថលេខាជំនួសដោយ ព្រះរាជសារ ប្រគល់សិទ្ធិ ។

ច្បាប់នេះត្រូវបានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
អនុម័តនៅថ្ងៃ១៤ ខែកក្កដា ឆ្នាំ ១៩៩៤
នាសម័យប្រជុំវិសាមញ្ញសម័យពិសេស
ភ្នំពេញថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ ១៩៩៤

ប្រធានរដ្ឋសភាស្ដីទី
ហត្ថលេខា និង ត្រា
ឡូយ ស៊ីមឈាង

# II ខុទ្ទកាល័យព្រះមហាក្សត្រ

## ព្រះរាជក្រម

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

យោងតាមមាត្រាទី១១ ជំពូកទី២ ស្តីអំពី ព្រះមហាក្សត្រ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រ កម្ពុជា ដែលត្រូវបានសភាធម្មនុញ្ញអនុម័ត នៅថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ១៩៩៣

បង្គាប់

មាត្រា ១ : ប្រកាសឲ្យប្រើជាផ្លូវការ នូវច្បាប់ស្តីពីការកែប្រែមាត្រា ២៨ នៃ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័ត នៅថ្ងៃទី១៤ ខែ កក្កដា ឆ្នាំ១៩៩៤ ។

មាត្រា ២ : ព្រះរាជក្រមនេះចូលជាធរមានច្បាប់ ចាប់ពីពេលចុះហត្ថលេខានេះតទៅ ។

*ធ្វើនៅព្រះរាជធានីភ្នំពេញ ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ១៩៩៤*

ក្នុងព្រះបរមនាម និងតាមព្រះរាជចំណារ

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និង ត្រា

**ជា ស៊ីម**

# វិសោធនកម្មលើកទី២

## ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១
## ចុះថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៩៩
## ប្រកាសឱ្យប្រើជាផ្លូវការនូវច្បាប់ធម្មនុញ្ញស្ដីពី
## វិសោធនកម្ម មាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី៨ ដល់ជំពូកទី១៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

វិសោធនកម្មលើកទី២ត្រូវបានធ្វើឡើងស្របតាមស្មារតីនៃកិច្ចប្រជុំកំពូលរវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សហ្វ៊ុនស៊ិនប៉ិច នៅថ្ងៃទី១២-១៣ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់នៃព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។

# I- ខុទ្ទកាល័យព្រះមហាក្សត្រ

## ១-ព្រះរាជក្រម

**ព្រះរាជក្រម នស/រកម/០៣៩៩/០១**

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ រាជហរិវង្ស**

**ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និគរោត្តម**

**ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

* * * *

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានទ្រង់យល់សម័យប្រជុំវិសាមញ្ញពេញអង្គ នៃរដ្ឋសភា នៅថ្ងៃទី២-៣-៤- ខែ មីនា ឆ្នាំ ១៩៩៩

-យោងតាមសំណើរបស់ ប្រធានរដ្ឋសភា ចុះថ្ងៃទី ៦ ខែ មីនា ឆ្នាំ ១៩៩៩

**ត្រាស់បង្គាប់**

មាត្រា ១ .- ប្រកាសអោយប្រើជាផ្លូវការ នូវច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្ម មាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រា ទាំងឡាយ នៃជំពូកទី៨ ដល់ជំពូកទី១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័ត នៅថ្ងៃទី៤ ខែ មីនា ឆ្នាំ ១៩៩៩

មាត្រា ២ .- ព្រះរាជក្រមនេះចូលជាធរមានច្បាប់ ចាប់ពីពេលឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅថ្ងៃទី ៨ ខែ មីនា ឆ្នាំ ១៩៩៩

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

★★★

# ច្បាប់ធម្មនុញ្ញ

## ស្តីពី

## វិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣

## និង

## មាត្រាទាំងឡាយ នៃជំពូកទី ៨

## ដល់

## ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ

**មាត្រាតែមួយ .-** មាត្រា១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយ នៃជំពូកទី៨ ដល់ជំពូកទី១៤ នៃរដ្ឋធម្មនុញ្ញ ត្រូវបានកែប្រែដូចតទៅ ៖

**មាត្រា ១១.- ថ្មី**

ក្នុងករណីដែលព្រះមហាក្សត្រពុំអាចបំពេញព្រះរាជភារៈ ជាព្រះប្រមុខរដ្ឋបានដូចធម្មតាដោយព្រះអង្គប្រឈួនជាទម្ងន់ មានការបញ្ជាក់ដោយក្រុមគ្រូពេទ្យជំនាញជ្រើសរើសដោយប្រធាន ព្រឹទ្ធសភា ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រី នោះប្រធានព្រឹទ្ធសភាបំពេញភារកិច្ចប្រមុខរដ្ឋជំនួសព្រះអង្គ ក្នុងឋានៈជាព្រះរាជានុសិទ្ធិ ។

ក្នុងករណីដែលប្រធានព្រឹទ្ធសភា ពុំមានលទ្ធភាពបំពេញភារកិច្ចជា ប្រមុខរដ្ឋជំនួសព្រះមហាក្សត្រ ក្នុងឋានៈជាព្រះរាជានុសិទ្ធិ ពេលព្រះអង្គទ្រង់ប្រឈួនជាទម្ងន់ ដូចមានចែងក្នុងវាក្យខ័ណ្ឌខាងលើ ប្រធានរដ្ឋសភាជាអ្នកបំពេញភារកិច្ចនេះ ។

តំណែងជាប្រមុខរដ្ឋជំនួសព្រះមហាក្សត្រក្នុងឋានៈជាព្រះរាជានុសិទ្ធិនេះ អាចនឹងផ្ទេរឥស្សរជនផ្សេងទៀត ក្នុងករណីដូចដែលបានចែងក្នុងវាក្យខ័ណ្ឌខាងលើ តាមឋានានុក្រមដូចតទៅ :

ក- អនុប្រធានទី ១ ព្រឹទ្ធសភា

ខ- អនុប្រធានទី ១ រដ្ឋសភា

គ- អនុប្រធានទី ២ ព្រឹទ្ធសភា

ឃ-អនុប្រធានទី ២ រដ្ឋសភា

**មាត្រា ១២.- ថ្មី**

នៅពេលព្រះមហាក្សត្រទ្រង់ចូលទីវង្គត់ ប្រធានព្រឹទ្ធសភាទទួលភារកិច្ច ជាប្រមុខរដ្ឋស្តីទី ក្នុងឋានៈជាព្រះរាជានុសិទ្ធិ នៃព្រះរាជាណាចក្រកម្ពុជា ។

ក្នុងករណីដែលប្រធានព្រឹទ្ធសភាពុំមានលទ្ធភាពបំពេញភារកិច្ចជាប្រមុខរដ្ឋស្ដីទី ជំនួសព្រះមហាក្សត្រ ក្នុងពេលព្រះអង្គចូលទីវង្គត ការទទួលភារកិច្ចជាប្រមុខរដ្ឋស្ដីទី ក្នុងឋានៈជាព្រះរាជានុសិទ្ធិ ត្រូវអនុវត្តតាមវាក្យខ័ណ្ឌទី២ និងទី៣ នៃមាត្រា១១ថ្មី ។

**មាត្រា ១៣.– ថ្មី**

ក្នុងរយៈពេល ៧ថ្ងៃយ៉ាងយូរ ព្រះមហាក្សត្រថ្មីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានជ្រើសរើសដោយក្រុមប្រឹក្សារាជសម្បត្តិ ។

សមាសភាពនៃក្រុមប្រឹក្សារាជសម្បត្តិមាន :

-ប្រធានព្រឹទ្ធសភា

-ប្រធានរដ្ឋសភា

-នាយករដ្ឋមន្ត្រី

-សម្ដេចព្រះសង្ឃរាជ គណៈមហានិកាយ និងគណៈធម្មយុត្តិកនិកាយ

-អនុប្រធានទី១ និងអនុប្រធានទី២ ព្រឹទ្ធសភា

-អនុប្រធានទី១ និងអនុប្រធានទី២ រដ្ឋសភា

ការរៀបចំ និងការប្រព្រឹត្តិទៅ នៃក្រុមប្រឹក្សារាជសម្បត្តិ នឹងមានកំណត់ក្នុងច្បាប់មួយ ។

**មាត្រា ១៨.– ថ្មី**

ព្រះមហាក្សត្រ ព្រះអង្គទ្រង់ទាក់ទងជាមួយព្រឹទ្ធសភា និងរដ្ឋសភាដោយព្រះរាជសារ ។

ព្រះរាជសារនេះ ព្រឹទ្ធសភានិងរដ្ឋសភាមិនអាចយកទៅជជែកពិភាក្សាឡើយ ។

**មាត្រា ២២ .– ថ្មី**

នៅពេលប្រជាជាតិប្រឈមមុខនឹងគ្រោះថ្នាក់ ព្រះមហាក្សត្រទ្រង់ប្រកាសប្រទានដំណឹងជាសាធារណៈ ដាក់ប្រទេសជាតិស្ថិតនៅក្នុងភាពអាសន្ន ក្រោយពីបានមតិឯកភាពពីនាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា និងប្រធានព្រឹទ្ធសភា ។

**មាត្រា ២៤ .– ថ្មី**

ព្រះមហាក្សត្រទ្រង់គង់ជាព្រះអធិបតីនៃឧត្តមក្រុមប្រឹក្សាការពារជាតិ ដែលនឹងត្រូវបង្កើតឡើងដោយច្បាប់មួយ ។

ព្រះមហាក្សត្រទ្រង់ប្រកាសសង្គ្រាម ក្រោយការអនុម័តរបស់រដ្ឋសភា និង ព្រឹទ្ធសភា ។

**មាត្រា ២៦ .– ថ្មី**

ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្ដលេខាលើសន្ធិសញ្ញា និងអនុសញ្ញាអន្តរជាតិ ហើយទ្រង់ប្រទានសច្ចាប័នលើសន្ធិសញ្ញានិងអនុសញ្ញាទាំងនេះ ក្រោយបានទទួលការអនុម័តយល់ព្រមពីរដ្ឋសភា និង ព្រឹទ្ធសភា ។

មាត្រា ២៨ .- ថ្មី

ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្ថលេខាលើព្រះរាជក្រមប្រកាសអោយប្រើរដ្ឋធម្មនុញ្ញ ច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់រួចហើយ និងទ្រង់ឡាយព្រះហស្ថលេខាលើព្រះរាជក្រឹត្យ តាមសេចក្តីស្នើសុំពីគណៈរដ្ឋមន្ត្រី ។

ក្នុងពេលដែលព្រះមហាក្សត្រប្រឈួន ហើយត្រូវព្យាបាលព្រះរោគនៅបរទេស ក្នុងពេលនោះ ព្រះមហាក្សត្រមានសិទ្ធិផ្ទេរអំណាច ឡាយព្រះហស្ថលេខានៅលើព្រះរាជក្រម ឬព្រះរាជក្រឹត្យខាងលើនេះ ទៅប្រមុខរដ្ឋស្តីទីចុះហត្ថលេខាជំនួសដោយព្រះរាជសារប្រគល់សិទ្ធិ ។

មាត្រា ៣០ .- ថ្មី

ក្នុងរយៈពេលព្រះមហាក្សត្រអវត្តមាន ប្រធានព្រឹទ្ធសភា ទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទី ។

ក្នុងករណីដែលប្រធានព្រឹទ្ធសភា ពុំមានលទ្ធភាពបំពេញភារកិច្ចជាប្រមុខរដ្ឋស្តីទីជំនួសព្រះមហាក្សត្រ ពេលព្រះអង្គទ្រង់អវត្តមាន ការទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទី ត្រូវអនុវត្តតាមវាក្យខណ្ឌទី ២ និងទី ៣ នៃមាត្រា ១១ថ្មី ។

មាត្រា ៣៤ .- ថ្មី

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិបោះឆ្នោត និងអាចឈរឈ្មោះអោយគេបោះឆ្នោត ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ១៨ឆ្នាំ មានសិទ្ធិបោះឆ្នោត ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ២៥ឆ្នាំ អាចឈរឈ្មោះអោយគេបោះឆ្នោតជ្រើសតាំងជាតំណាងរាស្ត្រ ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ៤០ឆ្នាំ អាចឈរឈ្មោះអោយគេបោះឆ្នោតជ្រើសតាំងជាសមាជិកព្រឹទ្ធសភា ។

បទប្បញ្ញត្តិបន្ថយសិទ្ធិបោះឆ្នោត និងសិទ្ធឈរឈ្មោះអោយគេបោះឆ្នោត ត្រូវចែងក្នុងច្បាប់បោះឆ្នោត ។

មាត្រា ៥១ .- ថ្មី

ព្រះរាជាណាចក្រកម្ពុជាអនុវត្តនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស ។

ប្រជាពលរដ្ឋខ្មែរជាម្ចាស់វាសនានៃប្រទេសជាតិរបស់ខ្លួន ។

អំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ ។ ប្រជាពលរដ្ឋប្រើអំណាចរបស់ខ្លួន តាមរយៈរដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាលនិងស្ថាប័នតុលាការ ។

អំណាចបែងចែកដាច់ពីគ្នារវាងអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ ។

មាត្រា ៩០ .- ថ្មី

រដ្ឋសភាជាអង្គការដែលមានអំណាចនីតិបញ្ញត្តិ ហើយបំពេញភារកិច្ចរបស់ខ្លួន ដូចបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន ៕

រដ្ឋសភាអនុម័តថវិកាជាតិ ផែនការរដ្ឋ ការអោយរដ្ឋខ្ចីប្រាក់ពីគេ ការអោយរដ្ឋអោយប្រាក់គេខ្ចី ការសន្យានានាផ្នែកហិរញ្ញវត្ថុ និងការបង្កើត កែប្រែ ឬ លុបចោលពន្ធដារ ។

រដ្ឋសភាអោយសេចក្តីយល់ព្រមចំពោះគណនីរដ្ឋបាល ។

រដ្ឋសភាអនុម័តច្បាប់ ស្តីពីការលើកលែងទោសជាទូទៅ ។

រដ្ឋសភាអនុម័តយល់ព្រម ឬលុបចោលសន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិ ។

រដ្ឋសភាអនុម័តច្បាប់ ស្តីពីការប្រកាសសង្គ្រាម ។

ការអនុម័តខាងលើនេះ ប្រព្រឹត្តទៅដោយមតិភាគច្រើន ដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល ។

រដ្ឋសភាបោះឆ្នោតទុកចិត្តដល់រាជរដ្ឋាភិបាល តាមមតិភាគច្រើន ពីរភាគបីនៃសមាជិករដ្ឋសភាទាំងមូល ។

**មាត្រា ៩១ .-ថ្មី**

សមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា និងនាយករដ្ឋមន្ត្រី មានសិទ្ធិផ្តួចផ្តើមគំនិតធ្វើច្បាប់ ។

តំណាងរាស្ត្រមានសិទ្ធិស្នើធ្វើវិសោធនកម្មច្បាប់ ប៉ុន្តែសំណើនេះមិនអាចទទួលយកបានទេ បើវិសោធនកម្មនោះសំដៅបន្ថយប្រាក់ចំណូលសាធារណៈ ឬបន្ថែមបន្ទុកលើប្រជាពលរដ្ឋ ។

**មាត្រា ៩៣ .-ថ្មី**

ច្បាប់ដែលរដ្ឋសភាបានអនុម័តនិងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់រួចហើយ ហើយត្រូវបានព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាប្រកាសអោយប្រើ ត្រូវចូលជាធរមាននៅរាជធានីភ្នំពេញក្នុងរយៈពេលដប់ថ្ងៃគត់ ក្រោយពីថ្ងៃប្រកាសអោយប្រើ និងនៅទូទាំងប្រទេសក្នុងរយៈពេលម្ភៃថ្ងៃគត់ ក្រោយពីថ្ងៃប្រកាសអោយប្រើ ។ ប៉ុន្តែបើច្បាប់នេះបានចែងថាជាការប្រញាប់ ច្បាប់នេះត្រូវចូលជាធរមានភ្លាមនៅទូទាំងប្រទេស ក្រោយថ្ងៃប្រកាសអោយប្រើ ។

ច្បាប់ដែលព្រះមហាក្សត្រទ្រង់បានឡាយព្រះហស្តលេខាប្រកាសអោយប្រើ ត្រូវចុះក្នុងរាជកិច្ច និងផ្សព្វផ្សាយនៅទូទាំងប្រទេស អោយទាន់តាមពេលកំណត់ខាងលើ ។

## ជំពូកទី ៨ ថ្មី
## អំពី
# ព្រឹទ្ធសភា

**មាត្រា ៩៩ .-ថ្មី**

ព្រឹទ្ធសភាជាអង្គការដែលមានអំណាចនីតិបញ្ញត្តិ ហើយបំពេញភារកិច្ចរបស់ខ្លួន ដូចមានកំណត់ក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន ។

ព្រឹទ្ធសភាមានចំនួនសមាជិកយ៉ាងច្រើនស្មើនឹងពាក់កណ្តាលនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

សមាជិកព្រឹទ្ធសភាត្រូវចាត់តាំងខ្លះនិងត្រូវជ្រើសតាំងដោយការបោះឆ្នោតអសកលខ្លះ ។

សមាជិកព្រឹទ្ធសភាអាចត្រូវបានចាត់តាំង និងជ្រើសតាំងសាជាថ្មីបាន ។ អ្នកដែលមានសិទ្ធិឈរឈ្មោះជាបេក្ខជនព្រឹទ្ធសភា គឺជាប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានសិទ្ធិបោះឆ្នោត មានអាយុយ៉ាងតិច ៤០ឆ្នាំ មានសញ្ជាតិខ្មែរតាំងពីកំណើត ។

មាត្រា ១០០ .-ថ្មី

សមាជិកព្រឹទ្ធសភាចំនួន ២រូប ត្រូវបានចាត់តាំងដោយ ព្រះមហាក្សត្រ ។

សមាជិកព្រឹទ្ធសភាចំនួន ២រូប ត្រូវបានរដ្ឋសភាជ្រើសតាំងតាមមតិភាគច្រើន ដោយប្រៀប ។

រីឯសមាជិកព្រឹទ្ធសភាឯទៀត ត្រូវបានជ្រើសតាំងដោយការបោះឆ្នោតអសកល ។

មាត្រា ១០១ .-ថ្មី

ការរៀបចំ បែបបទ និងការប្រព្រឹត្តិទៅនៃការចាត់តាំង និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ព្រមទាំងការកំណត់អំពីអ្នកបោះឆ្នោត អង្គបោះឆ្នោត និងមណ្ឌលបោះឆ្នោត ត្រូវចែងក្នុងច្បាប់មួយ ។

មាត្រា ១០២ .-ថ្មី

នីតិកាលរបស់ព្រឹទ្ធសភាមានកំណត់ ៦ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលដែលព្រឹទ្ធសភាថ្មីចូលកាន់តំណែង ។

ក្នុងពេលមានសង្គ្រាម ឬ ក្នុងកាលៈទេសៈពិសេសដទៃទៀត ដែលមិនអាចធ្វើការបោះឆ្នោតកើត ព្រឹទ្ធសភាអាចប្រកាសបន្តនីតិកាលរបស់ខ្លួនមួយដងបានមួយឆ្នាំ តាមសំណើរបស់ព្រះមហាក្សត្រ ។

ការប្រកាសបន្តនីតិកាលរបស់ព្រឹទ្ធសភា ត្រូវសំរេចដោយមតិយល់ព្រមពីរភាគបីយ៉ាងតិច នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

ក្នុងកាលៈទេសៈដូចបានរៀបរាប់ខាងលើ ព្រឹទ្ធសភាប្រជុំរាល់ថ្ងៃជាប់ជាប្រចាំ ។ ព្រឹទ្ធសភាមានសិទ្ធិសំរេចបញ្ចប់កាលៈទេសៈពិសេសខាងលើនេះ កាលបើសភាពការណ៍អនុញ្ញាត ។

បើព្រឹទ្ធសភាមិនអាចប្រជុំបានទេ ដោយមូលហេតុចាំបាច់ ជាអាទិ៍នៅពេលដែលកំលាំងបរទេសចូលមកកាន់កាប់ទឹកដី ការប្រកាសភាពអាសន្នត្រូវបន្តទៅមុខជាស្វ័យប្រវត្តិ ។

មាត្រា ១០៣ .-ថ្មី

អាណត្តិនៃសមាជិកព្រឹទ្ធសភាមានវិសមិតភាពជាមួយការបំពេញមុខងារសាធារណៈជាសកម្មជាមួយមុខងារជាតំណាងរាស្ត្រនិងជាមួយមុខងារជាសមាជិកស្ថាប័នដទៃទៀត ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ។

មាត្រា ១០៤ .-ថ្មី

សមាជិកព្រឹទ្ធសភា មានអភ័យឯកសិទ្ធិសភា ។

សមាជិកព្រឹទ្ធសភារូបណាក៏ដោយមិនអាចត្រូវបានចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួនដោយហេតុពីបានសំដែងយោបល់ ឬ បញ្ចេញមតិក្នុងការបំពេញមុខងាររបស់ខ្លួនសោះឡើយ ។

ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួន សមាជិកណាមួយនៃព្រឹទ្ធសភា នឹងអាចធ្វើទៅកើត លុះត្រាតែមានការយល់ព្រមពីព្រឹទ្ធសភា ឬពីគណៈកម្មាធិការ អចិន្ត្រៃយ៍របស់ព្រឹទ្ធសភា ក្នុងចន្លោះសម័យប្រជុំនៃព្រឹទ្ធសភា វៀរលែងតែក្នុងករណីបទល្មើសព្រហ្មទណ្ឌជាក់ស្តែង ។ ក្នុងករណីចុងក្រោយនេះ ក្រសួងមានសមត្ថកិច្ច ត្រូវធ្វើសេចក្តីរាយការណ៍ ជូនព្រឹទ្ធសភា ឬជូនគណៈកម្មាធិការអចិន្ត្រៃយ៍របស់ព្រឹទ្ធសភាជាបន្ទាន់ដើម្បីសំរេច ។

សេចក្តីសំរេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍របស់ព្រឹទ្ធសភាត្រូវដាក់ជូនសម័យប្រជុំព្រឹទ្ធសភាខាងមុខ ដើម្បីអនុម័តតាមមតិភាគច្រើនពីរភាគបីនៃសមាជិកព្រឹទ្ធសភាទាំងមូល ។

ក្នុងករណីទាំងអស់ខាងលើនេះ ការឃុំខ្លួន ការចោទប្រកាន់សមាជិកព្រឹទ្ធសភាណាមួយត្រូវផ្អាក ប្រសិនបើព្រឹទ្ធសភាបានបញ្ចេញមតិអោយផ្អាកតាមមតិភាគច្រើន បីភាគបួននៃសមាជិកព្រឹទ្ធសភាទាំងមូល ។

**មាត្រា ១០៥ .-ថ្មី**

ព្រឹទ្ធសភាមានថវិកាស្វយ័តសំរាប់ដំណើរការ ។

សមាជិកព្រឹទ្ធសភាត្រូវទទួលប្រាក់បំណាច់ ។

**មាត្រា ១០៦ .-ថ្មី**

ព្រឹទ្ធសភាបើកសម័យប្រជុំដំបូង ហុកសិបថ្ងៃយ៉ាងយូរ ក្រោយពេលបោះឆ្នោត តាមការកោះប្រជុំរបស់ព្រះមហាក្សត្រ ។

មុនចាប់ផ្តើមការងាររបស់ខ្លួន ព្រឹទ្ធសភាត្រូវប្រកាសសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗ និងត្រូវបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នានូវប្រធាន អនុប្រធានព្រឹទ្ធសភា និងសមាជិកទាំងអស់នៃគណៈកម្មការនានារបស់ព្រឹទ្ធសភា ដោយមតិភាគច្រើនពីរភាគបីនៃសមាជិកព្រឹទ្ធសភាទាំងមូល ។

សមាជិកព្រឹទ្ធសភាទាំងអស់ត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់តំណែងដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធទី៧ នៃរដ្ឋធម្មនុញ្ញ ។

**មាត្រា ១០៧ .-ថ្មី**

ព្រឹទ្ធសភាប្រជុំជាសាមញ្ញពីរដងក្នុងមួយឆ្នាំ ។

សម័យប្រជុំនីមួយៗមានថេរៈវេលាយ៉ាងតិចបីខែ ។ បើមានសំណូមពរពីព្រះមហាក្សត្រ ឬសេចក្តីស្នើសុំពីនាយករដ្ឋមន្ត្រី ឬពីសមាជិកព្រឹទ្ធសភាចំនួនមួយភាគបីយ៉ាងតិច ព្រឹទ្ធសភាកោះប្រជុំជាវិសាមញ្ញ ។

**មាត្រា ១០៨ .-ថ្មី**

នៅចន្លោះសម័យប្រជុំរបស់ព្រឹទ្ធសភា គណៈកម្មាធិការអចិន្ត្រៃយ៍របស់ព្រឹទ្ធសភាទទួលភារកិច្ចចាត់ចែងការងារ ។

គណៈកម្មាធិការអចិន្ត្រៃយ៍របស់ព្រឹទ្ធសភា រួមមាន : ប្រធានព្រឹទ្ធសភា អនុប្រធានព្រឹទ្ធសភា និងប្រធានគណៈកម្មការទាំងអស់របស់ព្រឹទ្ធសភា ។

**មាត្រា ១០៩ .-ថ្មី**

សម័យប្រជុំព្រឹទ្ធសភាត្រូវធ្វើនៅរាជធានីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងសាលប្រជុំរបស់ព្រឹទ្ធសភា លើកលែងតែមានការសំរេចផ្សេងចុះក្នុងលិខិតកោះប្រជុំ ដោយកាលៈទេសៈតម្រូវ ។

ក្រៅពីករណីខាងលើនិងក្រៅពីកន្លែង និងកាលបរិច្ឆេទដែលកំណត់ក្នុងសេចក្តីអញ្ជើញ ការប្រជុំណាក៏ដោយរបស់ព្រឹទ្ធសភាត្រូវទុកជាខុសច្បាប់ ហើយអសារសូន្យពេញលក្ខណៈ ។ ទទួលភារកិច្ចចាត់ចែងការងារ ។

**មាត្រា ១១០ .-ថ្មី**

ប្រធានព្រឹទ្ធសភាដឹកនាំអង្គប្រជុំរបស់ព្រឹទ្ធសភា ទទួលអាញត្តិច្បាប់ និងសេចក្តីសំរេចចិត្តទាំងឡាយដែលព្រឹទ្ធសភាបានអនុម័ត រ៉ាប់រងការអនុវត្តន៍បទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភា និងចាត់ចែងការទាក់ទងអន្តរជាតិទាំងឡាយរបស់ព្រឹទ្ធសភា ។

ក្នុងករណីដែលប្រធានព្រឹទ្ធសភាមានធុរៈ មិនអាចបំពេញមុខងារបាន ដោយហេតុមកពីមានជម្ងឺ ឬ បំពេញមុខងារជាប្រមុខរដ្ឋស្តីទី ឬ ជាព្រះរាជានុសិទ្ធិឬបំពេញបេសកកម្មនៅបរទេស អនុប្រធានព្រឹទ្ធសភាមួយរូប ត្រូវទទួលភារកិច្ចចាត់ចែងការងារជំនួស ។

ក្នុងករណីដែលប្រធាន ឬ អនុប្រធានព្រឹទ្ធសភាណាលែងពីមុខតំណែង ឬ ទទួលអនិច្ចកម្ម ព្រឹទ្ធសភាត្រូវបោះឆ្នោតជ្រើសតាំងប្រធាន ឬ អនុប្រធានថ្មី ។

**មាត្រា ១១១ .-ថ្មី**

ការប្រជុំព្រឹទ្ធសភា ត្រូវធ្វើជាសាធារណៈ ។

ព្រឹទ្ធសភាអាចប្រជុំជាសំងាត់បានតាមការសុំពីប្រធាន ឬពីសមាជិកចំនួនមួយភាគដប់យ៉ាងតិច ពីព្រះមហាក្សត្រ ពីនាយករដ្ឋមន្ត្រី ឬ ពីប្រធានរដ្ឋសភា ។

ការប្រជុំព្រឹទ្ធសភានឹងយកជាការបាន លុះត្រាតែមានកូរ៉ុមប្រាំពីរភាគដប់ នៃសមាជិកព្រឹទ្ធសភាទាំងមូល ។

ចំនួនសំឡេងដែលតម្រូវសំរាប់រដ្ឋសភាអនុម័តយល់ព្រម ហើយដែលបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ ត្រូវយកមកប្រើសំរាប់ព្រឹទ្ធសភាផងដែរ ។

**មាត្រា ១១២ .-ថ្មី**

ព្រឹទ្ធសភា មានភារកិច្ចសំរបសំរួលការងាររវាងរដ្ឋសភា និងរដ្ឋាភិបាល ។

**មាត្រា ១១៣ .-ថ្មី**

ព្រឹទ្ធសភាពិនិត្យហើយអោយយោបល់ក្នុងរយៈពេលមួយខែយ៉ាងយូរ លើសេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់ដែលរដ្ឋសភាបានអនុម័តយល់ព្រមលើកដំបូងរួចហើយ ព្រមទាំងលើបញ្ហាទាំងពួងដែលរដ្ឋសភាបានដាក់អោយពិនិត្យ ។ បើជាការប្រញាប់ រយៈពេលនោះត្រូវបន្ថយមកនៅត្រឹមតែប្រាំថ្ងៃ ។

បើព្រឹទ្ធសភាបានអោយយោបល់យល់ព្រម ឬ ពុំបានអោយយោបល់សោះ ក្នុងរយៈពេលដែលមានកំណត់ទុកហើយនោះទេ ច្បាប់ដែលរដ្ឋសភាបានអនុម័តយល់ព្រមហើយនោះ នឹងត្រូវបានយកទៅប្រកាសអោយប្រើ ។

បើព្រឹទ្ធសភាសុំអោយកែសំរួលសេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់នោះ រដ្ឋសភាត្រូវយកមកពិចារណាភ្លាមជាលើកទី២ ។ រដ្ឋសភាត្រូវពិនិត្យ និងសំរេចតែត្រង់បទប្បញ្ញត្តិឬចំណុចណាដែលព្រឹទ្ធសភាសុំអោយកែសំរួល ដោយបដិសេធចោលទាំងមូល ឬទុកជាបានការខ្លះ ។

ការបង្វិលទៅបង្វិលមករវាងព្រឹទ្ធសភានិងរដ្ឋសភា ត្រូវធ្វើតែក្នុងរយៈពេលមួយខែ ។ រយៈពេលនេះត្រូវបន្ថយមកត្រឹមដប់ថ្ងៃ បើត្រូវពិនិត្យសំរេចពីថវិកាជាតិ និងហិរញ្ញវត្ថុ ហើយមកត្រឹមតែពីរថ្ងៃ បើជាការប្រញាប់ ។

បើរដ្ឋសភាទុកអោយហួសរយៈពេលកំណត់ ឬ ពន្យារពេលដែលកំណត់ទុកសំរាប់ពិនិត្យនោះ រយៈពេលជាគោលការណ៍សំរាប់រដ្ឋសភា និងព្រឹទ្ធសភា ត្រូវបន្ថែមអោយស្មើគ្នាដែរ ។

បើព្រឹទ្ធសភាបដិសេធសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នោះជាអសារបង់ រដ្ឋសភាមិនអាចនឹងយកមកពិចារណាជាលើកទីពីរបាន មុនរយៈពេលមួយខែទេ ។ រយៈពេលនេះត្រូវបន្ថយមកត្រឹមដប់ប្រាំថ្ងៃ បើពិនិត្យពីថវិកាជាតិ និងហិរញ្ញវត្ថុ ហើយមកត្រឹមតែបួនថ្ងៃបើជាការប្រញាប់ ។

ក្នុងការពិនិត្យសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ជាលើកទី២នេះ រដ្ឋសភាត្រូវអនុម័តដោយវិធីបោះឆ្នោតចំហ និងយកតាមមតិភាគច្រើនដាច់ខាត ។

សេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់ណាដែលបានសំរេចដូចខាងលើនេះហើយនោះ នឹងត្រូវបានយកទៅប្រកាសអោយប្រើ ។

មាត្រា ១១៤ .-ថ្មី

ព្រឹទ្ធសភាបង្កើតគណៈកម្មការផ្សេងៗដែលចាំបាច់ ។ ការរៀបចំនិងការប្រព្រឹត្តិទៅនៃព្រឹទ្ធសភានឹងមានកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភា ។ បទបញ្ជាផ្ទៃក្នុងនេះ ត្រូវអនុម័តយល់ព្រមដោយសំឡេងភាគច្រើន ពីរភាគបីនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

មាត្រា ១១៥ .-ថ្មី

ក្នុងករណីមានសមាជិកព្រឹទ្ធសភាទទួលអនិច្ចកម្ម លាលែងឬប្រាសចាកសមាជិកភាពដែលកើតមានឡើងប្រាំមួយខែយ៉ាងតិចមុនចប់នីតិកាល ត្រូវចាត់តាំងឬជ្រើសតាំងជំនួសសមាជិកនោះតាមល័ក្ខខ័ណ្ឌកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងនៃព្រឹទ្ធសភានិងក្នុងច្បាប់ ស្តីពីការចាត់តាំងនិងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

## ជំពូកទី ៩ ថ្មី
## អំពី
## សមាជរដ្ឋសភា និងព្រឹទ្ធសភា

មាត្រា ១១៦ .-ថ្មី

ក្នុងករណីចាំបាច់ រដ្ឋសភា និង ព្រឹទ្ធសភាអាចប្រជុំរួមគ្នាជាសមាជ ដើម្បីដោះស្រាយបញ្ហាសំខាន់ៗរបស់ប្រទេសជាតិ ។

មាត្រា ១១៧ .-ថ្មី

បញ្ហាសំខាន់ៗរបស់ប្រទេសជាតិដូចមានចែងក្នុងមាត្រា ១១៦ថ្មី ខាងលើ ព្រមទាំងការរៀបចំ និងការប្រព្រឹត្តិទៅនៃសមាជ នឹងត្រូវកំណត់ក្នុងច្បាប់មួយ ។

## ជំពូកទី ១០ថ្មី

## អំពី

## រាជរដ្ឋាភិបាល

មាត្រា ១១៨ .-ថ្មី (មាត្រា ៩៩ ចាស់)

គណៈរដ្ឋមន្ត្រីជារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។

គណៈរដ្ឋមន្ត្រីត្រូវបានដឹកនាំដោយនាយករដ្ឋមន្ត្រីមួយរូប អមដោយឧបនាយករដ្ឋមន្ត្រី ព្រមទាំងមានទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការជាសមាជិក ។

មាត្រា ១១៩ .-ថ្មី (មាត្រា ១០០ ចាស់)

តាមសេចក្តីស្នើពីប្រធាន ដោយមានមតិឯកភាពពីអនុប្រធានទាំងពីរនៃរដ្ឋសភា ព្រះមហាក្សត្រទ្រង់ចាត់តាំងវរជនមួយរូប ក្នុងចំណោមតំណាងរាស្ត្រនៃគណបក្សដែលឈ្នះឆ្នោត អោយបង្កើតរាជរដ្ឋាភិបាល ។ វរជនដែលត្រូវបានចាត់តាំងនេះ នាំសហការីដែលជាតំណាងរាស្ត្រ ឬជាសមាជិកគណបក្សតំណាងនៅក្នុងរដ្ឋសភា ដែលផ្តល់អោយកាន់តំណែងផ្សេងៗក្នុងរាជរដ្ឋាភិបាល ទៅសុំសេចក្តីទុកចិត្តពីរដ្ឋសភា ។ កាលបើរដ្ឋសភាបានបោះឆ្នោតទុកចិត្តហើយនោះ ព្រះមហាក្សត្រទ្រង់ចេញព្រះរាជក្រឹត្យ តែងតាំងគណៈរដ្ឋមន្ត្រីទាំងមូល ។

មុនចូលកាន់តំណែង គណៈរដ្ឋមន្ត្រីត្រូវធ្វើសច្ចាប្រណិធាន ដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធ ៦ ។

មាត្រា ១២០ .-ថ្មី (មាត្រា ១០១ ចាស់)

មុខងារនៃសមាជិករាជរដ្ឋាភិបាល មាននិសមិតភាពនឹងសកម្មភាពខាងវិជ្ជាជីវៈផ្នែកពាណិជ្ជកម្ម ឬ ឧស្សាហកម្ម ហើយនិងការកាន់តំណែងណាមួយក្នុងមុខងារសាធារណៈ ។

មាត្រា ១២១ .-ថ្មី (មាត្រា ១០២ ចាស់)

សមាជិកទាំងឡាយនៃរាជរដ្ឋាភិបាលទទួលខុសត្រូវរួមគ្នាចំពោះរដ្ឋសភា អំពីនយោបាយទូទៅ របស់រាជរដ្ឋាភិបាល ។

សមាជិកមួយរូបៗនៃរាជរដ្ឋាភិបាលទទួលខុសត្រូវរៀងខ្លួន ចំពោះនាយករដ្ឋមន្ត្រី និងចំពោះរដ្ឋសភាអំពីការដែលខ្លួនបានប្រព្រឹត្ត ។

មាត្រា ១២២ .-ថ្មី (មាត្រា ១០៣ ចាស់)

សមាជិកទាំងឡាយនៃរាជរដ្ឋាភិបាលមិនអាចលើកសំអាងនៃសេចក្តីបង្គាប់ដោយលាយលក្ខអក្សរ ឬ ដោយវាចាអំពីនរណាមួយ ដើម្បីដោះសារអោយរួចខ្លួនពីការទទួលខុសត្រូវរបស់ខ្លួនបានឡើយ ។

មាត្រា ១២៣ .-ថ្មី (មាត្រា ១០៤ ចាស់)

គណៈរដ្ឋមន្ត្រីត្រូវប្រជុំរាល់សប្តាហ៍ ជាប្រជុំធំ ឬជាប្រជុំពិនិត្យស្រាវជ្រាវ ។

អង្គប្រជុំធំត្រូវដឹកនាំដោយនាយករដ្ឋមន្ត្រី ។ នាយករដ្ឋមន្ត្រីអាចប្រគល់ភារកិច្ចជូនឧបនាយករដ្ឋមន្ត្រីដឹកនាំអង្គប្រជុំពិនិត្យស្រាវជ្រាវបាន ។

កំណត់ហេតុនៃអង្គប្រជុំទាំងអស់របស់គណៈរដ្ឋមន្ត្រី ត្រូវធ្វើថ្វាយព្រះមហាក្សត្រទ្រង់ជ្រាប ។

មាត្រា ១២៤ .-ថ្មី (មាត្រា ១០៥ ចាស់)

នាយករដ្ឋមន្ត្រីអាចរំលែកអំណាចរបស់ខ្លួនអោយទៅឧបនាយករដ្ឋមន្ត្រី ឬសមាជិកណាមួយនៃរាជរដ្ឋាភិបាលបាន ។

មាត្រា ១២៥ .-ថ្មី (មាត្រា ១០៦ ចាស់)

បើតំណែងនាយករដ្ឋមន្ត្រីនៅទំនេរជាស្ថាពរនោះ ត្រូវតែងតាំងគណៈរដ្ឋមន្ត្រីមួយជាថ្មី ក្នុងលក្ខខ័ណ្ឌដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនេះ ។ បើការទំនេរនេះជាការទំនេរមួយកាលមួយគ្រាទេ ត្រូវចាត់តាំងនាយករដ្ឋមន្ត្រីស្តីទីជាបណ្តោះអាសន្ន ។

មាត្រា ១២៦ .-ថ្មី (មាត្រា ១០៧ ចាស់)

សមាជិកមួយរូបៗនៃរាជរដ្ឋាភិបាលត្រូវទទួលទណ្ឌកម្មពីបទឧក្រិដ្ឋ ឬបទមជ្ឈិមដែលខ្លួនបានប្រព្រឹត្តក្នុងការបំពេញការងាររបស់ខ្លួន ។

ក្នុងករណីនេះនិងក្នុងករណីធ្វើខុសជាទម្ងន់ ក្នុងការបំពេញការងាររបស់ខ្លួន រដ្ឋសភាអាចសំរេចប្តឹងទៅតុលាការមានសមត្ថកិច្ច ។

រដ្ឋសភាសំរេចក្នុងរឿងនេះ ដោយវិធីបោះឆ្នោតជាសំងាត់ តាមមតិភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល ។

មាត្រា ១២៧ .-ថ្មី (មាត្រា ១០៨ ចាស់)

ការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី នឹងត្រូវកំណត់ក្នុងច្បាប់មួយ ។

## ជំពូកទី ១១ ថ្មី

## អំពី

## អំណាចតុលាការ

មាត្រា ១២៨ .-ថ្មី (មាត្រា ១០៩ ចាស់)

-អំណាចតុលាការ ជាអំណាចឯករាជ្យ ។

-អំណាចតុលាការធានារក្សាអនាគត និងការពារសិទ្ធិ សេរីភាពរបស់ប្រជាពលរដ្ឋ ។

-អំណាចតុលាការគ្របដណ្តប់ទៅលើរឿងក្តីទាំងអស់ រួមទាំងរឿងក្តីរដ្ឋបាលផង ។

-អំណាចនេះត្រូវប្រគល់អោយតុលាការកំពូល និងសាលាជំរះក្តីគ្រប់ផ្នែក និងគ្រប់ជាន់ថ្នាក់ ។

មាត្រា ១២៩ .-ថ្មី (មាត្រា ១១០ ចាស់)

ការជំរះក្តីផ្តល់យុត្តិធម៌ ត្រូវធ្វើក្នុងនាមប្រជារាស្ត្រខ្មែរ តាមនីតិវិធីនិងច្បាប់ជាធរមាន ។

មានតែចៅក្រមទេ ដែលមានសិទ្ធិជំរះក្តី ។ ចៅក្រមត្រូវបំពេញភារកិច្ចនេះដោយគោរពច្បាប់យ៉ាងម៉ឺងម៉ាត់ និងអោយអស់ពីដួងចិត្ត និងសម្បជញ្ញៈរបស់ខ្លួន ។

មាត្រា ១៣០ .-ថ្មី (មាត្រា ១១១ ចាស់)

គ្មានអង្គការណាមួយនៃអំណាចនីតិបញ្ញត្តិ ឬនីតិប្រតិបត្តិអាចទទួលអំណាចតុលាការអ្វីបានឡើយ ។

មាត្រា ១៣១ .-ថ្មី (មាត្រា ១១២ ចាស់)

មានតែអង្គការអយ្យការទេ ដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា ។

មាត្រា ១៣២ .-ថ្មី (មាត្រា ១១៣ ចាស់)

ព្រះមហាក្សត្រទ្រង់ជាអ្នកធានាឯករាជ្យនៃអំណាចតុលាការ ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមជួយព្រះមហាក្សត្រក្នុងកិច្ចការនេះ ។

មាត្រា ១៣៣ .-ថ្មី (មាត្រា ១១៤ ចាស់)

ចៅក្រមមិនអាចត្រូវគេដកពីមុខងារបានទេ ។ ប៉ុន្តែឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សំរេចដាក់វិន័យលើចៅក្រមដែលបានប្រព្រឹត្តខុស ។

មាត្រា ១៣៤ .-ថ្មី (មាត្រា ១១៥ ចាស់)

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនឹងត្រូវបង្កើតដោយច្បាប់រៀបចំអង្គការមួយដែលនឹងកំណត់សមាសភាព និងមុខងារ ។

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ស្ថិតក្រោមព្រះរាជាធិបតីភាពនៃព្រះមហាក្សត្រ ។ ព្រះមហាក្សត្រ ព្រះអង្គទ្រង់អាចចាត់តាំងព្រះរាជតំណាងម្នាក់របស់ព្រះអង្គអោយធ្វើជាអធិបតី នៃឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រមនេះ ។

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម លើកសេចក្តីស្នើថ្វាយព្រះមហាក្សត្រអំពីការតែងតាំងចៅក្រម និងព្រះរាជអាជ្ញាអមសាលាជំរះក្តីទាំងអស់ ។

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្នុងមុខងារដាក់វិន័យចំពោះចៅក្រម និងព្រះរាជអាជ្ញា ត្រូវប្រជុំក្រោមអធិបតីភាពនៃប្រធានតុលាការកំពូល ឬអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល អាស្រ័យដោយករណីទាក់ទងនឹងចៅក្រម ឬ ព្រះរាជអាជ្ញា ។

មាត្រា ១៣៥ .-ថ្មី (មាត្រា ១១៦ ចាស់)

លក្ខន្តិកៈនៃចៅក្រមនិងព្រះរាជអាជ្ញានិងការរៀបចំអង្គការតុលាការនឹងត្រូវកំណត់ក្នុងច្បាប់ដោយឡែកពីគ្នា ។

## ជំពូកទី ១២ ថ្មី
## ស្តីពី
# ក្រុមប្រឹក្សាធម្មនុញ្ញ

**មាត្រា ១៣៦ .-ថ្មី**

ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចធានាការពារការគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និង ច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ ។

ក្រុមប្រឹក្សាធម្មនុញ្ញមានសិទ្ធិពិនិត្យ និងសំរេចអំពីករណីវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

**មាត្រា ១៣៧ .-ថ្មី ( មាត្រា ១១៨ ចាស់ )**

ក្រុមប្រឹក្សាធម្មនុញ្ញមានសមាជិកប្រាំបួនរូប ដែលទទួលអាណត្តិប្រាំបួនឆ្នាំ ។ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញចំនួនមួយភាគបី ត្រូវផ្លាស់ថ្មីក្នុងរយៈពេលបីឆ្នាំម្តង បីឆ្នាំម្តង ។ សមាជិកបីរូបត្រូវតែងតាំងដោយព្រះមហាក្សត្រ បីរូបត្រូវជ្រើសតាំងដោយរដ្ឋសភា ហើយបីរូបទៀត ត្រូវតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

ប្រធានត្រូវបានជ្រើសតាំងដោយសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ។ ប្រធានមានសំឡេងឧត្តមានុភាពក្នុងករណីបែកសំឡេងជាពីរស្មើគ្នា ។

**មាត្រា ១៣៨ .-ថ្មី ( មាត្រា ១១៩ ចាស់ )**

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញត្រូវជ្រើសរើសក្នុងចំណោមឥស្សរជនដែលមានសញ្ញាបត្រចាប់ពីឧត្តមសិក្សាទៅខាងច្បាប់ ខាងរដ្ឋបាល ខាងការទូតឬខាងសេដ្ឋកិច្ច ហើយមានពិសោធន៍ច្រើនក្នុងការងារ ។

**មាត្រា ១៣៩ .-ថ្មី**

មុខងារសមាជិកក្រុមប្រឹក្សាធម្មនុញ្ញមានវិសមិតភាពនឹងមុខងារសមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា សមាជិករាជរដ្ឋាភិបាល ចៅក្រមក្នុងតំណែង ការកាន់តំណែងណាមួយក្នុងមុខងារសាធារណៈ ប្រធាន ឬអនុប្រធានគណបក្ស នយោបាយ ប្រធាន ឬ អនុប្រធានសហជីព ។

**មាត្រា ១៤០ .-ថ្មី**

ព្រះមហាក្សត្រ នាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា តំណាងរាស្ត្រ ចំនួនមួយភាគដប់ ប្រធានព្រឹទ្ធសភា ឬសមាជិកព្រឹទ្ធសភាចំនួនមួយភាគបួន អាចបញ្ជូនច្បាប់ដែលរដ្ឋសភាបានអនុម័តទៅអោយក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុននឹងច្បាប់នោះត្រូវប្រកាសអោយប្រើ ។

បទបញ្ជាផ្ទៃក្នុងរដ្ឋសភា បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា និងច្បាប់រៀបចំអង្គការទាំងឡាយ ត្រូវតែបញ្ជូនទៅក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ មុននឹងប្រកាសអោយប្រើ ។ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសំរេច

ក្នុងរយៈពេលសាមសិប (៣០) ថ្ងៃយ៉ាងយូរ ថាតើច្បាប់ បទបញ្ជាផ្ទៃក្នុងរដ្ឋសភា និងបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភាខាងលើស្រប ឬមិនស្របនឹងរដ្ឋធម្មនុញ្ញ ។

មាត្រា ១៤១ .-ថ្មី

ក្រោយពីច្បាប់ណាមួយត្រូវបានប្រកាសអោយប្រើ ព្រះមហាក្សត្រ ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី សមាជិកព្រឹទ្ធសភាចំនួនមួយភាគបួន តំណាងរាស្ត្រចំនួនមួយភាគដប់ ឬតុលាការអាចសុំអោយក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យអំពីធម្មនុញ្ញភាពនៃច្បាប់នោះ ។

ប្រជារាស្ត្រមានសិទ្ធិប្តឹងអំពីធម្មនុញ្ញភាពនៃច្បាប់បាន តាមរយៈតំណាងរាស្ត្រ ឬ ប្រធានរដ្ឋសភា ឬសមាជិកព្រឹទ្ធសភា ឬប្រធានព្រឹទ្ធសភា ដូចមានចែងក្នុងវាក្យខ័ណ្ឌខាងលើ ។

មាត្រា ១៤២ .-ថ្មី (មាត្រា ១២៣ ចាស់)

បទប្បញ្ញត្តិក្នុងមាត្រាណាដែលក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាមិនស្របនឹងរដ្ឋធម្មនុញ្ញ មិនអាចយកទៅប្រកាសអោយប្រើ ឬយកទៅអនុវត្តបានឡើយ ។

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញជាសេចក្តីសំរេចបិទផ្លូវតវ៉ា ។

មាត្រា ១៤៣ .-ថ្មី (មាត្រា ១២៤ ចាស់)

ព្រះមហាក្សត្រទ្រង់ពិគ្រោះមតិក្រុមប្រឹក្សាធម្មនុញ្ញ ចំពោះសេចក្តីស្នើទាំងឡាយ ដែលសុំធ្វើវិសោធនកម្ម លើរដ្ឋធម្មនុញ្ញ ។

មាត្រា ១៤៤ .-ថ្មី (មាត្រា ១២៥ ចាស់)

ច្បាប់រៀបចំអង្គការមួយនឹងកំណត់ការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។

## ជំពូកទី ១៣ ថ្មី

## អំពី

## ការគ្រប់គ្រងរដ្ឋបាល

មាត្រា ១៤៥ .-ថ្មី (មាត្រា ១២៦ ចាស់)

ទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ចែកជាខេត្ត និង ក្រុង ។

ខេត្ត ចែកជាស្រុក ស្រុកចែកជា ឃុំ ។

ក្រុង ចែកជាខ័ណ្ឌ ខ័ណ្ឌចែកជាសង្កាត់ ។

**មាត្រា ១៤៦ .-ថ្មី (មាត្រា ១២៧ ចាស់)**

ខេត្ត ក្រុង ស្រុក ខ័ណ្ឌ ឃុំ និងសង្កាត់ ត្រូវគ្រប់គ្រងតាមលក្ខខ័ណ្ឌដែលមានចែងក្នុងច្បាប់រៀបចំអង្គការមួយ ។

## ជំពូកទី ១៤ ថ្មី
## អំពី
## សមាជជាតិ

**មាត្រា ១៤៧ .-ថ្មី (មាត្រា ១២៨ ចាស់)**

សមាជជាតិបើកអោយប្រជារាស្ត្រជ្រាបដោយផ្ទាល់ អំពីកិច្ចការផ្សេងៗ ដែលជាប្រយោជន៍ជាតិ និងលើកបញ្ហា និងសំណូមពរ ជូនរដ្ឋអំណាចដោះស្រាយ ។

ប្រជារាស្ត្រខ្មែរទាំងពីរភេទ មានសិទ្ធិទៅចូលរួមក្នុងសមាជជាតិ ។

**មាត្រា ១៤៨ .-ថ្មី (មាត្រា ១២៩ ចាស់)**

សមាជជាតិប្រជុំមួយដងក្នុងមួយឆ្នាំ នៅដើមខែធ្នូ តាមការកោះអញ្ជើញរបស់នាយករដ្ឋមន្ត្រី។

សមាជជាតិប្រព្រឹត្តទៅក្រោមព្រះរាជាធិបតីភាពនៃព្រះមហាក្សត្រ ។

**មាត្រា ១៤៩ .-ថ្មី**

សមាជជាតិអនុម័តសំណូមពរជូនព្រឹទ្ធសភា ជូនរដ្ឋសភា និងជូនរដ្ឋអំណាចពិចារណា ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃសមាជជាតិនឹងត្រូវកំណត់ក្នុងច្បាប់មួយ ។

## ជំពូកទី ១៥ ថ្មី
## អំពី
## អានុភាព ការសើរើ និង
## វិសោធនកម្មរដ្ឋធម្មនុញ្ញ

**មាត្រា ១៥០ .-ថ្មី (មាត្រា ១៣១ ចាស់)**

រដ្ឋធម្មនុញ្ញនេះជាច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជា ។

ច្បាប់ និង សេចក្តីសំរេចទាំងឡាយនៃស្ថាប័ននានា របស់រដ្ឋត្រូវស្របនឹងរដ្ឋធម្មនុញ្ញជាដាច់ខាត ។

**មាត្រា ១៥១ .-ថ្មី (មាត្រា ១៣២ ចាស់)**

ការផ្តើមគំនិតសើរើឬការផ្តើមគំនិតធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ជាសិទ្ធិរបស់ព្រះមហាក្សត្ររបស់នាយករដ្ឋមន្ត្រី និងរបស់ប្រធានរដ្ឋសភា តាមសេចក្តីស្នើរបស់តំណាងរាស្ត្រ មួយភាគបួននៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

ការសើរើឬវិសោធនកម្មរដ្ឋធម្មនុញ្ញត្រូវធ្វើឡើងដោយច្បាប់ធម្មនុញ្ញមួយដែលអនុម័តដោយរដ្ឋសភាតាមមតិភាគច្រើនពីរភាគបី នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

មាត្រា ១៥២ .-ថ្មី (មាត្រា ១៣៣ ចាស់)

ការសើរើ ឬ វិសោធនកម្មរដ្ឋធម្មនុញ្ញ ត្រូវហាមឃាត់មិនអោយធ្វើ នៅពេលប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ដូចមានចែងក្នុងមាត្រា ៨៦ ។

មាត្រា ១៥៣ .-ថ្មី (មាត្រា ១៣៤ ចាស់)

ការសើរើ ឬ វិសោធនកម្មរដ្ឋធម្មនុញ្ញមិនអាចធ្វើបានឡើយ កាលបើប៉ះពាល់ដល់ប្រព័ន្ធប្រជាធិបតេយ្យ សេរីពហុបក្ស និងរបបរាជានិយមអាស្រ័យដោយរដ្ឋធម្មនុញ្ញ ។

## ជំពូកទី ១៦ ថ្មី

## អំពី

## អន្តរប្បញ្ញត្តិ

មាត្រា ១៥៤ .-ថ្មី

រដ្ឋធម្មនុញ្ញនេះ ក្រោយពីបានទទួលការអនុម័ត ត្រូវបានប្រកាសអោយចូលជាធរមានភ្លាមដោយព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ១៥៥ .-ថ្មី (មាត្រា ១៣៦ ចាស់)

ក្រោយពេលរដ្ឋធម្មនុញ្ញនេះចូលជាធរមាន សភាធម្មនុញ្ញត្រូវក្លាយទៅជារដ្ឋសភា ។

បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភាត្រូវចូលជាធរមាន ក្រោយទទួលបានការអនុម័តពីរដ្ឋសភា ។

ក្នុងករណីដែលរដ្ឋសភាមិនទាន់ចាប់ដំណើរការបាន ប្រធាន អនុប្រធានទីមួយ និងអនុប្រធានទីពីរនៃសភាធម្មនុញ្ញ នឹងចូលរួមបំពេញភារកិច្ចក្នុងក្រុមប្រឹក្សារាជសម្បត្តិបើសភាពការណ៍ក្នុងប្រទេសទាមទារ ។

មាត្រា ១៥៦ .-ថ្មី

ក្រោយរដ្ឋធម្មនុញ្ញនេះចូលជាធរមាន ព្រះមហាក្សត្រជ្រើសតាំងតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ១៣ថ្មី និង ១៤ ។

មាត្រា ១៥៧ .-ថ្មី

នីតិកាលទី១ នៃព្រឹទ្ធសភាមានកំណត់៥ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលព្រឹទ្ធសភាថ្មីចូលកាន់តំណែង ។

សំរាប់នីតិកាលទី១ នៃព្រឹទ្ធសភា :

-សមាជិកព្រឹទ្ធសភា មានចំនួនសរុប ហុកសិបមួយរូប ។

-ព្រះមហាក្សត្រទ្រង់តែងតាំងសមាជិកព្រឹទ្ធសភាពីររូប ព្រមទាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា ។

-សមាជិកដទៃទៀតនៃព្រឹទ្ធសភាត្រូវបានតែងតាំងដោយព្រះមហាក្សត្រ តាមសំណើរបស់ព្រឹទ្ធសភា និងប្រធានរដ្ឋសភា ក្នុងចំណោមសមាជិកនៃគណបក្សដែលមានអាសនៈនៅក្នុងរដ្ឋសភា ។

-កិច្ចប្រជុំជាសមាជិករដ្ឋសភា និងព្រឹទ្ធសភា ត្រូវដឹកនាំដោយសហប្រធាន ។

**មាត្រា ១៥៨ .-ថ្មី ( មាត្រា ១៣៩ ចាស់ )**

ច្បាប់ និងលិខិតបទដ្ឋានទាំងអស់នៅកម្ពុជា ដែលធានាការពារបាននូវទ្រព្យសម្បត្តិរដ្ឋ សិទ្ធិសេរីភាព និងទ្រព្យសម្បត្តិត្រឹមត្រូវតាមច្បាប់របស់បុគ្គលនិងដែលសមស្របនឹងប្រយោជន៍ជាតិត្រូវមានអានុភាពអនុវត្តបន្តទៅមុខទៀត រហូតដល់មានអត្ថបទថ្មីមកកែប្រែ ឬលុបចោល លើកលែងតែបទប្បញ្ញត្តិណាដែលផ្ទុយនឹងស្មារតីនៃរដ្ឋធម្មនុញ្ញនេះ ។

ច្បាប់ធម្មនុញ្ញនេះ ត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា អនុម័តនៅថ្ងៃទី ៤ ខែ មីនា ឆ្នាំ ១៩៩៩ ក្នុងសម័យប្រជុំវិសាមញ្ញ នីតិកាលទី២ ។

ភ្នំពេញ, ថ្ងៃទី ៦ ខែ មីនា ឆ្នាំ ១៩៩៩

ប្រធានរដ្ឋសភា

ព្រះហស្ថលេខា និងត្រា

**នរោត្តម រណឫទ្ធិ**

***

**ឧបសម្ព័ន្ធទី ៧**

# សច្ចាប្រណិធាន

**ទូលព្រះបង្គំ**

**យើងខ្ញុំ**

**ប្រធាន អនុប្រធាន និងសមាជិកព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា**

**សូមធ្វើសច្ចាប្រណិធាន**

**នៅចំពោះព្រះភក្ត្រព្រះមហាក្សត្រ ព្រះភក្ត្រនៃសម្តេចព្រះសង្ឃរាជ**

**និងទេវតារក្សាទេវតាឆ័ត្រ**

**ដូចតទៅ :**

-ក្នុងពេលប្រតិបត្តិការ តាមមុខតំណែងខ្លួន និងក្នុងការបំពេញបេសកកម្មដែលប្រជារាស្ត្រកម្ពុជាបានប្រគល់ជូនចំពោះទូលព្រះបង្គំយើងខ្ញុំគ្រប់រូប ទូលព្រះបង្គំយើងខ្ញុំសូមប្តេជ្ញាគោរពរដ្ឋធម្មនុញ្ញ បំរើជាតិច្ច

ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគតនូវផលប្រយោជន៍របស់ប្រជារាស្ត្រ ប្រជាជាតិ និងមាតុភូមិកម្ពុជា ។ ទូលព្រះបង្គំយើងខ្ញុំ សូមសច្ចាថា មិនកេងប្រវ័ញ្ចនូវផលប្រយោជន៍ជាតិ សំរាប់ផ្ទាល់ខ្លួន ឬសំរាប់គ្រួសារឬសំរាប់បក្សពួក ឬសំរាប់ភាគីរៀងៗខ្លួនឡើយ ។

-ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញាប្តូរផ្តាច់ហ៊ានបូជាជីវិត ដើម្បីការពារជានិច្ច ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគតនូវ :

- ឯករាជ្យភាពទាំងស្រុងនៃមាតុភូមិកម្ពុជា
- អធិបតេយ្យភាពជាតិពេញបរិបូរណ៍
- បូរណភាពទឹកដីដ៏ត្រឹមត្រូវតាមច្បាប់ នៅក្នុងព្រំដែនដីគោក និងព្រំដែនសមុទ្រ ដែលកម្ពុជាធ្លាប់មានក្នុងជំនាន់ ឆ្នាំ ១៩៦៣ ដល់ ១៩៦៩
- ឯកភាពជាតិ ហើយមិនអនុញ្ញាតអោយមានការបែងចែក ឬការធ្វើអបគមន៍ណាមួយឡើយ ។

-ទូលបង្គំយើងខ្ញុំ សូមប្តេជ្ញារក្សាទុកជានិច្ច ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគតនូវអព្យាក្រឹត្យភាព និងភាពមិនចូលបក្សសម្ព័ន្ធសំរាប់កម្ពុជា ហើយមិនអនុញ្ញាតជាដាច់ខាតអោយជនណាមួយក៏ដោយ ដែលចង់ជ្រៀតជ្រែកចូលក្នុងផ្ទៃក្នុងនៃកម្ពុជា ឬមកបង្អាប់បញ្ជាចំពោះគោលនយោបាយជាតិ និងអន្តរជាតិរបស់កម្ពុជាបានឡើយ ។ ទូលព្រះបង្គំយើងខ្ញុំ មិនបំពើជាដាច់ខាតនូវផលប្រយោជន៍បរទេស ហើយធ្វើអោយខូចខាតដល់ផលប្រយោជន៍របស់ប្រជារាស្ត្រ ប្រជាជាតិ និងមាតុភូមិកម្ពុជាឡើយ ។

-ក្នុងការដោះស្រាយបញ្ហាទាំងឡាយលើផ្នែករបជាតិ និងអន្តរជាតិ ទូលព្រះបង្គំយើងខ្ញុំនឹងបំបាត់ចោលទាំងស្រុងនូវអំពើហឹង្សាគ្រប់បែបយ៉ាង ។

ប៉ុន្តែព្រះរាជាណាចក្រកម្ពុជា សូមរក្សាទុកនូវសិទ្ធិកាន់អាវុធតស៊ូប្រឆាំងនឹងការរំលោភឈ្លានពានមកពីក្រៅ ដើម្បីការពារជាតិមាតុភូមិខ្លួន ។

-ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញាគោរពជានិច្ច ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគតនូវលទ្ធិប្រជាធិបតេយ្យ សេរីនិយម ដែលមានរបបសភា និងពហុបក្ស ព្រមទាំងមានការគោរពយ៉ាងម៉ឺងម៉ាត់ចំពោះសិទ្ធិមនុស្ស ដូចមានចែងក្នុងសេចក្តីប្រកាសជាសកលស្តីអំពីសិទ្ធិមនុស្ស ។

-ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញាតស៊ូប្រឆាំងអំពើពុករលួយគ្រប់បែបយ៉ាង ប្រឆាំងអយុត្តិធម៌សង្គម ហើយតស៊ូដើម្បីផ្សះផ្សាជាតិ ដើម្បីឯកភាពជាតិ ដើម្បីសន្តិភាពសង្គម និងសន្តិភាពជាតិ ដើម្បីភាពសម្បូរសប្បាយនៃប្រជារាស្ត្រកម្ពុជា និងដើម្បីភាពរុងរឿងថ្កើងថ្កាន នៃមាតុភូមិកម្ពុជា ជាទីគោរពសក្ការៈ និងជាទីស្នេហានៃទូលព្រះបង្គំយើងខ្ញុំគ្រប់រូប ។

★★★

# វិសោធនកម្មលើកទី៣

## ព្រះរាជក្រមលេខ នស/រកម/០៧០១/១១
## ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០១
## ប្រកាសឱ្យប្រើជាផ្លូវការនូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្ម
## មាត្រា១៩ និងមាត្រា២៩ នៃរដ្ឋធម្មនុញ្ញ
## នៃព្រះរាជាណាចក្រកម្ពុជា

### វិសោធនកម្មលើកទី៣ត្រូវបានស្នើឡើងដោយសមាជិកតំណាងរាស្ត្រ
### នៃគណបក្សទាំងបី ដែលចុះហត្ថលេខាស្នើសុំធ្វើវិសោធនកម្ម
### ដើម្បីញ៉ាំងឱ្យរដ្ឋធម្មនុញ្ញកាន់តែមានភាពសុក្រឹតឡើង។

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋសភា

# ច្បាប់ធម្មនុញ្ញ

## ស្តីពី

## វិសោធនកម្មមាត្រា ១៩ និងមាត្រា ២៩ នៃរដ្ឋធម្មនុញ្ញ

**មាត្រាតែមួយ** : មាត្រា១៩ និងមាត្រា២៩ នៃរដ្ឋធម្មនុញ្ញត្រូវបានកែប្រែដូចតទៅ :

**មាត្រា ១៩ ថ្មី.-**

ព្រះមហាក្សត្រទ្រង់តែងតាំងនាយករដ្ឋមន្ត្រីនិងទ្រង់តែងតាំងគណៈរដ្ឋមន្ត្រីតាមបែបបទដែលមានចែងក្នុងមាត្រា ១១៩ ថ្មី ។

**មាត្រា ២៩ ថ្មី.-**

ព្រះមហាក្សត្រទ្រង់បង្កើតនិងប្រទានគ្រឿងឥស្សរិយយសជាតិ ។

ព្រះមហាក្សត្រទ្រង់សំរេចប្រទានឋានន្តរសក្តិ ឋានៈ យោធានិងស៊ីវិលតាមច្បាប់កំណត់ ។

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
អនុម័តនៅថ្ងៃទី ២ ខែ កក្កដា ឆ្នាំ ២០០១ នាសម័យ
ប្រជុំរដ្ឋសភាលើកទី ៦ នីតិកាលទី ២ ។

ភ្នំពេញ,ថ្ងៃទី [illegible] ខែ កក្កដា ឆ្នាំ ២០០១

ប្រធានរដ្ឋសភា

នរោត្តម រណឫទ្ធិ

ឆ្នាំទី ៥ លេខ ២៨ ថ្ងៃ ៣១ ខែ កក្កដា ឆ្នាំ ២០០១ រាជកិច្ច ទំព័រ ១៩១៨

# ព្រះរាជក្រម

នស/រកម/០៧០១/១១

## យើង

## ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣
- បានទ្រង់យល់លទ្ធផលសម័យប្រជុំរដ្ឋសភាលើកទី ៦ នីតិកាលទី ២ នៅថ្ងៃច័ន្ទ ទី ២ ខែ កក្កដា ឆ្នាំ ២០០១
- បានទ្រង់យល់លទ្ធផលសម័យប្រជុំព្រឹទ្ធសភាលើកទី ៥ នីតិកាលទី ១ នៅថ្ងៃច័ន្ទទី ២៣ ខែ កក្កដា ឆ្នាំ ២០០១
- បានទ្រង់យល់លិខិតស្នើសុំរបស់សម្តេចព្រះប្រធានរដ្ឋសភា ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០១

## ត្រាស់បង្គាប់

មាត្រា ១ : ប្រកាសឱ្យប្រើជាផ្លូវការនូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១៩ និងមាត្រា ២៩ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័ត នៅថ្ងៃច័ន្ទ ទី ២ ខែ កក្កដា ឆ្នាំ ២០០១ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របលើទម្រង់ និងគតិច្បាប់នេះទាំងស្រុង កាលពីថ្ងៃច័ន្ទ ទី ២៣ ខែ កក្កដា ឆ្នាំ ២០០១ ៕

មាត្រា ២ : ព្រះរាជក្រមនេះចូលជាធរមាន ចាប់ពីពេលឡាយព្រះហស្តលេខានេះតទៅ ៕

នរោត្តម សីហនុ

ធ្វើនៅភ្នំពេញ, ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ ២០០១

# វិសោធនកម្មលើកទី៤

## ព្រះរាជក្រមលេខ នស/រកម/០៦០៥/០១៨
## ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥
## ប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្ម
## មាត្រា៨៨ និងមាត្រា១១១ ថ្មី នៃរដ្ឋធម្មនុញ្ញ
## នៃព្រះរាជាណាចក្រកម្ពុជា

**វិសោធនកម្មលើកទី៤ត្រូវបានធ្វើឡើងអនុលោមតាមការព្រមព្រៀងកំពូលរវាង**
**សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ព្រះប្រធានរដ្ឋសភា និង សម្តេច ហ៊ុន សែន**
**នាយករដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃព្រហស្បតិ៍ ទី១៧ ខែមីនា ឆ្នាំ២០០៥។**

# ព្រះរាជក្រម

នស/រកម/០៦០៥/០១៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា៨៨ និងមាត្រា១១១ថ្មី នៃរដ្ឋធម្មនុញ្ញ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០០៥ នាសម័យប្រជុំរដ្ឋសភាលើកទី ២ នីតិកាលទី ៣ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គលើកទី ៩ នីតិកាលទី ១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

cl-kram-10

# ច្បាប់ធម្មនុញ្ញ
# ស្ដីពី
# វិសោធនកម្មមាត្រា ៨៨ និងមាត្រា ១១១ថ្មី នៃរដ្ឋធម្មនុញ្ញ

**មាត្រាតែមួយ.-**

មាត្រា ៨៨ និងមាត្រា ១១១ថ្មី នៃរដ្ឋធម្មនុញ្ញ ត្រូវបានកែប្រែដូចតទៅ :

**មាត្រា ៨៨ ថ្មី.-**

ការប្រជុំរដ្ឋសភាត្រូវធ្វើជាសាធារណៈ ។

រដ្ឋសភាអាចប្រជុំជាសម្ងាត់បានតាមការស្នើសុំពីប្រធាន ឬពីសមាជិកចំនួនមួយភាគដប់យ៉ាងតិច ពីព្រះមហាក្សត្រ ឬ ពីនាយករដ្ឋមន្ត្រី ។

ការប្រជុំរដ្ឋសភានឹងយកជាការបាន លុះត្រាតែមាន :

ក-កូរ៉ុមប្រាំពីរភាគដប់នៃសមាជិករដ្ឋសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឱ្យយកមតិភាគច្រើនពីរភាគបី ឬយកមតិភាគច្រើនបីភាគបួននៃសមាជិករដ្ឋសភាទាំងមូល ។

ខ-កូរ៉ុមប្រាំមួយភាគដប់នៃសមាជិករដ្ឋសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឱ្យយកមតិភាគច្រើនដោយប្រៀប ឬយកមតិភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល ។

314

**មាត្រា ១១១ ថ្មី (មួយ).-**

ការប្រជុំព្រឹទ្ធសភាត្រូវធ្វើជាសាធារណៈ ។

ព្រឹទ្ធសភាអាចប្រជុំជាសម្ងាត់បាន តាមការស្នើសុំពីប្រធាន ឬពីសមាជិកចំនួនមួយភាគដប់យ៉ាងតិច ពីព្រះមហាក្សត្រ ពីនាយករដ្ឋមន្ត្រី ឬពីប្រធានរដ្ឋសភា ។

ការប្រជុំព្រឹទ្ធសភានឹងយកជាការបាន លុះត្រាតែមាន :

ក-កូរ៉ុមប្រាំពីរភាគដប់នៃសមាជិកព្រឹទ្ធសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឱ្យយកមតិភាគច្រើនពីរភាគបី ឬយកមតិភាគច្រើនបីភាគបួននៃសមាជិកព្រឹទ្ធសភាទាំងមូល ។

ខ-កូរ៉ុមប្រាំមួយភាគដប់នៃសមាជិកព្រឹទ្ធសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឱ្យយកមតិភាគច្រើនដោយប្រៀប ឬយកមតិភាគច្រើនដាច់ខាតនៃសមាជិកព្រឹទ្ធសភាទាំងមូល ។

ចំនួនសំឡេងដែលតម្រូវសម្រាប់រដ្ឋសភាអនុម័តយល់ព្រម ហើយដែលបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ ត្រូវយកមកប្រើសម្រាប់ព្រឹទ្ធសភាផងដែរ ។

ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០៥

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រាល-០៥០៦.២៩៨

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**ហ៊ុន សែន**

លេខ ២៧៥១ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល
[illegible]

៤/៤

# វិសោធនកម្មលើកទី៥

## ព្រះរាជក្រមលេខ នស/រកម/០៣០៦/០០៦
## ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០០៦
## ប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្ម
## មាត្រា៨២ មាត្រា៨៨ ថ្មី មាត្រា៩០ ថ្មី មាត្រា៩៨ មាត្រា១០៦ ថ្មី
## មាត្រា១១១ ថ្មី (មួយ) មាត្រា១១៤ ថ្មី នៃរដ្ឋធម្មនុញ្ញ និង
## មាត្រា៦ នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការ
## ជាប្រក្រតីនៃស្ថាប័នជាតិ

វិសោធនកម្មលើកទី៥ត្រូវបានធ្វើឡើងអនុលោមតាមការព្រមព្រៀងកំពូល
រវាងគណបក្សនយោបាយទាំងបី ដែលមានអាសនៈនៅក្នុងរដ្ឋសភា នីតិកាលទី៣។

# ព្រះរាជក្រម

នស/រកម/០៣០៦/០០៦

## យើង

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥-- ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់សំណើរបស់តំណាងរាស្ត្រចំនួនលើសពីមួយភាគបួននៃចំនួនតំណាងរាស្ត្រទាំងមូល

-បានទ្រង់យល់លិខិតលេខ ៨២ លស ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០៦ របស់សម្ដេចនាយករដ្ឋមន្ត្រី

-បានទ្រង់យល់លិខិតលេខ ០០១/០១/២០០៦ កបធ ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០០៦ របស់ក្រុមប្រឹក្សាធម្មនុញ្ញ

-បានទ្រង់យល់ព្រះរាជសារព្រះមហាក្សត្រចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០៦

-បានទ្រង់យល់លិខិតលេខ ២៩៤ រស ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០០៦ របស់រដ្ឋសភា

-បានទ្រង់យល់លិខិតលេខ ០១៣/០៣០៦/ពស/នវ ចុះថ្ងៃទី ០៨ ខែមីនា ឆ្នាំ ២០០៦ របស់ព្រឹទ្ធសភា

-បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់ សម្ដេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី

## ប្រកាសឱ្យប្រើ

ច្បាប់ធម្មនុញ្ញស្ដីពីវិសោធនកម្មមាត្រា៨២ មាត្រា៨៨ថ្មី មាត្រា៩០ថ្មី មាត្រា៩៨ មាត្រា១០៦ថ្មី មាត្រា១១ថ្មី(មួយ) មាត្រា១១៤ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា៦ នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ ដែលរដ្ឋសភាអនុម័តនៅថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី ៤ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាពុំមានពេលវេលាគ្រប់គ្រាន់ដើម្បីពិនិត្យច្បាប់នេះឱ្យទាន់តាមការកំណត់របស់មាត្រា១១៣ថ្មីនៃរដ្ឋធម្មនុញ្ញ ហើយដែលមានសេចក្ដីទាំងស្រុងដូចតទៅនេះ :

9-03-06

# ច្បាប់ធម្មនុញ្ញ
# ស្ដីពី
# វិសោធនកម្ម
# មាត្រា ៨២ មាត្រា ៨៨ថ្មី មាត្រា ៩០ថ្មី មាត្រា ៩៨ មាត្រា ១០៦ថ្មី មាត្រា ១១១ថ្មី(មួយ) មាត្រា ១១៤ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា ៦ នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការ ជាប្រក្រតីនៃស្ថាប័នជាតិ

**មាត្រាតែមួយ.–**

មាត្រា ៨២ មាត្រា ៨៨ថ្មី មាត្រា ៩០ថ្មី មាត្រា ៩៨ មាត្រា ១០៦ថ្មី មាត្រា ១១១ថ្មី (មួយ) មាត្រា ១១៤ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា ៦ នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ ត្រូវបានកែប្រែដូចតទៅ ៖

**មាត្រា ៨២.– ថ្មី**

រដ្ឋសភាបើកសម័យប្រជុំដំបូង ហុកសិបថ្ងៃយ៉ាងយូរ ក្រោយពេលបោះឆ្នោត តាមការកោះប្រជុំរបស់ព្រះមហាក្សត្រ ។

មុនចាប់ផ្ដើមការងាររបស់ខ្លួន រដ្ឋសភាត្រូវប្រកាសសុពលភាព នៃអាណត្តិរបស់សមាជិកនីមួយៗ ត្រូវបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នា នូវប្រធាន អនុប្រធាន រដ្ឋសភា និង សមាជិកទាំងអស់នៃគណៈកម្មការនានារបស់រដ្ឋសភា ដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

រដ្ឋសភាត្រូវអនុម័តបទបញ្ជាផ្ទៃក្នុង ដោយមតិភាគច្រើនដាច់ខាត នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

តំណាងរាស្ត្រទាំងអស់ ត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់តំណែង ដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធទី៥ នៃរដ្ឋធម្មនុញ្ញ ។

**មាត្រា ៨៨ ...ថ្មី(ពីរ)**

ការប្រជុំរដ្ឋសភាត្រូវធ្វើជាសាធារណៈ ។

រដ្ឋសភាអាចប្រជុំជាសម្ងាត់បានតាមការស្នើសុំពីប្រធាន ឬ ពីសមាជិកចំនួនមួយភាគដប់យ៉ាងតិច ពីព្រះមហាក្សត្រ ឬ ពីនាយករដ្ឋមន្ត្រី ។

ការប្រជុំរដ្ឋសភា នឹងយកជាការបានលុះត្រាតែមាន :

ក- កូរ៉ុមលើសពី ពីរភាគបី នៃចំនួនសមាជិករដ្ឋសភាទាំងមូលសម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឱ្យយកមតិភាគច្រើន ពីរភាគបី នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

ខ- កូរ៉ុមលើសពីពាក់កណ្តាល នៃចំនួនសមាជិករដ្ឋសភាទាំងមូលសម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឱ្យយកមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

**មាត្រា ៩០ ...ថ្មី(ពីរ)**

រដ្ឋសភាជាអង្គការ ដែលមានអំណាចនីតិបញ្ញត្តិ ហើយបំពេញភារកិច្ចរបស់ខ្លួនដូចបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន ។

រដ្ឋសភាអនុម័តថវិកាជាតិ ផែនការរដ្ឋ ការឱ្យរដ្ឋខ្ចីប្រាក់ពីគេ ការឱ្យរដ្ឋឱ្យប្រាក់គេខ្ចី ការសន្យានានាផ្នែកហិរញ្ញវត្ថុ និងការបង្កើត កែប្រែ ឬ លុបចោលពន្ធដារ ។

រដ្ឋសភាឱ្យសេចក្តីយល់ព្រមចំពោះគណនីរដ្ឋបាល ។

រដ្ឋសភាអនុម័តច្បាប់ស្តីពីការលើកលែងទោសជាទូទៅ ។

រដ្ឋសភាអនុម័តយល់ព្រម ឬ លុបចោលសន្ធិសញ្ញា ឬ អនុសញ្ញាអន្តរជាតិ ។

រដ្ឋសភាអនុម័តច្បាប់ស្តីពីការប្រកាសសង្គ្រាម ។

ការអនុម័តខាងលើនេះប្រព្រឹត្តទៅដោយមតិភាគច្រើនដាច់ខាត នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

រដ្ឋសភាបោះឆ្នោតទុកចិត្តដល់រាជរដ្ឋាភិបាលតាមមតិភាគច្រើនដាច់ខាត នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

**មាត្រា ៩៨ .- ថ្មី**

រដ្ឋសភាអាចទម្លាក់សមាជិកគណៈរដ្ឋមន្ត្រី ឬ ទម្លាក់រាជរដ្ឋាភិបាលពីតំណែង ដោយអនុម័តញត្តិបន្ទោស តាមសំឡេងឆ្នោតភាគច្រើនដាច់ខាត នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

ញត្តិបន្ទោសរាជរដ្ឋាភិបាល ត្រូវបានលើកឡើងជូនរដ្ឋសភាដោយតំណាងរាស្ត្រចំនួនសាមសិបនាក់ ទើបរដ្ឋសភាអាចលើកមកពិភាក្សាបាន ។

**មាត្រា ១០៦ .- ថ្មី(មួយ)**

ព្រឹទ្ធសភាបើកសម័យប្រជុំដំបូង ហុកសិបថ្ងៃយ៉ាងយូរក្រោយពេលបោះឆ្នោត តាមការកោះប្រជុំរបស់ព្រះមហាក្សត្រ ។

មុនចាប់ផ្តើមការងាររបស់ខ្លួន ព្រឹទ្ធសភាត្រូវប្រកាសសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗ និងត្រូវបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នា នូវប្រធាន អនុប្រធានព្រឹទ្ធសភា និងសមាជិកទាំងអស់នៃគណៈកម្មការនានារបស់ព្រឹទ្ធសភា ដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

សមាជិកព្រឹទ្ធសភាទាំងអស់ ត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់តំណែង ដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធទី ៧ នៃរដ្ឋធម្មនុញ្ញ ។

**មាត្រា ១១១ .- ថ្មី(ពីរ)**

ការប្រជុំព្រឹទ្ធសភាត្រូវធ្វើជាសាធារណៈ ។

ព្រឹទ្ធសភាអាចប្រជុំជាសម្ងាត់បានតាមការស្នើសុំពីប្រធាន ឬ ពីសមាជិកចំនួនមួយភាគដប់យ៉ាងតិច ពីព្រះមហាក្សត្រ ពីនាយករដ្ឋមន្ត្រី ឬ ពីប្រធានរដ្ឋសភា ។

ការប្រជុំព្រឹទ្ធសភានឹងយកជាការបាន លុះត្រាតែមាន :

ក-កូរ៉ុមលើសពី ពីរភាគបី នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឱ្យយកមតិភាគច្រើន ពីរភាគបី នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

ខ-កូរ៉ុមលើសពីពាក់កណ្តាលនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឱ្យយកមតិភាគច្រើនដោយប្រៀប ឬ យកមតិភាគច្រើនដាច់ខាត នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

ចំនួនសំឡេងដែលតម្រូវសម្រាប់រដ្ឋសភាអនុម័តយល់ព្រម ហើយដែលមានកំណត់ក្នុងរដ្ឋធម្មនុញ្ញត្រូវយកមកប្រើសម្រាប់ព្រឹទ្ធសភាផងដែរ ។

**មាត្រា ១១៤ .- ថ្មី(មួយ)**

ព្រឹទ្ធសភាបង្កើតគណៈកម្មការផ្សេងៗ ដែលចាំបាច់ ។ ការរៀបចំនិងការប្រព្រឹត្តទៅនៃព្រឹទ្ធសភានឹងកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភា ។ បទបញ្ជាផ្ទៃក្នុងនេះត្រូវអនុម័តយល់ព្រម ដោយសំឡេងភាគច្រើនដាច់ខាត នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

**មាត្រា ៦ .— ថ្មី នៃច្បាប់ធម្មនុញ្ញបន្ថែម**

ការបោះឆ្នោតជាកញ្ចប់ខាងលើនេះ ត្រូវយកតាមមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

ក្នុងករណីការបោះឆ្នោតជុំទីមួយមិនបានសម្រេច នីតិវិធីដដែលនេះនឹងត្រូវអនុវត្តចំពោះការបោះឆ្នោតជុំក្រោយៗទៀត ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ៩ ខែ មីនា ឆ្នាំ ២០០៦

នស/រកម/០៣០៦/១២៤ **ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**ហត្ថលេខា**

**សុខ អាន**

លេខ ១១៣ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មីនា ឆ្នាំ២០០៦

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ណារី តាន់**

# វិសោធនកម្មលើកទី៦

## ព្រះរាជក្រមលេខ នស/រកម/០២០៨/០០៨
## ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨
## ប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញស្ដីពីវិសោធនកម្ម
## មាត្រា១៤៥ ថ្មី និងមាត្រា១៤៦ នៃរដ្ឋធម្មនុញ្ញ
## នៃព្រះរាជាណាចក្រកម្ពុជា

វិសោធនកម្មលើកទី៦ត្រូវបានធ្វើឡើងតាមការស្នើសុំរបស់រាជរដ្ឋាភិបាលកម្ពុជា។

ឆ្នាំ ទី ៨ លេខ ១៤ សប្តាហ៍ទី ៣ ថ្ងៃ ទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០០៨ រាជកិច្ច ទំព័រ ១៤១៦

# ព្រះរាជក្រម

នស/រកម/០២០៨/០០៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្ក ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមក ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ប្រកាសឱ្យប្រើ

ច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្ម មាត្រា ១៤៥ ថ្មី និងមាត្រា ១៤៦ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១ ខែមករា ឆ្នាំ២០០៨ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៣ និងដែលព្រឹទ្ធសភ ពុំមានពេលវេលាគ្រប់គ្រាន់អាចពិនិត្យ និងឱ្យយោបល់តាមលក្ខខណ្ឌកំណត់ ក្នុងមាត្រ ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញបានឡើយ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ

ROYAUME DU CAMBODGE

ច្បាប់ធម្មនុញ្ញ

ស្តីពីវិសោធនកម្ម

មាត្រា១៤៥ថ្មី និងមាត្រា១៤៦ ថ្មី

នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

មាត្រាមួយ.-

មាត្រា ១៤៥ ថ្មី និងមាត្រា ១៤៦ ថ្មី ជំពូកទី ១៣ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានធ្វើវិសោធនកម្មដូចតទៅ :

មាត្រា១៤៥ .-ថ្មី (មួយ)

ទឹកដីនៃព្រះរាជាណាចក្រកម្ពុជាចែកជា រាជធានី ខេត្ត ក្រុង ស្រុក-ខណ្ឌ ឃុំ សង្កាត់ ។

មាត្រា១៤៦ .-ថ្មី (មួយ)

រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ត្រូវគ្រប់គ្រងតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងច្បាប់រៀបចំអង្គការ ។

មាត្រាពីរ .-

ច្បាប់ធម្មនុញ្ញនេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ ២០០៨

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

ចស.០២០២.១៣៥

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ហត្ថលេខា

ស ខេង

លេខ ១៣៣ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែ កុម្ភៈ ឆ្នាំ២០០៨

អគ្គលេខាធិការរាជរដ្ឋាភិបាល

# វិសោធនកម្មលើកទី៧

## ព្រះរាជក្រមលេខ នស/រកម/១០១៤/០២២
## ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤
## ប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញស្ដីពីវិសោធនកម្ម
## មាត្រា៧៦ និងមាត្រាទាំងឡាយពីជំពូកទី១៥ ថ្មី
## ដល់ជំពូកទី១៦ ថ្មី នៃរដ្ឋធម្មនុញ្ញ
## នៃព្រះរាជាណាចក្រកម្ពុជា

**វិសោធនកម្មលើកទី៧ត្រូវបានធ្វើឡើងតាមសេចក្ដីស្នើពីតំណាងរាស្ត្រហត្ថលេខីចំនួន៨៥រូបដែលបានផ្ដួចផ្ដើមគំនិតធ្វើសេចក្ដីស្នើច្បាប់ធម្មនុញ្ញស្ដីពីវិសោធនកម្ម។**

រដ្ឋសភា
ចូល លេខ [illegible]
ថ្ងៃទី [illegible] ឆ្នាំ២០១៤ ម៉ោង [illegible]
បញ្ជូនទៅ [illegible]

# ព្រះរាជក្រម

នស/រកម/១០១៤/០២២

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា៧៦ និងមាត្រាទាំងឡាយពីជំពូកទី១៥ ថ្មី ដល់ជំពូកទី១៦ ថ្មី នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៤ នាសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៤ នាសម័យប្រជុំវិសាមញ្ញ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

១/៦

ចែង និងគ្រប់គ្រងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងការបោះឆ្នោតជ្រើសតាំងតំណាង-រាស្ត្រ ព្រមទាំងការបោះឆ្នោតផ្សេងទៀត តាមការកំណត់នៃច្បាប់ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវអនុវត្តសមត្ថកិច្ចរបស់ខ្លួន ប្រកបដោយឯករាជ្យ និងអព្យាក្រឹត ដើម្បីធានាឲ្យការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ស្របតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស ។

មុខងារជាសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានវិសមិតភាពជាមួយការបំពេញមុខតំណែងក្នុងមុខងារសាធារណៈ និងជាមួយមុខងារជាសមាជិកនៃស្ថាប័នដទៃទៀត ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនេះ ។ សមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមិនអាចធ្វើជាសមាជិកនៃគណបក្សនយោបាយ ឬធ្វើជាអ្នកដឹកនាំនៃអង្គការមិនមែនរដ្ឋាភិបាល សមាគម សហជីព ឬក្រុមហ៊ុនពាណិជ្ជកម្មណាមួយបានឡើយ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានថវិកាស្វយ័តសម្រាប់ដំណើរការ ។

**មាត្រា ១៥១.– ថ្មី(ពីរ)**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានសមាសភាពប្រាំបួនរូបដែលទទួលអាណត្តិប្រាំឆ្នាំ ។ សមាសភាពបួនរូបត្រូវជ្រើសរើសដោយគណបក្សដឹកនាំរាជរដ្ឋាភិបាល បួនរូបត្រូវជ្រើសរើសដោយគណបក្សមានអាសនៈក្នុងរដ្ឋសភាដែលមិនចូលរួមក្នុងរាជរដ្ឋាភិបាល និង មួយរូប ត្រូវជ្រើសរើសដោយមានការព្រមព្រៀងគ្នារវាងគណបក្សទាំងអស់ដែលមានអាសនៈក្នុងរដ្ឋសភា ។

គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ត្រូវដំណើរការរៀបចំឲ្យមានការជ្រើសរើសដោយបើកចំហ និងតម្លាភាព នូវសមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។ គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា រៀបចំបញ្ជីសមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដាក់ជូនរដ្ឋសភាដើម្បីបោះឆ្នោតទុកចិត្តតាមមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

សមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ។

ក្នុងករណីសមាជិកណាមួយនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បាត់បង់សមាជិកភាពរបស់ខ្លួន គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាត្រូវចាត់នីតិវិធីជ្រើសរើស សមាសភាពថ្មីជំនួស ក្នុងរយៈពេលយ៉ាងយូរ ១៥ ថ្ងៃ គិតពីថ្ងៃបាត់បង់សមាជិកភាព ។ នីតិវិធីលំអិតនៃការជ្រើសរើសសមាសភាពថ្មី ជំនួស ត្រូវកំណត់ដោយឡែកក្នុងច្បាប់ ។

ROYAUME DU CAMBODGE MINISTRE DU PALAIS ROYAL

៣/៦

## ច្បាប់ធម្មនុញ្ញ
## ស្តីពី
## វិសោធនកម្មមាត្រា ៧៦ និងមាត្រាទាំងឡាយពីជំពូកទី ១៥ ថ្មី ដល់ជំពូកទី ១៦ ថ្មី នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

**មាត្រាតែមួយ.-**

មាត្រា ៧៦ និងមាត្រាទាំងឡាយពី ជំពូកទី ១៥ ថ្មី ដល់ជំពូកទី ១៦ ថ្មី នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានកែប្រែដូចតទៅ ៖

**មាត្រា ៧៦.- ថ្មី**

រដ្ឋសភាមានសមាជិកតំណាងរាស្ត្រយ៉ាងតិច ១២០ រូប ។

តំណាងរាស្ត្រ ត្រូវជ្រើសតាំងដោយការបោះឆ្នោតជាសកល ដោយសេរី ដោយស្មើភាព ដោយចំពោះ និងតាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់ ។

តំណាងរាស្ត្រអាចឈរឈ្មោះបោះឆ្នោតសាជាថ្មីបាន ។

អ្នកដែលមានសិទ្ធិឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រ គឺជាប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានសិទ្ធិបោះឆ្នោត មានអាយុយ៉ាងតិច ២៥ឆ្នាំ មានសញ្ជាតិជាខ្មែរតាំងពីកំណើត ។

បែបបទ និងការប្រព្រឹត្តទៅនៃការបោះឆ្នោត ត្រូវកំណត់ក្នុងច្បាប់បោះឆ្នោត ។

### ជំពូកទី ១៥ ថ្មី(ពីរ)
### អំពីអង្គការរៀបចំការបោះឆ្នោត

**មាត្រា ១៥០.- ថ្មី (ពីរ)**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គឺជាអង្គការដែលមានសមត្ថកិច្ចរៀបចំចាត់

២/៦

ក្នុងករណីដែលខកខានមិនបានរៀបចំសមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលមានស្រាប់ ត្រូវអនុវត្តការងាររបស់ខ្លួនបន្តទៀត និងមានសមត្ថកិច្ចដើម្បីចាត់ចែងរៀបចំការបោះឆ្នោតតាមច្បាប់ ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត នឹងត្រូវកំណត់ក្នុងច្បាប់មួយ ។

## ជំពូកទី ១៦ ថ្មី (ពីរ)
## អំពីអានុភាព ការសើរើ និងវិសោធនកម្មរដ្ឋធម្មនុញ្ញ

**មាត្រា ១៥២.- ថ្មី (ពីរ មាត្រា ១៥០ ថ្មី)**

រដ្ឋធម្មនុញ្ញនេះជាច្បាប់កំពូល នៃព្រះរាជាណាចក្រកម្ពុជា ។

ច្បាប់ និងសេចក្ដីសម្រេចទាំងឡាយនៃស្ថាប័ននានារបស់រដ្ឋ ត្រូវស្របនឹងរដ្ឋធម្មនុញ្ញជាដាច់ខាត ។

**មាត្រា ១៥៣.- ថ្មី (ពីរ មាត្រា ១៥១ ថ្មី)**

ការផ្ដើមគំនិតសើរើ ឬការផ្ដើមគំនិតធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញជាសិទ្ធិរបស់ព្រះមហាក្សត្រ របស់នាយករដ្ឋមន្ត្រី និងរបស់ប្រធានរដ្ឋសភា តាមសេចក្ដីស្នើរបស់តំណាងរាស្ត្រមួយភាគបួននៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

ការសើរើ ឬវិសោធនកម្មរដ្ឋធម្មនុញ្ញ ត្រូវធ្វើឡើងដោយច្បាប់ធម្មនុញ្ញមួយ ដែលអនុម័តដោយរដ្ឋសភា តាមមតិភាគច្រើនពីរភាគបី នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

**មាត្រា ១៥៤.- ថ្មី (ពីរ មាត្រា ១៥២ ថ្មី)**

ការសើរើ ឬវិសោធនកម្មរដ្ឋធម្មនុញ្ញ ត្រូវហាមឃាត់មិនឲ្យធ្វើ នៅពេលប្រទេសជាតិឋិតក្នុងភាពអាសន្ន ដូចមានចែងក្នុងមាត្រា ៨៦ ។

**មាត្រា ១៥៥.- ថ្មី (ពីរ មាត្រា ១៥៣ ថ្មី)**

ការសើរើ ឬវិសោធនកម្មរដ្ឋធម្មនុញ្ញមិនអាចធ្វើបានឡើយ កាលបើប៉ះពាល់ដល់ប្រព័ន្ធប្រជាធិបតេយ្យ សេរីពហុបក្ស និងរបបរាជានិយមអាស្រ័យដោយរដ្ឋធម្មនុញ្ញ ។

## ជំពូកទី ១៧ ថ្មី
## អំពីអន្តរប្បញ្ញត្តិ

**មាត្រា ១៥៦.- ថ្មី (ពីរ មាត្រា ១៥៤ ថ្មី)**

រដ្ឋធម្មនុញ្ញនេះ ក្រោយពីបានទទួលការអនុម័ត ត្រូវបានប្រកាសឲ្យចូលជាធរមានភ្លាម ដោយព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ១៥៧.- ថ្មី (ពីរ មា ត្រា ១៥៥ ថ្មី)**

ក្រោយពេលរដ្ឋធម្មនុញ្ញនេះចូលជាធរមាន សភាធម្មនុញ្ញត្រូវក្លាយទៅជារដ្ឋសភា ។

បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភាត្រូវចូលជាធរមាន ក្រោយទទួលបានការអនុម័តពីរដ្ឋសភា ។

ក្នុងករណីដែលរដ្ឋសភាមិនទាន់ចាប់ដំណើរការបាន ប្រធាន អនុប្រធានទីមួយ និង អនុប្រធានទីពីរ នៃសភាធម្មនុញ្ញ នឹងចូលរួមបំពេញភារកិច្ចក្នុងក្រុមប្រឹក្សារាជសម្បត្តិ បើសភាពការណ៍ក្នុងប្រទេសទាមទារ ។

**មាត្រា ១៥៨.- ថ្មី(ពីរ មាត្រា ១៥៦ ថ្មី)**

ក្រោយរដ្ឋធម្មនុញ្ញនេះចូលជាធរមាន ព្រះមហាក្សត្រជ្រើសតាំងតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ១៣ ថ្មី និង ១៤ ។

**មាត្រា ១៥៩.- ថ្មី (ពីរ មាត្រា ១៥៧ ថ្មី)**

នីតិកាលទី ១ នៃព្រឹទ្ធសភាមានកំណត់ ៥ ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលព្រឹទ្ធសភាថ្មីចូលកាន់តំណែង ។

សម្រាប់នីតិកាលទី ១ នៃព្រឹទ្ធសភា :

-សមាជិកព្រឹទ្ធសភាមានចំនួនសរុបហុកសិបមួយរូប ។

-ព្រះមហាក្សត្រទ្រង់តែងតាំងសមាជិកព្រឹទ្ធសភាពីររូប ព្រមទាំងប្រធាន អនុប្រធានទី ១ អនុប្រធានទី ២ នៃព្រឹទ្ធសភា ។

-សមាជិកដទៃទៀតនៃព្រឹទ្ធសភា ត្រូវបានតែងតាំងដោយព្រះមហាក្សត្រ តាមសំណើរបស់ប្រធានព្រឹទ្ធសភា និងប្រធានរដ្ឋសភា ក្នុងចំណោមសមាជិក នៃគណបក្សដែលមានអាសនៈនៅក្នុងរដ្ឋសភា ។

-កិច្ចប្រជុំជាសមាជរដ្ឋសភា និងព្រឹទ្ធសភា ត្រូវដឹកនាំដោយសហប្រធាន ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

៥/៦

**មាត្រា ១៦០.- ថ្មី (ពីរ មាត្រា ១៥៨ ថ្មី)**

ច្បាប់ និងលិខិតបទដ្ឋានទាំងអស់នៅកម្ពុជា ដែលជានាការពារបាននូវទ្រព្យសម្បត្តិរដ្ឋ សិទ្ធិសេរីភាព និងទ្រព្យសម្បត្តិត្រឹមត្រូវតាមច្បាប់របស់បុគ្គល និងដែលសមស្របនឹងប្រយោជន៍ជាតិ ត្រូវមានអានុភាពអនុវត្តបន្តទៅមុខទៀត រហូតដល់មានអត្ថបទថ្មីមកកែប្រែ ឬលុបចោល លើកលែងតែបទប្បញ្ញត្តិណាដែលផ្ទុយនឹងស្មារតីនៃរដ្ឋធម្មនុញ្ញនេះ ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១៤

នស/រកម. ១៤១០.១៧០៤

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

លេខ:១៣៦៥ស.ណ

**សំណៅចែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ ១៣ ឆ្នាំ២០១៤

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

៦/៦

# វិសោធនកម្មលើកទី៨

## ព្រះរាជក្រមលេខ នស/រកម/0២១៨/00២
## ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៨
## ប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញស្ដីពីវិសោធនកម្ម
## មាត្រា៣៤ ថ្មី មាត្រា៤២ មាត្រា៤៩ មាត្រា៥៣ និងមាត្រា
## ១១៨ ថ្មីនៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

វិសោធនកម្មលើកទី៨ត្រូវបានធ្វើឡើងស្របតាមគំនិតផ្ដួចផ្ដើមដ៏ខ្ពង់ខ្ពស់
របស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
នៃព្រះរាជាណាចក្រកម្ពុជា។

រដ្ឋសភា
ចូល លេខ..........
ថ្ងៃទី.......... ឆ្នាំ.......... ម៉ោង..........
បញ្ជូនទៅ..........

# ព្រះរាជក្រម

នស/រកម/០២១៨/០០៤

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា៣៤ ថ្មី មាត្រា៤២ មាត្រា៤៩ មាត្រា៥៣ និងមាត្រា១១៨ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៨ នាសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៨ នាសម័យប្រជុំពេញអង្គលើកទី១១ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

១/៤

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

## ច្បាប់ធម្មនុញ្ញ
## ស្ដីពីវិសោធនកម្ម
## មាត្រា៣៤ ថ្មី មាត្រា៤២ មាត្រា៤៩ មាត្រា៥៣ និងមាត្រា១១៨ ថ្មី
## នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

**មាត្រាមួយ..**

មាត្រា៣៤ ថ្មី មាត្រា៤២ មាត្រា៤៩ មាត្រា៥៣ និងមាត្រា១១៨ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណា-ចក្រកម្ពុជា ត្រូវបានធ្វើវិសោធនកម្មដូចតទៅ៖

**មាត្រា៣៤.. ថ្មី (មួយ)**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិបោះឆ្នោត និងអាចឈរឈ្មោះឱ្យគេបោះឆ្នោត។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ១៨ ឆ្នាំ មានសិទ្ធិបោះឆ្នោត។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ២៥ ឆ្នាំ អាចឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសតាំងជាតំណាងរាស្ត្រ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ៤០ ឆ្នាំ អាចឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសតាំងជាសមាជិកព្រឹទ្ធសភា។

បទប្បញ្ញត្តិដកសិទ្ធិបោះឆ្នោត និងសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតត្រូវកំណត់ក្នុងច្បាប់។

**មាត្រា៤២.. ថ្មី**

ប្រជាពលរដ្ឋខ្មែរមានសិទ្ធិបង្កើតសមាគមនិងគណបក្សនយោបាយ។ សិទ្ធិនេះត្រូវកំណត់ក្នុងច្បាប់។

គណបក្សនយោបាយត្រូវតម្កល់ផលប្រយោជន៍ជាតិជាធំ ហើយមិនត្រូវធ្វើសកម្មភាពណាមួយទោះដោយផ្ទាល់ក្ដី ឬដោយប្រយោលក្ដី នាំឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ព្រះរាជាណាចក្រកម្ពុជា និងប្រជាពលរដ្ឋខ្មែរឡើយ។

ប្រជាពលរដ្ឋខ្មែរទាំងឡាយ អាចចូលរួមក្នុងអង្គការមហាជន ជួយគ្នាទៅវិញទៅមក ការពារសមិទ្ធផលជាតិ និងសណ្ដាប់ធ្នាប់សង្គម។




២/៤

**មាត្រា៤៩.. ថ្មី**

ប្រជាពលរដ្ឋខ្មែរគ្រប់រូបត្រូវគោរពរដ្ឋធម្មនុញ្ញ និងគោរពច្បាប់។

ប្រជាពលរដ្ឋខ្មែរគ្រប់រូបត្រូវតម្កល់ផលប្រយោជន៍ជាតិជាធំ ហើយមិនត្រូវធ្វើសកម្មភាពណាមួយ ទោះដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី នាំឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ព្រះរាជាណាចក្រកម្ពុជា និងប្រជាពលរដ្ឋខ្មែរឡើយ។

ប្រជាពលរដ្ឋខ្មែរគ្រប់រូបមានកាតព្វកិច្ចរួមចំណែកកសាងប្រទេសជាតិ និងការពារមាតុភូមិ។

កាតព្វកិច្ចការពារមាតុភូមិត្រូវអនុវត្តតាមបញ្ញត្តិច្បាប់។

**មាត្រា៥៣.. ថ្មី**

ព្រះរាជាណាចក្រកម្ពុជាប្រកាន់ខ្ជាប់ជានិច្ចនូវនយោបាយអព្យាក្រឹតអចិន្ត្រៃយ៍ និងមិនចូលបក្សសម្ព័ន្ធ។ ព្រះរាជាណាចក្រកម្ពុជារួមរស់ដោយសន្តិសហវិជ្ជមានជាមួយប្រទេសជិតខាង និងប្រទេសដទៃទៀតទាំងអស់នៅលើសកលលោក។

ព្រះរាជាណាចក្រកម្ពុជាមិនឈ្លានពានប្រទេសណាដាច់ខាត មិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងនៃប្រទេសដទៃដោយផ្ទាល់ ឬដោយប្រយោល ទោះបីក្រោមរូបភាពណាក៏ដោយ ដោះស្រាយរាល់បញ្ហាដោយសន្តិវិធី និងគោរពផលប្រយោជន៍ផងគ្នាទៅវិញទៅមក។

ព្រះរាជាណាចក្រកម្ពុជាប្រឆាំងដាច់ខាតការជ្រៀតជ្រែកពីបរទេស ចូលក្នុងកិច្ចការផ្ទៃក្នុងរបស់ខ្លួន ទោះបីក្រោមរូបភាពណាក៏ដោយ។

ព្រះរាជាណាចក្រកម្ពុជាមិនចងសម្ព័ន្ធយោធា ឬចូលក្នុងកិច្ចព្រមព្រៀងយោធាណាមួយ ដែលមិនស្របនឹងអព្យាក្រឹតភាពរបស់ខ្លួនឡើយ។

ព្រះរាជាណាចក្រកម្ពុជាមិនអនុញ្ញាតឱ្យមានមូលដ្ឋានយោធាបរទេសនៅលើទឹកដីរបស់ខ្លួន ហើយក៏មិនអនុញ្ញាតឱ្យមានមូលដ្ឋានយោធារបស់ខ្លួននៅបរទេសដែរ លើកលែងតែក្នុងក្របខ័ណ្ឌនៃសំណូមពររបស់អង្គការសហប្រជាជាតិ។

ព្រះរាជាណាចក្រកម្ពុជារក្សាសិទ្ធិទទួលយកជំនួយបរទេសជាសម្ភារៈយោធា អាវុធ គ្រាប់រំសេវ ការហ្វឹកហ្វឺនកងកម្លាំងប្រដាប់អាវុធ និងជំនួយផ្សេងៗទៀត ដើម្បីការពារខ្លួន និងធានាសណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈនៅផ្ទៃក្នុងប្រទេស។

**មាត្រា១១៨.. ថ្មី (មួយ)**

គណៈរដ្ឋមន្ត្រីជារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

គណៈរដ្ឋមន្ត្រី ត្រូវបានដឹកនាំដោយនាយករដ្ឋមន្ត្រីមួយរូប អមដោយឧបនាយករដ្ឋមន្ត្រី ព្រមទាំង ទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រី ជាសមាជិក។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

៣/៤

**មាត្រាពីរ..**

មាត្រា១១៨ ថ្មី (មួយ) នៃច្បាប់ធម្មនុញ្ញនេះ ត្រូវយកទៅអនុវត្តចាប់ពីនីតិកាលទី៦ នៃរដ្ឋសភាតទៅ។

**មាត្រាបី..**

ច្បាប់ធម្មនុញ្ញនេះ ត្រូវប្រកាសជាការប្រញាប់។

ថ្ងៃ អង្គារ ១៣ កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៨

**ក្នុងព្រះបរមនាមនិងតាមព្រះរាជបន្ទូលបង្គាប់**

**ប្រមុខរដ្ឋស្ដីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ**

[illegible]

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្ថលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

លេខៈ២៥៦ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

ថ្ងៃពុធ ទី១៤កើត ខែផល្គុន ឆ្នាំរកា នព្វស័ក.ព.ស.២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែកុម្ភៈ ឆ្នាំ២០១៨

**ជ.អគ្គលេខាធិការរាជរដ្ឋាភិបាល**

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ជាង អេងចូន**

៨៤

# វិសោធនកម្មលើកទី៩

## ព្រះរាជក្រមលេខ នស/រកម/១១២១/០១៦
## ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២១
## ប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញស្ដីពីវិសោធនកម្ម
## មាត្រា១៩ ថ្មី មាត្រា៨២ ថ្មី មាត្រា១០៦ ថ្មី (មួយ) មាត្រា១១៩ ថ្មី
## និងមាត្រា១៣៧ ថ្មី នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
## និង មាត្រា៣ និងមាត្រា៤ នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅ
## ធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ

វិសោធនកម្មលើកទី៩ត្រូវបានធ្វើឡើងស្របតាមគំនិតផ្ដួចផ្ដើមដ៏ខ្ពង់ខ្ពស់
របស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
នៃព្រះរាជាណាចក្រកម្ពុជា។

# ព្រះរាជក្រម

នស/រកម/១១២១/ ០១៦

# យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា១៩ ថ្មី មាត្រា៨២ ថ្មី មាត្រា១០៦ ថ្មី(មួយ) មាត្រា១១៩ ថ្មី និងមាត្រា១៣៧ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា៣និងមាត្រា៤ នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២១ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២១ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

# ច្បាប់ធម្មនុញ្ញ

# ស្តីពី

## វិសោធនកម្មមាត្រា១៩ ថ្មី មាត្រា៨២ ថ្មី មាត្រា១០៦ ថ្មី(មួយ) មាត្រា១១៩ ថ្មី និងមាត្រា១៣៧ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា៣និងមាត្រា៤ នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ




២/៥

**មាត្រាមួយ .-**

មាត្រា១៩ ថ្មី មាត្រា៨២ ថ្មី មាត្រា១០៦ ថ្មី(មួយ) មាត្រា១១៩ ថ្មី និងមាត្រា១៣៧ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានធ្វើវិសោធនកម្ម ដូចតទៅ៖

**មាត្រា១៩ .- ថ្មី(មួយ)**

ព្រះមហាក្សត្រទ្រង់តែងតាំងនាយករដ្ឋមន្ត្រី និងទ្រង់តែងតាំងគណៈរដ្ឋមន្ត្រី តាមបែបបទដែលមានចែងក្នុងមាត្រា១១៩ ថ្មី(មួយ)។

**មាត្រា៨២ .- ថ្មី(មួយ)**

រដ្ឋសភាបើកសម័យប្រជុំដំបូង ហុកសិបថ្ងៃយ៉ាងយូរក្រោយពេលបោះឆ្នោត តាមការកោះប្រជុំរបស់ព្រះមហាក្សត្រ។

មុនចាប់ផ្តើមការងាររបស់ខ្លួន រដ្ឋសភាត្រូវប្រកាសសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗ និងត្រូវបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នានូវប្រធាន អនុប្រធានរដ្ឋសភា និងសមាជិកទាំងអស់នៃគណៈកម្មការនានារបស់រដ្ឋសភា ដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល។

ប្រធានរដ្ឋសភា ត្រូវបោះឆ្នោតជ្រើសរើសចេញពីសមាជិករដ្ឋសភា ដែលមានសញ្ជាតិខ្មែរតែមួយគត់។

រដ្ឋសភាត្រូវអនុម័តបទបញ្ជាផ្ទៃក្នុង ដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល។

តំណាងរាស្ត្រទាំងអស់ ត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់តំណែង ដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធទី៥ នៃរដ្ឋធម្មនុញ្ញ។

**មាត្រា១០៦ .- ថ្មី(ពីរ)**

ព្រឹទ្ធសភាបើកសម័យប្រជុំដំបូង ហុកសិបថ្ងៃយ៉ាងយូរក្រោយពេលបោះឆ្នោត តាមការកោះប្រជុំរបស់ព្រះមហាក្សត្រ។

មុនចាប់ផ្តើមការងាររបស់ខ្លួន ព្រឹទ្ធសភាត្រូវប្រកាសសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗ និងត្រូវបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នានូវប្រធាន អនុប្រធានព្រឹទ្ធសភា និងសមាជិកទាំងអស់នៃគណៈកម្មការនានារបស់ព្រឹទ្ធសភា ដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។

ប្រធានព្រឹទ្ធសភា ត្រូវបោះឆ្នោតជ្រើសរើសចេញពីសមាជិកព្រឹទ្ធសភា ដែលមានសញ្ជាតិខ្មែរតែមួយគត់។

សមាជិកព្រឹទ្ធសភាទាំងអស់ ត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់តំណែង ដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធទី៧ នៃរដ្ឋធម្មនុញ្ញ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

៣/៥

**មាត្រា១១៩ .- ថ្មី(មួយ)**

តាមសេចក្ដីស្នើពីប្រធាន ដោយមានមតិឯកភាពពីអនុប្រធានទាំងពីរនៃរដ្ឋសភា ព្រះមហាក្សត្រទ្រង់ចាត់តាំងវរជនមួយរូបជានាយករដ្ឋមន្ត្រី ពីក្នុងចំណោមតំណាងរាស្ត្រនៃគណបក្សដែលមានអាសនៈច្រើនជាងគេនៅក្នុងរដ្ឋសភា ឱ្យបង្កើតរាជរដ្ឋាភិបាល។ វរជនដែលនឹងត្រូវទទួលបានការចាត់តាំងជានាយករដ្ឋមន្ត្រីនេះ ត្រូវតែជាតំណាងរាស្ត្រដែលមានសញ្ជាតិខ្មែរតែមួយគត់។ វរជនដែលត្រូវបានចាត់តាំងនេះ នាំសហការីដែលជាតំណាងរាស្ត្រ ឬជាសមាជិកគណបក្សតំណាងនៅក្នុងរដ្ឋសភាដែលផ្ដល់ផ្ដងឱ្យកាន់តំណែងផ្សេងៗក្នុងរាជរដ្ឋាភិបាល ទៅសុំសេចក្ដីទុកចិត្តពីរដ្ឋសភា។ កាលបើរដ្ឋសភាបានបោះឆ្នោតទុកចិត្តហើយនោះ ព្រះមហាក្សត្រទ្រង់ចេញព្រះរាជក្រឹត្យតែងតាំងគណៈរដ្ឋមន្ត្រីទាំងមូល។

មុនចូលកាន់តំណែង គណៈរដ្ឋមន្ត្រីត្រូវធ្វើសច្ចាប្រណិធានដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធទី៦។

**មាត្រា១៣៧ .- ថ្មី(មួយ)**

ក្រុមប្រឹក្សាធម្មនុញ្ញមានសមាជិកប្រាំបួនរូប ដែលទទួលអាណត្តិប្រាំបួនឆ្នាំ។ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញចំនួនមួយភាគបី ត្រូវផ្លាស់ថ្មីក្នុងរយៈពេលបីឆ្នាំម្ដង បីឆ្នាំម្ដង។ សមាជិកបីរូបត្រូវតែងតាំងដោយព្រះមហាក្សត្រ បីរូបត្រូវជ្រើសតាំងដោយរដ្ឋសភា ហើយបីរូបទៀតត្រូវតែងតាំងដោយឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រម។

ប្រធានត្រូវបានជ្រើសតាំងដោយសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ពីក្នុងចំណោមសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ដែលមានសញ្ជាតិខ្មែរពីកំណើត និងមានសញ្ជាតិខ្មែរតែមួយគត់។ ប្រធានមានសំឡេងឧត្ដមានុភាពក្នុងករណីបែកសំឡេងជាពីរស្មើគ្នា។

**មាត្រាពីរ .-**

មាត្រា៣និងមាត្រា៤ នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិត្រូវបានធ្វើវិសោធនកម្ម ដូចតទៅ៖

**មាត្រា៣ .- ថ្មី**

ក្នុងករណីដែលឃើញថានីតិវិធីនៃមាត្រា៨២ ថ្មី(មួយ) និងមាត្រា១១៩ ថ្មី(មួយ) នៃរដ្ឋធម្មនុញ្ញមិនអាចសម្រេចបាន រដ្ឋសភា តាមសំណើរបស់គណបក្សដែលមានអាសនៈច្រើនជាងគេនៅក្នុងរដ្ឋសភាអាចដំណើរការការបោះឆ្នោតជាកញ្ចប់ ដើម្បីជ្រើសតាំងប្រធាន អនុប្រធានរដ្ឋសភា ក៏ដូចជាប្រធាន និងអនុប្រធានគណៈកម្មការក្នុងពេលជាមួយគ្នានឹងការផ្ដល់សេចក្ដីទុកចិត្តចំពោះរាជរដ្ឋាភិបាល។




៤/៥

**មាត្រា៤ .. ថ្មី**

ការរៀបចំបញ្ជីរាយនាមសមាសភាព ដើម្បីបោះឆ្នោតជ្រើសតាំង និងផ្តល់សេចក្តីទុកចិត្ត ត្រូវអនុវត្តដូចតទៅៈ

-បញ្ជីរាយនាមសមាសភាពប្រធាន និងអនុប្រធាននៃរដ្ឋសភា ក៏ដូចជា ប្រធាន និងអនុប្រធានគណៈកម្មការជំនាញទាំងអស់នៃរដ្ឋសភា ត្រូវរៀបចំនិងស្នើដោយគណបក្សនយោបាយដែលព្រមព្រៀងគ្នា ដើម្បីបង្កើតរាជរដ្ឋាភិបាលចម្រុះ ហើយត្រូវផ្ញើជូនព្រឹទ្ធសមាជិករដ្ឋសភា។ ប្រធានរដ្ឋសភា ត្រូវជ្រើសរើសចេញពីសមាជិករដ្ឋសភាដែលមានសញ្ជាតិខ្មែរតែមួយគត់។

-តាមសេចក្តីស្នើពីគណបក្សនយោបាយដែលមានចំនួនអាសនៈច្រើនជាងគេ នៅក្នុងរដ្ឋសភា តាមរយៈព្រឹទ្ធសមាជិករដ្ឋសភា ព្រះមហាក្សត្រទ្រង់ចាត់តាំងវរជនមួយរូបជានាយករដ្ឋមន្ត្រីពីក្នុងចំណោមតំណាងរាស្ត្រនៃគណបក្សនយោបាយដែលមានចំនួនអាសនៈច្រើនជាងគេនៅក្នុងរដ្ឋសភា ឱ្យបង្កើតរាជរដ្ឋាភិបាល។ វរជនដែលនឹងត្រូវទទួលបានការចាត់តាំងជានាយករដ្ឋមន្ត្រីនេះ ត្រូវតែជាតំណាងរាស្ត្រដែលមានសញ្ជាតិខ្មែរតែមួយគត់។ វរជនដែលត្រូវបានចាត់តាំងនេះ ត្រូវរៀបចំផ្គូផ្គងតំណែងផ្សេងៗក្នុងរាជរដ្ឋាភិបាល រួចផ្ញើបញ្ជីរាយនាមសមាជិកទាំងអស់នៃរាជរដ្ឋាភិបាលជូនព្រឹទ្ធសមាជិករដ្ឋសភា។

-ព្រឹទ្ធសមាជិករដ្ឋសភាត្រូវរៀបចំបញ្ជីរាយនាមជាកញ្ចប់មួយនូវសមាសភាពប្រធាន និងអនុប្រធាននៃរដ្ឋសភា ក៏ដូចជាប្រធាន និងអនុប្រធានគណៈកម្មការជំនាញទាំងអស់នៃរដ្ឋសភា ព្រមទាំងនាយករដ្ឋមន្ត្រីដែលត្រូវបានចាត់តាំងដោយព្រះមហាក្សត្រ និងសមាជិកទាំងអស់នៃរាជរដ្ឋាភិបាល ដើម្បីដាក់ជូនរដ្ឋសភាបោះឆ្នោត។

**មាត្រាថី ..**

ច្បាប់ធម្មនុញ្ញនេះត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃ ១៣ កើត ខែ កក្ដិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ២០២១

នស/រកម.១១២១.៧៥១

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

៥/៥

# វិសោធនកម្មលើកទី១០

## ព្រះរាជក្រមលេខ នស/រកម/០៨២២/០០៧
## ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០២២
## ប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្ម
## មាត្រា១៩ ថ្មី (មួយ) មាត្រា៨៩ មាត្រា៩៨ ថ្មី មាត្រា១០២ ថ្មី
## មាត្រា១១៩ ថ្មី (មួយ) និងមាត្រា១២៥ ថ្មី នៃរដ្ឋធម្មនុញ្ញ
## នៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា៣ ថ្មី និងមាត្រា៤ ថ្មី
## នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជា
## ប្រក្រតីនៃស្ថាប័នជាតិ

វិសោធនកម្មលើកទី១០ត្រូវបានធ្វើឡើងស្របតាមគំនិតផ្តួចផ្តើមដ៏ខ្ពង់ខ្ពស់
របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
នៃព្រះរាជាណាចក្រកម្ពុជា។

# ព្រះរាជក្រម

នស/រកម/០៨២២/០០៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

រដ្ឋសភា
ចូល លេខ........ ថ្ងៃទី.... ម៉ោង....
បញ្ជូនទៅ........

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា១៩ ថ្មី(មួយ) មាត្រា៨៩ មាត្រា៩៨ ថ្មី មាត្រា១០២ ថ្មី មាត្រា១១៩ ថ្មី(មួយ) និងមាត្រា១២៥ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា៣ ថ្មី និងមាត្រា៤ ថ្មី នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២២ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី៥ ខែសីហា ឆ្នាំ២០២២ នាសម័យប្រជុំពេញអង្គលើកទី៩ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់ធម្មនុញ្ញ

## ស្តីពី

## វិសោធនកម្មមាត្រា១៩ ថ្មី (មួយ) មាត្រា៨៩ មាត្រា៩៨ ថ្មី មាត្រា១០២ ថ្មី មាត្រា១១៩ ថ្មី (មួយ) និងមាត្រា១២៥ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា៣ ថ្មី និងមាត្រា៤ ថ្មី នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ

២/៦

**មាត្រាមួយ ..**

មាត្រា១៩ ថ្មី(មួយ) មាត្រា៨៩ មាត្រា៩៨ ថ្មី មាត្រា១០២ ថ្មី មាត្រា១១៩ ថ្មី(មួយ) និងមាត្រា ១២៥ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានធ្វើវិសោធនកម្ម ដូចតទៅ៖

**មាត្រា១៩ .. ថ្មី(ពីរ)**

ព្រះមហាក្សត្រទ្រង់តែងតាំងនាយករដ្ឋមន្ត្រី និងទ្រង់តែងតាំងគណៈរដ្ឋមន្ត្រី តាមបែបបទ ដែលមានចែងក្នុងមាត្រា១១៩ ថ្មី(ពីរ)។

**មាត្រា៨៩ .. ថ្មី**

តាមការសុំពីសមាជិកចំនួនមួយភាគដប់យ៉ាងតិច រដ្ឋសភាអាចអញ្ជើញសមាជិករាជរដ្ឋាភិបាល មួយរូប ឬច្រើនរូប អមដោយឥស្សរជនជាអ្នកជំនាញក្នុងវិស័យណាមួយ មកបំភ្លឺរដ្ឋសភាអំពីបញ្ហាដែល មានសារៈសំខាន់ពិសេស។

**មាត្រា៩៨ .. ថ្មី(មួយ)**

រដ្ឋសភាអាចទម្លាក់សមាជិកគណៈរដ្ឋមន្ត្រី ឬ ទម្លាក់រាជរដ្ឋាភិបាលពីតំណែង ដោយអនុម័ត ញត្តិបន្ទោស តាមសំឡេងឆ្នោតភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល។ ក្នុងករណីដែល រាជរដ្ឋាភិបាលត្រូវបានទម្លាក់ពីមុខតំណែងដោយរដ្ឋសភា រាជរដ្ឋាភិបាលដែលត្រូវចេញពីមុខតំណែងនេះ មានតែការកិច្ចដឹកនាំការងារប្រចាំថ្ងៃតែប៉ុណ្ណោះ រហូតដល់មានរាជរដ្ឋាភិបាលថ្មីចូលកាន់តំណែង។

ញត្តិបន្ទោសរាជរដ្ឋាភិបាល ត្រូវបានលើកឡើងជូនរដ្ឋសភាដោយតំណាងរាស្ត្រចំនួនមួយភាគ បីនៃចំនួនសមាជិករដ្ឋសភាទាំងមូល ទើបរដ្ឋសភាអាចលើកមកពិភាក្សាបាន។

**មាត្រា១០២ .. ថ្មី(មួយ)**

នីតិកាលរបស់ព្រឹទ្ធសភាមានកំណត់ ៦ ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលដែលព្រឹទ្ធសភា ថ្មីចូលកាន់តំណែង។

ក្នុងពេលមានសង្គ្រាម ឬក្នុងកាលៈទេសៈពិសេសដទៃទៀត ដែលមិនអាចធ្វើការបោះឆ្នោត កើត ព្រឹទ្ធសភាអាចប្រកាសបន្តនីតិកាលរបស់ខ្លួនមួយដងបានមួយឆ្នាំ តាមសំណើរបស់ព្រះមហាក្សត្រ។

ការប្រកាសបន្តនីតិកាលរបស់ព្រឹទ្ធសភា ត្រូវសម្រេចដោយមតិយល់ព្រមពីរភាគបីយ៉ាងតិច នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។

ក្នុងកាលៈទេសៈដូចបានរៀបរាប់ខាងលើ ព្រឹទ្ធសភាប្រជុំរាល់ថ្ងៃជាប់ជាប្រចាំ។ ព្រឹទ្ធសភាមាន សិទ្ធិសម្រេចបញ្ចប់កាលៈទេសៈពិសេសខាងលើនេះ កាលបើសភាពការណ៍អនុញ្ញាត។ ប៉ុន្តែ ការសម្រេច បញ្ចប់កាលៈទេសៈពិសេសដែលប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ព្រឹទ្ធសភាត្រូវសម្រេចរួមគ្នាជាមួយ រដ្ឋសភា ក្នុងសមាជរដ្ឋសភានិងព្រឹទ្ធសភា វៀរលែងតែការអនុវត្តមាត្រា៨៦ នៃរដ្ឋធម្មនុញ្ញ។

បើព្រឹទ្ធសភាមិនអាចប្រជុំបានទេ ដោយមូលហេតុចាំបាច់ ជាអាទិ៍ នៅពេលដែលកម្លាំងបរទេសចូលមកកាន់កាប់ទឹកដី ការប្រកាសភាពអាសន្នត្រូវបន្តទៅមុខជាស្វ័យប្រវត្តិ។

**មាត្រា១១៩ .. ថ្មី(ពីរ)**

តាមសេចក្តីស្នើពីគណបក្សដែលមានអាសនៈច្រើនជាងគេក្នុងរដ្ឋសភា ព្រះមហាក្សត្រទ្រង់ចាត់តាំងវរជនមួយរូបជានាយករដ្ឋមន្ត្រី ឱ្យបង្កើតរាជរដ្ឋាភិបាល។ សេចក្តីស្នើពីគណបក្សដែលមានអាសនៈច្រើនជាងគេក្នុងរដ្ឋសភានេះ ត្រូវចម្លងជូនប្រធានរដ្ឋសភា។ វរជនដែលនឹងត្រូវទទួលបានការចាត់តាំងជានាយករដ្ឋមន្ត្រីនេះ ត្រូវតែជាតំណាងរាស្ត្រដែលមានសញ្ជាតិខ្មែរតែមួយគត់ និងដែលត្រូវបានជ្រើសរើសចេញពីគណបក្សដែលមានអាសនៈច្រើនជាងគេក្នុងរដ្ឋសភា។ វរជនដែលត្រូវបានចាត់តាំងនេះ នាំសហការីដែលជាតំណាងរាស្ត្រ ឬជាសមាជិកគណបក្សតំណាងនៅក្នុងរដ្ឋសភាដែលផ្ទុផ្ទុងឱ្យកាន់តំណែងផ្សេងៗក្នុងរាជរដ្ឋាភិបាល ទៅសុំសេចក្តីទុកចិត្តពីរដ្ឋសភា។ ការបោះឆ្នោតផ្តល់សេចក្តីទុកចិត្តនេះ ត្រូវធ្វើលើបញ្ជីសមាសភាពនៃគណៈរដ្ឋមន្ត្រីទាំងមូល។ កាលបើរដ្ឋសភាបានបោះឆ្នោតទុកចិត្តហើយនោះ ព្រះមហាក្សត្រទ្រង់ចេញព្រះរាជក្រឹត្យតែងតាំងគណៈរដ្ឋមន្ត្រីទាំងមូល។

មុនចូលកាន់តំណែង គណៈរដ្ឋមន្ត្រីត្រូវធ្វើសច្ចាប្រណិធានដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធទី៦។

នៅពេលផុតនីតិកាលនីមួយៗរបស់រដ្ឋសភា រាជរដ្ឋាភិបាលដែលត្រូវចេញពីតំណែង មានតែភារកិច្ចដឹកនាំការងារប្រចាំថ្ងៃតែប៉ុណ្ណោះ រហូតដល់មានរាជរដ្ឋាភិបាលថ្មីចូលកាន់តំណែង។

**មាត្រា១២៥ .. ថ្មី(មួយ)**

ក្នុងករណីដែលនាយករដ្ឋមន្ត្រីអវត្តមានមួយកាលមួយគ្រា នាយករដ្ឋមន្ត្រីត្រូវចាត់តាំងឧបនាយករដ្ឋមន្ត្រីមួយរូប ឱ្យធ្វើជានាយករដ្ឋមន្ត្រីស្តីទីដើម្បីទទួលភារកិច្ចដឹកនាំគណៈរដ្ឋមន្ត្រីជំនួសជាបណ្តោះអាសន្ន ។

បើតំណែងនាយករដ្ឋមន្ត្រីនៅទំនេរជាស្ថាពរ ដោយហេតុជាអាទិ៍មកពីការទទួលអនិច្ចកម្ម ឬការលាលែងពីមុខតំណែង គណៈរដ្ឋមន្ត្រីថ្មីមួយត្រូវតែងតាំងជាបន្ទាន់ ក្នុងលក្ខខណ្ឌដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនេះ។ ប្រធានរដ្ឋសភាត្រូវកោះប្រជុំរដ្ឋសភាជាបន្ទាន់ និងត្រូវធ្វើចំណាត់ការចាំបាច់ដទៃទៀតដោយរួសរាន់ ក្នុងរយៈវេលា ៧ ថ្ងៃយ៉ាងយូរ បន្ទាប់ពីបានទទួលសំណើពីគណបក្សដែលមានអាសនៈច្រើនជាងគេក្នុងរដ្ឋសភា។

ក្នុងករណីតំណែងនាយករដ្ឋមន្ត្រីនៅទំនេរជាស្ថាពរ ដោយហេតុមកពីការទទួលអនិច្ចកម្ម គណៈរដ្ឋមន្ត្រីដែលត្រូវចេញពីតំណែង ក្រោមការដឹកនាំរបស់ឧបនាយករដ្ឋមន្ត្រីដែលទទួលបានការចាត់តាំងជានាយករដ្ឋមន្ត្រីស្តីទី មានតែភារកិច្ចដឹកនាំការងារប្រចាំថ្ងៃតែប៉ុណ្ណោះ រហូតដល់មានគណៈរដ្ឋមន្ត្រីថ្មីចូលកាន់តំណែង។

ការលាលែងពីមុខតំណែងរបស់នាយករដ្ឋមន្ត្រី ត្រូវធ្វើឡើងតាមលិខិតលាលែងពីមុខតំណែងដែលត្រូវផ្ញើថ្វាយព្រះមហាក្សត្រ និងចម្លងជូនប្រធានរដ្ឋសភា។ ក្នុងករណីនេះ គណៈរដ្ឋមន្ត្រីដែលត្រូវចេញពីតំណែង ត្រូវបន្តដឹកនាំការងាររបស់រាជរដ្ឋាភិបាល រហូតដល់គណៈរដ្ឋមន្ត្រីថ្មីចូលកាន់តំណែង។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

៤/៦

**មាត្រាពីរ ..**

មាត្រា៣ ថ្មី និងមាត្រា៤ ថ្មី នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ ត្រូវបានធ្វើវិសោធនកម្ម ដូចតទៅ ៖

**មាត្រា៣ .. ថ្មី(មួយ)**

ក្នុងករណីដែលឃើញថានីតិវិធីនៃមាត្រា៨២ ថ្មី(មួយ) និងមាត្រា១១៩ ថ្មី(ពីរ) នៃរដ្ឋធម្មនុញ្ញ មិនអាចសម្រេចបាន រដ្ឋសភា តាមសំណើរបស់គណបក្សដែលមានអាសនៈច្រើនជាងគេក្នុងរដ្ឋសភា អាចដំណើរការការបោះឆ្នោតជាកញ្ចប់ ដើម្បីជ្រើសតាំងប្រធាន អនុប្រធានរដ្ឋសភា ក៏ដូចជាប្រធាន និងអនុប្រធានគណៈកម្មការក្នុងពេលជាមួយគ្នានឹងការផ្តល់សេចក្តីទុកចិត្តចំពោះរាជរដ្ឋាភិបាល។

**មាត្រា៤ .. ថ្មី(មួយ)**

ការរៀបចំបញ្ជីរាយនាមសមាសភាព ដើម្បីបោះឆ្នោតជ្រើសតាំង និងផ្តល់សេចក្តីទុកចិត្ត ត្រូវអនុវត្តដូចតទៅ ៖

-បញ្ជីរាយនាមសមាសភាពប្រធាន និងអនុប្រធាននៃរដ្ឋសភា ក៏ដូចជាប្រធាន និងអនុប្រធានគណៈកម្មការជំនាញទាំងអស់នៃរដ្ឋសភា ត្រូវរៀបចំនិងស្នើដោយគណបក្សនយោបាយដែលមានអាសនៈច្រើនជាងគេក្នុងរដ្ឋសភា ហើយត្រូវផ្ញើជូនព្រឹទ្ធសមាជិករដ្ឋសភា។ ប្រធានរដ្ឋសភា ត្រូវជ្រើសរើសចេញពីសមាជិករដ្ឋសភាដែលមានសញ្ជាតិខ្មែរតែមួយគត់។

-តាមសេចក្តីស្នើពីគណបក្សនយោបាយ ដែលមានអាសនៈច្រើនជាងគេក្នុងរដ្ឋសភា ព្រះមហាក្សត្រទ្រង់ចាត់តាំងវរជនមួយរូបជានាយករដ្ឋមន្ត្រី ឱ្យបង្កើតរាជរដ្ឋាភិបាល។ វរជនដែលនឹងត្រូវទទួលបានការចាត់តាំងជានាយករដ្ឋមន្ត្រីនេះ ត្រូវតែជាតំណាងរាស្ត្រដែលមានសញ្ជាតិខ្មែរតែមួយគត់ និងដែលត្រូវបានជ្រើសរើសចេញពីគណបក្សនយោបាយ ដែលមានអាសនៈច្រើនជាងគេក្នុងរដ្ឋសភា។ វរជនដែលត្រូវបានចាត់តាំងនេះ ត្រូវរៀបចំផ្គូផ្គងតំណែងផ្សេងៗក្នុងរាជរដ្ឋាភិបាល រួចផ្ញើបញ្ជីរាយនាមសមាជិកទាំងអស់នៃរាជរដ្ឋាភិបាលជូនព្រឹទ្ធសមាជិករដ្ឋសភា។

-ព្រឹទ្ធសមាជិករដ្ឋសភាត្រូវរៀបចំជាបន្ទាន់ និងដោយឥតបង្អង់នូវបញ្ជីរាយនាមជាកញ្ចប់មួយដែលរួមមានសមាសភាពប្រធាន និងអនុប្រធាននៃរដ្ឋសភា ក៏ដូចជាប្រធាន និងអនុប្រធានគណៈកម្មការជំនាញទាំងអស់នៃរដ្ឋសភា ព្រមទាំងនាយករដ្ឋមន្ត្រីដែលត្រូវបានចាត់តាំងដោយព្រះមហាក្សត្រ និងសមាជិកទាំងអស់នៃរាជរដ្ឋាភិបាល ដើម្បីដាក់ជូនរដ្ឋសភាបោះឆ្នោត។ ព្រឹទ្ធសមាជិករដ្ឋសភាត្រូវដឹកនាំប្រជុំរដ្ឋសភា ដើម្បីបោះឆ្នោតអនុម័តបញ្ជីនេះជាបន្ទាន់។

-ព្រឹទ្ធសមាជិករដ្ឋសភាត្រូវបានជ្រើសរើសដោយកំណត់យកសមាជិករដ្ឋសភា ដែលមានអាយុច្រើនជាងគេ ក្នុងចំណោមសមាជិករដ្ឋសភាទាំងអស់។ ក្នុងករណីដែលព្រឹទ្ធសមាជិករដ្ឋសភារូបនេះ មិនអាចអនុវត្តមុខងាររបស់ខ្លួនបាន មុខតំណែងព្រឹទ្ធសមាជិករដ្ឋសភាត្រូវប្រគល់ទៅសមាជិករដ្ឋសភាដទៃទៀតដែលមានអាយុច្រើនក្នុងលំដាប់បន្តបន្ទាប់។

៥/៦

**មាត្រាបី .-**

ច្បាប់ធម្មនុញ្ញនេះត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃ សៅរ៍ ៩កើត ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ២០២២

ន សីហមុនី

**នរោត្តម សីហមុនី**

ព្រស.២២០៥.៩១៥

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្ថលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

៦/៦

# វិសោធនកម្មលើកទី១១

## ព្រះរាជក្រមលេខ នស/រកម/០៧២៥/០២៩
## ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៥
## ប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្ម
## មាត្រា៣៣ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

**វិសោធនកម្មលើកទី១១ត្រូវបានធ្វើឡើងស្របតាមគំនិតផ្តួចផ្តើមដ៏ខ្ពង់ខ្ពស់
របស់សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី ប្រធានរដ្ឋសភា
ដោយទទួលបានសេចក្តីស្នើពីតំណាងរាស្ត្រចំនួន១២៥ រូប
និងគំនិតផ្តួចផ្តើមដ៏ខ្ពង់ខ្ពស់របស់សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

ព្រះរាជក្រម

នស/រកម/០៧២៥/០២៩

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

**ប្រកាសឱ្យប្រើ**

ច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា៣៣ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២៥ នាសម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាលទី៧ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២៥ នាសម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

១/២

# ច្បាប់ធម្មនុញ្ញ
# ស្តីពី
# វិសោធនកម្មមាត្រា៣៣ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

**មាត្រាមួយ.-**

មាត្រា៣៣ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានធ្វើវិសោធនកម្ម ដូចតទៅ៖

**មាត្រា៣៣ .- ថ្មី**

ប្រជាពលរដ្ឋខ្មែរមិនអាចត្រូវបាននិរទេស ឬចាប់បញ្ជូនខ្លួនទៅឱ្យប្រទេសក្រៅណាមួយឡើយ លើកលែងតែមានកិច្ចព្រមព្រៀងជាមួយគ្នាទៅវិញទៅមក។

ប្រជាពលរដ្ឋខ្មែរដែលកំពុងរស់នៅឯបរទេសត្រូវបានរដ្ឋគាំពារ។

ការទទួលសញ្ជាតិខ្មែរ និងការបាត់សញ្ជាតិខ្មែរ ដោយរួមទាំងការដកសញ្ជាតិខ្មែរ ត្រូវកំណត់ក្នុងច្បាប់។

**មាត្រាពីរ.-**

ច្បាប់ធម្មនុញ្ញនេះត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃ អង្គារ ៥ រោច ខែ អាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០២៥

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

ពរស. ២៥០៧. ៩៩៦

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**វង្សី វិស្សុត**

២/២

# ឧបសម្ព័ន្ធ១
# សេចក្តីថ្លែងហេតុនៃវិសោធនកម្ម
# រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

# សេចក្ដីថ្លែងហេតុនៃវិសោធនកម្ម
# លើកទី១
# ( គ្មាន )

# សេចក្តីថ្លែងហេតុនៃវិសោធនកម្ម
# លើកទី២

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋសភា

123
13.12.98

# សេចក្ដីថ្លែងហេតុ

## នៃសេចក្ដីស្នើច្បាប់ធម្មនុញ្ញ

## ស្ដីពី

## វិសោធនកម្ម មាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ និងជំពូកទី ៧ ជល់ទី ១៤ នៃរដ្ឋធម្មនុញ្ញ

ជោគជ័យនៃកិច្ចប្រជុំកំពូល ថ្ងៃទី ១២-១៣ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ជាជោគជ័យនៃស្មារតីស្នេហាជាតិ និងបង្រួបបង្រួមផ្សះផ្សារជាតិក្រោមព្រះរាជអធិបតីភាព នៃព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ។ ជោគជ័យនេះ ក៏ជាកូនសោដែលបើកអោយមានការដោះស្រាយប្រកបដោយវិចារណញ្ញាណ នូវវិបត្តិនយោបាយជាតិ និងទប់ស្កាត់បាននូវគ្រោះមហន្តរាយដែលអាច នឹងកើតមានដោយសារវិបត្តិនេះ ។

ដោយជោគជ័យនេះបំរើមូលហេតុដ៏ឧត្ដុងឧត្ដមរបស់ជាតិយើង ការអនុវត្តន៍អោយបានល្អនូវសេចក្ដីប្រកាសរួម អំពីគោលការណ៍សហប្រតិបត្តិការ ដែលបានសំរេចក្នុងកិច្ចប្រជុំកំពូល ថ្ងៃទី ១២-១៣ ខែ វិច្ឆិកា ១៩៩៨ គឺជាការចាំបាច់ខានមិនបាន ។ ការបង្កើតអោយមានព្រឹទ្ធសភា ដោយធ្វើវិសោធនកម្មលើរដ្ឋធម្មនុញ្ញបច្ចុប្បន្ន ស្ថិតក្នុងការចាំបាច់ខានមិនបាននេះ ។

សេចក្ដីស្នើច្បាប់ធម្មនុញ្ញ ស្ដីពីវិសោធនកម្ម ជំពូកទី ៧ និងមាត្រាទាំងឡាយដទៃទៀត នៃរដ្ឋធម្មនុញ្ញបច្ចុប្បន្នសំដៅសំរេចនូវសេចក្ដីតំរូវខាងលើនេះ តែប៉ុណ្ណោះ ។

ប៉ុន្តែដូចដែលបានចែងក្នុងចំណុចមួយចំនួន នៃសេចក្ដីប្រកាសរួម ជាពិសេសចំណុចទី ១ ការបង្កើតអោយមានព្រឹទ្ធសភា ទាមទារអោយមានធ្វើវិសោធនកម្ម នៃរដ្ឋធម្មនុញ្ញ ។

សេចក្ដីស្នើច្បាប់ធម្មនុញ្ញពេលនេះ ស្នើអោយមានការកែប្រែមាត្រារបស់រដ្ឋធម្មនុញ្ញចំនួន ២២ ក្នុងនេះនៅជំពូកទី ២ ចំនួន ៩ មាត្រា ( មាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ) ជំពូកទី ៣ មួយមាត្រា

៥

( មាត្រា៣៤ ) ជំពូកទី ៤ មួយមាត្រា ( មាត្រា ៥១ ) ជំពូកទី ៥ ប្រាំមាត្រា ( មាត្រា ៧៨ ៨២ ៩០ ៩១ ៩៣) ជំពូកទី ១០ បួនមាត្រា ( មាត្រា ១១៧ ១២០ ១២១ ១២២ ១៣០ ) ជំពូកទី ១២ មួយមាត្រា ( មាត្រា ១៣០) និងជំពូកទី ១៤ មួយមាត្រា ( មាត្រា ១៣៨ ) ។

ប្រការកែប្រែបណ្តាមាត្រា ក្នុងជំពូកទី ១ សំដៅរៀបចំទំនាក់ទំនងរវាងព្រះមហាក្សត្រ និងព្រឹទ្ធសភា ដែលទើបបង្កើតថ្មី ព្រមទាំងថ្នាក់ដឹកនាំព្រឹទ្ធសភា និងរដ្ឋសភា ។

ការកែប្រែមាត្រា ៣៤ សំដៅកំណត់អាយុបេក្ខជនឈរឈ្មោះជាព្រឹទ្ធសមាជិក ។

ការកែប្រែមាត្រា ៥១ សំដៅបញ្ជាក់ថា ព្រឹទ្ធសភាក៏ជាអង្គការតំណាងអំណាចពលរដ្ឋដែរ ។

ការកែប្រែមាត្រា ៧៨ ( មាត្រា ៨០ ថ្មី ) មាត្រា ៨២ ( មាត្រា ៨៤ ថ្មី ) មាត្រា ៩០ ( មាត្រា៩២ថ្មី ) មាត្រា ៩១ ( មាត្រា ៩៣ ថ្មី ) និងមាត្រា ៩៣ ( មាត្រា ៩៥ ថ្មី ) សំដៅកែសំរួលនិតិវិធីរបស់រដ្ឋសភា ដើម្បីអោយស្របទៅនឹងសភាពការណ៍ថ្មី ពោលគឺវត្តមាន នៃព្រឹទ្ធសភា ។ ការកែប្រែមាត្រា ១១៧ ១២០ ១២១ ១២២ ( មាត្រា ១៣៨ ១៤១ ១៤២ និង ១៤៣ ) សំដៅរៀបចំទំនាក់ទំនងរវាងក្រុមប្រឹក្សាធម្មនុញ្ញ និង ព្រឹទ្ធសភា ដែលទើបបង្កើត ។

អំពីព្រឹទ្ធសភាខ្លួនឯង សេចក្តីស្នើច្បាប់ធម្មនុញ្ញនេះ បានរៀបចំក្នុងជំពូកទី ៧ ដែលមានចំណងជើងថ្មីថា អំពីសភា ។ ជំពូកនេះ ចែកជាបីផ្នែក គឺផ្នែកទី ១ ស្តីពីរដ្ឋសភា ផ្នែកទី ២ ស្តីពីព្រឹទ្ធសភា និង ផ្នែកទី ៣ ស្តីពីសមាជសភា ។

សេចក្តីស្នើច្បាប់ធម្មនុញ្ញនេះ ដែលចែងពីព្រឹទ្ធសភា ប្រកាន់យកស្មារតី នៃសេចក្តីប្រកាសរួម អំពីគោល - ការណ៍សហប្រតិបត្តិការ ដែលបានសំរេចក្នុងកិច្ចប្រជុំកំពូល ថ្ងៃទី ១២-១៣ ខែ វិច្ឆិកា ១៩៩៨ ទាំងស្រុង ។

អំពីនិតិវិធី និងការងាររបស់ព្រឹទ្ធសភា គឺយកលំនាំតាមរដ្ឋសភា ។

ចំពោះបណ្តាមាត្រា នៃជំពូកពីទី ៨ ដល់ ជំពូកទី ១៤ មានតែមាត្រា ១១៧ ១២០ ១២១ ១២២ ១៣០ និង ១៣៨ ចាស់ទេ ដែលស្នើសុំកែប្រែ ឯមាត្រាដទៃទៀតគ្រាន់តែ កែប្រែលេខមាត្រា អាស្រ័យដោយមានការបន្ថែមមាត្រា ក្នុងជំពូកទី ៧ តែប៉ុណ្ណោះ ។

សេចក្តីដូចមានចែងខាងលើ ទូលបង្គំយើងខ្ញុំ សូមសម្តេចក្រុមព្រះប្រធានរដ្ឋសភាទ្រង់មេត្តាពិនិត្យ និងទ្រង់មានព្រះតំរិះតាមការគួរ ។

ធ្វើនៅរាជធានីភ្នំពេញ . ថ្ងៃទី27 ខែ 11 ឆ្នាំ ១៩៩៨

តំណាងក្រុមតំណាងរាស្ត្រហត្ថលេខី

៦

# សេចក្តីថ្លែងហេតុនៃវិសោធនកម្ម
# លើកទី៣

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋសភា

សូមក្រាបបង្គំទូលថ្វាយ

ក្រោមលំអងធូលីព្រះបាទ ព្រះករុណាព្រះបាទសម្ដេច ព្រះនរោត្តម សីហនុ

ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

*សូមក្រាបថ្វាយបង្គំព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត*

ទូលព្រះបង្គំជាខ្ញុំ សូមក្រាបបង្គំទូលថ្វាយព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត សូមទ្រង់ព្រះមេត្តាជ្រាប ដោយទូលព្រះបង្គំជាខ្ញុំ បានទទួលនូវពាក្យស្នើសុំធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ពីសមាជិកតំណាងរាស្ត្រនៃគណបក្សទាំងបី ដែលបានចុះហត្ថលេខា ស្នើសុំធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ លើមាត្រា ១៩ និងមាត្រា ២៩ ដើម្បីញ៉ាំងឱ្យរដ្ឋធម្មនុញ្ញ កាន់តែមានភាពសុក្រិតឡើង។

សេចក្ដីស្នើច្បាប់ធម្មនុញ្ញនេះ សំដៅកែប្រែមាត្រា ១៩ ដោយគ្រាន់តែកែកំហុសបច្ចេកទេសមួយ " *ពីមាត្រា ១០០ ទៅជាមាត្រា ១១៩ ថ្មី* " ប៉ុណ្ណោះ។ ចំពោះមាត្រា ២៩ ដែលចែងថា " *ព្រះមហាក្សត្រ ទ្រង់បង្កើត និងប្រទានគ្រឿង ឥស្សរិយយសជាតិ តាមសេចក្ដីស្នើ ពីគណៈរដ្ឋមន្ត្រី* " ការស្នើសុំកែប្រែមាត្រានេះ គឺសុំលុបចោលពាក្យ "*តាមសេចក្ដីស្នើពីគណៈរដ្ឋមន្ត្រី*" ដើម្បីថ្វាយព្រះមហាក្សត្រ នូវព្រះរាជសិទ្ធិ ទូលំទូលាយ ក្នុងការបង្កើត និងប្រទានគ្រឿងឥស្សរិយយសជាតិ ដល់មន្ត្រី រាជការ ស៊ីវិល យោធា សប្បុរសជន និងឥស្សរជនដទៃទៀត។

ទូលព្រះបង្គំជាខ្ញុំ សូមក្រាបបង្គំទូលថ្វាយ ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត សូមទ្រង់ព្រះមេត្តាជ្រាប ដោយការធ្វើវិសោធនកម្មនៃមាត្រា ២៩ នេះមានការទាក់ទងជាមួយសិទ្ធិរបស់គណៈរដ្ឋមន្ត្រី ទូលព្រះបង្គំជាខ្ញុំ បានធ្វើការពិភាក្សាជាមួយ សម្ដេច ហ៊ុន សែន នាយករដ្ឋមន្ត្រី ហើយបានឯកភាពគ្នា ចំពោះសេចក្ដីស្នើសុំធ្វើវិសោធនកម្មនេះ។

២២

យោងតាមមាត្រា ១៤៨ ថ្មី ជំពូក ១២ ថ្មី នៃរដ្ឋធម្មនុញ្ញដែលចែងថា " *ព្រះមហាក្សត្រ ទ្រង់ពិគ្រោះមតិក្រុមប្រឹក្សាធម្មនុញ្ញ ចំពោះសេចក្តីស្នើទាំងឡាយ ដែលសុំធ្វើវិសោធនកម្មលើរដ្ឋធម្មនុញ្ញ* " ទូលព្រះបង្គំជាខ្ញុំ សូមព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ព្រះអង្គទ្រង់ព្រះមេត្តា ពិគ្រោះជាមួយក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីសុំមតិ និងការគាំទ្រលើសំណើធ្វើវិសោធនកម្មនេះ ដោយព្រះករុណានុគ្រោះដ៏ខ្ពង់ខ្ពស់បំផុត ។

ទូលព្រះបង្គំជាខ្ញុំ សូមថ្វាយភ្ជាប់មកជាមួយនូវបញ្ជីរាយនាមអ្នកតំណាងរាស្ត្រហត្ថលេខី ទាំងបីគណបក្ស ដើម្បីទ្រង់ព្រះមេត្តាជ្រាបជាព្រះរាជពតិមានដ៏ខ្ពង់ខ្ពស់បំផុត ។

សូមព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ទ្រង់ព្រះមេត្តាទទួលនូវគារវកិច្ចកតញ្ញូតាធម៌ និងស្វាមីភក្តិដ៏ខ្ពង់ខ្ពស់បំផុតអំពីទូលព្រះបង្គំជាខ្ញុំ ។

ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០០១

ប្រធានរដ្ឋសភា

នរោត្តម រណឫទ្ធិ

# សេចក្តីថ្លែងហេតុនៃវិសោធនកម្ម
# លើកទី៤

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋសភា

លេខ: ៦៥៣
ថ្ងៃទី... ឆ្នាំ២០០៥ ម៉ោង...
បញ្ជូនទៅ ........................

# សេចក្តីថ្លែងហេតុ
# នៃសេចក្តីស្នើច្បាប់ធម្មនុញ្ញ
# ស្តីពី
# វិសោធនកម្មមាត្រា ៨៨ និងមាត្រា ១១១ថ្មី នៃរដ្ឋធម្មនុញ្ញ

អនុលោមតាមការព្រមព្រៀងកិច្ចលរវាងសម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ព្រះប្រធានរដ្ឋសភា និងសម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា កាលពីព្រឹកថ្ងៃព្រហស្បតិ៍ ទី ១៧ ខែ មីនា ឆ្នាំ ២០០៥ និងដោយពិនិត្យឃើញថា ក្វរ៉ុមសម្រាប់ប្រជុំរដ្ឋសភា និងព្រឹទ្ធសភា ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ចំនួនពីរភាគបី គឺជាក្វរ៉ុមមួយខ្ពស់មានលក្ខណៈសមស្របទៅនឹងកាលៈទេសៈផ្សះផ្សាបង្រួបបង្រួមជាតិ ។ ឆ្លងតាមការវិវត្តន៍របស់ព្រះរាជាណាចក្រកម្ពុជាមកដល់ពេលសព្វថ្ងៃនេះ ការប្រជុំរដ្ឋសភា និងព្រឹទ្ធសភាច្រើនជួបការរាក់រអួលដោយមូលហេតុខ្វះក្វរ៉ុម ។

ដោយផ្អែកលើភាពចាំបាច់ដើម្បីឱ្យស្ថាប័ននីតិបញ្ញត្តិទាំងពីរមានដំណើរការល្អប្រសើរជាងមុន និងដោយផ្អែកលើមាត្រា ១៥១ថ្មី (មាត្រា ១៣២ចាស់) នៃរដ្ឋធម្មនុញ្ញ ចែងថា "ការផ្តើមគំនិតសើរើ ឬការផ្តើមគំនិតធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញជាសិទ្ធិរបស់ព្រះមហាក្សត្រ របស់នាយករដ្ឋមន្ត្រី និងរបស់ប្រធានរដ្ឋសភាតាមសេចក្តីស្នើរបស់តំណាងរាស្ត្រមួយភាគបួននៃចំនួនសមាជិករដ្ឋសភាទាំងមូល " ទូលព្រះបង្គំ យើងខ្ញុំជាតំណាងរាស្ត្រហត្ថលេខីយល់ថា គប្បីធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញពាក់ព័ន្ធនឹងក្វរ៉ុម ។

សេចក្តីស្នើច្បាប់ធម្មនុញ្ញនេះ សំដៅកែប្រែមាត្រា ៨៨ និងមាត្រា ១១១ថ្មី នៃរដ្ឋធម្មនុញ្ញ ដើម្បីសម្រួលក្វរ៉ុមសម្រាប់ប្រជុំរដ្ឋសភា និងព្រឹទ្ធសភា ដូចមាន

៦៧

វិថីសម្តេចសុធារស សង្កាត់ចតុមុខ ភ្នំពេញ ទូរស័ព្ទលេខ : (៨៥៥-២៣) ២១២ ៥៣៥, ២១ ៧៥ ៧៥, ទូរសារលេខ : (៨៥៥-២៣) ២១៧ ៧៦៩

ខ្ទឹមសារថា ក្លរ៉ុមប្រាំពីរភាគដប់ត្រូវយកមកប្រើ សម្រាប់ការអនុម័តយកសម្លេងពីរភាគបី និងក្លរ៉ុមប្រាំមួយភាគដប់ត្រូវយកមកប្រើសម្រាប់ការអនុម័តយកសម្លេងភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភា និងសមាជិកព្រឹទ្ធសភាទាំងមូល ។

សេចក្តីដូចបានទូលថ្វាយខាងលើ ទូលព្រះបង្គំ យើងខ្ញុំ សូមសម្តេចក្រុមព្រះ ព្រះប្រធានរដ្ឋសភា ព្រះមេត្តាដាក់ជូនរដ្ឋសភាពិនិត្យ និងអនុម័តសេចក្តីស្នើច្បាប់ធម្មនុញ្ញស្តីពី វិសោធនកម្មមាត្រា ៨៨ និងមាត្រា ១១១ថ្មី នៃរដ្ឋធម្មនុញ្ញ ដោយចាត់ទុកជាការប្រញាប់ តាមការគួរ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០០៥

តំណាងក្រុមតំណាងរាស្ត្រហត្ថលេខី

# សេចក្តីថ្លែងហេតុនៃវិសោធនកម្ម
# លើកទី៥

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:..០៦..ស.ជ.ណ

# សេចក្តីថ្លែងហេតុ
# នៃសេចក្តីព្រាងច្បាប់ធម្មនុញ្ញ
# ស្តីពី
# វិសោធនកម្មមាត្រា ៨០ មាត្រា៨២ មាត្រា៨៨ថ្មី មាត្រា៩០ថ្មី មាត្រា៩៨ មាត្រា១០៨ថ្មី មាត្រា១០៦ថ្មី មាត្រា១១១ថ្មី (មួយ) មាត្រា១១៨ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា ៦ នៃ ច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ

អនុលោមតាមការព្រមព្រៀងកំពូលរវាងគណបក្សនយោបាយទាំងបី ដែលមានអាសនៈនៅក្នុងរដ្ឋសភានីតិកាលទី ៣ និងដោយពិនិត្យឃើញថា បណ្តាការអនុម័តរបស់រដ្ឋសភា និងរបស់ព្រឹទ្ធសភា ដោយមតិភាគច្រើនពីរភាគបី និងបីភាគបួន ដែលមានកំណត់ក្នុងមាត្រា ៨០ មាត្រា៨២ មាត្រា៩០ថ្មី មាត្រា៩៨ មាត្រា១០៨ថ្មី មាត្រា១០៦ថ្មី មាត្រា១១៨ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា ៦ នៃច្បាប់ធម្មនុញ្ញបន្ថែម មានកំរិតខ្ពស់ណាស់បើប្រៀបធៀបទៅនឹងប្រទេសប្រជាធិបតេយ្យនានានៅលើពិភពលោក ។ ម្យ៉ាងទៀតដោយពិនិត្យឃើញថា កូរ៉ុមសម្រាប់ប្រជុំរដ្ឋសភា និងប្រជុំព្រឹទ្ធសភា ដែលមានចែងក្នុងមាត្រា ៨៨ថ្មី និងមាត្រា ១១១ថ្មី (មួយ) តម្រូវឱ្យមានវត្តមានតំណាងរាស្ត្រ និង សមាជិកព្រឹទ្ធសភាច្រើនលើសលប់ បើប្រៀបធៀបទៅសភានៃប្រទេសប្រជាធិបតេយ្យសេរី ។ ឆ្លងតាមការវិវត្តន៍របស់ព្រះរាជាណាចក្រកម្ពុជាពីឆ្នាំ ១៩៩៣ មកដល់សព្វថ្ងៃនេះ យើងដកស្រង់មេរៀន និងពិសោធន៍ជាច្រើន ដែលទាមទារឱ្យមានការផ្តើមគំនិតធ្វើវិសោធនកម្មមាត្រាមួយចំនួននៃរដ្ឋធម្មនុញ្ញ និងមាត្រា ៦ នៃច្បាប់ធម្មនុញ្ញបន្ថែម សំដៅលើកកំពស់ប្រសិទ្ធភាពការដឹកនាំរបស់ស្ថាប័ននីតិបញ្ញត្តិ និងនីតិប្រតិបត្តិនៃយើង និងសំដៅអភិវឌ្ឍន៍លទ្ធិប្រជាធិបតេយ្យសេរីពហុបក្សឱ្យកាន់តែរីកចំរើនថែមទៀត ។ ប្រជាធិបតេយ្យកាន់តែរីកចំរើន សម្លេងអនុម័ត និងកូរ៉ុមកាន់តែថយចុះតិច ។

ដោយផ្អែកលើភាពចាំបាច់ ដូចបានរៀបរាប់ខាងលើ និងដោយផ្អែកលើមាត្រា ១៥១ថ្មី (មាត្រា ១៣២ចាស់) នៃរដ្ឋធម្មនុញ្ញចែងថា «ការផ្តើមគំនិតសើរើ ឬការផ្តើមគំនិតធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ជា

សិទ្ធិរបស់ព្រះមហាក្សត្រ របស់នាយករដ្ឋមន្ត្រី និងរបស់ប្រធានរដ្ឋសភា តាមសេចក្តីស្នើរបស់តំណាងរាស្ត្រមួយភាគបួននៃចំនួនសមាជិករដ្ឋសភាទាំងមូល» ទូលបង្គំយល់ថា គប្បីធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ និងច្បាប់ធម្មនុញ្ញបន្ថែមដែលពាក់ព័ន្ធនឹងបញ្ហាដូចមានចែងខាងលើ។

សេចក្តីស្នើច្បាប់ធម្មនុញ្ញនេះ សំដៅកែប្រែខ្លឹមសារមាត្រា ៨០ ៨២ ៩០ថ្មី ៩៨ ១០៨ថ្មី ១០៦ថ្មី ១១៨ថ្មី នៃរដ្ឋធម្មនុញ្ញ និងខ្លឹមសារមាត្រា ៦ នៃច្បាប់ធម្មនុញ្ញបន្ថែម ដោយសម្រេចមតិភាគច្រើន ពីរភាគបី ឱ្យចុះមកត្រឹម មតិភាគច្រើនដាច់ខាត និងសម្រេចមតិភាគច្រើនបីភាគបួនក្នុងមាត្រា ៩០ វាក្យខណ្ឌទី ៥ និងមាត្រា ១០៨ថ្មី វាក្យខណ្ឌទី ៤ ឱ្យចុះមកត្រឹមមតិភាគច្រើនពីរភាគបី ។ ព្រមជាមួយនេះ ក៏បានកែសម្រួលក្អូរ៉ុមសម្រាប់ប្រជុំរដ្ឋសភាចែងក្នុងមាត្រា ៨៨ថ្មី និងសម្រាប់ប្រជុំព្រឹទ្ធសភាចែងក្នុងមាត្រា ១១១ថ្មី (មួយ) ដូចមានខ្លឹមសារថា:

-ក្អូរ៉ុមលើសពី ពីរភាគបី សម្រាប់ការអនុម័តយកសម្លេងពីរភាគបី និង

-ក្អូរ៉ុមលើសពីពាក់កណ្តាល សម្រាប់ការអនុម័តយកសម្លេងភាគច្រើនដាច់ខាត នៃសមាជិករដ្ឋសភា ឬ សមាជិកព្រឹទ្ធសភាទាំងមូល ។

សេចក្តីដូចបានទូលថ្វាយនិងជំរាបជូនខាងលើ សូមរដ្ឋសភាមេត្តាពិនិត្យ និងអនុម័តសេចក្តីព្រាងច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា ៨០ មាត្រា៨២ មាត្រា៨៨ថ្មី មាត្រា៩០ថ្មី មាត្រា៩៨ មាត្រា១០៨ថ្មី មាត្រា១០៦ថ្មី មាត្រា១១១ថ្មី (មួយ) មាត្រា១១៨ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា ៦ នៃច្បាប់ធម្មនុញ្ញបន្ថែមនេះ ដោយចាត់ទុកជាការប្រញាប់តាមការគួរ ៕

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែកុម្ភៈ ឆ្នាំ ២០០៦

ហ៊ុន សែន

១០៤

# សេចក្តីថ្លែងហេតុនៃវិសោធនកម្ម
# លើកទី៦

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ..........

# សេចក្តីថ្លែងហេតុ

## នៃសេចក្តីព្រាងច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្ម មាត្រា ១៤៥ថ្មី និងមាត្រា ១៤៦ថ្មី នៃរដ្ឋធម្មនុញ្ញ

អនុវត្តតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៣ នៃរដ្ឋសភា រាជរដ្ឋាភិបាលកម្ពុជាបានអនុម័ត នូវក្របខ័ណ្ឌយុទ្ធសាស្ត្រ ស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ នាខែមិថុនា ឆ្នាំ២០០៥។ ផ្អែកតាមក្របខ័ណ្ឌយុទ្ធសាស្ត្រ ស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ឆ្នាំ២០០៦-២០១០ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបាននឹងកំពុងរៀបចំនូវប្រព័ន្ធគ្រប់គ្រងរដ្ឋបាលនៅថ្នាក់ក្រោមជាតិ សំដៅធានាឱ្យបាននូវការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់រដ្ឋបាលទាំងនោះ។ ដើម្បីសម្រេចបាននូវទិសដៅទាំងនេះ រាជរដ្ឋាភិបាលកម្ពុជាបាននឹងកំពុងរៀបចំសេចក្តីព្រាងច្បាប់រៀបចំអង្គការ ដូចដែលបានកំណត់ក្នុងមាត្រា ១៤៦ថ្មី នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា។

ការតាក់តែង សេចក្តីព្រាងច្បាប់ខាងលើនេះ មានការប៉ះពាល់ជាមួយបទប្បញ្ញត្តិមាត្រា ១៤៥ថ្មី នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ដែលចាំបាច់ត្រូវមានការកែសម្រួលឱ្យបានសមស្របជាមួយការរីកចម្រើន ខាងវិស័យនយោបាយ រដ្ឋបាល សង្គម និងសេដ្ឋកិច្ចរបស់ជាតិ ទាំងក្នុងពេលចំពោះមុខ និងក្នុងពេលអនាគត។

សេចក្តីដូចបានជម្រាបជូនខាងលើ រាជរដ្ឋាភិបាលកម្ពុជា ស្នើសុំធ្វើវិសោធនកម្មមាត្រា ១៤៥ថ្មី និងមាត្រា១៤៦ថ្មី នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា តាមខ្លឹមសារដូចខាងក្រោម ÷

មាត្រា ១៤៥ថ្មី ត្រូវកែសម្រួលទៅជា :

"ទឹកដីនៃព្រះរាជាណាចក្រកម្ពុជាចែកជា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។"

មាត្រា ១៤៦ថ្មី ត្រូវកែសម្រួលទៅជា :

" រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ត្រូវគ្រប់គ្រងតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងច្បាប់រៀបចំអង្គការ។ "

រាជរដ្ឋាភិបាលកម្ពុជាសង្ឃឹមថា តាមរយៈការធ្វើវិសោធនកម្មខាងលើនេះ នឹងបង្កភាពងាយស្រួល ក្នុងការរៀបចំកែទម្រង់ ការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ តាមគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីលើកកម្ពស់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់រដ្ឋបាលក្រោមជាតិទាំងនេះ សំដៅលើកកម្ពស់ការផ្តល់សេវាកម្ម និងការអភិវឌ្ឍ ប្រកបដោយប្រសិទ្ធភាព និងចីរភាព។

អាស្រ័យហេតុនេះ សូមរដ្ឋសភាមេត្តាពិនិត្យ និងអនុម័តនូវសេចក្តីព្រាងច្បាប់ ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា ១៤៥ថ្មី និង១៤៦ថ្មីនេះ ដោយចាត់ទុកជាការប្រញាប់តាមការគួរ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ [illegible] ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

១៤៣

# សេចក្តីថ្លែងហេតុនៃវិសោធនកម្ម
# លើកទី៧

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សូមក្រាបបង្គំទូលថ្វាយ

រដ្ឋសភា

លេខ ....០៣៣២.. រ.ស.

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា

ព្រះករុណាជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់

ទូលព្រះបង្គំជាខ្ញុំ ក្នុងនាមជាប្រធានរដ្ឋសភា បានទទួលនូវសេចក្តីស្នើច្បាប់ធម្មនុញ្ញពីតំណាងរាស្ត្រហត្ថលេខីចំនួន ៨៥ រូប បានផ្តើមគំនិតធ្វើសេចក្តីស្នើច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា ៧៦ និងមាត្រា ទាំងឡាយ ពីជំពូកទី ១៥ ថ្មី ដល់ជំពូកទី ១៦ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។ សេចក្តីស្នើច្បាប់ធម្មនុញ្ញនេះ ធ្វើឡើងស្របនឹងមាត្រា ១៥១ថ្មី (មាត្រា ១៣២ចាស់) នៃរដ្ឋធម្មនុញ្ញ ។

អនុលោមតាមមាត្រា ១៤៣ ថ្មី (មាត្រា ១២៤ ចាស់) នៃរដ្ឋធម្មនុញ្ញ ទូលព្រះបង្គំជាខ្ញុំ សូមថ្វាយនូវអត្ថបទសេចក្តីស្នើច្បាប់ធម្មនុញ្ញរបស់តំណាងរាស្ត្រហត្ថលេខី ដែលមានឯកសារថ្វាយភ្ជាប់មកជាមួយនេះ ដើម្បីព្រះករុណាជាទីគោរពសក្ការៈទ្រង់មានព្រះតម្រិះពិគ្រោះមតិក្រុមប្រឹក្សាធម្មនុញ្ញ ។

សូមព្រះករុណាថ្លៃវិសេសទ្រង់ព្រះមេត្តាប្រោស ទទួលនូវគារវកក្តីដ៏ខ្ពង់ខ្ពស់បំផុតពីទូលព្រះបង្គំជាខ្ញុំ ។

សូមក្រាបបង្គំទូលថ្វាយ នៅរាជធានីភ្នំពេញ,ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤

ប្រធានរដ្ឋសភា

សម្តេចអគ្គមហាពញាចក្រី ហេង សំរិន

១៨៦

វិមានរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : ( ៨៥៥-២៣ ) ...

# សេចក្តីថ្លែងហេតុនៃវិសោធនកម្ម
# លើកទី៨

**ព្រះរាជាណាចក្រកម្ពុជា**

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ: ៤៧ សរ.កបច

**សូមក្រាបបង្គំទូលថ្វាយ**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**

**ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា**

*ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត*

ទូលព្រះបង្គំជាខ្ញុំ ដោយអនុលោមតាមមាត្រា១៥៣ថ្មី (ពីរ) នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា និងក្នុងឋានៈជានាយករដ្ឋមន្ត្រី បានផ្តួចផ្តើមគំនិតធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ត្រង់មាត្រា៣៤ថ្មី មាត្រា៤២ មាត្រា៤៩ មាត្រា៥៣ និងមាត្រា១១៨ថ្មី ក្នុងគោលបំណងដើម្បីបង្កើនប្រសិទ្ធភាពការងាររបស់អង្គនីតិប្រតិបត្តិ និងដើម្បីលើកស្ទួយតម្លៃជាតិខ្មែរ ក្នុងបុព្វហេតុការពារឯករាជ្យជាតិ អធិបតេយ្យជាតិ និងឯកភាពជាតិ ប្រឆាំងនឹងការជ្រៀតជ្រែកពីខាងក្រៅ តាមគ្រប់រូបភាព ព្រមទាំងដើម្បីលើកស្ទួយការតម្កល់ផលប្រយោជន៍ជាតិ និងរបស់ប្រជាជនជាធំ។ ទូលព្រះបង្គំជាខ្ញុំ សូមថ្វាយនូវអត្ថបទសេចក្តីស្នើវិសោធនកម្មមាត្រា៣៤ថ្មី មាត្រា៤២ មាត្រា៤៩ មាត្រា៥៣ និងមាត្រា១១៨ថ្មី នៃរដ្ឋធម្មនុញ្ញ ដែលមានឯកសារថ្វាយភ្ជាប់មកជាមួយនេះ ដើម្បីព្រះករុណាជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ទ្រង់មានព្រះរាជតម្រិះពិគ្រោះមតិក្រុមប្រឹក្សាធម្មនុញ្ញ ដោយអនុលោមតាមបទប្បញ្ញត្តិនៃមាត្រា១៤៣ថ្មី នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា។

ទូលព្រះបង្គំជាខ្ញុំ សូមក្រាបបង្គំទូលថ្វាយ ព្រះករុណាជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ទ្រង់ព្រះមេត្តាជ្រាបថា សេចក្តីស្នើវិសោធនកម្មរដ្ឋធម្មនុញ្ញនេះ ត្រូវបានដាក់ឆ្លងក្នុងកិច្ចប្រជុំពេញអង្គរបស់គណៈរដ្ឋមន្ត្រី នាថ្ងៃសុក្រ ២ រោច ខែមាឃ ឆ្នាំរកា នព្វស័ក ពុទ្ធសករាជ ២៥៦១ ត្រូវនឹងថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១៨ ហើយសេចក្តីស្នើវិសោធនកម្មរដ្ឋធម្មនុញ្ញនេះ មិនប៉ះពាល់ដល់ប្រព័ន្ធប្រជាធិបតេយ្យសេរីពហុបក្ស និងរបបរាជានិយមអាស្រ័យដោយរដ្ឋធម្មនុញ្ញឡើយ។

ទូលព្រះបង្គំជាខ្ញុំ សូមព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ទ្រង់មានព្រះរាជតម្រិះ ដោយព្រះរាជហឫទ័យអនុគ្រោះ។

សូមព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ទ្រង់ព្រះមេត្តាទទួលនូវគារវកក្តីដ៏ខ្ពង់ខ្ពស់បំផុតពីទូលព្រះបង្គំជាខ្ញុំ។

ថ្ងៃ សុក្រ ២ [illegible] ខែ មាឃ ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១

ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែកុម្ភៈ ឆ្នាំ២០១៨

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# សេចក្ដីថ្លែងហេតុនៃវិសោធនកម្ម
# លើកទី៩

**ព្រះរាជាណាចក្រកម្ពុជា**

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ: ៦០២ លស.កបច

ក្រុមប្រឹក្សាធម្មនុញ្ញ
លេខ ៥០ | ២០២១
ថ្ងៃ ០៨|១០|២០២១ ១៦:៤៥

**សូមក្រាបបង្គំទូលថ្វាយ**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**

**ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា**

*ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត*

ទូលព្រះបង្គំជាខ្ញុំ ដោយអនុលោមតាមមាត្រា១៥៣ ថ្មី(ពីរ) នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងក្នុងឋានៈជានាយករដ្ឋមន្ត្រី បានផ្តួចផ្តើមគំនិតធ្វើវិសោធនកម្មមាត្រា១៩ ថ្មី មាត្រា៨២ ថ្មី មាត្រា១០៦ ថ្មី(មួយ) មាត្រា១១៩ ថ្មី និងមាត្រា១៣៧ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា៣និងមាត្រា៤ នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ ដើម្បីកំណត់ឱ្យប្រធានរដ្ឋសភា ប្រធានព្រឹទ្ធសភា នាយករដ្ឋមន្ត្រី និងប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវតែជាឥស្សរជនដែលមាន "**សញ្ជាតិខ្មែរតែមួយគត់**"។ ការស្នើសុំធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជានេះ គឺមានគោលបំណងដ៏សំខាន់ ដើម្បីធានាទាំងខាងផ្លូវច្បាប់ ទាំងខាងនយោបាយ ឱ្យឥស្សរជនជាន់ខ្ពស់ដែលកាន់មុខតំណែងជាប្រមុខនៃស្ថាប័នកំពូលទាំង ៤ របស់ជាតិ ដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រូវប្រកាន់ខ្ជាប់នូវភាពស្មោះត្រង់ឥតងាករេចំពោះជាតិ មាតុភូមិ និងប្រជាជនកម្ពុជានៅគ្រប់កាលៈទេសៈទាំងអស់ ក៏ដូចជាធ្វើការដឹកនាំប្រទេសដោយធានាការពារឧត្តមប្រយោជន៍របស់ជាតិនិងប្រជាជនកម្ពុជាជាធំ ព្រមទាំងប្រឆាំងនឹងការជ្រៀតជ្រែកពីខាងក្រៅចូលមកក្នុងកិច្ចការផ្ទៃក្នុងនៃការដឹកនាំជាតិរបស់កម្ពុជា។ ទូលព្រះបង្គំជាខ្ញុំសូមថ្វាយនូវអត្ថបទ "សេចក្តីស្នើសុំធ្វើវិសោធនកម្មមាត្រា១៩ ថ្មី មាត្រា៨២ ថ្មី មាត្រា១០៦ ថ្មី(មួយ) មាត្រា១១៩ ថ្មី និងមាត្រា១៣៧ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា៣និងមាត្រា៤ នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ" ដែលមានឯកសារថ្វាយភ្ជាប់មកជាមួយនេះ ដើម្បីព្រះករុណាជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ទ្រង់មានព្រះរាជតម្រិះពិគ្រោះមតិក្រុមប្រឹក្សាធម្មនុញ្ញ ដោយអនុលោមតាមបទប្បញ្ញត្តិនៃមាត្រា១៤៣ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

ទូលព្រះបង្គំជាខ្ញុំ សូមក្រាបបង្គំទូលថ្វាយ **ព្រះករុណាជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត** ទ្រង់ព្រះមេត្តាជ្រាបថា សេចក្តីស្នើសុំធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញនេះ ត្រូវបានដាក់ឆ្លងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃសុក្រ ២កើត ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី៨ ខែតុលា ឆ្នាំ២០២១ ហើយសេចក្តីស្នើសុំធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញនេះ មិនប៉ះពាល់ដល់ប្រព័ន្ធប្រជាធិបតេយ្យសេរីពហុបក្ស និងរបបរាជានិយមអាស្រ័យដោយរដ្ឋធម្មនុញ្ញឡើយ។

ទូលព្រះបង្គំជាខ្ញុំ សូមព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ទ្រង់មានព្រះរាជតម្រិះដោយព្រះរាជហឫទ័យអនុគ្រោះបំផុត។

សូមព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ទ្រង់ព្រះមេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់បំផុតពីទូលព្រះបង្គំជាខ្ញុំ។

ថ្ងៃ សុក្រ ២ កើត ខែ អស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ តុលា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**ព្រះរាជាណាចក្រកម្ពុជា**

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ: ៧៤ សរណ.ការ

# សេចក្តីថ្លែងហេតុ

# អំពី

# សេចក្តីព្រាងច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា១៩ ថ្មី មាត្រា៨២ ថ្មី មាត្រា១០៦ ថ្មី(មួយ) មាត្រា១១៩ ថ្មី និងមាត្រា១៣៧ ថ្មី នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា៣និងមាត្រា៤ នៃច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ

រដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និងក្រុមប្រឹក្សាធម្មនុញ្ញ គឺជាស្ថាប័នកំពូលរបស់ជាតិ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងមានការទទួលខុសត្រូវក្នុងការសម្រេចលើកិច្ចការសំខាន់ៗ ដែលជាអាយុជីវិតរបស់ប្រទេសជាតិ សំដៅធានាការពារឯករាជ្យជាតិ អធិបតេយ្យជាតិ និងបូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ឧត្តមប្រយោជន៍ជាតិនិងប្រជាជនកម្ពុជា និងការប្រឆាំងដាច់ខាតនឹងការជ្រៀតជ្រែកពីបរទេសចូលក្នុងកិច្ចការផ្ទៃក្នុងរបស់ជាតិ ឬការបង្គាប់បញ្ជាចំពោះគោលនយោបាយជាតិនិងអន្តរជាតិរបស់កម្ពុជា។ ផ្អែកលើមូលដ្ឋាននេះ ប្រធានរដ្ឋសភា ប្រធានព្រឹទ្ធសភា នាយករដ្ឋមន្ត្រី និងប្រធានក្រុមប្រឹក្សាធម្មនុញ្ញ សុទ្ធតែត្រូវបានកំណត់ឱ្យមានកាតព្វកិច្ចត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់តំណែង នៅចំពោះព្រះភ័ក្រ្ត ព្រះមហាក្សត្រ ព្រះភ័ក្រ្តនៃសម្តេចព្រះសង្ឃរាជ និងទេវតារក្សាស្វេតច្ឆត្រ ដោយត្រូវសច្ចាប្តេជ្ញាជាដាច់ខាតក្នុងការអនុវត្តកាតព្វកិច្ចស្មោះត្រង់ចំពោះជាតិនិងការការពារឧត្តមប្រយោជន៍ដែលជាអាយុជីវិតរបស់ជាតិនិងប្រជាជនកម្ពុជា។ ទន្ទឹមនេះ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជានិងច្បាប់ដែលមានការពាក់ព័ន្ធ ក៏បានតម្រូវឱ្យតំណាងរាស្ត្រ សមាជិកព្រឹទ្ធសភា នាយករដ្ឋមន្ត្រី និងសមាជិកក្រុមប្រឹក្សាធម្មនុញ្ញទាំងអស់ ត្រូវតែមានសញ្ជាតិខ្មែរតាំងពីកំណើត។ បន្ថែមពីនេះ ប្រធាន អនុប្រធាន និងសមាជិកទាំងអស់នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលជាស្ថាប័នមានចែងក្នុងរដ្ឋធម្មនុញ្ញផងដែរនោះ ក៏ត្រូវបានច្បាប់កំណត់ឱ្យត្រូវតែមានសញ្ជាតិខ្មែរពីកំណើតនិងមានសញ្ជាតិខ្មែរតែមួយគត់ ដើម្បីធានាឱ្យការបំពេញភារកិច្ចរបស់ខ្លួនទាក់ទងនឹងការងារបោះឆ្នោត ដែលជាស្នូលនៃដំណើរការប្រជាធិបតេយ្យសេរីពហុបក្សនៅកម្ពុជា ប្រព្រឹត្តទៅដោយឯករាជ្យ ដើម្បីធានាការពារឧត្តមប្រយោជន៍ជាតិពីការជ្រៀតជ្រែកពីខាងក្រៅចូលក្នុងកិច្ចការផ្ទៃក្នុង ទាក់ទងនឹងកិច្ចដំណើរការបោះឆ្នោត។

ដើម្បីធានាឱ្យវិកភាពទាំងខាងផ្លូវច្បាប់ ទាំងខាងនយោបាយ ចំពោះគោលជំហរ និងការប្តេជ្ញាចិត្តស្មោះត្រង់ឥតងាករេចំពោះជាតិ មាតុភូមិ និងប្រជាជនកម្ពុជានៅគ្រប់កាលៈទេសៈទាំងអស់ និងដើម្បីធានាការពារឧត្តមប្រយោជន៍របស់ជាតិនិងប្រជាជនកម្ពុជាពីការជ្រៀតជ្រែកពីបរទេស, ខ្ញុំ ក្នុងនាមជានាយករដ្ឋមន្ត្រី

១

នៃព្រះរាជាណាចក្រកម្ពុជា និងដោយយោងតាមមាត្រា១៥៣ ថ្មី(ពីរ) នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា សូមស្នើធ្វើវិសោធនកម្មមាត្រា១៩ ថ្មី មាត្រា៨២ ថ្មី មាត្រា១០៦ ថ្មី(មួយ) មាត្រា១១៩ ថ្មី និងមាត្រា១៣៧ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា៣និងមាត្រា៤ នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ សំដៅចារឹកគោលការណ៍គ្រឹះទាំងនេះចូលទៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលជាច្បាប់គ្រឹះនិងជាច្បាប់កំពូលរបស់ជាតិ ដោយកំណត់ឱ្យប្រធានរដ្ឋសភា ប្រធានព្រឹទ្ធសភា នាយករដ្ឋមន្ត្រី និងប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវតែជាឥស្សរជនដែលមាន "**សញ្ជាតិខ្មែរតែមួយគត់**"។

សេចក្តីព្រាងច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា១៩ ថ្មី មាត្រា៨២ ថ្មី មាត្រា១០៦ ថ្មី(មួយ) មាត្រា១១៩ ថ្មី និងមាត្រា១៣៧ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា៣និងមាត្រា៤ នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ ត្រូវបានដាក់ឆ្លងកិច្ចប្រជុំពេញអង្គរបស់គណៈរដ្ឋមន្ត្រី នាថ្ងៃសុក្រ ២កើត ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី៨ ខែតុលា ឆ្នាំ២០២១ កន្លងទៅនេះ។ ខ្ញុំបានក្រាបបង្គំទូលថ្វាយ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** រួចហើយ នូវអត្ថបទនៃសេចក្តីព្រាងច្បាប់ធម្មនុញ្ញនេះ ដើម្បី**ព្រះករុណាជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត** ទ្រង់មានព្រះរាជតម្រិះពិគ្រោះមតិជាមួយក្រុមប្រឹក្សាធម្មនុញ្ញ ស្របតាមមាត្រា១៤៣ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ហើយ**ព្រះករុណាជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត** ទ្រង់បានផ្ញើព្រះរាជសារតបដោយភ្ជាប់នូវលិខិតរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ដូចមានសេចក្តីចម្លងភ្ជាប់ជូនមកជាមួយនេះ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមរដ្ឋសភាមេត្តាពិនិត្យនិងអនុម័តសេចក្តីព្រាងច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា១៩ ថ្មី មាត្រា៨២ ថ្មី មាត្រា១០៦ ថ្មី(មួយ) មាត្រា១១៩ ថ្មី និងមាត្រា១៣៧ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា៣និងមាត្រា៤ នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ ដោយចាត់ទុកជាការប្រញាប់ ដោយក្តីអនុគ្រោះ។

ថ្ងៃច័ន្ទ ៥កើត ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី១១ ខែតុលា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

២

**ព្រះរាជាណាចក្រកម្ពុជា**

**ទីស្តីការគណៈរដ្ឋមន្ត្រី** **ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខ:** ០៧សជណ

# សេចក្តីថ្លែងហេតុ
# នៃ
# សេចក្តីព្រាងច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា១៩ ថ្មី មាត្រា៨២ ថ្មី មាត្រា១០៦ ថ្មី(មួយ) មាត្រា១១៩ ថ្មី និងមាត្រា១៣៧ ថ្មី នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា៣និងមាត្រា៤ នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ

- សូមគោរព **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត
- សូមគោរពសម្តេច ឯកឧត្តម លោកជំទាវ សមាជិក សមាជិកានៃអង្គគណៈរដ្ឋមន្ត្រី

ជាបឋម ខ្ញុំបាទសូមថ្លែងអំណរគុណចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានអនុញ្ញាតឱ្យដាក់សេចក្តីព្រាង "**ច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា១៩ ថ្មី មាត្រា៨២ ថ្មី មាត្រា១០៦ ថ្មី(មួយ) មាត្រា១១៩ ថ្មី និងមាត្រា១៣៧ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា៣និងមាត្រា៤ នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ**" នៅក្នុងរបៀបវារៈទី១នៃកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីនាថ្ងៃនេះ ដើម្បីពិនិត្យនិងអនុម័តដ៏ខ្ពង់ខ្ពស់។

ខ្ញុំបាទសូមគោរពជម្រាបជូន **សម្តេចតេជោនាយករដ្ឋមន្ត្រី** និងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីមេត្តាជ្រាបថា រដ្ឋសភា, ព្រឹទ្ធសភា, រាជរដ្ឋាភិបាល និងក្រុមប្រឹក្សាធម្មនុញ្ញ គឺជាស្ថាប័នកំពូលរបស់ជាតិ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងមានការទទួលខុសត្រូវក្នុងការសម្រេចលើកិច្ចការសំខាន់ៗ ដែលជាអាយុជីវិតរបស់ប្រទេសជាតិ សំដៅធានាការពារឯករាជ្យជាតិ អធិបតេយ្យជាតិ និងបូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា, ឧត្តមប្រយោជន៍ជាតិ និងប្រជាជនកម្ពុជា និងការប្រឆាំងដាច់ខាតនឹងការជ្រៀតជ្រែកពីបរទេសចូលក្នុងកិច្ចការផ្ទៃក្នុងរបស់ជាតិ ឬការបង្គាប់បញ្ជាចំពោះគោលនយោបាយជាតិ និងអន្តរជាតិរបស់កម្ពុជា។ ផ្អែកលើមូលដ្ឋាននេះ ប្រធានរដ្ឋសភា, ប្រធានព្រឹទ្ធសភា, នាយករដ្ឋមន្ត្រី និងប្រធានក្រុមប្រឹក្សាធម្មនុញ្ញ សុទ្ធតែត្រូវបានកំណត់ឱ្យមានកាតព្វកិច្ចត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់តំណែង នៅចំពោះព្រះភ័ក្ត្រព្រះមហាក្សត្រ ព្រះភ័ក្ត្រនៃសម្តេចព្រះសង្ឃរាជ និងទេវតារក្សាស្វេតច្ឆត្រ ដោយត្រូវសច្ចាប្តេជ្ញាជាដាច់ខាតក្នុងការអនុវត្តកាតព្វកិច្ចស្មោះត្រង់ចំពោះជាតិ និងការការពារឧត្តមប្រយោជន៍ ដែលជាអាយុជីវិតរបស់ជាតិ និងប្រជាជនកម្ពុជា។ ទន្ទឹមនេះ, រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់ដែលមានការពាក់ព័ន្ធ ក៏បាន

តម្រូវឱ្យតំណាងរាស្ត្រ, សមាជិកព្រឹទ្ធសភា, នាយករដ្ឋមន្ត្រី និងសមាជិកក្រុមប្រឹក្សាធម្មនុញ្ញទាំងអស់ ត្រូវតែមានសញ្ជាតិខ្មែរតាំងពីកំណើត។ បន្ថែមពីនេះ ប្រធាន អនុប្រធាន និងសមាជិកទាំងអស់នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលជាស្ថាប័នមានចែងក្នុងរដ្ឋធម្មនុញ្ញផងដែរនោះ ក៏ត្រូវបានច្បាប់កំណត់ឱ្យត្រូវតែមានសញ្ជាតិខ្មែរពីកំណើត និងមានសញ្ជាតិខ្មែរតែមួយគត់ ដើម្បីធានាឱ្យការបំពេញភារកិច្ចរបស់ខ្លួនទាក់ទងនឹងការងារបោះឆ្នោត ដែលជាស្នូលនៃដំណើរការប្រជាធិបតេយ្យសេរីពហុបក្សនៅកម្ពុជា ប្រព្រឹត្តទៅដោយឯករាជ្យ ដើម្បីធានាការពារឧត្តមប្រយោជន៍ជាតិពីការជ្រៀតជ្រែកចូលក្នុងកិច្ចការផ្ទៃក្នុង ទាក់ទងនឹងកិច្ចដំណើរការបោះឆ្នោតពីខាងក្រៅ។

ដើម្បីធានាបានឱឡារិកភាពទាំងខាងផ្លូវច្បាប់ ទាំងខាងនយោបាយ ចំពោះគោលជំហរ និងការប្តេជ្ញាចិត្តស្មោះត្រង់ឥតងាករេចំពោះជាតិ មាតុភូមិ និងប្រជាជនកម្ពុជានៅគ្រប់កាលៈទេសៈទាំងអស់ និងដើម្បីធានាការពារឧត្តមប្រយោជន៍របស់ជាតិ និងប្រជាជនកម្ពុជាពីការជ្រៀតជ្រែកពីបរទេស, និងដោយយោងតាមមាត្រា១៥៣ ថ្មី(ពីរ) នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា រាជរដ្ឋាភិបាលសូមស្នើធ្វើវិសោធនកម្មមាត្រា១៩ ថ្មី មាត្រា៨២ ថ្មី មាត្រា១០៦ ថ្មី(មួយ) មាត្រា១១៩ ថ្មី និងមាត្រា១៣៧ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា៣និងមាត្រា៤ នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ សំដៅចារឹកគោលការណ៍គ្រឹះទាំងនេះចូលទៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលជាច្បាប់គ្រឹះ និងជាច្បាប់កំពូលរបស់ជាតិ ដោយកំណត់ឱ្យប្រធានរដ្ឋសភា, ប្រធានព្រឹទ្ធសភា, នាយករដ្ឋមន្ត្រី និងប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវតែជាឥស្សរជនដែលមាន "សញ្ជាតិខ្មែរតែមួយគត់"។

សេចក្តីព្រាងច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា១៩ ថ្មី មាត្រា៨២ ថ្មី មាត្រា១០៦ ថ្មី(មួយ) មាត្រា១១៩ ថ្មី និងមាត្រា១៣៧ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា៣និងមាត្រា៤ នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ រួមមាន៣មាត្រាដែលមានខ្លឹមសារសង្ខេបដូចខាងក្រោម៖

- មាត្រាមួយ ចែងអំពីសំណើធ្វើវិសោធនកម្មមាត្រា១៩ ថ្មី មាត្រា៨២ ថ្មី មាត្រា១០៦ ថ្មី(មួយ) មាត្រា១១៩ ថ្មី និងមាត្រា១៣៧ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- មាត្រាពីរ ចែងអំពីសំណើធ្វើវិសោធនកម្មមាត្រា៣និងមាត្រា៤ នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- មាត្រាបី ចែងអំពីការប្រកាសច្បាប់នេះជាការប្រញាប់។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **សម្តេចតេជោនាយករដ្ឋមន្ត្រី** និងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី មេត្តាពិនិត្យនិងអនុម័តលើសេចក្តីព្រាងច្បាប់នេះដោយក្តីអនុគ្រោះ។

ថ្ងៃព្រហស្បតិ៍ ១កើត ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ តុលា ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

២

# សេចក្តីថ្លែងហេតុនៃវិសោធនកម្ម
# លើកទី១០

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៦២៥ ធស

# សូមក្រាបបង្គំទូលថ្វាយ
# ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
# ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា

*ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត*

ទូលព្រះបង្គំជាខ្ញុំ ដោយអនុលោមតាមមាត្រា១៥៣ ថ្មី(ពីរ) នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងក្នុងឋានៈជានាយករដ្ឋមន្ត្រី បានផ្តួចផ្តើមធ្វើវិសោធនកម្ម**មាត្រា១៩ ថ្មី(មួយ) មាត្រា៨៩ មាត្រា៩៨ ថ្មី មាត្រា១០២ ថ្មី មាត្រា១១៩ ថ្មី(មួយ) និងមាត្រា១២៥ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា៣ ថ្មី និងមាត្រា៤ ថ្មី នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ។** ការស្នើសុំធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជានេះ គឺធ្វើឡើងក្នុងគោលបំណងធានានូវគោលដៅសំខាន់របស់ជាតិចំនួនពីរ ៖ *(ទី១)*-ការធានាឱ្យស្ថាប័នកំពូលរបស់ជាតិ ជាពិសេស អំណាចនីតិប្រតិបត្តិដែលមានបេសកកម្មចម្បងក្នុងការដឹកនាំការងារទូទៅរបស់រដ្ឋ មានដំណើរការប្រព្រឹត្តទៅដោយរលូន និងប្រកបដោយនិរន្តរភាពនៅគ្រប់កាលៈទេសៈ និង*(ទី២)*-ការធានាការពារ និងថែរក្សាឱ្យបាននូវសន្តិភាព សន្តិសុខសង្គម សណ្តាប់ធ្នាប់សាធារណៈ និងស្ថិរភាពនយោបាយរបស់ប្រទេសជាតិនៅគ្រប់កាលៈទេសៈ ដើម្បីជាគ្រឹះសម្រាប់ការអភិវឌ្ឍប្រទេសជាតិលើគ្រប់វិស័យ និងសេចក្តីសុខសាន្តរបស់ប្រជាជនកម្ពុជា។

ទូលព្រះបង្គំជាខ្ញុំ សូមថ្វាយនូវអត្ថបទ **"សេចក្តីស្នើសុំធ្វើវិសោធនកម្មមាត្រា១៩ ថ្មី(មួយ) មាត្រា៨៩ មាត្រា៩៨ ថ្មី មាត្រា១០២ ថ្មី មាត្រា១១៩ ថ្មី(មួយ) និងមាត្រា១២៥ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា៣ ថ្មី និងមាត្រា៤ ថ្មី នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ"** ដែលមានឯកសារថ្វាយភ្ជាប់មកជាមួយនេះ ដើម្បី**ព្រះករុណាជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត** ទ្រង់មានព្រះរាជតម្រិះពិគ្រោះមតិក្រុមប្រឹក្សាធម្មនុញ្ញ ដោយអនុលោមតាមបទប្បញ្ញត្តិនៃមាត្រា១៤៣ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

ទូលព្រះបង្គំជាខ្ញុំ សូមក្រាបបង្គំទូលថ្វាយ **ព្រះករុណាជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត** ទ្រង់ព្រះមេត្តាជ្រាបថា សេចក្តីស្នើសុំធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញនេះ ត្រូវបានដាក់ឆ្លងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃសុក្រ ១០កើត ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០២២

ហើយសេចក្តីស្នើសុំធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញនេះ មិនប៉ះពាល់ដល់ប្រព័ន្ធប្រជាធិបតេយ្យសេរីពហុបក្ស និងរបបរាជានិយមអាស្រ័យដោយរដ្ឋធម្មនុញ្ញឡើយ។

ទូលព្រះបង្គំជាខ្ញុំ សូម **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ទ្រង់មានព្រះរាជតម្រិះដោយព្រះរាជហឫទ័យអនុគ្រោះបំផុត។

សូម **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ទ្រង់ព្រះមេត្តាទទួលនូវគារវភក្តីដ៏ខ្ពង់ខ្ពស់បំផុតពីទូលព្រះបង្គំជាខ្ញុំ។

ថ្ងៃ សុក្រ ១០កើត ខែ អាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ ថ្ងៃទី ៨ ខែកក្កដា ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ១១ សរណ.កបឌ

# សេចក្តីថ្លែងហេតុ
## អំពី
## សេចក្តីព្រាងច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា១៩ ថ្មី (មួយ) មាត្រា៨៩ មាត្រា៩៨ ថ្មី មាត្រា១០២ ថ្មី មាត្រា១១៩ ថ្មី (មួយ) និងមាត្រា១២៥ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា៣ ថ្មី និងមាត្រា៤ ថ្មី នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានប្រកាសឱ្យប្រើកាលពីថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ និងត្រូវបានធ្វើវិសោធនកម្មជាបន្តបន្ទាប់ចំនួន ៩ លើក សំដៅធានាឱ្យបាននូវនិរន្តរភាពជាតិ ក៏ដូចជាការពារនូវឧត្តមប្រយោជន៍របស់ប្រទេសជាតិ និងប្រជាជនកម្ពុជា។ សំណើវិសោធនកម្មលើកទី ១០ នៃរដ្ឋធម្មនុញ្ញនាពេលនេះ ក៏ត្រូវបានធ្វើឡើងក្នុងគោលបំណងសំខាន់ចំនួនពីរផងដែរ ដើម្បីជាឧត្តមប្រយោជន៍របស់ជាតិ គឺ៖ (ទី១)-ការធានាឱ្យស្ថាប័នកំពូលរបស់ជាតិ ជាពិសេស អំណាចនីតិប្រតិបត្តិដែលមានបេសកកម្មចម្បងក្នុងការដឹកនាំការងារទូទៅរបស់រដ្ឋ មានដំណើរការប្រព្រឹត្តទៅដោយរលូន និងប្រកបដោយនិរន្តរភាពនៅគ្រប់កាលៈទេសៈ និង(ទី២)-ការធានាការពារ និងថែរក្សាឱ្យបាននូវសន្តិភាព សន្តិសុខសង្គម សណ្តាប់ធ្នាប់សាធារណៈ និងស្ថិរភាពនយោបាយរបស់ប្រទេសជាតិនៅគ្រប់កាលៈទេសៈ ដើម្បីជាគ្រឹះសម្រាប់ការអភិវឌ្ឍប្រទេសជាតិលើគ្រប់វិស័យ និងសេចក្តីសុខសាន្តរបស់ប្រជាជនកម្ពុជា។

បន្ថែមពីនេះ ការស្នើធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញលើកនេះ ក៏ធានាបាននូវការគោរពគោលការណ៍គ្រឹះនៃរបបរាជានិយមអាស្រ័យដោយរដ្ឋធម្មនុញ្ញ ដែលជារបបដឹកនាំប្រទេសតាមបែបរបបសភានិយម ព្រមទាំងជាការលើកកម្ពស់នូវគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ដែលប្រជាជនកម្ពុជាបង្ហាញឆន្ទៈ និងប្រើសិទ្ធិអំណាចរបស់ខ្លួន តាមរយៈការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលប្រព្រឹត្តទៅរៀងរាល់ ៥ ឆ្នាំម្តង ប្រកបដោយលក្ខណៈសេរី ត្រឹមត្រូវ និងយុត្តិធម៌ ស្របតាមគោលការណ៍ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ព្រមទាំងច្បាប់ និងបទដ្ឋានគតិយុត្តជាធរមានរបស់ជាតិ។

ដើម្បីឆ្លើយតបនឹងសំណូមពរចាំបាច់ និងគោលដៅខាងលើនេះ ពិសេសដើម្បីធានានូវនិរន្តរភាពចំពោះកិច្ចដំណើរការប្រព្រឹត្តទៅជាប្រក្រតី និងដោយរលូនរបស់ស្ថាប័នកំពូលរបស់ជាតិ ស្របតាមគោលការណ៍លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស និងគោលការណ៍នៃរបបរាជានិយមអាស្រ័យដោយរដ្ឋធម្មនុញ្ញ, ខ្ញុំ ក្នុងនាមនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងដោយអនុលោមតាមមាត្រា១៥៣ ថ្មី(ពីរ) នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជា

ណាចក្រកម្ពុជា សូមស្នើធ្វើវិសោធនកម្មមាត្រា១៩ ថ្មី(មួយ) មាត្រា៨៩ មាត្រា៩៨ ថ្មី មាត្រា១០២ ថ្មី មាត្រា១១៩ ថ្មី (មួយ) និងមាត្រា១២៥ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា៣ ថ្មី និងមាត្រា៤ ថ្មី នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ។

សេចក្តីព្រាងច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា១៩ ថ្មី(មួយ) មាត្រា៨៩ មាត្រា៩៨ ថ្មី មាត្រា១០២ ថ្មី មាត្រា១១៩ ថ្មី (មួយ) និងមាត្រា១២៥ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា៣ ថ្មី និងមាត្រា៤ ថ្មី នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ ត្រូវបានដាក់ឆ្លងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីនាថ្ងៃសុក្រ ១០កើត ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី៨ ខែកក្កដា ឆ្នាំ ២០២២ កន្លងទៅនេះ។ ខ្ញុំបានក្រាបបង្គំទូលថ្វាយ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** រួចហើយ នូវអត្ថបទនៃសេចក្តីព្រាងច្បាប់ធម្មនុញ្ញនេះ ដើម្បី **ព្រះករុណាជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត** ទ្រង់មានព្រះរាជតម្រិះពិគ្រោះមតិក្រុមប្រឹក្សាធម្មនុញ្ញ ស្របតាមមាត្រា១៤៣ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ហើយ **ព្រះករុណាជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត** ទ្រង់បានផ្ញើព្រះរាជសារតបដោយភ្ជាប់នូវលិខិតរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ដូចមានសេចក្តីចម្លងភ្ជាប់ជូនមកជាមួយនេះ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **រដ្ឋសភា** មេត្តាពិនិត្យ និងអនុម័តសេចក្តីព្រាងច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា១៩ ថ្មី(មួយ) មាត្រា៨៩ មាត្រា៩៨ ថ្មី មាត្រា១០២ ថ្មី មាត្រា១១៩ ថ្មី(មួយ) និងមាត្រា១២៥ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា៣ ថ្មី និងមាត្រា៤ ថ្មី នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ ដោយចាត់ទុកជាការប្រញាប់ ដោយក្តីអនុគ្រោះ។

ថ្ងៃពុធ ១៥កើត ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*រាជធានីភ្នំពេញ, ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២២ (V1)*

## បទអន្តរាគមន៍

## របស់ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាល

*ថ្លែងក្នុងកិច្ចប្រជុំពេញអង្គលើកទី៧ នីតិកាលទី៦ នៃរដ្ឋសភា ពាក់ព័ន្ធនឹងការធ្វើវិសោធនកម្មលើកទី១០ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា នាព្រឹកថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២២ នៅវិមានរដ្ឋសភា*

- *សូមគោរព **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ប្រធានរដ្ឋសភា ជាទីគោរពដ៏ខ្ពង់ខ្ពស់!*
- *សូមគោរព **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់!*
- *សូមគោរព **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ជាម យៀប អនុប្រធានទី១** នៃរដ្ឋសភា ជាទីគោរព!*
- *សូមគោរព **លោកជំទាវកិត្តិសង្គហបណ្ឌិត ឃួន សុដារី អនុប្រធានទី២** នៃរដ្ឋសភា ជាទីគោរព!*
- *សូមគោរព **គណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភា** ជាទីគោរព!*
- *សូមគោរព **សម្តេច ឯកឧត្តម លោកជំទាវ** ជាសមាជិក សមាជិកានៃរដ្ឋសភាដ៏ឧត្តុង្គឧត្តម!*

ថ្ងៃនេះ ដោយមានការអនុញ្ញាត និងការចាត់តាំងដ៏ខ្ពង់ខ្ពស់ពី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ខ្ញុំបាទ ព្រមទាំងសហការី ក្នុងនាមជាតំណាងរាជរដ្ឋាភិបាលការពារ "សេចក្តីព្រាងច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា១៩ ថ្មី(មួយ), មាត្រា៨៩, មាត្រា៩៨ ថ្មី, មាត្រា១០២ ថ្មី, មាត្រា១១៩ ថ្មី(មួយ) និងមាត្រា១២៥ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា៣ ថ្មី និងមាត្រា៤ ថ្មី នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ" ដែលតទៅនេះយើងហៅកាត់ថា "វិសោធនកម្មលើកទី១០ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា" សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅជូនចំពោះ **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងគណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភា ដែលបានសម្រេចដាក់សេចក្តីព្រាងច្បាប់ធម្មនុញ្ញនេះចូលក្នុងរបៀបវារៈនៃសម័យប្រជុំពេញអង្គលើកទី៧ នីតិកាលទី៦ នៃរដ្ឋសភា នាពេលនេះ។

ខ្ញុំសូមឆ្លៀតឱកាសដ៏បវរនេះ ថ្លែងអំណរគុណចំពោះ **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ប៉ែន បញ្ញា ប្រធានគណៈកម្មការនីតិកម្ម និងយុត្តិធម៌នៃរដ្ឋសភា**, ឯកឧត្តម លោកជំទាវ ជាអនុប្រធាន

១

និងសមាជិកទាំងអស់នៃគណៈកម្មការនីតិកម្ម និងយុត្តិធម៌នៃរដ្ឋសភា ព្រមទាំង ឯកឧត្តម និង លោកជំទាវ ជាប្រធាន និងជាតំណាងគណៈកម្មការនានានៃរដ្ឋសភា ដែលបានជួយពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ធម្មនុញ្ញនេះ ប្រកបដោយការយកចិត្តទុកដាក់ និងស្មារតីទទួលខុសត្រូវខ្ពស់។ ខ្ញុំសូមឯកភាពជាមួយខ្លឹមសារនៃរបាយការណ៍ដែលបានលើកឡើងមុននេះបន្តិចដោយ **ឯកឧត្តម កិត្តិនីតិកោសលបណ្ឌិត ម៉ែន ចញ្ញា ប្រធានគណៈកម្មការនីតិកម្ម និងយុត្តិធម៌នៃរដ្ឋសភា** ទាំងលើខ្លឹមសារនៃសេចក្តីព្រាងច្បាប់ធម្មនុញ្ញនេះ ទាំងលើដំណើរការនៃការរៀបចំសេចក្តីព្រាងច្បាប់ធម្មនុញ្ញ។

***សម្តេចមហាពញាចក្រី** ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់!*
*សម្តេច ឯកឧត្តម លោកជំទាវ សមាជិក សមាជិកា នៃរដ្ឋសភាដ៏ឧត្តុង្គឧត្តម!*

បន្តទៅទៀតនេះ, ខ្ញុំបាទសូមអនុញ្ញាតបង្ហាញជូនអង្គរដ្ឋសភាដ៏ឧត្តុង្គឧត្តមអំពីគោលបំណង, អំពីមូលដ្ឋានច្បាប់ និងអំពីខ្លឹមសារសំខាន់ៗនៃការធ្វើវិសោធនកម្មលើក១០ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជា-ណាចក្រកម្ពុជា ដូចតទៅ៖

### *I-អំពីគោលបំណងនៃការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញលើកទី១០៖*

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានប្រកាសឱ្យប្រើកាលពីថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ ១៩៩៣ ត្រូវបានធ្វើវិសោធនកម្មជាបន្តបន្ទាប់ចំនួន ៩ លើក រួចមកហើយ ក្នុងគោលបំណងធានាឱ្យបាននូវនិរន្តរភាពជាតិ ក៏ដូចជាធានាការពារនូវឧត្តមប្រយោជន៍របស់ប្រទេសជាតិ និងប្រជាជនកម្ពុជា។ ចំពោះសំណើវិសោធនកម្មលើកទី១០ នៃរដ្ឋធម្មនុញ្ញ នាពេលនេះ ក៏ត្រូវបានធ្វើឡើងក្នុងគោលបំណងសំខាន់ចំនួន ២ ផងដែរ ដើម្បីជាឧត្តមប្រយោជន៍ជាតិ គឺ៖ *(ទី១)*-ការធានាឱ្យស្ថាប័នកំពូលរបស់ជាតិ ជាពិសេស អំណាចនីតិប្រតិបត្តិដែលមានបេសកកម្មចម្បងក្នុងការដឹកនាំការងារទូទៅរបស់រដ្ឋ បានដំណើរការប្រព្រឹត្តទៅដោយរលូន និងប្រកបដោយនិរន្តរភាព នៅគ្រប់កាលៈទេសៈ និង *(ទី២)*-ការធានាការពារ និងថែរក្សាឱ្យបាននូវសន្តិភាព, សន្តិសុខសង្គម, សណ្តាប់ធ្នាប់សាធារណៈ និងស្ថិរភាពនយោបាយរបស់ប្រទេសជាតិ នៅគ្រប់កាលៈទេសៈទាំងអស់ ដើម្បីជាគ្រឹះសម្រាប់ការអភិវឌ្ឍន៍ប្រទេសជាតិលើគ្រប់វិស័យ និងសេចក្តីសុខសាន្តរបស់ប្រជាជនកម្ពុជា។

ដើម្បីបម្រើឱ្យគោលបំណងដ៏សំខាន់របស់ប្រទេសជាតិទាំង ២ ខាងលើនេះ សំណើធ្វើវិសោធនកម្មលើកទី១០ នេះ មានការពាក់ព័ន្ធនឹងមាត្រាចំនួន ៨ មាត្រា ក្នុងនោះ៖ *រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ចំនួន ៦ មាត្រា* គឺមាត្រា១៩ ថ្មី(មួយ), មាត្រា៨៩, មាត្រា៩៨ ថ្មី, មាត្រា១០២ ថ្មី, មាត្រា ១១៩ ថ្មី(មួយ) និងមាត្រា១២៥ ថ្មី និង*ច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ ចំនួន ២ មាត្រា* គឺ មាត្រា៣ ថ្មី និង មាត្រា៤ ថ្មី។

២

*II-អំពីមូលដ្ឋានច្បាប់សម្រាប់ការធ្វើសំណើវិសោធនកម្មរដ្ឋធម្មនុញ្ញលើកទី១០ នេះ៖*

ដូចមានក្នុងសេចក្ដីថ្លែងហេតុជូនរដ្ឋសភារួចហើយ និងលិខិតគោរពជូន **សម្ដេចប្រធានរដ្ឋ-សភា**, សំណើធ្វើវិសោធនកម្មលើកទី១០ នៃរដ្ឋធម្មនុញ្ញនេះ ត្រូវបានធ្វើឡើង ដោយផ្អែកលើមូលដ្ឋាន នៃមាត្រា១៥៣ ថ្មី(ពីរ) នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលចែងថា *"ការផ្ដើមគំនិតសើរើ ឬការផ្ដើមគំនិតធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញជាសិទ្ធិរបស់ព្រះមហាក្សត្រ របស់នាយករដ្ឋមន្ត្រី និងរបស់ប្រធានរដ្ឋសភា តាមសេចក្ដីស្នើរបស់តំណាងរាស្ត្រមួយភាគបួននៃចំនួនសមាជិករដ្ឋសភាទាំងមូល"*។ ផ្អែកលើមូលដ្ឋាននៃមាត្រា១៥៣ ថ្មី(ពីរ) ខាងលើ, **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ក្នុងនាមជា **នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានផ្ដួចផ្ដើមធ្វើវិសោធនកម្មលើកទី១០ នៃរដ្ឋធម្មនុញ្ញនេះ និងបានដាក់សេចក្ដីព្រាងវិសោធនកម្មនេះ ឆ្លងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០២២ កន្លងទៅនេះ។ ទន្ទឹមនេះ, និងស្របតាមមាត្រា១៤៣ ថ្មី នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា, **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី **នៃព្រះរាជាណាចក្រកម្ពុជា** ក៏បានក្រាបបង្គំទូលថ្វាយ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** នូវអត្ថបទនៃសេចក្ដីព្រាងច្បាប់ធម្មនុញ្ញនេះ តាមលិខិតលេខ ៦២៥ លស ចុះថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០២២ ដើម្បី **ព្រះករុណាជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត** ទ្រង់មានព្រះរាជតម្រិះពិគ្រោះមតិក្រុមប្រឹក្សាធម្មនុញ្ញ។ **ព្រះករុណាជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត** ទ្រង់បានធ្វើព្រះរាជសារតបវិញ តាម **ព្រះរាជសារចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២២** ដោយភ្ជាប់នូវ*លិខិតលេខ ០៦៤/០១/២០២២ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២២ របស់ក្រុមប្រឹក្សាធម្មនុញ្ញ* ដោយក្រុមប្រឹក្សាធម្មនុញ្ញ បានថ្វាយមតិដែលមានខ្លឹមសារសំខាន់ថា សំណើធ្វើវិសោធនកម្មលើកទី១០ នេះ អាចធ្វើទៅបាន គឺស្របតាមបរិបទនៃសភាពការណ៍ជាក់ស្ដែង និងពុំមានអ្វីប៉ះពាល់ដល់ *ប្រព័ន្ធប្រជា-ធិបតេយ្យសេរីពហុបក្ស* និង *របបរាជានិយមអាស្រ័យដោយរដ្ឋធម្មនុញ្ញ* ព្រមទាំង *ធ្វើឡើងក្នុងពេលដែលប្រទេសជាតិមិនឋិតក្នុងភាពអាសន្ន* ឡើយ។

សំណើធ្វើវិសោធនកម្មលើកទី១០ នៃរដ្ឋធម្មនុញ្ញនាពេលនេះ គឺធ្វើឡើងត្រឹមត្រូវស្របតាមគោលការណ៍ និងនីតិវិធីដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ជាពិសេស មាត្រា១៤៣ ថ្មី និងជំពូកទី១៦ ថ្មី(ពីរ) ចាប់ពីមាត្រា១៥២ ថ្មី ដល់មាត្រា១៥៥ ថ្មី។

*III-អំពីខ្លឹមសារសំខាន់ៗនៃការធ្វើវិសោធនកម្មលើកទី១០ នៃរដ្ឋធម្មនុញ្ញ៖* ខ្លឹមសារសំខាន់ៗ ចំពោះសំណើសុំធ្វើវិសោធនកម្មលើកទី១០ នេះ មានដូចតទៅ៖

៣

*ទី១-ការស្នើធ្វើវិសោធនកម្មមាត្រា១៩ ថ្មី(មួយ) នៃរដ្ឋធម្មនុញ្ញ៖* មាត្រា១៩ ថ្មី(មួយ) នេះ ចែងទាក់ទងនឹងការតែងតាំងនាយករដ្ឋមន្ត្រី និងគណៈរដ្ឋមន្ត្រីដោយព្រះមហាក្សត្រ។ ការធ្វើវិសោធនកម្មមាត្រា១៩ ថ្មី(មួយ) គឺដោយសារមាត្រា១៩ ថ្មី(មួយ) នេះ បានយោងនៅក្នុងបទប្បញ្ញត្តិខ្លួន ទៅមាត្រា១១៩ ថ្មី(មួយ) ហើយដែលមាត្រា១១៩ ថ្មី(មួយ) នេះ ត្រូវធ្វើវិសោធនកម្មលើកនេះ ទៅជាមាត្រា១១៩ ថ្មី(ពីរ)។ ដូចនេះ, វាជាការចាំបាច់ខាងផ្នែកទម្រង់ ដែលមាត្រា១៩ ថ្មី(មួយ) ត្រូវបានស្នើធ្វើវិសោធនកម្ម ដូរខ្លឹមសារមាត្រាយោង ដើម្បីធានាបាននូវសង្គតិភាពជាមួយការធ្វើវិសោធនកម្មមាត្រា១១៩ ថ្មី(មួយ) ទៅជាមាត្រា១១៩ ថ្មី(ពីរ)។

*ទី២-ការស្នើធ្វើវិសោធនកម្មមាត្រា៨៩ នៃរដ្ឋធម្មនុញ្ញ៖* មាត្រា៨៩ នេះ ចែងទាក់ទងនឹងការអញ្ជើញឥស្សរជនដ៏ឧត្ដមណាមួយ ដើម្បីមកបំភ្លឺរដ្ឋសភា។ យោងតាមមាត្រា៨៩ បច្ចុប្បន្ន តាមការស្នើសុំពីសមាជិកចំនួនមួយភាគដប់ យ៉ាងតិច, រដ្ឋសភាអាចអញ្ជើញ **"ឥស្សរជនដ៏ឧត្ដមណាមួយ"** មកបំភ្លឺរដ្ឋសភាអំពីបញ្ហាដែលមានសារសំខាន់ពិសេស។ ពាក្យថា **"ឥស្សរជនដ៏ឧត្ដមណាមួយ"** នៅទីនេះ គឺមិនមានភាពច្បាស់លាស់នោះទេ ហើយអាចយកទៅបកស្រាយបានច្រើនយ៉ាង ដែលអាចធ្វើឱ្យប៉ះពាល់ដល់គោលការណ៍គ្រឹះនៃការបែងចែកអំណាចដាច់ពីគ្នា ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ គឺអំណាចនីតិប្បញ្ញត្តិ, អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ។ ម្យ៉ាងទៀត ជាគោលការណ៍ក្នុងរបបសភានិយម, រាជរដ្ឋាភិបាល ដែលជាអង្គការនីតិប្រតិបត្តិ គឺជាស្ថាប័ន ដែលត្រូវមានការទទួលខុសត្រូវចំពោះមុខរដ្ឋសភា។ ផ្អែកលើគោលការណ៍ទាំងនេះ, មាត្រា៨៩ នៃរដ្ឋធម្មនុញ្ញ ត្រូវបានស្នើធ្វើវិសោធនកម្ម ដោយកំណត់ឱ្យរាជរដ្ឋាភិបាលត្រូវមានការទទួលខុសត្រូវចំពោះមុខរដ្ឋសភា នៅគ្រប់កាលៈទេសៈ ដោយរួមទាំងការបំភ្លឺលើបញ្ហាបច្ចេកទេស ឬជំនាញអ្វីមួយ។

*ទី៣-ការស្នើធ្វើវិសោធនកម្មមាត្រា៩៨ ថ្មី នៃរដ្ឋធម្មនុញ្ញ៖* មាត្រា៩៨ ថ្មី ចែងថា៖ *"រដ្ឋសភាអាចទម្លាក់សមាជិកគណៈរដ្ឋមន្ត្រី ឬ ទម្លាក់រាជរដ្ឋាភិបាលពីតំណែង ដោយអនុម័តញត្តិបន្ទោស តាមសំឡេងឆ្នោតភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល។ ញត្តិបន្ទោសរាជរដ្ឋាភិបាលត្រូវបានលើកឡើងជូនរដ្ឋសភាដោយតំណាងរាស្ត្រចំនួនសាមសិបនាក់ ទើបរដ្ឋសភាអាចលើកមកពិភាក្សាបាន។"* មាត្រា៩៨ ថ្មី នេះ ត្រូវបានស្នើធ្វើវិសោធនកម្មដើម្បីកែសម្រួលដោយផ្អែកលើហេតុផលចំនួន ២ ដូចតទៅ ៖

*(១)-ដើម្បីបំពេញចន្លោះខ្វះខាតនៃបទប្បញ្ញត្តិនៃមាត្រា៩៨ ថ្មី៖* មាត្រា៩៨ ថ្មី បច្ចុប្បន្ន មិនបានចែងកំណត់ថា នៅពេលដែលរាជរដ្ឋាភិបាលត្រូវបានទម្លាក់ពីមុខតំណែងដោយការអនុម័តញត្តិបន្ទោសដោយរដ្ឋសភា, តើការដឹកនាំអំណាចនីតិប្រតិបត្តិត្រូវធ្វើដូចម្ដេច ចាប់ពីពេលដែលរាជ-

៤

រដ្ឋាភិបាល ត្រូវបានទម្លាក់ពីមុខតំណែង រហូតដល់ពេលដែលរាជរដ្ឋាភិបាលថ្មីត្រូវបានបង្កើត។ ប្រការដែលរដ្ឋធម្មនុញ្ញ ពុំបានកំណត់ត្រង់ចំណុចនេះ នឹងបង្កើតឱ្យមានស្ថានភាពមួយ ហៅថា *"សុញ្ញភាពនៃអំណាច"* ដែលអាចបង្កជាហានិភ័យនាំទៅដល់អស្ថិរភាពនយោបាយ។ ក្នុងន័យនេះ ការស្នើធ្វើវិសោធនកម្មមាត្រា៩៨ ថ្មី នាពេលនេះ គឺដើម្បីបំពេញមាត្រា៩៨ ថ្មី ដោយបន្ថែមខ្លឹមសារដូចតទៅៈ *"ក្នុងករណីដែលរាជរដ្ឋាភិបាល ត្រូវបានទម្លាក់ពីមុខតំណែងដោយរដ្ឋសភា រាជរដ្ឋាភិបាលដែលត្រូវចេញពីមុខតំណែងនេះមានតែភារកិច្ចដឹកនាំការងារប្រចាំថ្ងៃតែប៉ុណ្ណោះ រហូតដល់មានរាជរដ្ឋាភិបាលថ្មីចូលកាន់តំណែង។"*

*(២)-ដើម្បីធានានូវសង្គតិភាពរវាងមាត្រា៩៨ ថ្មី និងមាត្រាដទៃទៀតនៃរដ្ឋធម្មនុញ្ញៈ* យោងតាម មាត្រា៩៨ ថ្មី នៃរដ្ឋធម្មនុញ្ញ, រដ្ឋសភាត្រូវការសម្លេង ៣០ នាក់ ដើម្បីធ្វើញត្តិបន្ទោសដាក់ជូនរដ្ឋសភា។ ប៉ុន្តែ ការកំណត់យកចំនួនសមាជិករដ្ឋសភាចំនួន ៣០ នាក់ ដើម្បីធ្វើញត្តិបន្ទោស គឺពុំមានមូលដ្ឋានរឹងមាំត្រង់ចំណុចណាមួយនៅក្នុងរដ្ឋធម្មនុញ្ញឡើយ។ ដូចនេះ មាត្រា៩៨ ថ្មី នៃរដ្ឋធម្មនុញ្ញត្រូវបានស្នើធ្វើវិសោធនកម្ម ដោយកំណត់យកចំនួន ១/៣ នៃចំនួនសមាជិករដ្ឋសភាទាំងមូល ដើម្បីធ្វើញត្តិបន្ទោស សំដៅធានាឱ្យបាននូវសង្គតិភាព និងភាពរលូនជាមួយបទប្បញ្ញត្តិផ្សេងទៀត ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ដូចជា មាត្រា៨៣ ទាក់ទងនឹងការកោះប្រជុំរដ្ឋសភាជាវិសាមញ្ញ និងមាត្រា១០៧ ថ្មី ទាក់ទងនឹងការកោះប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ ព្រោះការធ្វើញត្តិបន្ទោសទម្លាក់រាជរដ្ឋាភិបាល ដែលជាកិច្ចការសំខាន់របស់រដ្ឋសភាស្របតាមគោលការណ៍ប្រជាធិបតេយ្យតាមបែបសភានិយម ក៏ត្រូវអនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ និងដោយអាចត្រូវផ្សារភ្ជាប់នឹងនីតិវិធីនៃការកោះប្រជុំរដ្ឋសភាជាវិសាមញ្ញផងដែរ។ បន្ថែមពីនេះ ការកែសម្រួលចំនួននៃសមាជិករដ្ឋសភាពី ៣០ នាក់ ទៅចំនួន ១/៣ នៃចំនួន សមាជិករដ្ឋសភាទាំងមូល ក៏ត្រូវបានធ្វើឡើង *ម្យ៉ាង* ដើម្បីធានាឱ្យអំណាចនីតិប្រតិបត្តិអាចមានដំណើរការប្រព្រឹត្តទៅ ដោយរលូនក្នុងការដឹកនាំកិច្ចការទូទៅរបស់រដ្ឋប្រកបដោយការទទួលខុសត្រូវ ហើយ *ម្យ៉ាងទៀត* ដើម្បីបង្ហាញអំពីការទទួលខុសត្រូវខ្ពស់របស់រដ្ឋសភាក្នុងការដំណើរការនីតិវិធីនៃការធ្វើញត្តិបន្ទោស ជាពិសេស របៀបវារៈដ៏សំខាន់ទាក់ទងនឹងការអនុម័តញត្តិបន្ទោសដើម្បីទម្លាក់សមាជិករាជរដ្ឋាភិបាល ឬទម្លាក់រាជរដ្ឋាភិបាល ដោយប្រើសម្លេងភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល។

*ទី៤-ការស្នើធ្វើវិសោធនកម្មមាត្រា១០២ ថ្មី នៃរដ្ឋធម្មនុញ្ញៈ* មាត្រា១០២ ថ្មី បានចែងអំពីសមត្ថកិច្ចរបស់ព្រឹទ្ធសភាក្នុងការសម្រេចបញ្ចប់កាលៈទេសៈពិសេស ដែលប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ដែលសមត្ថកិច្ចនេះដូចគ្នា ឬជាន់គ្នាទៅនឹងសមត្ថកិច្ចរបស់រដ្ឋសភា ដែលមានចែងក្នុង

៥

មាត្រា៨៦ នៃរដ្ឋធម្មនុញ្ញ។ ស្ថានភាពនេះ បានបង្កើតជាភាពមិនច្បាស់លាស់អំពីសមត្ថកិច្ចក្នុងការសម្រេចបញ្ចប់ការដាក់ប្រទេសជាតិក្នុងភាពអាសន្ន ហើយក៏អាចបង្កជាការលំបាកខាងផ្លូវច្បាប់ ប្រសិនបើមានការសម្រេចខ្វែងគ្នារវាងស្ថាប័នព្រឹទ្ធសភានិងស្ថាប័នរដ្ឋសភានេះ។

ដូច្នេះ ដើម្បីដោះស្រាយភាពមិនច្បាស់លាស់ខាងលើ ព្រមទាំងដើម្បីធានានូវសង្គតិភាពរវាងបទប្បញ្ញត្តិនានា ដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ, មាត្រា១០២ ថ្មី នេះ ត្រូវបានស្នើធ្វើវិសោធនកម្ម ដើម្បីកែសម្រួលដោយកំណត់ឱ្យព្រឹទ្ធសភាសម្រេចរួមគ្នាជាមួយរដ្ឋសភា ក្នុងក្របខណ្ឌនៃសមាជរវាងរដ្ឋសភា និងព្រឹទ្ធសភា ក្នុងការបញ្ចប់កាលៈទេសៈពិសេសដែលប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ហើយរក្សាសមត្ថកិច្ចទោលរបស់រដ្ឋសភាក្នុងការសម្រេចបញ្ចប់កាលៈទេសៈដាក់ប្រទេសជាតិក្នុងភាពអាសន្ន ដោយយោងតាមតម្រូវការចាំបាច់នៃកាលៈទេសៈពិសេស ស្របតាមមាត្រា៨៦ នៃរដ្ឋធម្មនុញ្ញ។

*ទី៥-ការស្នើធ្វើវិសោធនកម្មមាត្រា១១៩ ថ្មី(មួយ) នៃរដ្ឋធម្មនុញ្ញ៖* កថាខណ្ឌទី១ នៃមាត្រា១១៩ ថ្មី(មួយ)នេះ ត្រូវបានស្នើធ្វើវិសោធនកម្ម ដោយមានខ្លឹមសារដូចតទៅ៖ *"តាមសេចក្តីស្នើពីគណបក្សដែលមានអាសនៈច្រើនជាងគេក្នុងរដ្ឋសភា ព្រះមហាក្សត្រទ្រង់ចាត់តាំងវរជនមួយរូបជានាយករដ្ឋមន្ត្រី ឱ្យបង្កើតរាជរដ្ឋាភិបាល។ សេចក្តីស្នើពីគណបក្សដែលមានអាសនៈច្រើនជាងគេក្នុងរដ្ឋសភានេះ ត្រូវចម្លងជូនប្រធានរដ្ឋសភា។ វរជនដែលនឹងត្រូវទទួលបានការចាត់តាំងជានាយករដ្ឋមន្ត្រីនេះ ត្រូវតែជាតំណាងរាស្ត្រដែលមានសញ្ជាតិខ្មែរតែមួយគត់ និងដែល ត្រូវបានជ្រើសរើសចេញពីគណបក្សដែលមានអាសនៈច្រើនជាងគេក្នុងរដ្ឋសភា។ វរជនដែលត្រូវបានចាត់តាំង នេះ នាំសហការីដែលជាតំណាងរាស្ត្រ ឬជាសមាជិកគណបក្សតំណាងនៅក្នុងរដ្ឋសភាដែលផ្តល់ផ្តងឱ្យកាន់តំណែងផ្សេងៗក្នុងរាជរដ្ឋាភិបាល ទៅសុំសេចក្តីទុកចិត្តពីរដ្ឋសភា។ ការបោះឆ្នោតផ្តល់សេចក្តីទុកចិត្តនេះ ត្រូវធ្វើលើបញ្ជីសមាសភាពនៃគណៈរដ្ឋមន្ត្រីទាំងមូល។ កាលបើរដ្ឋសភា បានបោះឆ្នោតទុកចិត្តហើយនោះ ព្រះមហាក្សត្រទ្រង់ចេញព្រះរាជក្រឹត្យតែងតាំងគណៈរដ្ឋមន្ត្រីទាំងមូល។"*

បន្ថែមពីនេះ ការធ្វើវិសោធនកម្មមាត្រា១១៩ ថ្មី(មួយ) ក៏មានគោលបំណងដើម្បីធានាឱ្យបានច្បាស់លាស់អំពីនិរន្តរភាពនៃការដឹកនាំអំណាចនីតិប្រតិបត្តិពីនីតិកាលមួយ ទៅនីតិកាលមួយទៀតនៃរដ្ឋសភា។ ក្នុងន័យនេះ មាត្រា១១៩ ថ្មី(មួយ) ក៏ត្រូវបានចែងបន្ថែមនូវបទប្បញ្ញត្តិដែលកំណត់ថា៖ *"នៅពេលផុតនីតិកាលនីមួយៗរបស់រដ្ឋសភា រាជរដ្ឋាភិបាលដែលត្រូវចេញពីតំណែង មានតែការកិច្ចដឹកនាំការងារប្រចាំថ្ងៃតែប៉ុណ្ណោះ រហូតដល់មានរាជរដ្ឋាភិបាលថ្មីចូលកាន់តំណែង។"*

*ទី៦-ការស្នើធ្វើវិសោធនកម្មមាត្រា១២៥ ថ្មី នៃរដ្ឋធម្មនុញ្ញ ទាក់ទងនឹងការរៀបចំចាំបាច់នានាក្នុងករណីតំណែងនាយករដ្ឋមន្ត្រីនៅទំនេរជាស្ថាពរ៖* មាត្រា១២៥ ថ្មី បច្ចុប្បន្ន ចែងថា *"បើតំណែង*

៦

*នាយករដ្ឋមន្ត្រី នៅទំនេរជាស្ថាពរនោះ ត្រូវតែងតាំងគណៈរដ្ឋមន្ត្រីមួយជាថ្មី ក្នុងល័ក្ខខ័ណ្ឌដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនេះ។ កាលបើការទំនេរនេះជាការទំនេរមួយកាលមួយគ្រាទេ ត្រូវចាត់តាំងនាយករដ្ឋមន្ត្រីស្តីទីជាបណ្តោះអាសន្ន។"* មាត្រា១២៥ ថ្មី នេះ ពុំបានបញ្ជាក់ឱ្យបានច្បាស់លាស់ថា៖ *(ទី១)*-តើករណីណាខ្លះ ដែលតំណែង នាយករដ្ឋមន្ត្រី ត្រូវបានកំណត់ថា នៅទំនេរជាស្ថាពរ? *(ទី២)*-តើការលាលែងពីមុខតំណែងជានាយករដ្ឋមន្ត្រី ដែលត្រូវបានចាត់ទុក ជាទូទៅថា ជាស្ថានភាពមួយនៃស្ថានភាពទំនេរស្ថាពរនៃតំណែងនាយករដ្ឋមន្ត្រី ត្រូវអនុវត្តតាមនីតិវិធីបែបណា? ហើយ *(ទី៣)*-នៅពេលតំណែងនាយករដ្ឋមន្ត្រីនៅទំនេរជាស្ថាពរនោះ តើការគ្រប់គ្រងអំណាចចាប់ពីពេលដែលតំណែងនាយករដ្ឋមន្ត្រីនៅទំនេរជាស្ថាពរ រហូតដល់គណៈរដ្ឋមន្ត្រីថ្មី ចូលកាន់តំណែង ត្រូវអនុវត្តដូចម្តេច? ការចែងមិនច្បាស់លាស់ និងមិនគ្រប់ជ្រុងជ្រោយសម្រាប់ស្ថានភាពដែលតំណែងនាយករដ្ឋមន្ត្រីនៅទំនេរជាស្ថាពរ នឹងអាចមានហានិភ័យខ្ពស់ប៉ះពាល់ដល់និរន្តរភាពនៃអំណាចរបស់រដ្ឋាភិបាល។ មាត្រា១២៥ ថ្មី ត្រូវបានស្នើធ្វើវិសោធនកម្មដើម្បី បំពេញចន្លោះប្រហោងនៃរដ្ឋធម្មនុញ្ញ ក៏ដូចជារៀបចំឱ្យបានគ្រប់ជ្រុងជ្រោយឡើង ជាពិសេស ការកំណត់ឱ្យបានច្បាស់លាស់នូវចំណុចសំខាន់ៗយ៉ាងតិចចំនួន ៤ រួមមាន៖ (ទី១)-ការចាត់តាំងនាយករដ្ឋមន្ត្រីស្តីទី ក្នុងករណីដែលនាយករដ្ឋមន្ត្រីអវត្តមានមួយកាលមួយគ្រា, (ទី២)-ការចែងអំពីមូលហេតុនានាដែលនាំឱ្យតំណែង នាយករដ្ឋមន្ត្រីនៅទំនេរជាស្ថាពរ ជាអាទិ៍ អនិច្ចកម្ម, ការលាលែងពីមុខតំណែងរបស់នាយករដ្ឋមន្ត្រី ព្រមទាំងការចែងអំពីការចាត់ចែងចាំបាច់នានា ដើម្បីធានាដល់និរន្តរភាពនៃការដឹកនាំអំណាចនីតិប្រតិបត្តិ តាមរយៈការតែងតាំងគណៈរដ្ឋមន្ត្រីថ្មីឱ្យបានឆាប់រហ័ស, (ទី៣)-ការចែងអំពីបែបបទ នីតិវិធី និងការចាត់ចែងចាំបាច់នានាសម្រាប់ការលាលែងពីមុខតំណែងរបស់នាយករដ្ឋមន្ត្រី និង (ទី៤)-ការធានានិរន្តរភាពអំណាចរបស់រាជរដ្ឋាភិបាលចាប់ពីពេលដែលតំណែងនាយករដ្ឋមន្ត្រីនៅទំនេរជាស្ថាពរ រហូតដល់គណៈរដ្ឋមន្ត្រីថ្មីចូលកាន់តំណែង ដែលជាគ្រឹះសម្រាប់ធានានិរន្តរភាព និងស្ថិរភាពរបស់ប្រទេសជាតិ។

*ទី៧-<u>ការស្នើធ្វើវិសោធនកម្មមាត្រា៣ ថ្មី និងមាត្រា៤ ថ្មី នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ៖</u>* មាត្រា៣ ថ្មី និងមាត្រា៤ ថ្មី នៃច្បាប់ធម្មនុញ្ញបន្ថែម ចែងទាក់ទងនឹងការបោះឆ្នោតជាកញ្ចប់ក្នុងការបង្កើតរាជរដ្ឋាភិបាល និងការរៀបចំក្បាលម៉ាស៊ីននៃរដ្ឋសភាក្នុងពេលតែមួយ នៅដើមនីតិកាលនៃរដ្ឋសភា។ ការស្នើធ្វើវិសោធនកម្មមាត្រាទាំងពីរមាត្រានេះ ធ្វើឡើងម្យ៉ាង ដើម្បីធានាសង្គតិភាពផ្នែកទម្រង់ផង និងផ្នែកខ្លឹមសារផងជាមួយខ្លឹមសារនៃមាត្រានានាក្នុងរដ្ឋធម្មនុញ្ញដែលត្រូវស្នើធ្វើវិសោធនកម្មលើកទី១០ នេះ និង ម្យ៉ាងទៀត ដើម្បីធានាថា ការបោះឆ្នោតជាកញ្ចប់តាមច្បាប់ធម្មនុញ្ញបន្ថែម អាចដំណើរការប្រព្រឹត្តទៅបាន នៅដើមនីតិកាលនីមួយៗនៃរដ្ឋសភា។

៧

ការបែងបន្ថែមបទប្បញ្ញត្តិមួយចំនួនឱ្យបានច្បាស់លាស់ទាក់ទងនឹងឥស្សរជន ដែលជាព្រឹទ្ធសមាជិកនៃរដ្ឋសភា ដើម្បីធានាថា កិច្ចដំណើរការនៃការបោះឆ្នោតជាកញ្ចប់ដើម្បីបង្កើតក្បាលម៉ាស៊ីននៃរដ្ឋសភា និងរាជរដ្ឋាភិបាលក្នុងពេលតែមួយ នឹងពុំត្រូវបានរាំងស្ទះដោយប្រការណាមួយឡើយ ជាពិសេសទាក់ទងនឹងការអនុវត្តតួនាទី និងការទទួលខុសត្រូវរបស់ព្រឹទ្ធសមាជិករដ្ឋសភានៅដើមនីតិកាលនីមួយៗនៃរដ្ឋសភា ទាក់ទងនឹង ការបោះឆ្នោតជាកញ្ចប់។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋសភាដ៏ឧត្តុង្គឧត្តម មេត្តាពិនិត្យ និងមេត្តាអនុម័ត *សេចក្តីព្រាងច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា១៩ ថ្មី(មួយ), មាត្រា៨៩, មាត្រា៩៨ ថ្មី, មាត្រា ១០២ ថ្មី, មាត្រា១១៩ ថ្មី(មួយ) និងមាត្រា១២៥ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា៣ ថ្មី និងមាត្រា៤ ថ្មី នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ* ជាការប្រញាប់ ដោយក្តីអនុគ្រោះ។

ម៉្យាងទៀត នាឱកាសនេះ ដើម្បីឆ្លើយតបនឹងកង្វល់របស់គណបក្សនយោបាយ និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួន ពាក់ព័ន្ធនឹងការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញលើកទី១០ នេះ, ខ្ញុំបាទសូមគោរពស្នើសុំការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **សម្តេចអគ្គមហាពញាចក្រី** ប្រធានរដ្ឋសភា, **សម្តេចអគ្គ-មហាសេនាបតីតេជោ** នាយករដ្ឋមន្រ្តីនៃព្រះរាជាណាចក្រកម្ពុជា, ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **អនុប្រធានទី១ នៃរដ្ឋសភា, លោកជំទាវកិត្តិសង្គហបណ្ឌិត អនុប្រធានទី២ នៃរដ្ឋសភា** ព្រមទាំង **សម្តេច ឯកឧត្តម លោកជំទាវ** ជាសមាជិក សមាជិកានៃរដ្ឋសភាដ៏ឧត្តុង្គឧត្តម មេត្តាអនុញ្ញាតជូន **ឯកឧត្តម កើត រិទ្ធ រដ្ឋមន្រ្តីក្រសួងយុត្តិធម៌** មានមតិមួយចំនួន។

*សូមអរគុណ!*

៨

# សេចក្តីថ្លែងហេតុនៃវិសោធនកម្ម
# លើកទី១១

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋសភា** **រាជរដ្ឋាភិបាល**

**សូមក្រាបបង្គំទូលថ្វាយ**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**

**ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា**

***ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង*** *ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត*

ទូលព្រះបង្គំ យើងខ្ញុំ សូមព្រះបរមរាជានុញ្ញាតទូលថ្វាយ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** ទ្រង់ព្រះមេត្តាជ្រាបថា ដោយអនុលោមតាមមាត្រា១៥៣ ថ្មី(ពីរ) នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ទូលព្រះបង្គំ យើងខ្ញុំ ក្នុងឋានៈជាប្រធានរដ្ឋសភា ដោយទទួលបានសេចក្តីស្នើពីតំណាងរាស្ត្រចំនួន ១២៥រូប និងក្នុងឋានៈជានាយករដ្ឋមន្ត្រី បានសម្រេចផ្តួចផ្តើមគំនិតរួមគ្នាធ្វើវិសោធនកម្ម**មាត្រា៣៣ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា** ដើម្បីបើកផ្លូវអនុញ្ញាតឱ្យមានការរៀបចំក្របខ័ណ្ឌច្បាប់សម្រាប់ដកសញ្ជាតិខ្មែរ ពីពលរដ្ឋខ្មែរណាដែលបានប្រព្រឹត្តអំពើក្បត់ជាតិ ឬធ្វើសកម្មភាពប៉ះពាល់ធ្ងន់ធ្ងរដល់ផលប្រយោជន៍របស់ព្រះរាជាណាចក្រកម្ពុជា និងប្រជាពលរដ្ឋខ្មែរ ពិសេស អំពើឃុបឃិតជាមួយបរទេស។

ការស្នើសុំធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រង់មាត្រា៣៣ នេះ គឺមានគោលបំណងដើម្បីលើកកម្ពស់ឧត្តមគតិជាតិ មនសិការស្នេហាជាតិ និងគោលជំហរស្មោះត្រង់ឥតងាករេរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប ចំពោះជាតិ មាតុភូមិ និងប្រជាជនកម្ពុជានៅគ្រប់កាលៈទេសៈទាំងអស់ ពិសេស ការតម្កល់ផលប្រយោជន៍ជាតិជាធំ ដោយប្រជាពលរដ្ឋខ្មែរគ្រប់រូបមិនត្រូវធ្វើសកម្មភាពណាមួយ ទោះដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី នាំឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ព្រះរាជាណាចក្រកម្ពុជា ស្របតាមមាត្រា៤៩ ថ្មី វាក្យខណ្ឌទី២ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ ទន្ទឹមនេះ, ការធ្វើវិសោធនកម្មនេះ ក៏នឹងរួមចំណែកយ៉ាងសំខាន់ក្នុងការប្រឆាំងនឹងការជ្រៀតជ្រែកពីខាងក្រៅចូលមកក្នុងកិច្ចការផ្ទៃក្នុងរបស់កម្ពុជា ពិសេស ការប្រឆាំងនឹងអំពើក្បត់ជាតិ និងអំពើឃុបឃិតគ្នាជាមួយនឹងបរទេស ដែលនឹងធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់វិស័យសន្តិសុខជាតិ និងឧត្តមប្រយោជន៍របស់ប្រទេសជាតិ និងប្រជាជនកម្ពុជា។

ទូលព្រះបង្គំ យើងខ្ញុំ សូមថ្វាយនូវអត្ថបទ "**សេចក្តីស្នើសុំធ្វើវិសោធនកម្មមាត្រា៣៣ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា**" ដែលមានឯកសារថ្វាយភ្ជាប់មកជាមួយនេះ ដើម្បី **ព្រះករុណាជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត** ទ្រង់មានព្រះរាជតម្រិះពិគ្រោះមតិក្រុមប្រឹក្សាធម្មនុញ្ញ ដោយអនុលោមតាមបទប្បញ្ញត្តិនៃមាត្រា១៤៣ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

ទូលព្រះបង្គំ យើងខ្ញុំ សូមក្រាបបង្គំទូលថ្វាយ **ព្រះករុណាជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត** ទ្រង់ព្រះមេត្តាជ្រាបថា សេចក្តីស្នើសុំធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញនេះ មិនប៉ះពាល់ដល់ប្រព័ន្ធប្រជាធិបតេយ្យសេរីពហុបក្ស និងរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញឡើយ។

ទូលព្រះបង្គំ យើងខ្ញុំ សូម **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ទ្រង់មានព្រះរាជតម្រិះដោយព្រះរាជហឫទ័យអនុគ្រោះបំផុត។

សូម **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ទ្រង់ព្រះមេត្តាទទួលនូវគារវភក្តីដ៏ខ្ពង់ខ្ពស់បំផុតពីទូលព្រះបង្គំ យើងខ្ញុំ។

ថ្ងៃ ៥ ៥រោច ខែ ទុតិយាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ២០២៥

**ប្រធានរដ្ឋសភា** **នាយករដ្ឋមន្ត្រី**

**សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី** **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋសភា

### យើងខ្ញុំទាំងអស់គ្នាជាតំណាងរាស្ត្រហត្ថលេខី

### សូមគោរពជូន
### សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី
### ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

**កម្មវត្ថុ ៖** សេចក្តីស្នើសុំធ្វើវិសោធនកម្មមាត្រា៣៣ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
**យោង ៖** មាត្រា១៥៣ថ្មី(ពីរ មាត្រា១៥១ថ្មី) នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

តបតាមកម្មវត្ថុ និងយោងខាងលើ យើងខ្ញុំទាំងអស់គ្នាជាតំណាងរាស្ត្រហត្ថលេខី ដូចមានបញ្ជីរាយនាមជូនភ្ជាប់ មានកិត្តិយសផ្ញើជូន សម្តេចមហារដ្ឋសភាធិការធិបតី ប្រធានរដ្ឋសភា នូវសេចក្តីស្នើច្បាប់ធម្មនុញ្ញស្តីពី វិសោធនកម្មមាត្រា៣៣ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីបើកផ្លូវអនុញ្ញាតឱ្យមានការរៀបចំក្របខ័ណ្ឌច្បាប់សម្រាប់ការដកសញ្ជាតិខ្មែរ ចំពោះប្រជាពលរដ្ឋខ្មែរណាដែលបានប្រព្រឹត្តអំពើក្បត់ជាតិ ឬការធ្វើសកម្មភាពប៉ះពាល់ធ្ងន់ធ្ងរដល់ផលប្រយោជន៍ នៃព្រះរាជាណាចក្រកម្ពុជា និងប្រជាពលរដ្ឋខ្មែរ ដោយឃុបឃិតជាមួយបរទេស ដូចមានសេចក្តីថ្លែងហេតុ និងអត្ថបទនៃសេចក្តីស្នើច្បាប់ធម្មនុញ្ញជូនភ្ជាប់មកជាមួយ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សម្តេចរដ្ឋសភាធិបតី ប្រធានរដ្ឋសភា មេត្តាពិនិត្យ និងចាត់នីតិវិធីលើសេចក្តីស្នើសុំធ្វើវិសោធនកម្មខាងលើ ដោយចាត់ទុកជាការប្រញាប់ តាមការគួរ។

សូម សម្តេចមហារដ្ឋសភាធិការធិបតី ប្រធានរដ្ឋសភា មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

ថ្ងៃអាទិត្យ ៤កើត ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស ២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៥

**តំណាងក្រុមតំណាងរាស្ត្រហត្ថលេខី**

**កិត្តិសេដ្ឋាបណ្ឌិត ជាម យៀប** | **អគ្គ ខេង ខន្ធារ៉ា**

វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១៣ ៥៣៥, ២២០ ៦២៨
ទូរសារ: (៨៥៥-២៣) ២២០ ៦២៩ សារអេឡិចត្រូនិច:sg@na.gov.kh គេហទំព័រ: www.na.gov.kh

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រដ្ឋសភា

រដ្ឋសភា
ចូល លេខ ១០៣៦
ថ្ងៃទី ០៣/០៧ ឆ្នាំ២០២៥ ម៉ោង ១៥:០០
បញ្ជូនទៅ

# សេចក្តីថ្លែងហេតុ
# នៃសេចក្តីស្នើច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា៣៣
# នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

យោងតាមមាត្រា៤៩ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលជាច្បាប់កំពូលរបស់ជាតិ, ប្រជាពលរដ្ឋខ្មែរគ្រប់រូបត្រូវតែម្កល់ផលប្រយោជន៍ជាតិជាធំ ហើយមិនត្រូវធ្វើសកម្មភាពណាមួយ ទោះដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី នាំឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ព្រះរាជាណាចក្រកម្ពុជា និងប្រជាពលរដ្ឋខ្មែរឡើយ។ ជាមួយគ្នានេះ មាត្រានេះក៏បញ្ជាក់យ៉ាងច្បាស់ដែរថា ប្រជាពលរដ្ឋខ្មែរគ្រប់រូបមានកាតព្វកិច្ចរួមចំណែកកសាងប្រទេសជាតិ និងការពារមាតុភូមិ។ ផ្អែកតាមស្មារតីនេះ, ការប្រព្រឹត្តអំពើក្បត់ជាតិ ឬការធ្វើសកម្មភាពណាមួយដែលបំផ្លាញឧត្តមប្រយោជន៍របស់ប្រទេសជាតិ និងប្រជាជនកម្ពុជា ពិសេស ការឃុបឃិតគ្នាជាមួយបរទេស ដើម្បីធ្វើសកម្មភាពទាំងនេះ គឺជាការប្រព្រឹត្តខុសទៅនឹងរដ្ឋធម្មនុញ្ញ និងច្បាប់ព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងប្រាសចាកពីឧត្តមគតិ និងមនសិការជាពលរដ្ឋខ្មែរ។

ដូចនេះ ដោយផ្អែកតាមមាត្រា១៥៣ ថ្មី(ពីរ) នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងដើម្បីលើកកម្ពស់ឧត្តមគតិជាតិ មនសិការស្នេហាជាតិ និងគោលជំហរស្មោះត្រង់ឥតងាករេរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប ចំពោះជាតិ មាតុភូមិ និងប្រជាជនកម្ពុជានៅគ្រប់កាលៈទេសៈទាំងអស់ **សម្តេចមហារដ្ឋសភាធិការធិបតី ប្រធានរដ្ឋសភា** នៃព្រះរាជាណាចក្រកម្ពុជា ដោយទទួលបានសេចក្តីស្នើពីតំណាងរាស្ត្រចំនួន ១២៥រូប និង **សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា បានផ្តួចផ្តើមគំនិតរួមគ្នាធ្វើវិសោធនកម្មមាត្រា៣៣ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីបើកផ្លូវអនុញ្ញាតឱ្យមានការរៀបចំក្របខ័ណ្ឌច្បាប់សម្រាប់ដកសញ្ជាតិខ្មែរ ពីពលរដ្ឋខ្មែរណាដែលបានប្រព្រឹត្តអំពើក្បត់ជាតិ ឬធ្វើសកម្មភាពប៉ះពាល់ធ្ងន់ធ្ងរដល់ផលប្រយោជន៍របស់ព្រះរាជាណាចក្រកម្ពុជា និងប្រជាពលរដ្ឋខ្មែរ ពិសេស អំពើឃុបឃិតជាមួយបរទេស។ យោងតាមការសិក្សាស្រាវជ្រាវ, ការដកសញ្ជាតិខ្មែរពីពលរដ្ឋរបស់ខ្លួនណាម្នាក់មិនមែនជារឿងថ្មីនោះទេ។ សម្រាប់កម្ពុជា, កាលពីសម័យមុនក៏មានច្បាប់កំណត់អំពីដកសញ្ជាតិខ្មែរ ដូចជា ក្រមរដ្ឋប្បវេណីឆ្នាំ១៩២០ ដែលត្រូវបានធ្វើវិសោធនកម្មជាបន្តបន្ទាប់ និងច្បាប់ស្តីពីការបាត់សញ្ជាតិខ្មែរ ដែលត្រូវបានប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ ៣៧៧/៦៨-ប.រ. ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ១៩៦៨ ជាដើម។ ទន្ទឹមនេះ, នៅបណ្តាប្រទេសជាច្រើន ដូចជា បារាំង, អាមេរិក, អង់គ្លេស, អាល្លឺម៉ង់, អូស្ត្រាលី, អ៊ីតាលី, ប៊ែលហ្ស៊ិក, ឥណ្ឌា, កូរ៉េខាងត្បូង និងសិង្ហបុរី ជាដើម សុទ្ធតែមានច្បាប់កំណត់អំពីការដកសញ្ជាតិពីពលរដ្ឋរបស់ខ្លួន ជាពិសេស ក្នុងករណីអំពើធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់ផលប្រយោជន៍របស់ជាតិ ឬអំពើធ្វើឱ្យប៉ះពាល់ដល់វិស័យសន្តិសុខជាតិ។

វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១៣ ៥៣៥, ២២០ ៦២៨
ទូរសារ: (៨៥៥-២៣) ២២០ ៦២៩ សារអេឡិចត្រូនិច:sg@na.gov.kh គេហទំព័រ: www.na.gov.kh

ម្យ៉ាងទៀត, ការធ្វើវិសោធនកម្មមាត្រា៣៣ នេះ ក៏នឹងរួមចំណែកយ៉ាងសំខាន់ក្នុងការប្រឆាំងនឹងការជ្រៀតជ្រែកពីខាងក្រៅចូលមកក្នុងកិច្ចការផ្ទៃក្នុងរបស់កម្ពុជា ពិសេស ការប្រឆាំងនឹងអំពើក្បត់ជាតិ និងអំពើឃុបឃិតគ្នាជាមួយបរទេស ដែលនឹងធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់វិស័យសន្តិសុខជាតិ សេចក្តីសុខសាន្តរបស់ប្រជាជន និងឧត្តមប្រយោជន៍របស់ប្រទេសជាតិ។

ផ្អែកតាមមូលដ្ឋានខាងលើ, សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា និង សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានធ្វើលិខិតរួមគ្នាក្រាបបង្គំទូលថ្វាយ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** នូវអត្ថបទនៃសេចក្តីស្នើច្បាប់ធម្មនុញ្ញនេះ ដើម្បី **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ទ្រង់មានព្រះរាជតម្រិះពិគ្រោះមតិក្រុមប្រឹក្សាធម្មនុញ្ញ ស្របតាមមាត្រា១៤៣ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ទ្រង់បានផ្ញើព្រះរាជសារតបចុះថ្ងៃទី២ ខែកក្កដា ឆ្នាំ២០២៥ ដោយភ្ជាប់នូវមតិរបស់ក្រុមប្រឹក្សាធម្មនុញ្ញ។ ផ្អែកតាមលិខិតចុះថ្ងៃទី២ ខែកក្កដា ឆ្នាំ២០២៥ របស់ក្រុមប្រឹក្សាធម្មនុញ្ញ, ក្រុមប្រឹក្សាធម្មនុញ្ញ បានបញ្ជាក់ថា៖ *(១)*-សេចក្តីស្នើសុំធ្វើវិសោធនកម្មមាត្រា៣៣ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជានេះ មិនប៉ះពាល់ដល់ប្រព័ន្ធប្រជាធិបតេយ្យ សេរីពហុបក្ស និងរបបរាជានិយមអាស្រ័យដោយរដ្ឋធម្មនុញ្ញឡើយ ព្រមទាំងធ្វើឡើងនៅពេលប្រទេសជាតិមិនឋិតក្នុងភាពអាសន្ន និង *(២)*-សេចក្តីស្នើសុំធ្វើវិសោធនកម្មមាត្រា៣៣ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជានេះ អាចធ្វើទៅបាន។

ខ្លឹមសារនៃវិសោធនកម្មមាត្រា៣៣ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មានដូចតទៅ៖

*"ប្រជាពលរដ្ឋខ្មែរមិនអាចត្រូវបាននិរទេស ឬចាប់បញ្ជូនខ្លួនទៅឱ្យប្រទេសក្រៅណាមួយឡើយ លើកលែងតែមានកិច្ចព្រមព្រៀងជាមួយគ្នាទៅវិញទៅមក។*

*ប្រជាពលរដ្ឋខ្មែរដែលកំពុងរស់នៅឯបរទេសត្រូវបានរដ្ឋគាំពារ។*

*ការទទួលសញ្ជាតិខ្មែរ និងការបាត់សញ្ជាតិខ្មែរ ដោយរួមទាំងការដកសញ្ជាតិខ្មែរ ត្រូវកំណត់ក្នុងច្បាប់។"*

អាស្រ័យហេតុនេះ សូម សម្តេចរដ្ឋសភាធិបតី ប្រធានរដ្ឋសភា មេត្តាពិនិត្យ និងសម្រេចដាក់សេចក្តីស្នើច្បាប់ធម្មនុញ្ញខាងលើ ក្នុងរបៀបវារៈនៃកិច្ចប្រជុំរដ្ឋសភា ដើម្បីពិនិត្យ និងអនុម័ត ដោយចាត់ទុកជាការប្រញាប់តាមការគួរ។

សូម សម្តេចមហារដ្ឋសភាធិការធិបតី ប្រធានរដ្ឋសភា មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

ថ្ងៃព្រហស្បតិ៍ ៨កើត ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី ៣ ខែកក្កដា ឆ្នាំ២០២៥

**តំណាងក្រុមតំណាងរាស្ត្រហត្ថលេខី**

**កិត្តិសេដ្ឋាបណ្ឌិត ជាម យៀប** | **អគ្គ ទេព្យ ទេព្យានា**

# ឧបសម្ព័ន្ធ២

# រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

## ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣

# រដ្ឋធម្មនុញ្ញ

នៃ

# ព្រះរាជាណាចក្រកម្ពុជា

១៩៩៣

# រដ្ឋធម្មនុញ្ញ

នៃ

# ព្រះរាជាណាចក្រកម្ពុជា

១៩៩៣

# ព្រះរាជក្រម

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស**

**អគ្គមហាបុរសរតន៍ និករោត្តម**

**ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

យោងតាមមាត្រាទី ១៣៥ និង ១៣៦ នៃ ជំពូក ១៤ ស្តីអំពីអន្តរប្បញ្ញត្តិ នៃ រដ្ឋធម្មនុញ្ញ ព្រះរាជាណាចក្រ កម្ពុជា អនុម័តដោយសភាធម្មនុញ្ញ នៅថ្ងៃទី ២១ ខែកញ្ញា គ.ស. ១៩៩៣ ។

## ត្រាស់បង្គាប់

**មាត្រាទី១:** ប្រកាសឱ្យប្រើជាផ្លូវការភ្លាម នូវ រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា ដែលសភាធម្មនុញ្ញបានអនុម័ត នៅថ្ងៃទី ២១ ខែកញ្ញា គ.ស. ១៩៩៣ ។

**មាត្រាទី២:** សភាធម្មនុញ្ញ បានត្រឡប់ទៅជា រដ្ឋសភា នៃ កម្ពុជា ចាប់ពីពេលនេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែកញ្ញា គ.ស.១៩៩៣

ន. សីហនុ

**នរោត្តម សីហនុ**

១

# បុព្វកថា

*****

## យើង ប្រជារាស្ត្រខ្មែរ

ដែលធ្លាប់មានអារ្យធម៌ឧត្តុង្គឧត្តម ប្រទេសជាតិស្តុកស្តម្ភធំទូលាយថ្កុំថ្កើងរុងរឿង កិត្យានុភាពខ្ពង់ខ្ពស់ ភ្លឺថែងចាំងដូចពេជ្រពណ្ណរាយ

បានធ្លាក់ខ្លួនដ៏សែនរន្ធត់ ក្នុងអំឡុងពីរទសវត្សចុងក្រោយនេះ ឆ្លងកាត់ទុក្ខសោកវិនាសអន្តរាយទ្រុឌទ្រោមឱនថយមហាសោកស្តាយ

បានភ្ញាក់រលឹក ក្រោកឈរឡើង ចងបាច់ឆន្ទៈមោះមុត ប្តូរផ្តាច់ រួបរួមធ្លាពង្រឹងឯកភាពជាតិ រក្សាការពារ ទឹកដីកម្ពុជា អធិបតេយ្យថ្លៃថ្លា និងអារ្យធម៌អង្គរដ៏បវរ កសាងប្រទេសជាតិឱ្យទៅជា «កោះសន្តិភាព» ឡើងវិញ ផ្អែកលើប្រព័ន្ធ ប្រជាធិបតេយ្យសេរីពហុបក្ស ធានាសិទ្ធិមនុស្ស គោរពច្បាប់ ទទួលខុសត្រូវខ្ពស់ ចំពោះវាសនាអនាគតជាតិ ឱ្យបានឈានឡើង រីកចំរើនលូតលាស់ សម្បូររុងរឿង ជានិច្ចនិរន្តរ៍ ។

## ក្នុងឆន្ទៈមោះមុតនេះ

យើងសរសេរចារឹកក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាដូចតទៅ ៖

# ជំពូកទី ១

## អំពី អធិបតេយ្យ

មាត្រា ១._

ប្រទេសកម្ពុជា ជាព្រះរាជាណាចក្រដែលព្រះមហាក្សត្រទ្រង់ប្រតិបត្តិតាមរដ្ឋធម្មនុញ្ញនិងតាមលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស ។

ព្រះរាជាណាចក្រកម្ពុជា ជារដ្ឋឯករាជ្យ អធិបតេយ្យ សន្តិភាព អព្យាក្រឹត្យ អចិន្ត្រៃយ៍ មិនចូលបក្សសម្ព័ន្ធ ។

មាត្រា ២._

បូរណភាពទឹកដីរបស់ព្រះរាជាណាចក្រកម្ពុជា មិនអាចរំលោភបានដាច់ខាតក្នុងព្រំដែនរបស់ខ្លួនដែលមានកំណត់ក្នុងផែនទីខ្នាត ១/១០០.០០០ ធ្វើនៅចន្លោះឆ្នាំ ១៩៣៣_១៩៥៣ ហើយដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិនៅចន្លោះ ឆ្នាំ ១៩៦៣_១៩៦៩ ។

មាត្រា ៣._

ព្រះរាជាណាចក្រកម្ពុជា ជារដ្ឋដែលមិនអាចបំបែកបាន ។

មាត្រា ៤._

បាវចនានៃព្រះរាជាណាចក្រកម្ពុជា គឺ : ជាតិ សាសនា ព្រះមហាក្សត្រ ។

មាត្រា ៥._

ភាសា និងអក្សរ ដែលប្រើជាផ្លូវការ គឺភាសា និងអក្សរខ្មែរ ។

មាត្រា ៦._

ភ្នំពេញជារាជធានីនៃព្រះរាជាណាចក្រកម្ពុជា ។

ទង់ជាតិ ភ្លេងជាតិ និងសញ្ញាជាតិ មានកំណត់នៅក្នុងឧបសម្ព័ន្ធ ១,២ និង ៣ ។

# ជំពូកទី ២
# អំពី ព្រះមហាក្សត្រ

មាត្រា ៧._

ព្រះមហាក្សត្រកម្ពុជាទ្រង់គ្រងរាជសម្បត្តិ ប៉ុន្តែទ្រង់មិនកាន់អំណាចឡើយ ។

ព្រះមហាក្សត្រទ្រង់ជាព្រះប្រមុខរដ្ឋមួយជីវិត ។

អង្គព្រះមហាក្សត្រ មិនអាចនរណារំលោភបំពានបានឡើយ ។

មាត្រា ៨._

ព្រះមហាក្សត្រព្រះអង្គទ្រង់ជានិមិត្តរូបនៃឯកភាពជាតិ និងនិរន្តរភាពជាតិ ។

ព្រះមហាក្សត្រទ្រង់ជាអ្នកធានាឯករាជ្យជាតិ អធិបតេយ្យនិងបូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ជាអ្នកធានាការគោរពសិទ្ធិ និងសេរីភាពរបស់ប្រជាពលរដ្ឋ និងការគោរពសន្ធិសញ្ញាអន្តរជាតិ ។

មាត្រា ៩._

ព្រះមហាក្សត្រទ្រង់មានតួនាទីខ្ពង់ខ្ពស់ជាអាជ្ញាកណ្តាល ដើម្បីធានាការប្រព្រឹត្តិទៅនៃអំណាចសាធារណៈឱ្យមានភាពទៀងទាត់ ។

មាត្រា ១០._

របបរាជានិយមកម្ពុជា ជារបបជ្រើសតាំង ។

ព្រះមហាក្សត្រទ្រង់ឥតមានព្រះរាជអំណាចចាត់តាំងព្រះរជ្ជទាយាទសម្រាប់គ្រងរាជសម្បត្តិឡើយ ។

មាត្រា ១១._

ក្នុងករណីដែលព្រះមហាក្សត្រពុំអាចបំពេញព្រះរាជភារៈ ជាព្រះប្រមុខរដ្ឋបានដូចធម្មតា ដោយព្រះអង្គទ្រង់ប្រឈួនជាទម្ងន់ មានការបញ្ជាក់ដោយក្រុមគ្រូពេទ្យជំនាញជ្រើសរើសដោយប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រីនោះប្រធានរដ្ឋសភាបំពេញភារកិច្ចប្រមុខរដ្ឋជំនួសព្រះអង្គក្នុងឋានៈជា " ព្រះរាជានុសិទ្ធិ " ។

២

មាត្រា ១២.-

នៅពេលព្រះមហាក្សត្រទ្រង់ចូលទីវង្គត ប្រធានរដ្ឋសភាទទួលភារកិច្ចជាប្រមុខរដ្ឋស្ដីទីក្នុងឋានៈជាព្រះរាជានុសិទ្ធិ នៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ១៣.-

ក្នុងរយៈវេលាប្រាំពីរថ្ងៃយ៉ាងយូរ ព្រះមហាក្សត្រថ្មីនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានជ្រើសរើសដោយក្រុមប្រឹក្សារាជសម្បត្តិ ។

សមាសភាពនៃក្រុមប្រឹក្សារាជសម្បត្តិមាន :

- ប្រធានរដ្ឋសភា
- នាយករដ្ឋមន្ត្រី
- សម្ដេចព្រះសង្ឃរាជគណៈមហានិកាយ និងគណៈធម្មយុត្តិកនិកាយ
- អនុប្រធានទីមួយ និងអនុប្រធានទីពីរ នៃរដ្ឋសភា ។

ការរៀបចំនិងការប្រព្រឹត្តិទៅនៃក្រុមប្រឹក្សារាជសម្បត្តិ នឹងមានកំណត់ ក្នុងច្បាប់មួយ ។

មាត្រា ១៤.-

ត្រូវបានជ្រើសរើសជាព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាសមាជិកនៃព្រះរាជវង្សានុវង្សខ្មែរ ដែលមានព្រះជន្មាយុយ៉ាងតិច៣០ព្រះវស្សា ហើយដែលជាព្រះរាជបច្ឆាញាតិនៃព្រះមហាក្សត្រ អង្គឌួង ឬ ព្រះមហាក្សត្រនរោត្តម ឬក៏ព្រះមហាក្សត្រ ស៊ីសុវត្ថិ ។

មុនចូលគ្រងរាជសម្បត្តិ ព្រះមហាក្សត្រទ្រង់ថ្លែងសច្ចាប្រណិធានដូចមានចែងក្នុងឧបសម្ព័ន្ធ ទី៤ ។

មាត្រា ១៥.-

ព្រះជាយានៃព្រះមហាក្សត្រមានព្រះរាជឋានៈជាព្រះមហេសីនៃព្រះរាជាណាចក្រកម្ពុជា ។

៣

មាត្រា ១៦.-

ព្រះមហេសីនៃព្រះរាជាណាចក្រកម្ពុជា ពុំមានព្រះរាជសិទ្ធិធ្វើនយោបាយ ទទួលតួនាទីជាអ្នកដឹកនាំរដ្ឋ ឬជាអ្នកដឹកនាំរាជរដ្ឋាភិបាល ឬទទួលតួនាទីរដ្ឋបាល ឬនយោបាយឡើយ ។

ព្រះមហេសីនៃព្រះរាជាណាចក្រកម្ពុជាទុកព្រះរាជកាយពលបំពេញព្រះរាជភារៈបំរើប្រយោជន៍សង្គម មនុស្សធម៌ សាសនា និងជួយព្រះមហាក្សត្រក្នុងព្រះរាជកាតព្វកិច្ច ផ្នែកពិធីការ និងការទូត ។

មាត្រា ១៧.-

ប្រការដែលព្រះមហាក្សត្រទ្រង់គ្រងរាជសម្បត្តិប៉ុន្តែទ្រង់មិនកាន់អំណាចឡើយ ហើយដែលមានចែងក្នុងវាក្យខ័ណ្ឌទីមួយនៃមាត្រា ៧ នៃរដ្ឋធម្មនុញ្ញនេះ មិនអាចសុំកែប្រែបានជាដាច់ខាត ។

មាត្រា ១៨.-

ព្រះមហាក្សត្រព្រះអង្គទ្រង់ទាក់ទងជាមួយរដ្ឋសភាដោយព្រះរាជសារ ។ ព្រះរាជសារនេះ រដ្ឋសភាមិនអាចយកទៅជជែកពិភាក្សាឡើយ ។

មាត្រា ១៩.-

ព្រះមហាក្សត្រទ្រង់តែងតាំងនាយករដ្ឋមន្ត្រីនិងទ្រង់តែងតាំងគណៈរដ្ឋមន្ត្រី តាមបែបបទដែលមានចែងក្នុងមាត្រា ១០០ ។

មាត្រា ២០.-

ព្រះមហាក្សត្រទ្រង់ទទួលសវនាការជាផ្លូវការពីរដងក្នុងមួយខែ ឱ្យនាយករដ្ឋមន្ត្រីនិងគណៈរដ្ឋមន្ត្រីចូលគាល់រាយការណ៍ទូលថ្វាយទ្រង់ជ្រាបអំពីសភាពការណ៍នៃប្រទេសជាតិ ។

មាត្រា ២១.-

តាមសេចក្តីស្នើរបស់គណៈរដ្ឋមន្ត្រី ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្ថលេខាលើព្រះរាជក្រឹត្យតែងតាំង ផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីជាន់ខ្ពស់ស៊ីវិលនិងយោធា ឯកអគ្គរាជទូត និងប្រេសិតវិសាមញ្ញ និងពេញសមត្ថភាព ។

តាមសេចក្តីស្នើរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រឹត្យតែងតាំង ផ្លាស់ប្តូរ ឬដកចៅក្រមផ្នែកយុត្តាធិការ ។

មាត្រា ២២._

នៅពេលប្រជាជាតិប្រឈមមុខនឹងគ្រោះថ្នាក់ ព្រះមហាក្សត្រទ្រង់ប្រកាសប្រទានដំណឹងជាសាធារណៈដាក់ប្រទេសជាតិឋិតក្នុងភាពអាសន្នក្រោយពីបានមតិឯកភាពពីនាយករដ្ឋមន្ត្រី និងប្រធានរដ្ឋសភា ។

មាត្រា ២៣._

ព្រះមហាក្សត្រទ្រង់ជាមេបញ្ជាការកំពូលនៃកងយោធពលខេមរភូមិន្ទ ។ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ ត្រូវបានតែងតាំងឡើង ដើម្បីបញ្ជាកងយោធពលខេមរភូមិន្ទនេះ ។

មាត្រា ២៤._

ព្រះមហាក្សត្រទ្រង់គង់ជាព្រះអធិបតីនៃឧត្តមក្រុមប្រឹក្សាការពារជាតិដែលនឹងត្រូវបង្កើតឡើងដោយច្បាប់មួយ ។

ព្រះមហាក្សត្រទ្រង់ប្រកាសសង្គ្រាម ក្រោយការអនុម័តរបស់រដ្ឋសភា ។

មាត្រា ២៥._

ព្រះមហាក្សត្រទ្រង់ទទួលសារតាំងឯកអគ្គរដ្ឋទូត ឬប្រេសិតវិសាមញ្ញនិងពេញសមត្ថភាពនៃប្រទេសក្រៅ មកប្រចាំព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ២៦._

ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាលើសន្ធិសញ្ញា និងអនុសញ្ញាអន្តរជាតិ ហើយទ្រង់ប្រទានសច្ចាប័នលើសន្ធិសញ្ញានិងអនុសញ្ញាទាំងនេះ ក្រោយបានទទួលការអនុម័តយល់ព្រមពីរដ្ឋសភា ។

មាត្រា ២៧._

ព្រះមហាក្សត្រទ្រង់មានព្រះរាជសិទ្ធិបន្ធូរបន្ថយទោសនិងលើកលែងទោស ។

៥

**មាត្រា ២៨.**_ (*)

ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្ថលេខាលើព្រះរាជក្រមប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញ ច្បាប់ដែលរដ្ឋសភាបានអនុម័ត និងទ្រង់ឡាយព្រះហស្ថលេខាលើព្រះរាជក្រឹត្យតាមសេចក្ដីស្នើសុំពីគណៈរដ្ឋមន្ត្រី ។

**មាត្រា ២៩.**_

ព្រះមហាក្សត្រទ្រង់បង្កើតនិងប្រទានគ្រឿងឥស្សរិយយសជាតិតាមសេចក្ដីស្នើសុំពីគណៈរដ្ឋមន្ត្រី ។

ព្រះមហាក្សត្រទ្រង់សំរេចប្រទានឋានន្តរសក្តិ ឋានៈ យោធា និងស៊ីវិល តាមច្បាប់កំណត់ ។

**មាត្រា ៣០.**_

ក្នុងរយៈពេលព្រះមហាក្សត្រទ្រង់អវត្តមាន ប្រធានរដ្ឋសភាទទួលភារកិច្ចជាប្រមុខរដ្ឋស្ដីទី ។

(*) សូមមើលច្បាប់កែប្រែ ទំព័រ ៤៧

៦

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានអាយុយ៉ាងតិច ១៨ ឆ្នាំ មានសិទ្ធិបោះឆ្នោត ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានអាយុយ៉ាងតិច ២៥ ឆ្នាំ អាចឈរឈ្មោះឱ្យគេបោះឆ្នោត ។

បទបញ្ញត្តិបន្ថយសិទ្ធិបោះឆ្នោត និងសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោត ត្រូវចែងក្នុងច្បាប់បោះឆ្នោត ។

មាត្រា ៣៥.-

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ប្រទេសជាតិ ។

សេចក្តីស្នើទាំងឡាយរបស់ប្រជាពលរដ្ឋ ត្រូវបានទទួលការពិនិត្យ និងដោះស្រាយយ៉ាងហ្មត់ចត់ពីអង្គការរដ្ឋ ។

មាត្រា ៣៦.-

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិជ្រើសរើសមុខរបរ សមស្រប តាមសមត្ថភាពរបស់ខ្លួន តាមសេចក្តីត្រូវការរបស់សង្គម ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិទទួលប្រាក់បំណាច់ស្មើគ្នា ចំពោះការងារដូចគ្នា ។

ការងារមេផ្ទះមានតម្លៃស្មើគ្នា នឹងកំរៃដែលបានមកពីការងារធ្វើនៅក្រៅផ្ទះ ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិទទួលការធានារ៉ាប់រងសង្គម និងអត្ថប្រយោជន៍ខាងសង្គមកិច្ចដែលមានចែងក្នុងច្បាប់ ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិបង្កើតសហជីព និងចូលជាសមាជិកសហជីពនេះ ។

ការរៀបចំនិងការប្រព្រឹត្តទៅនៃសហជីព នឹងមានកំណត់ក្នុងច្បាប់ ។

មាត្រា ៣៧.-

សិទ្ធិធ្វើកូដកម្ម និងធ្វើបាតុកម្មដោយសន្តិវិធី ត្រូវយកមកអនុវត្តនៅក្នុងក្របខ័ណ្ឌនៃច្បាប់ ។

មាត្រា ៣៨.-

ច្បាប់រ៉ាប់រងមិនឱ្យមានការរំលោភបំពានលើរូបរាងកាយបុគ្គលណាមួយឡើយ ។

ច្បាប់ការពារជីវិត កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ ។

ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួន ជនណាមួយ នឹងអាចធ្វើទៅកើត លុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់ ។

ការបង្ខិតបង្ខំ ការធ្វើបាបឈឺរូបរាងកាយ ឬប្រព្រឹត្តិកម្មណាមួយ ដែលបន្ថែមទម្ងន់ទណ្ឌកម្មអនុវត្តចំពោះជនជាប់ឃុំឃាំង ឬជាប់ពន្ធនាគារត្រូវហាម ឃាត់មិនឱ្យធ្វើឡើយ ។ អ្នកដែលរំលោភ អ្នករួមប្រព្រឹត្ត និងអ្នកសមគំនិតត្រូវទទួលទោសតាមច្បាប់ ។

ការទទួលសារភាពដែលកើតឡើងពីការបង្ខិតបង្ខំតាមផ្លូវកាយក្តី តាមផ្លូវចិត្តក្តី មិនត្រូវទុកជាភស្តុតាងនៃពិរុទ្ធភាពទេ ។

វិមតិសង្ស័យ ត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ ។

ជនជាប់ចោទណាក៏ដោយ ត្រូវទុកជាមនុស្សឥតទោស ដរាបណា តុលាការមិនទាន់កាត់ទោសជាស្ថាពរ ។

ជនគ្រប់រូបមានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ ។

មាត្រា ៣៩.-

ប្រជាពលរដ្ឋខ្មែរមានសិទ្ធិប្តឹងបរិហារ ប្តឹងតវ៉ា ឬប្តឹងទារសំណង ជួសជុលការខូចខាតដែលបណ្តាលមកពីអំពើខុសច្បាប់របស់អង្គការរដ្ឋ របស់អង្គការសង្គម និងរបស់បុគ្គលិកនៃអង្គការទាំងនោះ ។ ការដោះស្រាយបណ្តឹងតវ៉ា និងសំណងជួសជុលការខូចខាតជាសមត្ថកិច្ចរបស់តុលាការ ។

មាត្រា ៤០.-

សេរីភាពក្នុងការធ្វើដំណើរឆ្ងាយជិត និងតាំងទីលំនៅក្នុងស្ថានភាពស្រប ច្បាប់ របស់ប្រជាពលរដ្ឋត្រូវបានគោរព ។

ប្រជាពលរដ្ឋខ្មែរអាចចេញទៅតាំងទីលំនៅ នៅប្រទេសក្រៅ ឬ វិលត្រឡប់មកវិញបាន ។

ការរក្សាសិទ្ធិមិនឱ្យរំលោភលើលំនៅឋាន និងអាថ៌កំបាំងនៃការ ឆ្លើយឆ្លងតាមលិខិត តាមសារទូរលេខ ទូរពុម្ព ទូរគមនាគមន៍ និងតាមទូរស័ព្ទត្រូវបាន ធានា ។

ការឆែកឆេរលំនៅឋាន សម្ភារៈវត្ថុ និងឈើរូបបុគ្គល ត្រូវធ្វើឱ្យ ស្របនឹងបញ្ញត្តិច្បាប់ ។

៩

**មាត្រា ៤១.-**

ប្រជាពលរដ្ឋខ្មែរមានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារពត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ ។ ជនណាក៏ដោយមិនអាចឆ្លៀតប្រើសិទ្ធិនេះ ដោយរំលោភនាំឱ្យប៉ះពាល់ដល់កិត្តិយសរបស់អ្នកដទៃ ដល់ទំនៀមទំលាប់ល្អរបស់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិបានឡើយ ។

របបសារពត៌មាន ត្រូវរៀបចំឡើងដោយច្បាប់ ។

**មាត្រា ៤២.-**

ប្រជាពលរដ្ឋខ្មែរមានសិទ្ធិបង្កើតសមាគម និងគណៈបក្សនយោបាយ ។ សិទ្ធិនេះត្រូវកំណត់ក្នុងច្បាប់ ។

ប្រជាពលរដ្ឋខ្មែរទាំងឡាយ អាចចូលរួមក្នុងអង្គការមហាជនជួយគ្នាទៅវិញទៅមក ការពារសមិទ្ធផលជាតិ និងសណ្តាប់ធ្នាប់សង្គម ។

**មាត្រា ៤៣.-**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិពេញទីខាងជំនឿ ។

សេរីភាពខាងជំនឿ និងការប្រតិបត្តិខាងផ្លូវសាសនា ត្រូវបានរដ្ឋធានាក្នុងលក្ខខណ្ឌដែលមិនប៉ះពាល់ដល់ជំនឿ ឬ សាសនាដទៃទៀត ដល់សណ្តាប់ធ្នាប់និងសន្តិសុខសាធារណៈ ។

ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ ។

**មាត្រា ៤៤.-**

ជនណាក៏ដោយ ទោះជាបុគ្គលក្តី ជាសមូហភាពក្តី មានសិទ្ធិជាម្ចាស់កម្មសិទ្ធិ ។ មានតែរូបវន្តបុគ្គល ឬនីតិបុគ្គល ដែលមានសញ្ជាតិជាខ្មែរទេ ទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លី ។

កម្មសិទ្ធិឯកជនស្របច្បាប់ ឋិតនៅក្រោមការគាំពារនៃច្បាប់ ។

ដែលនឹងដកហូតកម្មសិទ្ធិអំពីជនណាមួយបាននោះ លុះត្រាតែប្រយោជន៍សាធារណៈតម្រូវឱ្យធ្វើក្នុងករណីដែលច្បាប់បានបញ្ញត្តិទុក ហើយត្រូវផ្តល់សំណងជាមុនដោយ សមរម្យ និងយុត្តិធម៌ ។

**មាត្រា ៤៥.-**

ការរើសអើងគ្រប់ប្រភេទប្រឆាំងនឹងស្ត្រីភេទត្រូវបំបាត់ចោល ។

ការធ្វើអាជីវកម្ម លើការងាររបស់ស្ត្រី ត្រូវហាមឃាត់ ។

បុរស និងស្ត្រី មានសិទ្ធិស្មើគ្នាក្នុងគ្រប់វិស័យទាំងអស់ ជាពិសេសក្នុងអាពាហ៍ពិពាហ៍ និងគ្រួសារ ។

អាពាហ៍ពិពាហ៍ ត្រូវធ្វើតាមលក្ខខ័ណ្ឌដែលមានចែងក្នុងច្បាប់និងតាមគោលការណ៍ស្ម័គ្រចិត្ត ប្តីមួយប្រពន្ធមួយ ។

<u>មាត្រា ៤៦.</u>_

អំពើលក់ដូរមនុស្ស អំពើធ្វើអាជីវកម្មផ្នែកពេស្យាកម្ម និងអំពើអាសអាភាស ដែលប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់នារី ត្រូវហាមឃាត់ ។

ត្រូវហាមឃាត់មិនឱ្យមានការបញ្ឈប់នារីពីការងារ ដោយមូលហេតុមានគភ៌។ នារីមានសិទ្ធិឈប់សម្រាកនៅពេលសម្រាលកូន ដោយទទួលប្រាក់បៀវត្សនិងដោយមានការធានារក្សាសិទ្ធិអតីតភាពក្នុងការងារ និងអត្ថប្រយោជន៍សង្គមផ្សេងៗទៀត ។

រដ្ឋនិងសង្គមយកចិត្តទុកដាក់បង្កលក្ខណៈឱ្យនារី ជាពិសេសនារីនៅជនបទ ដែលគ្មានទីពឹង បានទទួលការងារធ្វើ ដើម្បីមានមុខរបរ មានលទ្ធភាពព្យាបាលជម្ងឺ ឱ្យកូនទៅរៀន និងមានជីវភាពរស់នៅសមរម្យ ។

<u>មាត្រា ៤៧.</u>_

មាតាបិតាមានកាតព្វកិច្ចចិញ្ចឹមថែរក្សា និងអប់រំកូនឱ្យទៅជាពលរដ្ឋល្អ ។.

កូនមានករណីយកិច្ចចិញ្ចឹមនិងបីបាច់ថែរក្សាមាតាបិតា ដែលចាស់ជរាតាមទំនៀមទំលាប់ខ្មែរ ។

<u>មាត្រា ៤៨.</u>_

រដ្ឋធានារក្សាការពារសិទ្ធិរបស់កុមារ ដែលមានចែងក្នុងអនុសញ្ញាស្តីពីកុមារ ជាពិសេសសិទ្ធិមានជីវិតរស់នៅ សិទ្ធិទទួលការអប់រំរៀនសូត្រ សិទ្ធិត្រូវបានទទួលការគាំពារក្នុងស្ថានការណ៍មានសង្គ្រាម និងការការពារប្រឆាំងនឹងអាជីវកម្ម សេដ្ឋកិច្ច ឬកាមគុណលើកុមារ ។

រដ្ឋគាំពារប្រឆាំងនឹងការងារទាំងឡាយ ដែលអាចធ្វើឱ្យខូចដល់ការអប់រំ និងការរៀនសូត្ររបស់កុមារ ឬដែលនាំឱ្យអន្តរាយដល់សុខភាព ឬសុខុមាលភាពរបស់កុមារ ។

<u>មាត្រា ៤៩.</u>_

ប្រជាពលរដ្ឋខ្មែរគ្រប់រូបត្រូវគោរពរដ្ឋធម្មនុញ្ញ និងគោរពច្បាប់ ។

១១

ប្រជាពលរដ្ឋខ្មែរគ្រប់រូបមានភារកិច្ចរួមចំណែកកសាងប្រទេសជាតិនិងការពារមាតុភូមិ ។

ភារកិច្ចការពារមាតុភូមិត្រូវអនុវត្តតាមបញ្ញត្តិច្បាប់ ។

<u>មាត្រា ៥០.</u>-

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទត្រូវគោរពគោលការណ៍អធិបតេយ្យជាតិនិងលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទត្រូវគោរពទ្រព្យសម្បត្តិសាធារណៈនិងកម្មសិទ្ធិ ស្របច្បាប់របស់ឯកជន ។

១២

## ជំពូកទី ៤

## អំពី របបនយោបាយ

មាត្រា ៥១.-

ព្រះរាជាណាចក្រកម្ពុជា អនុវត្តរបបនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស ។

ប្រជាពលរដ្ឋខ្មែរ ជាម្ចាស់វាសនានៃប្រទេសជាតិរបស់ខ្លួន ។

អំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ ។ ប្រជាពលរដ្ឋប្រើអំណាចរបស់ខ្លួនតាមរយៈរដ្ឋសភា រាជរដ្ឋាភិបាល និងសាលាជំរះក្តី ។

អំណាចបែងចែកដាច់ពីគ្នា រវាងអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ ។

មាត្រា ៥២.-

រាជរដ្ឋាភិបាលកម្ពុជា ប្តេជ្ញារក្សាការពារឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា អនុវត្តនយោបាយបង្រួបបង្រួមជាតិ ដើម្បីការពារឯកភាពជាតិ រក្សាការពារទំនៀមទំលាប់និងប្រពៃណីល្អរបស់ជាតិ ។ រាជរដ្ឋាភិបាលកម្ពុជាត្រូវការពារនីត្យានុកូលភាព ធានាសណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈ ។ រដ្ឋយកចិត្តទុកដាក់ជាអាទិភាព ចំពោះជីវភាពរស់នៅ និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ ។

មាត្រា ៥៣.-

ព្រះរាជាណាចក្រកម្ពុជា ប្រកាន់ខ្ជាប់ជានិច្ចនូវន៍យោបាយអព្យាក្រឹតអចិន្ត្រៃយ៍ និងមិនចូលបក្សសម្ព័ន្ធ ។ ព្រះរាជាណាចក្រកម្ពុជារួមរស់ដោយសន្តិសហវិជ្ជមានជាមួយប្រទេសជិតខាង និងប្រទេសដទៃទៀតទាំងអស់នៅលើសកលលោក ។

ព្រះរាជាណាចក្រកម្ពុជា មិនឈ្លានពានប្រទេសណាដាច់ខាត មិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុង នៃប្រទេសដទៃដោយផ្ទាល់ ឬដោយប្រយោល ទោះបីក្រោមរូបភាពណាក៏ដោយ ដោះស្រាយរាល់បញ្ហាដោយសន្តិវិធី និង គោរពផលប្រយោជន៍ផងគ្នាទៅវិញទៅមក ។

ព្រះរាជាណាចក្រកម្ពុជា មិនចងសម្ព័ន្ធយោធា ឬចូលក្នុងកិច្ចព្រមព្រៀង យោធាណាមួយ ដែលមិនស្របនឹងអព្យាក្រឹតភាពរបស់ខ្លួនឡើយ ។

១៣

ព្រះរាជាណាចក្រកម្ពុជា មិនអនុញ្ញាតឱ្យមានមូលដ្ឋានយោធាបរទេសនៅលើទឹកដីរបស់ខ្លួន ហើយក៏មិនអនុញ្ញាតឱ្យមានមូលដ្ឋានយោធារបស់ខ្លួននៅបរទេសដែរ លើកលែងតែក្នុងក្របខ័ណ្ឌនៃសំណូមពររបស់អង្គការសហប្រជាជាតិ ។

ព្រះរាជាណាចក្រកម្ពុជា រក្សាសិទ្ធិទទួលយកជំនួយបរទេសជាសម្ភារៈ យោធា អាវុធ គ្រាប់រំសេវ ការហ្វឹកហ្វឺនកងកម្លាំងប្រដាប់អាវុធ និងជំនួយផ្សេងៗទៀត ដើម្បីការពារខ្លួន និងធានាសណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈនៅផ្ទៃក្នុងប្រទេស ។

មាត្រា ៥៤.-

ការផលិត ការប្រើប្រាស់ ការរក្សាទុកអាវុធបរមាណូ អាវុធគីមី ឬអាវុធជីវសាស្ត្រ ត្រូវហាមឃាត់ដាច់ខាត ។

មាត្រា ៥៥.-

សន្ធិសញ្ញានិងកិច្ចព្រមព្រៀងទាំងឡាយណាដែលមិនស្របនឹងឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដី អព្យាក្រឹតភាព និងឯកភាពជាតិរបស់ព្រះរាជាណាចក្រកម្ពុជា ត្រូវលុបចោល ។

## ជំពូកទី ៥
## អំពី សេដ្ឋកិច្ច

**មាត្រា ៥៦.-**

ព្រះរាជាណាចក្រកម្ពុជា អនុវត្តប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ ។

ការរៀបចំ និងការប្រព្រឹត្តទៅ នៃប្រព័ន្ធសេដ្ឋកិច្ចនេះ នឹងមានកំណត់ក្នុងច្បាប់ ។

**មាត្រា ៥៧.-**

ការយកពន្ធដារនឹងអាចធ្វើទៅបាន លុះត្រាតែមានច្បាប់អនុញ្ញាត ។ ថវិកាជាតិត្រូវបានកំណត់ឱ្យអនុវត្តតាមច្បាប់ ។

របបគ្រប់គ្រងរូបិយវត្ថុនិងប្រព័ន្ធហិរញ្ញវត្ថុត្រូវកំណត់ក្នុងច្បាប់ ។

**មាត្រា ៥៨.-**

ទ្រព្យសម្បត្តិរបស់រដ្ឋមានជាអាទិ៍ ដីធ្លី ក្រោមដី ភ្នំ សមុទ្ទ បាតសមុទ្ទ ក្រោមបាតសមុទ្ទ ឆ្នេរសមុទ្ទ អាកាស កោះ ទន្លេ ព្រែក ស្ទឹង បឹង ព្រៃឈើ ធនធានធម្មជាតិ មជ្ឈមណ្ឌលសេដ្ឋកិច្ចវប្បធម៌ មូលដ្ឋានការពារប្រទេស សំណង់ផ្សេងៗទៀតដែលបានកំណត់ថាជារបស់រដ្ឋ ។

ការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ នឹងត្រូវកំណត់ក្នុងច្បាប់ ។

**មាត្រា ៥៩.-**

រដ្ឋត្រូវរក្សាការពារបរិដ្ឋាន និងតុល្យភាពនៃភោគទ្រព្យធម្មជាតិ ហើយត្រូវចាត់ចែងឱ្យមានផែនការច្បាស់លាស់ក្នុងការគ្រប់គ្រង មានជាអាទិ៍ ដីធ្លី ទឹក អាកាស ខ្យល់ ភោគភោគសាស្ត្រ ប្រព័ន្ធអេកូឡូស៊ី រ៉ែ ថាមពល ប្រេងកាត និងឧស្ម័ន ថ្មនិងខ្សាច់ ត្បូងថ្ម ព្រៃឈើ និងអនុផលព្រៃឈើ ពពួកសត្វព្រៃ មច្ឆាជាតិ ធនធានជលផល ។

**មាត្រា ៦០.-**

ពលរដ្ឋមានសិទ្ធិលក់ដូរផលិតផលរបស់ខ្លួនដោយសេរី ។ ការតម្រូវឱ្យលក់ផលិតផលជូនរដ្ឋ ឬការយកភោគផល ឬទ្រព្យសម្បត្តិឯកជនទៅប្រើប្រាស់

ទោះបីមួយរយៈពេលក៏ដោយត្រូវហាមឃាត់ វៀរលែងតែក្នុងករណីពិសេសដែលមានច្បាប់អនុញ្ញាត ។

<u>មាត្រា ៦១.</u>-

រដ្ឋជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ចគ្រប់វិស័យ ជាពិសេសវិស័យកសិកម្ម សិប្បកម្ម ឧស្សាហកម្ម ចាប់ពីតំបន់ដាច់ស្រយាលដោយយកចិត្តទុកដាក់ទៅលើ នយោបាយទឹក ភ្លើង ផ្លូវ និងមធ្យោបាយដឹកជញ្ជូន បច្ចេកទេសទំនើបនិងប្រព័ន្ធឥណទាន ។

<u>មាត្រា ៦២.</u>-

រដ្ឋយកចិត្តទុកដាក់ជួយដោះស្រាយមធ្យោបាយផលិត ការពារថ្លៃផលិតផល ជូនកសិករ សិប្បករ និងជួយរកទីផ្សារលក់ផលិតផល ។

<u>មាត្រា ៦៣.</u>-

រដ្ឋយកចិត្តទុកដាក់គ្រប់គ្រងទីផ្សារ ជួយឱ្យជីវភាពរស់នៅរបស់ប្រជាពលរដ្ឋមានកម្រិតសមរម្យ ។

<u>មាត្រា ៦៤.</u>-

រដ្ឋហាមឃាត់និងផ្តន្ទាទោសជាទម្ងន់ដល់ជនណា ដែលនាំចូល ផលិត លក់ដូរ គ្រឿងញៀន ទំនិញក្លែងក្លាយ ហួសរយៈពេលប្រើដែលប៉ះពាល់ដល់សុខភាព អាយុជីវិតរបស់អ្នកប្រើ ។

# ជំពូកទី ៦
## អំពី អប់រំ វប្បធម៌ និងសង្គមកិច្ច

**មាត្រា ៦៥.-**

រដ្ឋត្រូវការពារ និងលើកស្ទួយសិទ្ធិរបស់ប្រជាពលរដ្ឋ ក្នុងការទទួលការអប់រំប្រកបដោយគុណភាពនៅគ្រប់កំរិតនិងត្រូវចាត់វិធានការគ្រប់បែបយ៉ាង ជាជំហានៗ ដើម្បីឱ្យការអប់រំនេះបានទៅដល់ប្រជាពលរដ្ឋគ្រប់រូប ។

រដ្ឋយកចិត្តទុកដាក់ដល់វិស័យអប់រំកាយនិងកីឡា ដែលជាសុខុមាលភាពរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប ។

**មាត្រា ៦៦.-**

រដ្ឋកសាងប្រព័ន្ធអប់រំមួយពេញលេញនិងឯកភាព នៅទូទាំងប្រទេសដែលធានាឱ្យបាននូវគោលការណ៍សេរីភាពខាងសិក្សាធិការនិងគោលការណ៍សមភាពក្នុងការអប់រំ ដើម្បីឱ្យប្រជាពលរដ្ឋគ្រប់រូបមានភព្វសំណាង គ្រប់គ្រាន់ ស្មើគ្នាក្នុងការកសាងជីវិត ។

**មាត្រា ៦៧.-**

រដ្ឋអនុវត្តកម្មវិធីសិក្សា និងគោលការណ៍គរុកោសល្យទំនើប រាប់បញ្ចូលទាំងបច្ចេកវិទ្យា និងភាសាបរទេស ។

រដ្ឋគ្រប់គ្រងគ្រឹះស្ថានសិក្សា និងថ្នាក់សិក្សាសាធារណៈនិងឯកជននៅគ្រប់ភូមិសិក្សា ។

**មាត្រា ៦៨.-**

រដ្ឋផ្តល់កិច្ចការអប់រំថ្នែកបឋម និងមធ្យមសិក្សានៅសាលារៀនសាធារណៈ សំរាប់ប្រជាពលរដ្ឋគ្រប់រូបដោយឥតបង់ថ្លៃ ។

ប្រជាពលរដ្ឋ ត្រូវបានទទួលការអប់រំយ៉ាងតិចប្រាំបួនឆ្នាំ ។

រដ្ឋជួយផ្សព្វផ្សាយនិងលើកតំកើងសាលាបាលីនិងពុទ្ធិកសិក្សា ។

**មាត្រា ៦៩.-**

រដ្ឋមានភារកិច្ចថែរក្សា និងពង្រីកវប្បធម៌ជាតិ ។

រដ្ឋមានភារកិច្ចការពារនិងពង្រីកភាសាខ្មែរឱ្យសមស្របនឹងសេចក្តីត្រូវការ ។

១៧

រដ្ឋមានភារកិច្ចថែរក្សានិងការពារ ប្រាសាទបុរាណវត្ថុ សិល្បៈបុរាណនិងកែលំអរមណីយដ្ឋានប្រវត្តិសាស្ត្រឡើងវិញ ។

<u>មាត្រា ៧០.</u>_

បទល្មើសទាំងឡាយដែលប៉ះពាល់ ឬទាក់ទងនឹងបេតិកភ័ណ្ឌវប្បធម៌ នឹងបេតិកភ័ណ្ឌសិល្បៈ ត្រូវផ្តន្ទាទោសជាទម្ងន់ ។

<u>មាត្រា ៧១.</u>_

បរិវេណបេតិកភ័ណ្ឌជាតិ ក៏ដូចជាបេតិកភ័ណ្ឌដែលបានបញ្ចូលជាបេតិកភ័ណ្ឌពិភពលោក ត្រូវទុកជាតំបន់អព្យាក្រឹត ដែលមិនឱ្យមានសកម្មភាពយោធា ។

<u>មាត្រា ៧២.</u>_

សុខភាពរបស់ប្រជារាស្ត្រត្រូវបានធានា ។ រដ្ឋយកចិត្តទុកដាក់ដល់ការការពារជម្ងឺនិងព្យាបាលជម្ងឺ ។ ប្រជារាស្ត្រក្រីក្រត្រូវបានទទួលការពិនិត្យរោគដោយឥតបង់ថ្លៃនៅតាមមន្ទីរពេទ្យ គិលានដ្ឋាន និងមន្ទីរសម្ភពសាធារណៈ ។

រដ្ឋរៀបចំឱ្យមានគិលានដ្ឋាន និងមន្ទីរសម្ភពដល់ជនបទ ។

<u>មាត្រា ៧៣.</u>_

រដ្ឋយកចិត្តទុកដាក់ចំពោះកុមារនិងមាតា ។ រដ្ឋរៀបចំឱ្យមានទារកដ្ឋាន និងជួយឧបត្ថម្ភនារីដែលមានកូនច្រើនក្នុងបន្ទុក ហើយឥតទីពឹង ។

<u>មាត្រា ៧៤.</u>_

រដ្ឋជួយឧបត្ថម្ភជនពិការនិងដល់គ្រួសារយុទ្ធជនដែលបានបូជាជីវិតដើម្បីប្រទេសជាតិ ។

<u>មាត្រា ៧៥.</u>_

រដ្ឋចាត់ចែងឱ្យមានរបបសន្តិសុខសង្គម ដល់កម្មករនិងនិយោជិត ។

# ជំពូកទី ៧
# អំពី រដ្ឋសភា

**មាត្រា ៧៦.-**

រដ្ឋសភាមានសមាជិកជាតំណាងរាស្ត្រយ៉ាងតិច ១២០ រូប ។

តំណាងរាស្ត្រត្រូវជ្រើសតាំងដោយការបោះឆ្នោតជាសកល ដោយសេរី ដោយស្មើភាព ដោយចំពោះ និងតាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់ ។

តំណាងរាស្ត្រអាចឈរឈ្មោះបោះឆ្នោតសាជាថ្មីបាន ។

អ្នកដែលមានសិទ្ធិឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រ គឺប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានសិទ្ធិបោះឆ្នោត មានអាយុយ៉ាងតិច ២៥ ឆ្នាំ មានសញ្ជាតិជាខ្មែរតាំងពីកំណើត។

អង្គការរៀបចំការបោះឆ្នោត បែបបទនិងការប្រព្រឹត្តិទៅនៃការបោះឆ្នោត ត្រូវកំណត់ក្នុងច្បាប់បោះឆ្នោត ។

**មាត្រា ៧៧.-**

តំណាងរាស្ត្រក្នុងរដ្ឋសភា ជាតំណាងប្រជាជាតិខ្មែរទាំងមូលពុំមែនគ្រាន់តែជាតំណាងប្រជាពលរដ្ឋក្នុងមណ្ឌលរបស់ខ្លួននោះទេ ។

អាណត្តិអាជ្ញាបញ្ជាទាំងឡាយត្រូវទុកជាមោឃៈ ។

**មាត្រា ៧៨.-**

នីតិកាលរបស់រដ្ឋសភាមានកំណត់ ៥ ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលដែលរដ្ឋសភាថ្មីចូលកាន់តំណែង ។ រដ្ឋសភាមិនអាចត្រូវបានរំលាយមុនផុតអាណត្តិបានឡើយ វៀរលែងតែក្នុងករណីដែលរាជរដ្ឋាភិបាលត្រូវបានទំលាក់ពីរដងក្នុងរយៈ ១២ ខែ ។

ក្នុងករណីនេះ ព្រះមហាក្សត្រត្រូវរំលាយរដ្ឋសភា ក្រោយពីព្រះអង្គទ្រង់បានទទួលការស្នើពីនាយករដ្ឋមន្ត្រី និងបន្ទាប់ពីទ្រង់បានការយល់ព្រមពីប្រធានរដ្ឋសភា ។

ការបោះឆ្នោតដើម្បីជ្រើសរើសរដ្ឋសភាថ្មី នឹងប្រព្រឹត្តទៅក្នុងរយៈពេល ៦០ ថ្ងៃយ៉ាងយូរ ចាប់តាំងពីថ្ងៃរំលាយរដ្ឋសភាមក ។

១៩

ក្នុងរយៈកាលនេះ រាជរដ្ឋាភិបាលមានតែភារកិច្ចដឹកនាំការងារប្រ-ចាំថ្ងៃតែប៉ុណ្ណោះ ។

ក្នុងពេលមានសង្គ្រាម ឬក្នុងកាលៈទេសៈពិសេសដទៃទៀតដែលមិនអាចធ្វើការបោះឆ្នោតកើត រដ្ឋសភាអាចប្រកាសបន្តនីតិកាលរបស់ខ្លួនមួយដងបានមួយឆ្នាំ តាមសំណើរបស់ព្រះមហាក្សត្រ ។

ការប្រកាសបន្តនីតិកាលរបស់រដ្ឋសភា ត្រូវសំរេចដោយមតិយល់ព្រមពីរភាគបីយ៉ាងតិចនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

**មាត្រា ៧៩.-**

អាណត្តិនៃសមាជិករដ្ឋសភាមានវិសមិតភាពជាមួយការបំពេញមុខងារសាធារណៈជាសកម្ម និងជាមួយមុខងារជាសមាជិកនៃស្ថាប័នដទៃទៀតដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនេះ វៀរលែងតែទៅបំពេញមុខងារក្នុងគណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល ។

ក្នុងករណីនេះ សមាជិករដ្ឋសភារូបនោះ មានឋានៈជាសមាជិករដ្ឋសភាធម្មតា ប៉ុន្តែមិនត្រូវមានមុខតំណែងអ្វីទាំងអស់ក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍ និងក្នុងគណៈកម្មការផ្សេងៗនៃរដ្ឋសភា ។

**មាត្រា ៨០.-**

តំណាងរាស្ត្រមានអភ័យឯកសិទ្ធិសភា ។

តំណាងរាស្ត្ររូបណាក៏ដោយ មិនអាចត្រូវបានចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួន ដោយហេតុពីបានសំដែងយោបល់ ឬបញ្ចេញមតិក្នុងការបំពេញមុខងាររបស់ខ្លួនសោះឡើយ ។

ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនសមា-ជិកណាមួយនៃរដ្ឋសភានឹងអាចធ្វើទៅកើត លុះត្រាតែមានការយល់ព្រមពីរដ្ឋសភា ឬពីគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាក្នុងចន្លោះសម័យប្រជុំនៃរដ្ឋសភា វៀរលែងតែក្នុងករណីបទល្មើសព្រហ្មទណ្ឌជាក់ស្តែង ។ ក្នុងករណីខាងក្រោយនេះ ក្រសួងមានសមត្ថកិច្ចត្រូវធ្វើសេចក្តីរាយការណ៍ជូនរដ្ឋសភា ឬជូនគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាជាបន្ទាន់ដើម្បីសំរេច ។

សេចក្តីសំរេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាត្រូវដាក់ជូនសម័យប្រជុំរដ្ឋសភាខាងមុខ ដើម្បីអនុម័តតាមមតិភាគច្រើនពីរភាគបី នៃសមា-ជិករដ្ឋសភាទាំងមូល ។

២០

ក្នុងករណីទាំងអស់ខាងលើនេះ ការឃុំខ្លួន ការចោទប្រកាន់តំណាងរាស្ត្រណាមួយត្រូវផ្អាក ប្រសិនបើរដ្ឋសភាបានបញ្ចេញមតិឱ្យផ្អាកតាមមតិភាគច្រើន បីភាគបួន នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

មាត្រា ៨១._

រដ្ឋសភាមានថវិកាស្វយ័ត សំរាប់ដំណើរការ ។

តំណាងរាស្ត្រត្រូវទទួលប្រាក់បំណាច់ ។

មាត្រា ៨២._

រដ្ឋសភាបើកសម័យប្រជុំដំបូង ហុកសិបថ្ងៃយ៉ាងយូរក្រោយពេលបោះឆ្នោត តាមការកោះប្រជុំរបស់ព្រះមហាក្សត្រ ។

មុនចាប់ផ្តើមការងាររបស់ខ្លួន រដ្ឋសភាត្រូវអនុម័តបទបញ្ជាផ្ទៃក្នុងសម្រេចអំពីសុពលភាពនៃអាណត្តិរបស់សមាជិកនិមួយៗ និងត្រូវបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នានូវប្រធាន អនុប្រធានរដ្ឋសភា និងសមាជិកទាំងអស់នៃគណៈកម្មការនានារបស់រដ្ឋសភា ដោយមតិភាគច្រើនពីរភាគបី នៃសមាជិករដ្ឋសភាទាំងមូល ។

តំណាងរាស្ត្រទាំងអស់ត្រូវធ្វើសច្ចាប្រណិធាន មុនចូលកាន់តំណែងដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធ ៥ ។

មាត្រា ៨៣._

រដ្ឋសភាប្រជុំជាសាមញ្ញពីរដងក្នុងមួយឆ្នាំ ។

សម័យប្រជុំនិមួយៗ មានថិរៈវេលាយ៉ាងតិចបីខែ ។ បើមានសំណូមពរពីព្រះមហាក្សត្រ ឬសេចក្តីស្នើសុំពីនាយករដ្ឋមន្ត្រីឬពីសមាជិករដ្ឋសភាចំនួនមួយភាគបីយ៉ាងតិច គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាកោះប្រជុំរដ្ឋសភាជាវិសាមញ្ញ ។

ក្នុងករណីនេះ របៀបវារៈដាក់លាក់នៃសម័យប្រជុំជាវិសាមញ្ញត្រូវផ្សាយដល់ប្រជារាស្ត្រជាមួយនឹងថ្ងៃកំណត់ប្រជុំ ។

មាត្រា ៨៤._

នៅចន្លោះសម័យប្រជុំរបស់រដ្ឋសភា គណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាទទួលភារកិច្ចចាត់ចែងការងារ ។

គណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភារួមមាន : ប្រធានរដ្ឋសភា អនុប្រធានរដ្ឋសភា និងប្រធានគណៈកម្មការទាំងអស់របស់រដ្ឋសភា ។

២១

**មាត្រា ៨៥.-**

សម័យប្រជុំរដ្ឋសភាត្រូវធ្វើ នៅរាជធានីនៃព្រះរាជាណាចក្រកម្ពុជា- ក្នុងសាលប្រជុំរបស់រដ្ឋសភា លើកលែងតែមានការសំរេចផ្សេង ចុះក្នុងលិខិតកោះប្រជុំ ដោយកាលៈទេសៈតម្រូវ ។

ក្រៅពីករណីខាងលើ និងក្រៅពីកន្លែង និងពីកាលបរិច្ឆេទដែលកំណត់ក្នុងសេចក្តីអញ្ជើញ ការប្រជុំណាក៏ដោយរបស់រដ្ឋសភាត្រូវទុកជាខុសច្បាប់ ហើយជាអាសាសូន្យពេញលក្ខណៈ ។

**មាត្រា ៨៦.-**

ក្នុងកាលៈទេសៈដែលប្រទេសជាតិស្ថិតក្នុងភាពអាសន្ន រដ្ឋសភាប្រជុំរាល់ថ្ងៃជាប់ជាប្រចាំ ។ រដ្ឋសភាមានសិទ្ធិសំរេចបញ្ចប់កាលៈទេសៈពិសេសខាងលើនេះ កាលបើសភាពការណ៍អនុញ្ញាត ។

បើរដ្ឋសភាមិនអាចប្រជុំបានទេ ដោយមូលហេតុចាំបាច់ ជាអាទិ៍ នៅពេលដែលកំលាំងបរទេសចូលមកកាន់កាប់ទឹកដី ការប្រកាសភាពអាសន្ន ត្រូវបន្តទៅមុខជាស្វ័យប្រវត្តិ ។

នៅពេលដែលប្រទេសជាតិឋិតក្នុងភាពអាសន្ន រដ្ឋសភាមិនអាចត្រូវរំលាយបានឡើយ ។

**មាត្រា ៨៧.-**

ប្រធានរដ្ឋសភាដឹកនាំអង្គប្រជុំរបស់រដ្ឋសភា ទទួលអាញត្តិច្បាប់ និងសេចក្តីសំរេចចិត្តទាំងឡាយ ដែលរដ្ឋសភាបានអនុម័ត រ៉ាប់រងការ អនុវត្តន៍បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា និងចាត់ចែងការទាក់ទងអន្តរជាតិទាំងឡាយ របស់រដ្ឋសភា ។

ក្នុងករណីដែលប្រធានរដ្ឋសភាមានធុរៈ មិនអាចបំពេញមុខងារបាន ដោយហេតុមកពីមាន់ជម្ងឺ ឬបំពេញមុខងារជាប្រមុខរដ្ឋស្តីទី ឬជាព្រះរាជានុសិទ្ធិ ឬបំពេញបេសកកម្មនៅបរទេស អនុប្រធានរដ្ឋសភាមួយរូប ត្រូវទទួលភារកិច្ចចាត់ចែងការងារជំនួស ។

ក្នុងករណីដែលប្រធាន ឬអនុប្រធានរដ្ឋសភាលាលែងពីមុខតំណែង ឬទទួលអនិច្ចកម្ម រដ្ឋសភាត្រូវបោះឆ្នោតជ្រើសតាំងប្រធាន ឬអនុប្រធានថ្មី ។

**មាត្រា ៨៨.-**

ការប្រជុំរដ្ឋសភាត្រូវធ្វើជាសាធារណៈ ។

២២

រដ្ឋសភាអាចប្រជុំជាសម្ងាត់បាន តាមការសុំពីប្រធាន ឬពីសមាជិកចំនួនមួយភាគដប់យ៉ាងតិច ពីព្រះមហាក្សត្រ ឬពីនាយករដ្ឋមន្ត្រី ។

ការប្រជុំរដ្ឋសភានឹងយកជាការបាន លុះត្រាតែមានកូរ៉ុមប្រាំពីរភាគដប់ នៃសមាជិករដ្ឋសភាទាំងមូល ។

មាត្រា ៨៩.-

តាមការសុំពីសមាជិកចំនួនមួយភាគដប់យ៉ាងតិច រដ្ឋសភាអាចអញ្ជើញឥស្សរជនដ៏ឧត្តមណាមួយ មកបំភ្លឺរដ្ឋសភាអំពីបញ្ហាដែលមានសារៈសំខាន់ពិសេស ។

មាត្រា ៩០.-

រដ្ឋសភាជាអង្គការតែមួយគត់ដែលមានអំណាចនីតិបញ្ញត្តិ ។ អំណាចនេះ រដ្ឋសភាមិនអាចប្រគល់ឱ្យទៅអង្គការ ឬបុគ្គលណាមួយបានឡើយ ។

រដ្ឋសភាអនុម័តថវិកាជាតិ ផែនការរដ្ឋ ការឱ្យរដ្ឋខ្ចីប្រាក់ពីគេ ការឱ្យរដ្ឋឱ្យប្រាក់គេខ្ចី ការសន្យានានាផ្នែកហិរញ្ញវត្ថុ និងការបង្កើត កែប្រែ ឬលុបចោលពន្ធដារ ។

រដ្ឋសភាឱ្យសេចក្តីយល់ព្រមចំពោះគណនីរដ្ឋបាល ។

រដ្ឋសភាអនុម័តច្បាប់ស្តីពីការលើកលែងទោសជាទូទៅ ។

រដ្ឋសភាអនុម័តយល់ព្រម ឬលុបចោលសន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិ ។

រដ្ឋសភាអនុម័តច្បាប់ស្តីពីការប្រកាសសង្គ្រាម ។

ការអនុម័តខាងលើនេះ ប្រព្រឹត្តទៅដោយមតិភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល ។

រដ្ឋសភាបោះឆ្នោតទុកចិត្តដល់រាជរដ្ឋាភិបាល តាមមតិភាគច្រើនពីរភាគបី នៃសមាជិករដ្ឋសភាទាំងមូល ។

មាត្រា ៩១.-

តំណាងរាស្ត្រ និងនាយករដ្ឋមន្ត្រីមានសិទ្ធិផ្តួចផ្តើមគំនិតធ្វើច្បាប់ ។

តំណាងរាស្ត្រមានសិទ្ធិស្នើធ្វើវិសោធនកម្មច្បាប់ ប៉ុន្តែសំណើនេះមិនអាចទទួលយកបានទេ បើវិសោធនកម្មនោះ សំដៅបន្ថយប្រាក់ចំណូលសាធារណៈ ឬបន្ថែមបន្ទុកទៅលើប្រជាពលរដ្ឋ ។

មាត្រា ៩២.-

ការអនុម័តទាំងឡាយរបស់រដ្ឋសភាដែលផ្ទុយនឹងគោលការណ៍រក្សាការពារ ឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដី នៃព្រះរាជាណាចក្រកម្ពុជា ហើយដែលនាំឱ្យប៉ះពាល់ដល់ឯកភាពនយោបាយ ឬការគ្រប់គ្រងរដ្ឋបាលរបស់ប្រទេសជាតិ នឹងត្រូវចាត់ទុកជាអាសាសូន្យ ។ ក្រុមប្រឹក្សាធម្មនុញ្ញជាអង្គការតែមួយគត់ដែលមានសមត្ថកិច្ចសម្រេចពីមោឃភាពនេះ ។

មាត្រា ៩៣.-

ច្បាប់ដែលរដ្ឋសភាបានអនុម័តរួចហើយ ហើយត្រូវបានព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាប្រកាសឱ្យប្រើ ត្រូវចូលជាធរមាននៅរាជធានីភ្នំពេញក្នុងរយៈពេល ១០ ថ្ងៃគត់ ក្រោយថ្ងៃប្រកាសឱ្យប្រើ និងនៅទូទាំងប្រទេស ក្នុងរយៈពេល ២០ ថ្ងៃគត់ ក្រោយថ្ងៃប្រកាសឱ្យប្រើ ។

ប៉ុន្តែបើច្បាប់នេះបានចែងថាជាការប្រញាប់ ច្បាប់នេះត្រូវចូលជាធរមានភ្លាមនៅទូទាំងប្រទេសក្រោយថ្ងៃប្រកាសឱ្យប្រើ ។

ច្បាប់ដែលព្រះមហាក្សត្រទ្រង់បានឡាយព្រះហស្តលេខាប្រកាសឱ្យប្រើ ត្រូវចុះក្នុងរាជកិច្ចនិងផ្សព្វផ្សាយនៅទូទាំងប្រទេស ឱ្យទាន់តាមពេលកំណត់ខាងលើ ។

មាត្រា ៩៤.-

រដ្ឋសភាបង្កើត គណៈកម្មការផ្សេងៗ ដែលចាំបាច់ ។ ការរៀបចំនិងការប្រព្រឹត្តិទៅ នៃរដ្ឋសភា នឹងមានកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ។

មាត្រា ៩៥.-

ក្នុងករណីមានសមាជិករដ្ឋសភាទទួលអនិច្ចកម្ម លាលែង ឬបាត់សមាជិកភាព ដែលកើតមានឡើង ៦ ខែយ៉ាងតិចមុនចប់នីតិកាល ត្រូវចាត់ការជ្រើសតាំងជំនួសសមាជិកនោះ តាមលក្ខខណ្ឌកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរដ្ឋសភា និងក្នុងច្បាប់បោះឆ្នោត ។

មាត្រា ៩៦.-

តំណាងរាស្ត្រមានសិទ្ធិដាក់សំណួរដល់រាជរដ្ឋាភិបាល ។ សំណួរនេះ ត្រូវសរសេរជាលាយលក្ខណ៍អក្សរប្រគល់ជូនតាមរយៈប្រធានរដ្ឋសភា ។

២៤

ចម្លើយអាចធ្វើឡើងដោយរដ្ឋមន្ត្រីមួយរូបឬច្រើនរូប អាស្រ័យដោយបញ្ហាដែលបានចោទឡើង ពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់រដ្ឋមន្ត្រីមួយរូបឬច្រើនរូប ។ បើបញ្ហាពាក់ព័ន្ធដល់នយោបាយទូទៅរបស់រាជរដ្ឋាភិបាល នាយករដ្ឋមន្ត្រីត្រូវឆ្លើយផ្ទាល់ខ្លួន ។

ចម្លើយរបស់រដ្ឋមន្ត្រីឬរបស់នាយករដ្ឋមន្ត្រី អាចធ្វើដោយផ្ទាល់មាត់ឬសរសេរជាលាយលក្ខអក្សរ ។

ចម្លើយខាងលើនេះ ត្រូវធ្វើឡើងក្នុងរយៈពេលប្រាំពីរថ្ងៃ បន្ទាប់ពីបានទទួលសំណួរ ។

ចំពោះចម្លើយផ្ទាល់មាត់ ប្រធានរដ្ឋសភាអាចសំរេចបើកឱ្យមានឬមិនឱ្យមានការជជែកដេញដោល ។ បើគ្មានការបើកឱ្យជជែកដេញដោលទេ នោះចម្លើយរបស់រដ្ឋមន្ត្រី ឬរបស់នាយករដ្ឋមន្ត្រី នឹងបញ្ចប់សំណួរតែម្តង ។

បើមានការបើកឱ្យជជែកដេញដោល ម្ចាស់សំណួរ វាគ្មិនឯទៀតនិងរដ្ឋមន្ត្រីពាក់ព័ន្ធឬនាយករដ្ឋមន្ត្រី អាចជជែកប្តូរយោបល់ក្នុងរយៈពេលដែលមិនអាចលើសពីមួយពេលប្រជុំឡើយ ។

រដ្ឋសភាកំណត់ទុកពេលមួយថ្ងៃក្នុងមួយសប្តាហ៍ សំរាប់ការឆ្លើយសំណួរ ។

ទោះបីយ៉ាងណាក៏ដោយ សម័យប្រជុំសម្រាប់ឆ្លើយសំណួរខាងលើនេះ មិនអាចបើកលទ្ធភាពឱ្យមានការបោះឆ្នោតប្រភេទណាមួយបានឡើយ ។

<u>មាត្រា ៩៧.</u>

គណៈកម្មការទាំងឡាយរបស់រដ្ឋសភា អាចអញ្ជើញរដ្ឋមន្ត្រីមកបំភ្លឺអំពីបញ្ហាអ្វីមួយដែលពាក់ព័ន្ធនឹងវិស័យទទួលខុសត្រូវរបស់ខ្លួន ។

<u>មាត្រា ៩៨.</u>

រដ្ឋសភាអាចទំលាក់សមាជិកគណៈរដ្ឋមន្ត្រី ឬទំលាក់រាជរដ្ឋាភិបាលពីតំណែងដោយអនុម័តញត្តិបន្ទោសតាមសម្លេងឆ្នោតពីរភាគបី នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

ញត្តិបន្ទោសរាជរដ្ឋាភិបាល ត្រូវបានលើកឡើងជូនរដ្ឋសភាដោយតំណាងរាស្ត្រចំនួនសាមសិបនាក់ ទើបរដ្ឋសភាអាចលើកមកពិភាក្សាបាន ។

២៥

# ជំពូកទី ៨
# អំពី រាជរដ្ឋាភិបាល

មាត្រា ៩៩.-

គណៈរដ្ឋមន្ត្រី ជារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។

គណៈរដ្ឋមន្ត្រី ត្រូវបានដឹកនាំដោយនាយករដ្ឋមន្ត្រីមួយរូប អមដោយឧបនាយករដ្ឋមន្ត្រី ព្រមទាំងមានទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការជាសមាជិក ។

មាត្រា ១០០.-

តាមសេចក្ដីស្នើពីប្រធានដោយមានមតិឯកភាពពីអនុប្រធានទាំងពីរនៃរដ្ឋសភា ព្រះមហាក្សត្រទ្រង់ចាត់តាំងវរជនមួយរូបក្នុងចំណោមតំណាងរាស្ត្រនៃគណៈបក្សដែលឈ្នះឆ្នោត ឱ្យបង្កើតរាជរដ្ឋាភិបាល ។ វរជនដែលត្រូវបានចាត់តាំងនេះ នាំសហការីដែលជាតំណាងរាស្ត្រ ឬជាសមាជិកគណៈបក្សតំណាងនៅក្នុងរដ្ឋសភា ដែលផ្ទួរផ្ដងឱ្យកាន់តំណែងផ្សេងៗ ក្នុងរាជរដ្ឋាភិបាល ទៅសុំសេចក្ដីទុកចិត្តពីរដ្ឋសភា ។ កាលបើរដ្ឋសភាបានបោះឆ្នោតទុកចិត្តហើយនោះ ព្រះមហាក្សត្រទ្រង់ចេញព្រះរាជក្រឹត្យតែងតាំងគណៈរដ្ឋមន្ត្រីទាំងមូល ។

មុនចូលកាន់តំណែង គណៈរដ្ឋមន្ត្រីត្រូវធ្វើសច្ចាប្រណិធានដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធ ៦ ។

មាត្រា ១០១.-

មុខងារនៃសមាជិករាជរដ្ឋាភិបាល មានវិសមិតភាពនឹងសកម្មភាពខាងវិជ្ជាជីវៈ ផ្នែកពាណិជ្ជកម្ម ឬឧស្សាហកម្ម ហើយនិងការកាន់តំណែងណាមួយក្នុងមុខងារសាធារណៈ ។

មាត្រា ១០២.-

សមាជិកទាំងឡាយនៃរាជរដ្ឋាភិបាល ទទួលខុសត្រូវរួមគ្នាចំពោះរដ្ឋសភា អំពីនយោបាយទូទៅរបស់រាជរដ្ឋាភិបាល ។

សមាជិកមួយរូបៗ នៃរាជរដ្ឋាភិបាលទទួលខុសត្រូវរៀងខ្លួនចំពោះនាយករដ្ឋមន្ត្រី និងចំពោះរដ្ឋសភា អំពីការដែលខ្លួនបានប្រព្រឹត្ត ។

មាត្រា ១០៣.-

សមាជិកទាំងឡាយនៃរាជរដ្ឋាភិបាល មិនអាចយកសំអាងនៃសេចក្តីបង្គាប់ដោយលាយល័ក្ខអក្សរ ឬដោយវាចា អំពីនរណាមួយ ដើម្បីដោះសារឱ្យរួចខ្លួនពីការទទួលខុសត្រូវរបស់ខ្លួនបានឡើយ ។

មាត្រា ១០៤.-

គណៈរដ្ឋមន្ត្រីត្រូវប្រជុំរាល់សប្តាហ៍ ជាប្រជុំធំឬជាប្រជុំពិនិត្យស្រាវជ្រាវ ។

អង្គប្រជុំធំត្រូវដឹកនាំដោយនាយករដ្ឋមន្ត្រី ។ នាយករដ្ឋមន្ត្រីអាចប្រគល់ភារកិច្ចជូនឧបនាយករដ្ឋមន្ត្រីដឹកនាំអង្គប្រជុំពិនិត្យស្រាវជ្រាវបាន ។

កំណត់ហេតុនៃអង្គប្រជុំទាំងអស់របស់គណៈរដ្ឋមន្ត្រី ត្រូវធ្វើថ្វាយព្រះមហាក្សត្រទ្រង់ជ្រាប ។

មាត្រា ១០៥.-

នាយករដ្ឋមន្ត្រីអាចរំលែកអំណាចរបស់ខ្លួនឱ្យទៅឧបនាយករដ្ឋមន្ត្រី ឬសមាជិកណាមួយនៃរាជរដ្ឋាភិបាលបាន ។

មាត្រា ១០៦.-

បើតំណែងនាយករដ្ឋមន្ត្រីនៅទំនេរជាស្ថាពរនោះ ត្រូវតែងតាំងគណៈរដ្ឋមន្ត្រីមួយជាថ្មី ក្នុងលក្ខខណ្ឌដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនេះ ។ បើការទំនេរនេះ ជាការទំនេរមួយកាលមួយគ្រាទេ ត្រូវចាត់តាំងនាយករដ្ឋមន្ត្រីស្តីទី ជាបណ្តោះអាសន្ន ។

មាត្រា ១០៧.-

សមាជិកមួយរូបៗនៃរាជរដ្ឋាភិបាល ត្រូវទទួលទណ្ឌកម្មពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ដែលខ្លួនបានប្រព្រឹត្តក្នុងការបំពេញការងាររបស់ខ្លួន ។

ក្នុងករណីនេះនិងក្នុងករណីធ្វើខុសជាទម្ងន់ ក្នុងការបំពេញការងាររបស់ខ្លួន រដ្ឋសភាអាចសំរេចប្តឹងទៅតុលាការមានសមត្ថកិច្ច ។

រដ្ឋសភាសំរេចក្នុងរឿងនេះដោយវិធីបោះឆ្នោតជាសម្ងាត់ តាមមតិភាគច្រើនដាច់ខាត នៃសមាជិករដ្ឋសភាទាំងមូល ។

មាត្រា ១០៨.-

ការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីនឹងត្រូវកំណត់ក្នុងច្បាប់មួយ ។

# ជំពូកទី ៩
## អំពី អំណាចតុលាការ

មាត្រា ១០៩.-

អំណាចតុលាការ ជាអំណាចឯករាជ្យ ។

អំណាចតុលាការ ធានារក្សាអនាគតិ និងការពារសិទ្ធិ សេរីភាពរបស់ប្រជាពលរដ្ឋ ។

អំណាចតុលាការគ្របដណ្ដប់ទៅលើរឿងក្ដីទាំងអស់ រួមទាំងរឿងក្ដីរដ្ឋបាលផង ។

អំណាចនេះ ត្រូវប្រគល់ឱ្យតុលាការកំពូល និងសាលាជំរះក្ដីគ្រប់ផ្នែក និងគ្រប់ជាន់ថ្នាក់ ។

មាត្រា ១១០.-

ការជំរះក្ដីផ្ដល់យុត្តិធម៌ ត្រូវធ្វើក្នុងនាមប្រជារាស្ត្រខ្មែរ តាមនីតិវិធី និងច្បាប់ជាធរមាន ។

មានតែចៅក្រមទេដែលមានសិទ្ធិជំរះក្ដី ។ ចៅក្រមត្រូវបំពេញភារកិច្ចនេះ ដោយគោរពច្បាប់យ៉ាងម៉ឺងម៉ាត់ និងឱ្យអស់ពីដួងចិត្តនិងសម្បជញ្ញៈរបស់ខ្លួន ។

មាត្រា ១១១.-

គ្មានអង្គការណាមួយនៃអំណាចនីតិបញ្ញត្តិ ឬនីតិប្រតិបត្តិអាចទទួលអំណាចតុលាការអ្វីបានឡើយ ។

មាត្រា ១១២.-

មានតែអង្គការអយ្យការទេ ដែលមានសិទ្ធិធ្វើបណ្ដឹងអាជ្ញា ។

មាត្រា ១១៣.-

ព្រះមហាក្សត្រទ្រង់ ជាអ្នកធានាឯករាជ្យនៃអំណាចតុលាការ ។

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមជួយព្រះមហាក្សត្រក្នុងកិច្ចការនេះ។

មាត្រា ១១៤.-

ចៅក្រមមិនអាចត្រូវគេដកពីមុខងារបានទេ ។ ប៉ុន្តែឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមសំរេចដាក់វិន័យលើចៅក្រមដែលបានប្រព្រឹត្តខុស ។

២៨

**មាត្រា ១១៥.-**

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនឹងត្រូវបង្កើតដោយច្បាប់រៀបចំអង្គការមួយដែលនឹងកំណត់សមាសភាព និងមុខងារ ។

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមស្ថិតក្រោមព្រះរាជាធិបតីភាពនៃព្រះមហាក្សត្រ ។ ព្រះមហាក្សត្រព្រះអង្គទ្រង់អាចចាត់តាំងព្រះរាជតំណាងម្នាក់របស់ព្រះអង្គឱ្យធ្វើជាអធិបតីនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនេះ ។

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម លើកសេចក្តីស្នើថ្វាយព្រះមហាក្សត្រអំពីការតែងតាំងចៅក្រម និងព្រះរាជអាជ្ញាអមសាលាជំរះក្តីទាំងអស់ ។

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្នុងមុខការដាក់វិន័យចំពោះចៅក្រមនិងព្រះរាជអាជ្ញា ត្រូវប្រជុំក្រោមអធិបតីភាពនៃប្រធានតុលាការកំពូល ឬអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល អាស្រ័យដោយករណីទាក់ទងនឹងចៅក្រមឬព្រះរាជអាជ្ញា ។

**មាត្រា ១១៦.-**

លក្ខន្តិកៈនៃចៅក្រមនិងព្រះរាជអាជ្ញា និងការរៀបចំអង្គការតុលាការ នឹងត្រូវកំណត់ក្នុងច្បាប់ដោយឡែកពីគ្នា ។

២៩

## ជំពូកទី ១០
## អំពី ក្រុមប្រឹក្សាធម្មនុញ្ញ

មាត្រា ១១៧.-

ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចធានាការពារការគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ដែលរដ្ឋសភាអនុម័តហើយ ។

ក្រុមប្រឹក្សាធម្មនុញ្ញមានសិទ្ធិពិនិត្យ និងសំរេចអំពីករណីវិវាទកម្ម ទាក់ទងនឹងការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ ។

មាត្រា ១១៨.-

ក្រុមប្រឹក្សាធម្មនុញ្ញ មានសមាជិកប្រាំបួនរូប ដែលទទួលអាណត្តិ ប្រាំបួនឆ្នាំ ។ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញចំនួនមួយភាគបី ត្រូវផ្លាស់ថ្មីក្នុង រយៈពេលបីឆ្នាំម្តង បីឆ្នាំម្តង ។ សមាជិកបីរូបត្រូវតែងតាំងដោយព្រះមហាក្សត្រ បីរូបត្រូវជ្រើសតាំងដោយរដ្ឋសភា ហើយបីរូបទៀតត្រូវតែងតាំងដោយឧត្តមក្រុម ប្រឹក្សានៃអង្គចៅក្រម ។

ប្រធានត្រូវបានជ្រើសតាំងដោយសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ។ ប្រធាន មានសម្លេងឧត្តមានុភាពក្នុងករណីបែកសម្លេងជាពីរស្មើគ្នា ។

មាត្រា ១១៩.-

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវជ្រើសរើសក្នុងចំណោមឥស្សរជន ដែលមានសញ្ញាប័ត្រចាប់ពីឧត្តមសិក្សាទៅ ខាងច្បាប់ ខាងរដ្ឋបាល ខាងការទូត ឬខាងសេដ្ឋកិច្ច ហើយមានពិសោធន៍ច្រើនក្នុងការងារ ។

មាត្រា ១២០.-

មុខងារសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ មានវិសមិតភាពនឹងមុខងារសមាជិករដ្ឋាភិបាល សមាជិករដ្ឋសភា ប្រធាន ឬអនុប្រធានគណៈបក្សនយោបាយ ប្រធាន ឬ អនុប្រធានសហជីព ចៅក្រមក្នុងតំណែង ។

មាត្រា ១២១.-

ព្រះមហាក្សត្រ នាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា ឬតំណាងរាស្ត្រ ចំនួនមួយភាគដប់ អាចបញ្ជូនសេចក្តីព្រាងច្បាប់ទៅឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុន និងសេចក្តីព្រាងច្បាប់នោះ ត្រូវបានប្រកាសឱ្យប្រើ ។

៣០

បទបញ្ជាផ្ទៃក្នុងរដ្ឋសភា និងច្បាប់រៀបចំអង្គការទាំងឡាយត្រូវតែបញ្ជូនទៅក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុននឹងត្រូវបានប្រកាសឱ្យប្រើ ។

ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវសំរេចក្នុងរយៈពេលសាមសិបថ្ងៃយ៉ាងយូរថា តើច្បាប់និងបទបញ្ជាផ្ទៃក្នុងរដ្ឋសភាខាងលើស្រប ឬមិនស្របនឹងរដ្ឋធម្មនុញ្ញ ។

**មាត្រា ១២២.-**

ក្រោយពីច្បាប់ណាមួយត្រូវបានប្រកាសឱ្យប្រើ ព្រះមហាក្សត្រ នាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា តំណាងរាស្ត្រមួយភាគដប់ ឬតុលាការអាចសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យអំពីធម្មនុញ្ញភាពនៃច្បាប់នោះ ។

ប្រជារាស្ត្រមានសិទ្ធិប្តឹងអំពីធម្មនុញ្ញភាពនៃច្បាប់បាន តាមរយៈតំណាងរាស្ត្រ ឬ ប្រធានរដ្ឋសភាដូចមានចែងក្នុងវាក្យខំណ្ឌខាងលើ ។

**មាត្រា ១២៣.-**

បទបញ្ញត្តិក្នុងមាត្រាណាដែលក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាមិនស្របនឹងរដ្ឋធម្មនុញ្ញ មិនអាចយកទៅប្រកាសឱ្យប្រើ ឬយកទៅអនុវត្តបានឡើយ ។

សេចក្តីសំរេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសំរេចបិទផ្លូវតវ៉ា ។

**មាត្រា ១២៤.-**

ព្រះមហាក្សត្រទ្រង់ពិគ្រោះមតិក្រុមប្រឹក្សាធម្មនុញ្ញ ចំពោះសេចក្តីស្នើទាំងឡាយដែលសុំធ្វើវិសោធនកម្មលើរដ្ឋធម្មនុញ្ញ ។

**មាត្រា ១២៥.-**

ច្បាប់រៀបចំអង្គការមួយនឹងកំណត់ការរៀបចំនិងការប្រព្រឹត្តិទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។

## ជំពូកទី ១១
## អំពី ការគ្រប់គ្រងរដ្ឋបាល

**មាត្រា ១២៦.-**

ទឹកដីនៃព្រះរាជាណាចក្រកម្ពុជាចែកជាខេត្ត និងក្រុង ។
ខេត្តចែកជាស្រុក ស្រុកចែកជាឃុំ ។
ក្រុងចែកជាខណ្ឌ ខណ្ឌចែកជាសង្កាត់ ។

**មាត្រា ១២៧.-**

ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ និង សង្កាត់ ត្រូវគ្រប់គ្រងតាមលំនាំខណ្ឌ ដែលមានចែងក្នុងច្បាប់រៀបចំអង្គការមួយ ។

៣២

# ជំពូកទី ១២
## អំពី សមាជជាតិ

មាត្រា ១២៨._

សមាជជាតិបើកឱ្យប្រជារាស្ត្រជ្រាបដោយផ្ទាល់ អំពីកិច្ចការផ្សេងៗ ដែលជាប្រយោជន៍ជាតិ និងលើកបញ្ហា និងសំណូមពរជូនរដ្ឋអំណាចដោះស្រាយ ។

ប្រជារាស្ត្រខ្មែរទាំងពីរភេទមានសិទ្ធិទៅចូលរួមក្នុងសមាជជាតិ ។

មាត្រា ១២៩._

សមាជជាតិប្រជុំមួយដងក្នុងមួយឆ្នាំ នៅដើមខែធ្នូ តាមការកោះអញ្ជើញរបស់នាយករដ្ឋមន្ត្រី ។

សមាជជាតិប្រព្រឹត្តទៅក្រោមព្រះរាជាធិបតីភាពនៃព្រះមហាក្សត្រ។

មាត្រា ១៣០._

សមាជជាតិអនុម័តសំណូមពរជូនរដ្ឋអំណាច និងជូនរដ្ឋសភាពិចារណា ។

ការរៀបចំនិងការប្រព្រឹត្តិទៅនៃសមាជជាតិនឹងត្រូវកំណត់ក្នុងច្បាប់មួយ ។

# ជំពូកទី ១៣

## អំពី អានុភាព ការសើរើ និង វិសោធនកម្មរដ្ឋធម្មនុញ្ញ

**មាត្រា ១៣១.-**

រដ្ឋធម្មនុញ្ញនេះ ជាច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជា ។

ច្បាប់ និងសេចក្តីសម្រេចទាំងឡាយនៃស្ថាប័ននានារបស់រដ្ឋត្រូវស្របនឹងរដ្ឋធម្មនុញ្ញជាដាច់ខាត ។

**មាត្រា ១៣២.-**

ការផ្តើមគំនិតសើរើ ឬការផ្តើមគំនិតធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ជាសិទ្ធិរបស់ព្រះមហាក្សត្រ របស់នាយករដ្ឋមន្ត្រី និងរបស់ប្រធានរដ្ឋសភា តាមសេចក្តីស្នើរបស់តំណាងរាស្ត្រមួយភាគបួន នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

ការសើរើ ឬវិសោធនកម្មរដ្ឋធម្មនុញ្ញត្រូវធ្វើឡើងដោយច្បាប់ធម្មនុញ្ញមួយដែលអនុម័តដោយរដ្ឋសភាតាមមតិភាគច្រើនពីរភាគបី នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

**មាត្រា ១៣៣.-**

ការសើរើ ឬវិសោធនកម្មរដ្ឋធម្មនុញ្ញត្រូវហាមឃាត់មិនឱ្យធ្វើ នៅពេលប្រទេសជាតិឋិតក្នុងភាពអាសន្ន ដូចមានចែងក្នុងមាត្រា ៨៦ ។

**មាត្រា ១៣៤.-**

ការសើរើ ឬវិសោធនកម្មរដ្ឋធម្មនុញ្ញមិនអាចធ្វើបានឡើយកាលបើប៉ះពាល់ដល់ប្រព័ន្ធប្រជាធិបតេយ្យសេរីពហុបក្ស និងរបបរាជានិយមអាស្រ័យដោយរដ្ឋធម្មនុញ្ញ ។

# ជំពូក ទី ១៤
# អំពី អន្តរប្បញ្ញត្តិ

**មាត្រា ១៣៥.-**

រដ្ឋធម្មនុញ្ញនេះ ក្រោយពីបានទទួលការអនុម័ត ត្រូវបានប្រកាសឱ្យចូលជាធរមានភ្លាមដោយព្រះប្រមុខរដ្ឋកម្ពុជា ។

**មាត្រា ១៣៦.-**

ក្រោយពេលរដ្ឋធម្មនុញ្ញនេះចូលជាធរមាន សភាធម្មនុញ្ញត្រូវក្លាយទៅជារដ្ឋសភា ។

បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភាត្រូវចូលជាធរមាន ក្រោយទទួលបានការអនុម័តពីរដ្ឋសភា ។

ក្នុងករណីដែលរដ្ឋសភាមិនទាន់ចាប់ដំណើរការបាន ប្រធាន អនុប្រធានទីមួយ និងអនុប្រធានទីពីរនៃសភាធម្មនុញ្ញនឹងចូលរួមបំពេញភារកិច្ចក្នុងក្រុមប្រឹក្សារាជសម្បត្តិ បើសភាពការណ៍ក្នុងប្រទេសទាមទារ ។

**មាត្រា ១៣៧.-**

ក្រោយរដ្ឋធម្មនុញ្ញនេះចូលជាធរមាន ព្រះមហាក្សត្រជ្រើសតាំងតាមលក្ខខំណ្ឌ ដែលមានចែងក្នុងមាត្រា ១៣ និង ១៤ ។

**មាត្រា ១៣៨.-**

ក្រោយពេលរដ្ឋធម្មនុញ្ញនេះចូលជាធរមាន ហើយក្នុងនីតិកាល ទី ១ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ព្រះអង្គទ្រង់ចាត់តាំងនាយករដ្ឋមន្ត្រីទីមួយមួយរូប និងនាយករដ្ឋមន្ត្រីទីពីរមួយរូប ឱ្យបង្កើតរាជរដ្ឋាភិបាលក្រោយបានមតិឯកភាពពីប្រធានរដ្ឋសភា និងអនុប្រធានទាំងពីរនៃរដ្ឋសភា ។

សហនាយករដ្ឋមន្ត្រី ដែលមានមុនការអនុម័តរដ្ឋធម្មនុញ្ញនេះ ត្រូវចូលជាសមាជិកនៃគណៈកម្មការ និងក្រុមប្រឹក្សារាជសម្បត្តិដែលមានចែងក្នុងមាត្រា ១១ និង ១៣ ខាងលើ ។

**មាត្រា ១៣៩.-**

ច្បាប់និងលិខិតបទដ្ឋានទាំងអស់នៅកម្ពុជា ដែលធានាការពារបាននូវទ្រព្យសម្បត្តិរដ្ឋ សិទ្ធិ សេរីភាព និងទ្រព្យសម្បត្តិត្រឹមត្រូវតាមច្បាប់របស់បុគ្គល

៣៥

និងដែលសមស្របនឹងប្រយោជន៍ជាតិ ត្រូវមានអានុភាពអនុវត្តបន្តទៅមុខទៀត រហូតដល់មានអត្ថបទថ្មីមកកែប្រែ ឬលុបចោលលើកលែងតែបទបញ្ញត្តិណា ដែលផ្ទុយនឹងស្មារតីនៃរដ្ឋធម្មនុញ្ញនេះ ។

រដ្ឋធម្មនុញ្ញនេះ ត្រូវបានសភាធម្មនុញ្ញអនុម័ត
នៅភ្នំពេញថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ១៩៩៣ នាសម័យប្រជុំពេញអង្គលើកទី ២
ភ្នំពេញ, ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ១៩៩៣

ប្រធាន

សឺន សាន

៣៦

ឧបសម្ព័ន្ធទី ១

# ទង់ជាតិ



៣៧

ឧបសម្ព័ន្ធទី ២

# ភ្លេងជាតិ នគររាជ

១ ‿ សូមពពួកទេវតា　រក្សា មហាក្សត្រយើង
ឱ្យ បានរុងរឿង　ដោយជ័យមង្គល សិរីសួស្តី
យើងខ្ញុំព្រះអង្គ　សូមជ្រកក្រោមម្លប់ព្រះបារមី
នៃព្រះន_របតី　វង្សក្សត្រាដែលសាងប្រាសាទថ្ម
គ្រប់គ្រងដែនខ្មែរ　បុរាណថ្កើងថ្កាន ៗ

២ ‿ ប្រាសាទសិលា　កំបាំងកណ្តាលព្រៃ
គួរឱ្យស្រមៃ　នឹកដល់យសសក្តិ មហានគរ
ជាតិខ្មែរដូចថ្ម　គង់វង់នៅល្អ រឹងប៉ឹងជំហរ
យើងសង្ឃឹមពរ　ភ័ព្វព្រេងសំណាងរបស់កម្ពុជា
មហារដ្ឋកើតមាន　យូរអង្វែងហើយ ៗ

៣ ‿ គ្រប់វត្តអារាម　ឮតែសូរស័ព្ទធម៌
សូត្រដោយអំណរ　រំឭកគុណពុទ្ធសាសនា
ចូរយើងជាអ្នក　ជឿជាក់ស្មោះស្ម័គ្រ តាមបែបដូនតា
គង់តែទេវតា　នឹងជួយជ្រោមជ្រែងផ្គត់ផ្គង់ប្រយោជន៍ឱ្យ
ដល់ប្រទេសខ្មែរ　ជាមហានគរ ៗ

៣៨

ឧបសម្ព័ន្ធទី ៣

## សញ្ញាជាតិ



ឧបសម្ព័ន្ធទី ៤

# សច្ចាប្រណិធាន
# នៃ
# ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា

ខ្ញុំតាំងសច្ចាថានឹងប្រព្រឹត្តតាមរដ្ឋធម្មនុញ្ញ និង ច្បាប់

ទាំងឡាយនៃព្រះរាជាណាចក្រ ហើយនឹងតាំងចិត្តធ្វើផល

ប្រយោជន៍ដល់រដ្ឋ និង ប្រជារាស្ត្រ ។

ឧបសម្ព័ន្ធទី ៥

## សច្ចាប្រណិធាន

ទូលព្រះបង្គំ
យើងខ្ញុំ
ប្រធាន អនុប្រធាន និង សមាជិករដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
សូមធ្វើសច្ចាប្រណិធាន
នៅចំពោះព្រះភ័ក្ត្រព្រះមហាក្សត្រ ព្រះភ័ក្ត្រនៃសម្ដេចព្រះសង្ឃរាជ
និងទេវតារក្សាស្វេតច្ឆត្រ
ដូចតទៅ ៖

- ក្នុងពេលប្រតិបត្តិការ តាមមុខតំណែងខ្លួន និងក្នុងការបំពេញបេសកកម្ម ដែលប្រជារាស្ត្រកម្ពុជា បានប្រគល់ជូន ចំពោះទូលព្រះបង្គំយើងខ្ញុំគ្រប់ៗរូប ទូលព្រះបង្គំយើងខ្ញុំ សូមប្ដេជ្ញាគោរពរដ្ឋធម្មនុញ្ញ បំរើជានិច្ច ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគត នូវផលប្រយោជន៍ របស់ប្រជារាស្ត្រ ប្រជាជាតិ និងមាតុភូមិកម្ពុជា ។ ទូលព្រះបង្គំយើងខ្ញុំ សូមសច្ចាថា មិនកេងប្រវ័ញ្ច នូវផលប្រយោជន៍ជាតិ សម្រាប់ផ្ទាល់ខ្លួន ឬសម្រាប់គ្រួសារ ឬសម្រាប់បក្សពួក ឬសំរាប់ភាគីរៀងៗខ្លួនឡើយ ។

- ទូលព្រះបង្គំយើងខ្ញុំ សូមប្ដេជ្ញាប្ដូរផ្ដាច់ហ៊ានបូជាជីវិត ដើម្បីការពារជានិច្ច ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគត នូវ ៖

. ឯករាជ្យភាពទាំងស្រុង នៃមាតុភូមិកម្ពុជា

. អធិបតេយ្យភាពជាតិពេញបរិបូណ៌

. បូរណភាពទឹកដីដ៏ត្រឹមត្រូវតាមច្បាប់ នៅក្នុងព្រំដែនដីគោក និងព្រំដែនសមុទ្ទ ដែលកម្ពុជាធ្លាប់មាន ក្នុងជំនាន់ឆ្នាំ ១៩៦៣ ដល់ ១៩៦៩

. ឯកភាពជាតិ ហើយមិនអនុញ្ញាតឱ្យមានការបែងចែក ឬការធ្វើអបគមន៍ណាមួយឡើយ ។

៤១

- ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញារក្សាទុកជានិច្ច ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគត នូវអព្យាក្រឹត្យភាព និងភាពមិនចូលបក្សសម្ព័ន្ធ សំរាប់កម្ពុជា ហើយមិនអនុញ្ញាតជាដាច់ខាតឱ្យជនណាក៏ដោយ ដែលចង់ជ្រៀតជ្រែកចូលក្នុងផ្ទៃក្នុងនៃកម្ពុជា ឬមកបង្គាប់បញ្ជាចំពោះគោលនយោបាយជាតិ និងអន្តរជាតិរបស់កម្ពុជាបានឡើយ ។ ទូលព្រះបង្គំយើងខ្ញុំមិនបំរើជាដាច់ខាត នូវផលប្រយោជន៍បរទេសហើយធ្វើឱ្យខូចខាតដល់ផលប្រយោជន៍ របស់ប្រជារាស្ត្រ ប្រជាជាតិ និងមាតុភូមិកម្ពុជាឡើយ ។

-ក្នុងការដោះស្រាយបញ្ហាទាំងឡាយ លើផ្ទៃរាបជាតិនិងអន្តរជាតិ ទូលព្រះបង្គំយើងខ្ញុំ នឹងបំបាត់ចោលទាំងស្រុង នូវអំពើហិង្សាគ្រប់បែបយ៉ាង ។

ប៉ុន្តែ ព្រះរាជាណាចក្រកម្ពុជា សូមរក្សាទុក នូវសិទ្ធិកាន់អាវុធតស៊ូប្រឆាំងនិងការរំលោភឈ្លានពានមកពីក្រៅ ដើម្បីការពារជាតិមាតុភូមិខ្លួន ។

- ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញាគោរពជានិច្ច ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគត នូវលទ្ធិប្រជាធិបតេយ្យ សេរីនិយម ដែលមានរបបសភា និងពហុបក្ស ព្រមទាំងមានការគោរពយ៉ាងម៉ឺងម៉ាត់ចំពោះសិទ្ធិមនុស្ស ដូចមានចែងក្នុងសេចក្តីប្រកាសជាសកល ស្តីអំពីសិទ្ធិមនុស្ស ។

- ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញាតស៊ូប្រឆាំង អំពើពុករលួយគ្រប់បែបយ៉ាង ប្រឆាំងអយុត្តិធម៌សង្គម ហើយតស៊ូដើម្បីផ្សះផ្សាជាតិ ដើម្បីឯកភាពជាតិ ដើម្បីសន្តិភាពសង្គម និងសន្តិភាពជាតិ ដើម្បីភាពសម្បូរសប្បាយ នៃប្រជារាស្ត្រកម្ពុជា និងដើម្បីភាពរុងរឿង ថ្កើងថ្កាន នៃមាតុភូមិកម្ពុជា ជាទីគោរពសក្ការៈ និងជាទីស្នេហានៃទូលព្រះបង្គំយើងខ្ញុំគ្រប់រូប ។

៤២

ឧបសម្ព័ន្ធទី ៦

# សច្ចាប្រណិធាន

ទូលព្រះបង្គំ
យើងខ្ញុំ
នាយករដ្ឋមន្ត្រី និងសមាជិករាជរដ្ឋាភិបាល
សូមធ្វើសច្ចាប្រណិធាន
នៅចំពោះព្រះភ័ក្ត្រព្រះមហាក្សត្រ ព្រះភ័ក្ត្រនៃសម្តេចព្រះសង្ឃរាជ
និងទេវតារក្សាស្វេតឆត្រ
ដូចតទៅ ៖

- ក្នុងពេលប្រតិបត្តិការ តាមមុខតំណែងខ្លួន និងក្នុងការបំពេញបេសកកម្ម ដែលប្រជារាស្ត្រកម្ពុជា បានប្រគល់ជូន ចំពោះទូលព្រះបង្គំយើងខ្ញុំគ្រប់ៗរូប ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញាគោរពរដ្ឋធម្មនុញ្ញ បំពេញជានិច្ច ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគត នូវផលប្រយោជន៍ របស់ប្រជារាស្ត្រ ប្រជាជាតិ និងមាតុភូមិកម្ពុជា ។ ទូលព្រះបង្គំយើងខ្ញុំ សូមសច្ចាថា មិនកេងប្រវ័ញ្ច នូវផលប្រយោជន៍ជាតិ សម្រាប់ផ្ទាល់ខ្លួន ឬសម្រាប់គ្រួសារ ឬសម្រាប់បក្សពួក ឬសំរាប់ភាគីរៀងៗខ្លួនឡើយ ។

- ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញាប្តូរផ្តាច់ហ៊ានបូជាជីវិត ដើម្បីការពារជានិច្ច ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគត នូវ :

. ឯករាជ្យភាពទាំងស្រុង នៃមាតុភូមិកម្ពុជា

. អធិបតេយ្យភាពជាតិពេញបរិបូណ៌

. បូរណភាពទឹកដីដ៏ត្រឹមត្រូវតាមច្បាប់ នៅក្នុងព្រំដែនដីគោក និងព្រំដែនសមុទ្ទ ដែលកម្ពុជាធ្លាប់មាន ក្នុងជំនាន់ឆ្នាំ ១៩៦៣ ដល់ ១៩៦៩

. ឯកភាពជាតិ ហើយមិនអនុញ្ញាតឱ្យមានការបែងចែក ឬការធ្វើអបគមន៍ណាមួយឡើយ ។

៤៣

- ទូលព្រះបង្គំយើងខ្ញុំ សូមប្ដេជ្ញារក្សាទុកជានិច្ច ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគត នូវអព្យាក្រឹត្យភាព និងភាពមិនចូលបក្សសម្ព័ន្ធ សំរាប់កម្ពុជា ហើយមិនអនុញ្ញាតជាដាច់ខាតឱ្យជនណាក៏ដោយ ដែលចង់ជ្រៀតជ្រែកចូលក្នុងផ្ទៃក្នុងនៃកម្ពុជា ឬមកបង្គាប់បញ្ជាចំពោះគោលនយោបាយជាតិ និងអន្តរជាតិរបស់កម្ពុជាបានឡើយ ។ ទូលព្រះបង្គំយើងខ្ញុំ មិនបំរើជាដាច់ខាត នូវផលប្រយោជន៍បរទេសហើយធ្វើឱ្យខូចខាតដល់ផលប្រយោជន៍ របស់ប្រជារាស្ត្រ ប្រជាជាតិ និងមាតុភូមិកម្ពុជាឡើយ ។

-ក្នុងការដោះស្រាយបញ្ហាទាំងឡាយ លើផ្ទៃរាបជាតិ និងអន្តរជាតិ ទូលព្រះបង្គំយើងខ្ញុំ នឹងបំបាត់ចោលទាំងស្រុង នូវអំពើហឹង្សាគ្រប់បែបយ៉ាង ។

ប៉ុន្តែ ព្រះរាជាណាចក្រកម្ពុជា សូមរក្សាទុក នូវសិទ្ធិកាន់អាវុធតស៊ូប្រឆាំងនឹងការរំលោភឈ្លានពានមកពីក្រៅ ដើម្បីការពារជាតិមាតុភូមិខ្លួន ។

- ទូលព្រះបង្គំយើងខ្ញុំ សូមប្ដេជ្ញាគោរពជានិច្ច ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគត នូវលទ្ធិប្រជាធិបតេយ្យ សេរីនិយម ដែលមានរបបសភា និងពហុបក្ស ព្រមទាំងមានការគោរពយ៉ាងម៉ឺងម៉ាត់ចំពោះសិទ្ធិមនុស្ស ដូចមានចែងក្នុងសេចក្ដីប្រកាសជាសកល ស្ដីអំពីសិទ្ធិមនុស្ស ។

- ទូលព្រះបង្គំយើងខ្ញុំ សូមប្ដេជ្ញាតស៊ូប្រឆាំង អំពើពុករលួយគ្រប់បែបយ៉ាង ប្រឆាំងអយុត្តិធម៌សង្គម ហើយតស៊ូដើម្បីផ្សះផ្សាជាតិ ដើម្បីឯកភាពជាតិ ដើម្បីសន្តិភាពសង្គម និង សន្តិភាពជាតិ ដើម្បីភាពសម្បូរសប្បាយ នៃប្រជារាស្ត្រកម្ពុជា និងដើម្បីភាពរុងរឿង ថ្កើងថ្កាន នៃមាតុភូមិកម្ពុជា ជាទីគោរពសក្ការៈ និងជាទីស្នេហានៃទូលព្រះបង្គំយើងខ្ញុំគ្រប់រូប ។

## គណៈកម្មការអចិន្ត្រៃយ៍រៀបរៀងរដ្ឋធម្មនុញ្ញ
## បានអនុម័តដោយសភាធម្មនុញ្ញនាសម័យប្រជុំពេញអង្គលើកទី ១
## ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៩៣

១_ ឯកឧត្តមសម្តេចប្រធានសភាធម្មនុញ្ញឬឯកឧត្តមអនុប្រធាន
សភាធម្មនុញ្ញ «ករណីសម្តេចប្រធានអវត្តមាន» ជាប្រធាន

| | | |
|---|---|---|
| ២_ | ឯកឧត្តម ចែម ស្ងួន | ជាអនុប្រធាន |
| ៣_ | ឯកឧត្តមបណ្ឌិត តាវ សេងហួរ | ជាអ្នករាយការណ៍ |
| ៤_ | ឯកឧត្តម កាន់ ម៉ន | ជាសមាជិក |
| ៥_ | ឯកឧត្តម គាត ឈន់ | ជាសមាជិក |
| ៦_ | ឯកឧត្តម ឈួរ លាងហួត | ជាសមាជិក |
| ៧_ | ឯកឧត្តម ថោ ប៉េងលាត | ជាសមាជិក |
| ៨_ | ឯកឧត្តម សម រង្ស៊ី | ជាសមាជិក |
| ៩_ | អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ សិរីរត្ន | ជាសមាជិក |
| ១០_ | ឯកឧត្តម ស៊ីន សុំបឿ | ជាសមាជិក |
| ១១_ | ឯកឧត្តម សោម ចាន់បុត្រ | ជាសមាជិក |
| ១២_ | ឯកឧត្តម អ៊ិន នឹង | ជាសមាជិក |
| ១៣_ | ឯកឧត្តម ឡូយ ស៊ីមឈាង | ជាសមាជិក |
| ១៤_ | ឯកឧត្តម ជាម យៀប | ជាសមាជិកបំរុង |
| ១៥_ | ឯកឧត្តម ប៉ុល ហំម | ជាសមាជិកបំរុង |
| ១៦_ | ឯកឧត្តម ពូ សុធីរៈ | ជាសមាជិកបំរុង |
| ១៧_ | ឯកឧត្តម សរ សារអាត | ជាសមាជិកបំរុង |

| | | |
|---|---|---|
| ១៨_ | ឯកឧត្តម អ៊ឹង គៀត | ជាសមាជិកបំរុង |
| ១៩_ | ឯកឧត្តម អ៊ុក វ៉ាប៊ុន | ជាសមាជិកបំរុង |
| ២០_ | ឯកឧត្តម អ៊ុង ផន | ជាសមាជិកបំរុង |
| ២១_ | ឯកឧត្តម ឯក សំអុល | ជាសមាជិកបំរុង |
| ២២_ | ឯកឧត្តម សាយ បូរី | ជាអ្នកជំនាញការ |
| ២៣_ | ឯកឧត្តម ចាន់ សុខ | ជាអ្នកជំនាញការ |
| ២៤_ | ឯកឧត្តម ឈន សៀម | ជាអ្នកជំនាញការ |
| ២៥_ | ឯកឧត្តម ហេង វង្សប៊ុនឆាត | ជាអ្នកជំនាញការ |
| ២៦_ | ឯកឧត្តម ខៀវ វ៉ាដា | ជាអ្នកជំនាញការ |

<u>កំណត់សំគាល់</u> : * យោងជំពូក ៧ ប្រការ១៨ ស្តីពីគណៈកម្មការ និង ប្រធានគណៈកម្មការសភាធម្មនុញ្ញ

៨៦

# ឧបសម្ព័ន្ធ៣
# ច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ

ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤

# ព្រះរាជក្រម

នស/ រកម / ០៧០៤ / ០០១

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សម័យប្រជុំពេញអង្គលើកទី ១ នីតិកាលទី ៣ នៃរដ្ឋសភា នាថ្ងៃទី ៨ ខែ កក្កដា ឆ្នាំ ២០០៤
- បានទ្រង់យល់សម័យប្រជុំពេញអង្គលើកទី ៩ នីតិកាលទី ១ នៃព្រឹទ្ធសភា នាថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០៤
- យោងតាមសំណើ ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ២០០៤ របស់ព្រឹទ្ធសមាជិករដ្ឋសភា នីតិកាលទី៣

## ប្រកាសឱ្យប្រើ

ច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០៤ នាសម័យប្រជុំពេញអង្គលើកទី ១ នីតិកាលទី ៣ ហើយដែលព្រឹទ្ធសភាបានឱ្យយោបល់យល់ព្រម កាលពីថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០៤ នាសម័យប្រជុំពេញអង្គលើកទី៩ នីតិកាលទី១ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅ ៖

# ច្បាប់ធម្មនុញ្ញបន្ថែម
# សំដៅ
# ធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ

**មាត្រា ១.-**

ច្បាប់ធម្មនុញ្ញនេះ មានគោលដៅធានាក្នុងគ្រប់កាលៈទេសៈនូវដំណើរការល្អប្រសើរនៃស្ថាប័នជាតិ ដោយគោរពទៅតាមគោលការណ៍ជាមូលដ្ឋាន នៃលទ្ធិប្រជាធិបតេយ្យសេរី-ពហុបក្ស សមស្របតាមតំរូវការនៃភាពចាំបាច់ ។

**មាត្រា ២.-**

នៅដើមនីតិកាលថ្មីនីមួយៗ រដ្ឋសភា ក្រោមអធិបតីភាពព្រឹទ្ធសមាជិករដ្ឋសភា មុននឹងផ្ដើមការងាររបស់ខ្លួន និង ក្រោយពេលសំរេចអំពីសុពលភាពនៃអាណត្តិរបស់សមាជិកម្នាក់ៗ អាចចាប់ផ្ដើមអនុម័ត អត្ថបទដែលមានចរិក ជារដ្ឋធម្មនុញ្ញ ឬ ច្បាប់ដើម្បីអនុវត្តបាននូវគោលដៅដូចមានចែងក្នុងមាត្រា ១ ។

អត្ថបទទាំងនេះ ក្រោយពីបានត្រូវទទួលការបោះឆ្នោតអនុម័តដោយរដ្ឋសភារួចហើយ ត្រូវតែបានទទួលជាបន្ទាន់នូវចំណាត់ការដោយរួសរាន់ពីសំណាក់ព្រឹទ្ធសមាជិករដ្ឋសភា តាមនីតិវិធីកំណត់សំរាប់ អត្ថបទទាំងនោះ រហូតដល់ពេលដែលត្រូវបានប្រកាសអោយចូលជាធរមាន ។

**មាត្រា ៣.-**

ក្នុងករណីដែលឃើញថានីតិវិធីនៃមាត្រា ៨២ និង ១១៩ថ្មី នៃរដ្ឋធម្មនុញ្ញ មិនអាចសំរេចបាន រដ្ឋសភា តាមសំណើរបស់គណបក្សដែលមានអាសនៈច្រើនជាងគេនៅក្នុងរដ្ឋសភា អាចដំណើរការការបោះឆ្នោតជាកញ្ចប់ ដើម្បី ជ្រើសតាំងប្រធាន អនុប្រធានរដ្ឋសភា ក៏ដូចជា ប្រធាន និង អនុប្រធានគណៈ កម្មការក្នុងពេលជាមួយគ្នា និង ការផ្ដល់សេចក្ដីទុកចិត្តចំពោះ រាជរដ្ឋាភិបាល ។

**មាត្រា ៤.-**

ការរៀបចំបញ្ជីរាយនាមបេក្ខជន ដើម្បីបោះឆ្នោតជ្រើសតាំង និង ផ្តល់សេចក្តីទុកចិត្ត ត្រូវអនុវត្តដូចតទៅ :

- បញ្ជីរាយនាមបេក្ខជនប្រធាន អនុប្រធាននៃរដ្ឋសភា ក៏ដូចជា ប្រធាន និង អនុប្រធានគណៈ កម្មការ ជំនាញទាំងអស់ នៃរដ្ឋសភា ត្រូវរៀបចំ និង ស្នើដោយគណបក្សនយោបាយដែលព្រមព្រៀងគ្នា ដើម្បីបង្កើតរាជរដ្ឋាភិបាលចំរុះ ហើយត្រូវផ្ញើជូនព្រឹទ្ធសមាជិករដ្ឋសភា ។

- តាមសេចក្តីស្នើពីគណបក្សនយោបាយ ដែលមានចំនួនអាសនៈច្រើនជាងគេនៅក្នុងរដ្ឋសភា តាមរយៈព្រឹទ្ធសមាជិករដ្ឋសភា ព្រះមហាក្សត្រទ្រង់ចាត់តាំងវរជនមួយរូបក្នុងចំណោមតំណាងរាស្ត្រ នៃគណបក្សនយោបាយដែលឈ្នះឆ្នោតអោយបង្កើតរាជរដ្ឋាភិបាល ។

វរជនដែលត្រូវបានចាត់តាំងនេះ ត្រូវរៀបចំផ្គូរផ្គងតំណែងផ្សេងៗក្នុងរាជរដ្ឋាភិបាល រួចផ្ញើបញ្ជី រាយនាម សមាជិកទាំងអស់នៃរាជរដ្ឋាភិបាលជូនព្រឹទ្ធសមាជិករដ្ឋសភា ។

- ព្រឹទ្ធសមាជិករដ្ឋសភា ត្រូវរៀបចំបញ្ជីរាយនាមជាកញ្ចប់មួយនូវបេក្ខជន ប្រធាន អនុប្រធាន នៃរដ្ឋសភា ក៏ដូចជាប្រធាន និង អនុប្រធានគណកម្មការ ជំនាញទាំងអស់នៃរដ្ឋសភា ព្រមទាំងបេក្ខជន នាយករដ្ឋមន្ត្រី និង សមាជិកទាំងអស់នៃរាជរដ្ឋាភិបាល ដើម្បីដាក់ជូនរដ្ឋសភាបោះឆ្នោត ។

**មាត្រា ៥.-**

នៅក្នុងដំណើរការនៃការបោះឆ្នោតជាកញ្ចប់ មិនអាចជជែកពិភាក្សាអ្វីឡើយ ហើយក៏មិនអាចមានការពន្យល់អំពីការបោះឆ្នោតនេះ ក្រោយការប្រកាសលទ្ធផល នៃការបោះឆ្នោតជាកញ្ចប់នេះដែរ ។

សមាជិករដ្ឋសភា ត្រូវធ្វើការបោះឆ្នោតដោយបញ្ជាក់ថាព្រម ឬ មិនព្រមចំពោះបញ្ជីរាយនាមជាកញ្ចប់មួយ ដែលព្រឹទ្ធសមាជិករដ្ឋសភាបានដាក់ជូន ។ ការបោះឆ្នោតនេះត្រូវធ្វើឡើងដោយវិធីលើកដៃ ។

៣

មាត្រា ៦.-

ការបោះឆ្នោតជាកញ្ចប់ខាងលើនេះ ត្រូវយកតាមមតិភាគច្រើន ពីរភាគបី នៃសមាជិករដ្ឋសភាទាំងមូល ។

ក្នុងករណី ការបោះឆ្នោតជុំទីមួយមិនបានសំរេច នីតិវិធីដដែលនេះ នឹងត្រូវអនុវត្តចំពោះការបោះឆ្នោតជុំក្រោយៗទៀត ។

មាត្រា ៧.-

ច្បាប់ធម្មនុញ្ញបន្ថែមនេះ ត្រូវបានប្រកាសជាការប្រញាប់ និង យកមកអនុវត្តចាប់តាំងពីដើម នីតិកាលបច្ចុប្បន្ននេះទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០៤
តាមព្រះបរមនាម និងតាមព្រះរាជបញ្ជាដ៏ខ្ពង់ខ្ពស់

នស.០៤.០៧.១១៧

ប្រមុខរដ្ឋស្ដីទី
ហត្ថលេខា និងព្រះរាជលញ្ឆករ
ជា ស៊ីម

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្ថលេខាព្រះមហាក្សត្រ
ព្រឹទ្ធសមាជិក និង ជាប្រធានអន្តរប្រជុំរដ្ឋសភា
ហត្ថលេខា
ជា ស៊ីម

លេខ: ៩៧០ ច.ល
ចម្លងចេញពីច្បាប់ដើម
រាជធានីភ្នំពេញ,ថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ២០០៤
អគ្គលេខាធិការរាជរដ្ឋាភិបាល
សាវ៉ាង តាន់

៤

**មាត្រា ៦.-**

ការបោះឆ្នោតជាកញ្ចប់ខាងលើនេះ ត្រូវយកតាមមតិភាគច្រើន ពីរភាគបី នៃសមាជិករដ្ឋសភាទាំងមូល ។

ក្នុងករណី ការបោះឆ្នោតជុំទីមួយមិនបានសំរេច នីតិវិធីដដែលនេះ នឹងត្រូវអនុវត្តចំពោះការបោះឆ្នោតជុំក្រោយៗទៀត ។

**មាត្រា ៧.-**

ច្បាប់ធម្មនុញ្ញបន្ថែមនេះ ត្រូវបានប្រកាសជាការប្រញាប់ និង យកមកអនុវត្តចាប់តាំងពីដើម នីតិកាល បច្ចុប្បន្ននេះទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០៤

ឆ្លងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

នស.០៤.០៧.១១៧

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ញឹក ប៊ុនឆៃ

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**ព្រឹទ្ធសមាជិក និង ជាប្រធានអន្តរប្រជុំរដ្ឋសភា**

**ហត្ថលេខា**

**ជា ស៊ុម**

លេខ: ៩០ ច.ល

ចម្លងចែកជូន

រាជធានីភ្នំពេញ.ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ២០០៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

សុខ តាន់

៤

# ឧបសម្ព័ន្ធ៤

# រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

( គិតត្រឹមថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៦ )

# រដ្ឋធម្មនុញ្ញ

# ជំពូកទី១
# អំពី
# អធិបតេយ្យ

**មាត្រា ១.-**

ប្រទេសកម្ពុជា ជាព្រះរាជាណាចក្រដែលព្រះមហាក្សត្រទ្រង់ប្រតិបត្តិ តាមរដ្ឋធម្មនុញ្ញនិងតាមលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស។

ព្រះរាជាណាចក្រកម្ពុជា ជារដ្ឋឯករាជ្យ អធិបតេយ្យ សន្តិភាព អព្យាក្រឹត្យ អចិន្ត្រៃយ៍ មិនចូលបក្សសម្ព័ន្ធ។

**មាត្រា ២.-**

បូរណភាពទឹកដីរបស់ព្រះរាជាណាចក្រកម្ពុជា មិនអាចរំលោភបានដាច់ខាតក្នុងព្រំដែនរបស់ខ្លួនដែលមានកំណត់ក្នុងផែនទី ខ្នាត១/១០០.០០០ ធ្វើនៅចន្លោះឆ្នាំ ១៩៣៣-១៩៥៣ ហើយដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិនៅចន្លោះ ឆ្នាំ ១៩៦៣ - ១៩៦៩។

**មាត្រា ៣.-**

ព្រះរាជាណាចក្រកម្ពុជា ជារដ្ឋដែលមិនអាចបំបែកបាន។

**មាត្រា ៤.-**

បាវចនានៃព្រះរាជាណាចក្រកម្ពុជា គឺ : ជាតិ សាសនា ព្រះមហាក្សត្រ។

**មាត្រា ៥.-**

ភាសា និងអក្សរ ដែលប្រើជាផ្លូវការ គឺភាសា និងអក្សរខ្មែរ។

**មាត្រា ៦.-**

ភ្នំពេញជារាជធានីនៃព្រះរាជាណាចក្រកម្ពុជា។

ទង់ជាតិ ភ្លេងជាតិ និងសញ្ញាជាតិ មានកំណត់នៅក្នុងឧបសម្ព័ន្ធ ១, ២ និង ៣។

# ជំពូកទី ២
# អំពី
# ព្រះមហាក្សត្រ

**មាត្រា ៧.-**

ព្រះមហាក្សត្រកម្ពុជាទ្រង់គ្រងរាជសម្បត្តិ ប៉ុន្តែទ្រង់មិនកាន់អំណាចឡើយ។

ព្រះមហាក្សត្រទ្រង់ជាព្រះប្រមុខរដ្ឋមួយជីវិត។

អង្គព្រះមហាក្សត្រ មិនអាចនរណារំលោភបំពានបានឡើយ។

**មាត្រា ៨.-**

ព្រះមហាក្សត្រព្រះអង្គទ្រង់ជានិមិត្តរូបនៃឯកភាពជាតិ និងនិរន្តរភាពជាតិ។

ព្រះមហាក្សត្រទ្រង់ជាអ្នកធានាឯករាជ្យជាតិ អធិបតេយ្យនិងបូរណភាព ទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ជាអ្នកធានាការគោរពសិទ្ធិនិងសេរីភាពរបស់ប្រជាពលរដ្ឋ និងការគោរពសន្ធិសញ្ញាអន្តរជាតិ។

**មាត្រា ៩.-**

ព្រះមហាក្សត្រទ្រង់មានតួនាទីខ្ពង់ខ្ពស់ជាអាជ្ញាកណ្តាល ដើម្បីធានាការប្រព្រឹត្តទៅនៃអំណាចសាធារណៈឲ្យមានភាពទៀងទាត់។

**មាត្រា ១០.-**

របបរាជានិយមកម្ពុជា ជារបបជ្រើសតាំង។

ព្រះមហាក្សត្រទ្រង់ឥតមានព្រះរាជអំណាចចាត់តាំងព្រះរជ្ជទាយាទសម្រាប់គ្រងរាជសម្បត្តិឡើយ។

**មាត្រា ១១.- ថ្មី**

ក្នុងករណីដែលព្រះមហាក្សត្រពុំអាចបំពេញព្រះរាជភារៈ ជាព្រះប្រមុខរដ្ឋបានដូចធម្មតាដោយព្រះអង្គទ្រង់ប្រឈួនជាទម្ងន់ មានការបញ្ជាក់ដោយក្រុមគ្រូពេទ្យជំនាញជ្រើសរើសដោយប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រី នោះប្រធានព្រឹទ្ធសភាបំពេញភារកិច្ចប្រមុខរដ្ឋជំនួស ព្រះអង្គក្នុងឋានៈជាព្រះរាជានុសិទ្ធិ។

ក្នុងករណីដែលប្រធានព្រឹទ្ធសភា ពុំមានលទ្ធភាពបំពេញភារកិច្ចជាប្រមុខរដ្ឋជំនួសព្រះមហាក្សត្រក្នុងឋានៈជាព្រះរាជានុសិទ្ធិ ពេលព្រះអង្គទ្រង់ប្រឈួនជាទម្ងន់ ដូចមានចែងក្នុងវាក្យខ័ណ្ឌខាងលើ ប្រធានរដ្ឋសភាជាអ្នកបំពេញភារកិច្ចនេះ។

តំណែងជាប្រមុខរដ្ឋជំនួសព្រះមហាក្សត្រក្នុងឋានៈជាព្រះរាជានុសិទ្ធិនេះ អាចនឹងដូរឥស្សរជនផ្សេងទៀត ក្នុងករណីដូចដែលបានចែងក្នុងវាក្យខ័ណ្ឌ ខាងលើ តាមឋានានុក្រមដូចតទៅ :

ក-អនុប្រធានទី ១ ព្រឹទ្ធសភា

ខ-អនុប្រធានទី ១ រដ្ឋសភា

គ-អនុប្រធានទី ២ ព្រឹទ្ធសភា

ឃ-អនុប្រធានទី ២ រដ្ឋសភា

**មាត្រា ១២.- ថ្មី**

នៅពេលព្រះមហាក្សត្រទ្រង់ចូលទីវង្គត ប្រធានព្រឹទ្ធសភាទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទីក្នុងឋានៈជាព្រះរាជានុសិទ្ធិនៃព្រះរាជាណាចក្រកម្ពុជា។

ក្នុងករណីដែលប្រធានព្រឹទ្ធសភាពុំមានលទ្ធភាពបំពេញភារកិច្ចជាប្រមុខរដ្ឋស្តីទីជំនួសព្រះមហាក្សត្រក្នុងពេលព្រះអង្គចូលទីវង្គត ការទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទីក្នុងឋានៈជាព្រះរាជានុសិទ្ធិត្រូវអនុវត្តតាមវាក្យខ័ណ្ឌ ទី ២ និងទី ៣ នៃមាត្រា ១១ថ្មី។

**មាត្រា ១៣.- ថ្មី**

ក្នុងរយៈវេលា ៧ថ្ងៃយ៉ាងយូរ ព្រះមហាក្សត្រថ្មីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានជ្រើសរើសដោយក្រុមប្រឹក្សារាជសម្បត្តិ។

សមាសភាពនៃក្រុមប្រឹក្សារាជសម្បត្តិមាន :

-ប្រធានព្រឹទ្ធសភា

-ប្រធានរដ្ឋសភា

-នាយករដ្ឋមន្ត្រី

-សម្ដេចព្រះសង្ឃរាជ គណៈមហានិកាយ និងគណៈធម្មយុត្តិកនិកាយ

-អនុប្រធានទី ១ និងអនុប្រធានទី ២ ព្រឹទ្ធសភា

-អនុប្រធានទី ១ និងអនុប្រធានទី ២ រដ្ឋសភា

ការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សារាជសម្បត្តិនឹងមានកំណត់ក្នុងច្បាប់មួយ។

**មាត្រា ១៤.-**

ត្រូវបានជ្រើសរើសជាព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា សមាជិកនៃព្រះរាជវង្សានុវង្សខ្មែរ ដែលមានព្រះជន្មាយុយ៉ាងតិច៣០ព្រះវស្សា ហើយដែលជាព្រះរាជបច្ឆាញាតិនៃព្រះមហាក្សត្រ **អង្គឌួង** ឬព្រះមហាក្សត្រ **នរោត្តម** ឬក៏ព្រះមហាក្សត្រ **ស៊ីសុវត្ថិ**។

មុនចូលគ្រងរាជសម្បត្តិ ព្រះមហាក្សត្រទ្រង់ថ្លែងសច្ចាប្រណិធាន ដូចមានចែងក្នុងឧបសម្ព័ន្ធទី៤។

**មាត្រា ១៥.-**

ព្រះជាយានៃព្រះមហាក្សត្រមានព្រះរាជឋានៈជាព្រះមហេសីនៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ១៦.-**

ព្រះមហេសីនៃព្រះរាជាណាចក្រកម្ពុជា ពុំមានព្រះរាជសិទ្ធិធ្វើនយោបាយ ទទួលតួនាទីជាអ្នកដឹកនាំរដ្ឋ ឬជាអ្នកដឹកនាំរាជរដ្ឋាភិបាល ឬទទួលតួនាទីរដ្ឋបាល ឬនយោបាយឡើយ។

ព្រះមហេសីនៃព្រះរាជាណាចក្រកម្ពុជាទុកព្រះរាជកាយពលបំពេញព្រះរាជភារៈបំរើប្រយោជន៍សង្គម មនុស្សធម៌ សាសនា និងជួយព្រះមហាក្សត្រក្នុងព្រះរាជកាតព្វកិច្ច ផ្នែកពិធីការ និងការទូត។

**មាត្រា ១៧.-**

ប្រការដែលព្រះមហាក្សត្រទ្រង់គ្រងរាជសម្បត្តិប៉ុន្តែទ្រង់មិនកាន់អំណាចឡើយ ហើយដែលមានចែងក្នុងវាក្យខ័ណ្ឌទីមួយនៃមាត្រា ៧ នៃរដ្ឋធម្មនុញ្ញនេះ មិនអាចសុំកែប្រែបានជាដាច់ខាត។

**មាត្រា ១៨.- ថ្មី**

ព្រះមហាក្សត្រព្រះអង្គទ្រង់ទាក់ទងជាមួយព្រឹទ្ធសភានិងរដ្ឋសភាដោយព្រះរាជសារ។

ព្រះរាជសារនេះ ព្រឹទ្ធសភានិងរដ្ឋសភាមិនអាចយកទៅជជែកពិភាក្សាឡើយ។

**មាត្រា ១៩.- ថ្មី(ពីរ)**

ព្រះមហាក្សត្រទ្រង់តែងតាំងនាយករដ្ឋមន្ត្រី និងទ្រង់តែងតាំងគណៈរដ្ឋមន្ត្រី តាមបែបបទដែលមានចែងក្នុងមាត្រា១១៩ ថ្មី(ពីរ)។

**មាត្រា ២០.-**

ព្រះមហាក្សត្រទ្រង់ទទួលសវនាការជាផ្លូវការពីរដងក្នុងមួយខែ ឲ្យនាយករដ្ឋមន្ត្រី និងគណៈរដ្ឋមន្ត្រីចូលគាល់រាយការណ៍ទូលថ្វាយទ្រង់ជ្រាប អំពីសភាពការណ៍នៃប្រទេសជាតិ។

**មាត្រា ២១.-**

តាមសេចក្តីស្នើរបស់គណៈរដ្ឋមន្ត្រី ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រឹត្យតែងតាំង ផ្លាស់ប្តូរ ឬបញ្ចប់ភារៈកិច្ចមន្ត្រីជាន់ខ្ពស់ ស៊ីវិលនិងយោធា ឯកអគ្គរាជទូត និងប្រេសិតវិសាមញ្ញនិងពេញសមត្ថភាព។

តាមសេចក្តីស្នើរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រឹត្យតែងតាំង ផ្លាស់ប្តូរ ឬដកចៅក្រមផ្នែកយុត្តាធិការ។

**មាត្រា ២២.- ថ្មី**

នៅពេលប្រជាជាតិប្រឈមមុខនឹងគ្រោះថ្នាក់ ព្រះមហាក្សត្រទ្រង់ប្រកាសប្រទានដំណឹងជាសាធារណៈ ដាក់ប្រទេសជាតិស្ថិតនៅក្នុងភាពអាសន្ន ក្រោយពីបានមតិឯកភាពពីនាយករដ្ឋមន្ត្រីប្រធានរដ្ឋសភានិងប្រធានព្រឹទ្ធសភា។

**មាត្រា ២៣.-**

ព្រះមហាក្សត្រទ្រង់ជាមេបញ្ជាការកំពូលនៃកងយោធពលខេមរភូមិន្ទ។ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ ត្រូវបានតែងតាំងឡើងដើម្បីបញ្ជាកងយោធពលខេមរភូមិន្ទនេះ។

**មាត្រា ២៤.- ថ្មី**

ព្រះមហាក្សត្រទ្រង់គង់ជាព្រះអធិបតីនៃឧត្តមក្រុមប្រឹក្សាការពារជាតិ ដែលនឹងត្រូវបង្កើតឡើងដោយច្បាប់មួយ។

ព្រះមហាក្សត្រទ្រង់ប្រកាសសង្គ្រាម ក្រោយការអនុម័តរបស់រដ្ឋសភា និងព្រឹទ្ធសភា។

**មាត្រា ២៥.-**

ព្រះមហាក្សត្រទ្រង់ទទួលសារតាំងឯកអគ្គរដ្ឋទូត ឬប្រេសិតវិសាមញ្ញ និងពេញសមត្ថភាពនៃប្រទេសក្រៅ មកប្រចាំព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ២៦.- ថ្មី**

ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាលើសន្ធិសញ្ញានិងអនុសញ្ញាអន្តរជាតិ ហើយទ្រង់ប្រទានសច្ចាប័នលើសន្ធិសញ្ញានិងអនុសញ្ញាទាំងនេះ ក្រោយបានទទួលការអនុម័តយល់ព្រមពីរដ្ឋសភានិងព្រឹទ្ធសភា។

**មាត្រា ២៧.-**

ព្រះមហាក្សត្រទ្រង់មានព្រះរាជសិទ្ធិបន្ធូរបន្ថយទោស និងលើកលែងទោស។

**មាត្រា ២៨.- ថ្មី**

ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្ថលេខាលើព្រះរាជក្រមប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញ ច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់រួចហើយ និងទ្រង់ឡាយព្រះហស្ថលេខាលើព្រះរាជក្រឹត្យ តាមសេចក្តីស្នើសុំពីគណៈរដ្ឋមន្ត្រី។

ក្នុងពេលដែលព្រះមហាក្សត្រប្រឈួន ហើយត្រូវព្យាបាលព្រះរោគនៅបរទេស ក្នុងពេលនោះព្រះមហាក្សត្រមានសិទ្ធិផ្ទេរអំណាចឡាយព្រះហស្ថលេខានៅលើព្រះរាជក្រម ឬព្រះរាជក្រឹត្យខាងលើនេះទៅប្រមុខរដ្ឋស្តីទីចុះហត្ថលេខាជំនួសដោយព្រះរាជសារប្រគល់សិទ្ធិ។

**មាត្រា ២៩.- ថ្មី**

ព្រះមហាក្សត្រទ្រង់បង្កើតនិងប្រទានគ្រឿងឥស្សរិយយសជាតិ។

ព្រះមហាក្សត្រទ្រង់សំរេចប្រទានឋានន្តរសក្តិ ឋានៈ យោធានិងស៊ីវិលតាមច្បាប់កំណត់។

**មាត្រា ៣០.- ថ្មី**

ក្នុងរយៈពេលព្រះមហាក្សត្រទ្រង់អវត្តមាន ប្រធានព្រឹទ្ធសភាទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទី។

ក្នុងករណីដែលប្រធានព្រឹទ្ធសភា ពុំមានលទ្ធភាពបំពេញភារកិច្ចជាជាប្រមុខរដ្ឋស្តីទីជំនួសព្រះមហាក្សត្រ ពេលព្រះអង្គទ្រង់អវត្តមាន ការទទួលក្នុងភារកិច្ចជាប្រមុខរដ្ឋស្តីទីត្រូវអនុវត្តតាមវាក្យខ័ណ្ឌទី ២ និងទី ៣ នៃមាត្រា ១១ថ្មី។

## ជំពូកទី ៣
## អំពី
## សិទ្ធិ និងករណីយកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ

**មាត្រា ៣១.-**

ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ។

ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ។ ការប្រើសិទ្ធិ សេរីភាពផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ មិនត្រូវឲ្យប៉ះពាល់ដល់សិទ្ធិ សេរីភាពអ្នកដទៃឡើយ។ ការប្រើសិទ្ធិ សេរីភាពនេះ ត្រូវប្រព្រឹត្តតាមលក្ខខ័ណ្ឌកំណត់ក្នុងច្បាប់។

**មាត្រា ៣២.-**

ជនគ្រប់រូប មានសិទ្ធិរស់រានមានជីវិត មានសេរីភាពនិងមានសន្តិសុខ ផ្ទាល់ខ្លួន។

ទោសប្រហារជីវិតមិនត្រូវឲ្យមានឡើយ។

**មាត្រា ៣៣.- ថ្មី**

ប្រជាពលរដ្ឋខ្មែរ មិនអាចត្រូវបាននិរទេស ឬចាប់បញ្ជូនខ្លួនទៅឱ្យប្រទេសក្រៅណាមួយឡើយ លើកលែងតែមានកិច្ចព្រមព្រៀងជាមួយគ្នាទៅវិញទៅមក។

ប្រជាពលរដ្ឋខ្មែរដែលកំពុងរស់នៅឯបរទេសត្រូវបានរដ្ឋគាំពារ។

ការទទួលសញ្ញាតិខ្មែរ និងការបាត់សញ្ញាតិខ្មែរដោយរួមទាំងការដកសញ្ញាតិខ្មែរត្រូវកំណត់ក្នុងច្បាប់។

**មាត្រា ៣៤.- ថ្មី(មួយ)**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិបោះឆ្នោត និងអាចឈរឈ្មោះឱ្យគេបោះឆ្នោត។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ១៨ ឆ្នាំ មានសិទ្ធិ បោះឆ្នោត។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ២៥ ឆ្នាំ អាចឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសតាំងជាតំណាងរាស្ត្រ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ៤០ ឆ្នាំ អាចឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសតាំងជាសមាជិកព្រឹទ្ធសភា។

បទប្បញ្ញត្តិដកសិទ្ធិបោះឆ្នោត និងសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតត្រូវកំណត់ក្នុងច្បាប់។

**មាត្រា ៣៥.-**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាព នយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ប្រទេសជាតិ។

សេចក្តីស្នើទាំងឡាយរបស់ប្រជាពលរដ្ឋ ត្រូវបានទទួលការពិនិត្យ និងដោះស្រាយយ៉ាងហ្មត់ចត់ពីអង្គការរដ្ឋ។

**មាត្រា ៣៦.-**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិជ្រើសរើសមុខរបរ សមស្របតាមសមត្ថភាពរបស់ខ្លួនតាមសេចក្តីត្រូវការរបស់សង្គម។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិទទួលប្រាក់បំណាច់ស្មើគ្នាចំពោះការងារដូចគ្នា។

ការងារមេផ្ទះមានតម្លៃស្មើគ្នា នឹងកំរៃដែលបានមកពីការងារធ្វើនៅក្រៅផ្ទះ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិទទួលការធានារ៉ាប់រងសង្គម និងអត្ថប្រយោជន៍ខាងសង្គមកិច្ច ដែលមានចែងក្នុងច្បាប់។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិបង្កើតសហជីព និងចូលជាសមាជិកសហជីពនេះ។

ការរៀបចំនិងការប្រព្រឹត្តទៅនៃសហជីព នឹងមានកំណត់ក្នុងច្បាប់។

**មាត្រា ៣៧.-**

សិទ្ធិធ្វើកូដកម្ម និងធ្វើបាតុកម្មដោយសន្តិវិធី ត្រូវយកមកអនុវត្តនៅក្នុងក្របខ័ណ្ឌនៃច្បាប់។

**មាត្រា ៣៨.-**

ច្បាប់ការពារមិនឲ្យមានការរំលោភបំពានលើរូបរាងកាយបុគ្គលណាមួយឡើយ។

ច្បាប់ការពារជីវិត កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ។

ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនជនណាមួយនឹងអាចធ្វើទៅកើត លុះត្រាតែអនុវត្តត្រឹមត្រូវតាម បញ្ញត្តិច្បាប់។

ការបង្ខិតបង្ខំ ការធ្វើបាបលើរូបរាងកាយ ឬប្រព្រឹត្តិកម្មណាមួយ ដែលបន្ថែមទម្ងន់ទណ្ឌកម្មអនុវត្តចំពោះជនជាប់ឃុំឃាំង ឬជាប់ពន្ធនាគារ ត្រូវហាមឃាត់មិនឲ្យធ្វើឡើយ។ អ្នកដៃដល់ អ្នករួមប្រព្រឹត្ត និងអ្នកសមគំនិតត្រូវទទួលទោសតាមច្បាប់។

ការទទួលសារភាពដែលកើតឡើងពីការបង្ខិតបង្ខំតាមផ្លូវកាយក្តី តាមផ្លូវចិត្តក្តី មិនត្រូវទុកជាភស្តុតាងនៃពិរុទ្ធភាពទេ។

វិមតិសង្ស័យ ត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ។

ជនជាប់ចោទណាក៏ដោយ ត្រូវទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ។

ជនគ្រប់រូបមានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ។

**មាត្រា ៣៩.-**

ប្រជាពលរដ្ឋខ្មែរមានសិទ្ធិប្តឹងបរិហារ ប្តឹងតវ៉ា ឬប្តឹងទារសំណងជួសជុលការខូចខាតដែលបណ្តាលមកពីអំពើខុសច្បាប់របស់អង្គការរដ្ឋ របស់អង្គការសង្គម និងរបស់បុគ្គលិកនៃអង្គការទាំងនោះ។ ការដោះស្រាយបណ្តឹងតវ៉ា និងសំណងជួសជុលការខូចខាតជាសមត្ថកិច្ចរបស់តុលាការ។

**មាត្រា ៤០.-**

សេរីភាពក្នុងការធ្វើដំណើរឆ្ងាយជិត និងតាំងទីលំនៅក្នុងស្ថានភាពស្របច្បាប់របស់ប្រជាពលរដ្ឋត្រូវបានគោរព។

ប្រជាពលរដ្ឋខ្មែរអាចចេញទៅតាំងទីលំនៅ នៅប្រទេសក្រៅ ឬ វិលត្រឡប់មកវិញបាន។

ការរក្សាសិទ្ធិមិនឲ្យរំលោភលើលំនៅឋាន និងអាថ៌កំបាំងនៃការឆ្លើយឆ្លងតាមលិខិត តាមសារទូរលេខ ទូរពុម្ព ទូរគមន៍ និងតាមទូរស័ព្ទ ត្រូវបានធានា។

ការឆែកឆេរលំនៅឋាន សម្ភារៈវត្ថុ និងលើរូបបុគ្គល ត្រូវធ្វើឲ្យស្របនឹងបញ្ញត្តិច្បាប់។

**មាត្រា ៤១.-**

ប្រជាពលរដ្ឋខ្មែរមានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន ខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ។ ជនណាក៏ដោយមិនអាចឆ្លៀតប្រើសិទ្ធិនេះ ដោយរំលោភនាំឲ្យប៉ះ

ពាល់ដល់កិត្តិយសរបស់អ្នកដទៃ ដល់ទំនៀមទម្លាប់ល្អរបស់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិបានឡើយ។

របបសារព័ត៌មាន ត្រូវរៀបចំឡើងដោយច្បាប់។

**មាត្រា៤២.- ថ្មី**

ប្រជាពលរដ្ឋខ្មែរមានសិទ្ធិបង្កើតសមាគមនិងគណបក្សនយោបាយ។ សិទ្ធិនេះត្រូវកំណត់ក្នុងច្បាប់។

គណបក្សនយោបាយត្រូវតែម្កល់ផលប្រយោជន៍ជាតិជាធំ ហើយមិនត្រូវធ្វើសកម្មភាពណាមួយ ទោះដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី នាំឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ព្រះរាជាណាចក្រកម្ពុជា និងប្រជាពលរដ្ឋខ្មែរឡើយ។

ប្រជាពលរដ្ឋខ្មែរទាំងឡាយ អាចចូលរួមក្នុងអង្គការមហាជន ជួយគ្នាទៅវិញទៅមក ការពារសមិទ្ធផលជាតិ និងសណ្តាប់ធ្នាប់សង្គម។

**មាត្រា ៤៣.-**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិពេញទីខាងជំនឿ។

សេរីភាពខាងជំនឿ និងការប្រតិបត្តិខាងផ្លូវសាសនា ត្រូវបានរដ្ឋធានាក្នុងលក្ខខ័ណ្ឌដែលមិនប៉ះពាល់ដល់ជំនឿ ឬ សាសនាដទៃទៀត ដល់សណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈ។

ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ។

**មាត្រា ៤៤.-**

ជនណាក៏ដោយ ទោះជាបុគ្គលក្តី ជាសមូហភាពក្តី មានសិទ្ធិជាម្ចាស់កម្មសិទ្ធិ។ មានតែរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិជាខ្មែរទេ ទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លី។

កម្មសិទ្ធិឯកជនស្របច្បាប់ ឋិតនៅក្រោមការគាំពារនៃច្បាប់។

ដែលនឹងដកហូតកម្មសិទ្ធិអំពីជនណាមួយបាននោះ លុះត្រាតែប្រយោជន៍សាធារណៈតម្រូវឲ្យធ្វើក្នុងករណីដែលច្បាប់បានបញ្ញត្តិទុក ហើយត្រូវផ្តល់សំណងជាមុនដោយ សមរម្យ និងយុត្តិធម៌។

**មាត្រា ៤៥.-**

ការរើសអើងគ្រប់ប្រភេទប្រឆាំងនឹងស្ត្រីភេទត្រូវបំបាត់ចោល។

ការធ្វើអាជីវកម្ម លើការងាររបស់ស្ត្រី ត្រូវហាមឃាត់។

បុរស និង ស្ត្រី មានសិទ្ធិស្មើគ្នាក្នុងគ្រប់វិស័យទាំងអស់ ជាពិសេសក្នុងអាពាហ៍ពិពាហ៍ និងគ្រួសារ។

អាពាហ៍ពិពាហ៍ ត្រូវធ្វើតាមលក្ខខ័ណ្ឌដែលមានចែងក្នុងច្បាប់ និងតាមគោលការណ៍ស្ម័គ្រចិត្ត ប្តីមួយប្រពន្ធមួយ។

**មាត្រា ៤៦.-**

អំពើលក់ដូរមនុស្ស អំពើធ្វើអាជីវកម្មផ្នែកពេស្យាកម្ម និងអំពើអាសអាភាស ដែលប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់នារី ត្រូវហាមឃាត់។

ត្រូវហាមឃាត់មិនឲ្យមានការបញ្ឈប់នារីពីការងារ ដោយមូលហេតុមានគភ៌។ នារីមានសិទ្ធិឈប់សំរាកនៅពេលសំរាលកូន ដោយទទួលប្រាក់បៀវត្ស និងដោយមានការធានារក្សាសិទ្ធិអតីតភាពក្នុងការងារ និងអត្ថប្រយោជន៍សង្គមផ្សេងៗទៀត។

រដ្ឋនិងសង្គមយកចិត្តទុកដាក់បង្កលក្ខណៈឲ្យនារី ជាពិសេសនារីនៅជនបទ ដែលគ្មានទីពឹង បានទទួលការឧបត្ថម្ភដើម្បីមានមុខរបរ មានលទ្ធភាពព្យាបាលជម្ងឺ ឲ្យកូនទៅរៀន និងមានជីវភាពរស់នៅសមរម្យ។

**មាត្រា ៤៧.-**

មាតាបិតាមានកាតព្វកិច្ចចិញ្ចឹមថែរក្សា និងអប់រំកូនឲ្យទៅជាពលរដ្ឋល្អ។

កូនមានករណីយកិច្ចចិញ្ចឹមនិងបីបាច់ថែរក្សាមាតាបិតា ដែលចាស់ជរាតាមទំនៀមទម្លាប់ខ្មែរ។

**មាត្រា ៤៨.-**

រដ្ឋធានារក្សាការពារសិទ្ធិរបស់កុមារ ដែលមានចែងក្នុងអនុសញ្ញាស្តីពីកុមារ ជាពិសេសសិទ្ធិមានជីវិតរស់នៅ សិទ្ធិទទួលការអប់រំរៀនសូត្រ សិទ្ធិត្រូវបានទទួលការគាំពារក្នុងស្ថានការណ៍មានសង្គ្រាម និងការការពារប្រឆាំងនឹងអាជីវកម្ម សេដ្ឋកិច្ច ឬកាមគុណ លើកុមារ។

រដ្ឋគាំពារប្រឆាំងនឹងការងារទាំងឡាយ ដែលអាចធ្វើឲ្យខូចដល់ការអប់រំ និងការរៀនសូត្ររបស់កុមារ ឬ ដែលនាំអោយអន្តរាយដល់សុខភាព ឬសុខុមាលភាពរបស់កុមារ។

**មាត្រា ៤៩.- ថ្មី**

ប្រជាពលរដ្ឋខ្មែរគ្រប់រូបត្រូវគោរពរដ្ឋធម្មនុញ្ញ និងគោរពច្បាប់។

ប្រជាពលរដ្ឋខ្មែរគ្រប់រូបត្រូវតម្កល់ផលប្រយោជន៍ជាតិជាធំ ហើយមិនត្រូវធ្វើសកម្មភាពណាមួយទោះដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី នាំឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ព្រះរាជាណាចក្រកម្ពុជា និងប្រជាពលរដ្ឋខ្មែរឡើយ។

ប្រជាពលរដ្ឋខ្មែរគ្រប់រូបមានកាតព្វកិច្ចរួមចំណែកកសាងប្រទេសជាតិ និងការពារមាតុភូមិ។

កាតព្វកិច្ចការពារមាតុភូមិត្រូវអនុវត្តតាមបញ្ញត្តិច្បាប់។

**មាត្រា ៥០.-**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទត្រូវគោរពគោលការណ៍អធិបតេយ្យជាតិនិងលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទត្រូវគោរពទ្រព្យសម្បត្តិសាធារណៈ និងកម្មសិទ្ធិ ស្របច្បាប់របស់ឯកជន។

## ជំពូកទី ៤
## អំពី
## របបនយោបាយ

**មាត្រា ៥១.- ថ្មី**

ព្រះរាជាណាចក្រកម្ពុជាអនុវត្តនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស។

ប្រជាពលរដ្ឋខ្មែរជាម្ចាស់វាសនានៃប្រទេសជាតិរបស់ខ្លួន។

អំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ។ ប្រជាពលរដ្ឋប្រើអំណាចរបស់ខ្លួន តាមរយៈរដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាលនិងសាលាជំរះក្តី។

អំណាចបែងចែកដាច់ពីគ្នារវាងអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ។

**មាត្រា ៥២.-**

រាជរដ្ឋាភិបាលកម្ពុជា ប្តេជ្ញារក្សាការពារឯករាជ្យ អធិបតេយ្យ បូរណភាព ទឹកដីនៃព្រះរាជាណាចក្រកម្ពុជា អនុវត្តនយោបាយបង្រួបបង្រួមជាតិ ដើម្បីការពារឯកភាពជាតិ រក្សាការពារទំនៀមទម្លាប់និងប្រពៃណីល្អរបស់ជាតិ។ រាជរដ្ឋាភិបាលកម្ពុជាត្រូវការពារនីត្យានុកូលភាព ធានាសណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈ។ រដ្ឋយកចិត្តទុកដាក់ជាអាទិភាព ចំពោះជីវភាព រស់នៅ និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ។

**មាត្រា ៥៣.- ថ្មី**

ព្រះរាជាណាចក្រកម្ពុជាប្រកាន់ខ្ជាប់ជានិច្ចនូវនយោបាយអព្យាក្រឹត អចិន្ត្រៃយ៍ និងមិនចូលបក្សសម្ព័ន្ធ។ ព្រះរាជាណាចក្រកម្ពុជារួមរស់ដោយសន្តិសហវិជ្ជមានជាមួយប្រទេសជិតខាង និងប្រទេសដទៃទៀតទាំងអស់នៅលើសកលលោក។

ព្រះរាជាណាចក្រកម្ពុជាមិនឈ្លានពានប្រទេសណាដាច់ខាត មិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងនៃប្រទេសដទៃដោយផ្ទាល់ ឬដោយប្រយោល ទោះបីក្រោមរូបភាពណាក៏ដោយ ដោះស្រាយរាល់បញ្ហាដោយសន្តិវិធី និងគោរពផលប្រយោជន៍ផងគ្នាទៅវិញទៅមក។

ព្រះរាជាណាចក្រកម្ពុជាប្រឆាំងដាច់ខាតការជ្រៀតជ្រែកពីបរទេស ចូលក្នុងកិច្ចការផ្ទៃក្នុងរបស់ខ្លួន ទោះបីក្រោមរូបភាពណាក៏ដោយ។

ព្រះរាជាណាចក្រកម្ពុជាមិនចងសម្ព័ន្ធយោធា ឬចូលក្នុងកិច្ចព្រមព្រៀងយោធាណាមួយ ដែលមិនស្របនឹងអព្យាក្រឹតភាពរបស់ខ្លួនឡើយ។

ព្រះរាជាណាចក្រកម្ពុជាមិនអនុញ្ញាតឱ្យមានមូលដ្ឋានយោធាបរទេសនៅលើទឹកដីរបស់ខ្លួន ហើយក៏មិនអនុញ្ញាតឱ្យមានមូលដ្ឋានយោធារបស់ខ្លួននៅបរទេសដែរ លើកលែងតែក្នុងក្របខ័ណ្ឌនៃសំណូមពររបស់អង្គការសហប្រជាជាតិ។

ព្រះរាជាណាចក្រកម្ពុជារក្សាសិទ្ធិទទួលយកជំនួយបរទេសជាសម្ភារៈ យោធា អាវុធ គ្រាប់រំសេវ ការហ្វឹកហ្វឺនកងកម្លាំងប្រដាប់អាវុធ និងជំនួយផ្សេងៗទៀតដើម្បីការពារខ្លួន និងធានាសណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈនៅផ្ទៃក្នុងប្រទេស។

**មាត្រា ៥៤.-**

ការផលិត ការប្រើប្រាស់ ការរក្សាទុកអាវុធបរមាណូ អាវុធគីមី ឬអាវុធជីវគ្រាណូ ត្រូវហាមឃាត់ដាច់ខាត។

**មាត្រា ៥៥.-**

សន្ធិសញ្ញានិងកិច្ចព្រមព្រៀងទាំងឡាយណាដែលមិនស្របនឹងឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដី អព្យាក្រឹតភាព និងឯកភាពជាតិរបស់ព្រះរាជាណាចក្រកម្ពុជា ត្រូវលុបចោល។

## ជំពូកទី ៥
## អំពី
## សេដ្ឋកិច្ច

**មាត្រា ៥៦.-**

ព្រះរាជាណាចក្រកម្ពុជា អនុវត្តប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃប្រព័ន្ធសេដ្ឋកិច្ចនេះ នឹងមានកំណត់ក្នុងច្បាប់។

**មាត្រា ៥៧.-**

ការយកពន្ធដារនឹងអាចធ្វើទៅបាន លុះត្រាតែមានច្បាប់អនុញ្ញាត។ ថវិកាជាតិត្រូវបានកំណត់ឲ្យអនុវត្តតាមច្បាប់។

របបគ្រប់គ្រងរូបិយវត្ថុនិងប្រព័ន្ធហិរញ្ញវត្ថុត្រូវកំណត់ក្នុងច្បាប់។

**មាត្រា ៥៨.-**

ទ្រព្យសម្បត្តិរបស់រដ្ឋមានជាអាទិ៍ ដីធ្លី ក្រោមដី ភ្នំ សមុទ្រ បាតសមុទ្រ ក្រោមបាតសមុទ្រ ឆ្នេរសមុទ្រ អាកាស កោះ ទន្លេ ព្រែក ស្ទឹង បឹង ព្រៃឈើ ធនធានធម្មជាតិ មជ្ឈមណ្ឌលសេដ្ឋកិច្ចវប្បធម៌ មូលដ្ឋានការពារប្រទេស សំណង់ផ្សេងៗទៀតដែលបានកំណត់ថាជារបស់រដ្ឋ។

ការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋនឹងត្រូវកំណត់ក្នុងច្បាប់។

**មាត្រា ៥៩.-**

រដ្ឋត្រូវរក្សាការពារបរិដ្ឋាន និងតុល្យភាពនៃភោគទ្រព្យធម្មជាតិហើយ ត្រូវចាត់ចែងឲ្យមានផែនការច្បាស់លាស់ក្នុងការគ្រប់គ្រង មានជាអាទិ៍ ដីធ្លី ទឹក អាកាស ខ្យល់ ភោគោគ្គសាស្ត្រ ប្រព័ន្ធអេកូឡូស៊ី រ៉ែ ឋាមពល ប្រេងកាត និងឧស្ម័ន ថ្មនិងខ្សាច់ ត្បូងថ្ម ព្រៃឈើ និងអនុផលព្រៃឈើ ពពួកសត្វព្រៃ មច្ឆាជាតិ ធនធានជលផល។

**មាត្រា ៦០.-**

ពលរដ្ឋមានសិទ្ធិលក់ដូរផលិតផលរបស់ខ្លួនដោយសេរី។ ការតម្រូវឲ្យលក់ផលិតផលជូនរដ្ឋ ឬការយកភោគផល ឬទ្រព្យសម្បត្តិឯកជនទៅប្រើប្រាស់ ទោះបីមួយរយៈពេលក៏ដោយត្រូវហាមឃាត់ វៀរលែងតែក្នុងករណីពិសេសដែលមានច្បាប់អនុញ្ញាត។

**មាត្រា ៦១.-**

រដ្ឋជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ចគ្រប់វិស័យ ជាពិសេសវិស័យកសិកម្ម សិប្បកម្ម ឧស្សាហកម្ម ចាប់ពីតំបន់ដាច់ស្រយាលដោយយកចិត្តទុកដាក់ទៅលើនយោបាយទឹក ភ្លើង ផ្លូវ និងមធ្យោបាយដឹកជញ្ជូន បច្ចេកទេសទំនើប និងប្រព័ន្ធឥណទាន។

**មាត្រា ៦២.-**

រដ្ឋយកចិត្តទុកដាក់ជួយដោះស្រាយមធ្យោបាយផលិត ការពារថ្លៃ ផលិតផល ជូនកសិករ សិប្បករ និងជួយរកទីផ្សារលក់ផលិតផល។

**មាត្រា ៦៣.-**

រដ្ឋយកចិត្តទុកដាក់គ្រប់គ្រងទីផ្សារ ជួយឲ្យជីវភាពរស់នៅរបស់ប្រជាពលរដ្ឋមានកម្រិតសមរម្យ។

**មាត្រា ៦៤.-**

រដ្ឋហាមឃាត់និងផ្តន្ទាទោសជាទម្ងន់ដល់ជនណា ដែលនាំចូល ផលិត លក់ដូរ គ្រឿងញៀន ទំនិញក្លែងក្លាយ ហួសរយៈពេលប្រើដែលប៉ះពាល់ដល់សុខភាព អាយុជីវិតរបស់អ្នកប្រើ។

## ជំពូក ទី ៦
## អំពី
## អប់រំ វប្បធម៌ និងសង្គមកិច្ច

**មាត្រា ៦៥.-**

រដ្ឋត្រូវការពារ និងលើកស្ទួយសិទ្ធិរបស់ប្រជាពលរដ្ឋ ក្នុងការទទួលការអប់រំប្រកបដោយគុណភាពនៅគ្រប់កំរិត និងត្រូវចាត់វិធានការគ្រប់បែបយ៉ាងជាជំហានៗ ដើម្បីឲ្យការអប់រំនេះបានទៅដល់ប្រជាពលរដ្ឋគ្រប់រូប។

រដ្ឋយកចិត្តទុកដាក់ដល់វិស័យអប់រំកាយនិងកីឡា ដែលជាសុខុមាលភាពរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប។

**មាត្រា ៦៦.-**

រដ្ឋកសាងប្រព័ន្ធអប់រំមួយពេញលេញនិងឯកភាព នៅទូទាំងប្រទេសដែលធានាឲ្យបាននូវគោលការណ៍សេរីភាពខាងសិក្សាធិការនិងគោលការណ៍សមភាពក្នុងការអប់រំ ដើម្បីឲ្យប្រជាពលរដ្ឋគ្រប់រូបមានភ័ព្វសំណាងគ្រប់គ្រាន់ស្មើគ្នាក្នុងការកសាងជីវិត។

**មាត្រា ៦៧.-**

រដ្ឋអនុវត្តកម្មវិធីសិក្សា និងគោលការណ៍គរុកោសល្យទំនើប រាប់បញ្ចូលទាំងបច្ចេកវិទ្យា និងភាសាបរទេស។

រដ្ឋគ្រប់គ្រងគ្រឹះស្ថានសិក្សា និងថ្នាក់សិក្សាសាធារណៈនិងឯកជននៅគ្រប់ភូមិសិក្សា។

**មាត្រា ៦៨.-**

រដ្ឋផ្តល់កិច្ចការអប់រំផ្នែកបឋម និងមធ្យមសិក្សានៅសាលារៀនសាធារណៈ សំរាប់ប្រជាពលរដ្ឋគ្រប់រូបដោយឥតបង់ថ្លៃ ។

ប្រជាពលរដ្ឋ ត្រូវបានទទួលការអប់រំយ៉ាងតិចប្រាំបួនឆ្នាំ។

រដ្ឋជួយផ្សព្វផ្សាយនិងលើកតំកើងសាលាបាលីនិងពុទ្ធិកសិក្សា។

**មាត្រា ៦៩.-**

រដ្ឋមានកាតព្វកិច្ចថែរក្សា និងពង្រីកវប្បធម៌ជាតិ។

រដ្ឋមានកាតព្វកិច្ចការពារ និងពង្រីកភាសាខ្មែរឲ្យសមស្របនឹងសេចក្ដីត្រូវការ។

រដ្ឋមានកាតព្វកិច្ចថែរក្សានិងការពារ ប្រាសាទបុរាណវត្ថុសិល្បៈបុរាណ និងកែលំអរមណីយដ្ឋានប្រវត្តិសាស្ត្រឡើងវិញ។

**មាត្រា ៧០.-**

បទល្មើសទាំងឡាយដែលប៉ះពាល់ ឬទាក់ទងនឹងបេតិកភ័ណ្ឌវប្បធម៌ និងបេតិកភ័ណ្ឌសិល្បៈ ត្រូវផ្ដន្ទាទោសជាទម្ងន់។

**មាត្រា ៧១.-**

បរិវេណបេតិកភ័ណ្ឌជាតិក៏ដូចជាបេតិកភ័ណ្ឌដែលបានបញ្ចូលជា បេតិកភ័ណ្ឌពិភពលោក ត្រូវទុកជាតំបន់អព្យាក្រឹត ដែលមិនឲ្យមានសកម្មភាពយោធា។

**មាត្រា ៧២.-**

សុខភាពរបស់ប្រជារាស្ត្រត្រូវបានធានា។ រដ្ឋយកចិត្តទុកដាក់ដល់ការការពារជម្ងឺនិងព្យាបាលជម្ងឺ។ ប្រជារាស្ត្រក្រីក្រត្រូវបានទទួលការពិនិត្យរោគដោយឥតបង់ថ្លៃនៅតាមមន្ទីរពេទ្យ គិលានដ្ឋាន និងមន្ទីរសម្ភពសាធារណៈ។

រដ្ឋរៀបចំឲ្យមានគិលានដ្ឋាន និងមន្ទីរសម្ភពដល់ជនបទ។

**មាត្រា ៧៣.-**

រដ្ឋយកចិត្តទុកដាក់ចំពោះកុមារនិងមាតា។ រដ្ឋរៀបចំឲ្យមានទារកដ្ឋាន និងជួយឧបត្ថម្ភនារីដែលមានកូនច្រើនក្នុងបន្ទុក ហើយឥតទីពឹង។

**មាត្រា ៧៤.-**

រដ្ឋជួយឧបត្ថម្ភជនពិការ និងដល់គ្រួសារយុទ្ធជនដែលបានបូជាជីវិតដើម្បីប្រទេសជាតិ។

**មាត្រា ៧៥.-**

រដ្ឋចាត់ចែងឲ្យមានរបបសន្តិសុខសង្គម ដល់កម្មករនិងនិយោជិត។

## ជំពូកទី ៧
## អំពី
## រដ្ឋសភា

**មាត្រា ៧៦.- ថ្មី**

រដ្ឋសភាមានសមាជិកតំណាងរាស្ត្រយ៉ាងតិច ១២០ រូប ។

តំណាងរាស្ត្រ ត្រូវជ្រើសតាំងដោយការបោះឆ្នោតជាសកល ដោយសេរី ដោយស្មើភាព ដោយចំពោះ និងតាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់។

តំណាងរាស្ត្រអាចឈរឈ្មោះបោះឆ្នោតសាជាថ្មីបាន។

អ្នកដែលមានសិទ្ធិឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រ គឺជាប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានសិទ្ធិបោះឆ្នោត មានអាយុយ៉ាងតិច ២៥ឆ្នាំ មានសញ្ជាតិជាខ្មែរតាំងពីកំណើត។

បែបបទ និងការប្រព្រឹត្តទៅនៃការបោះឆ្នោត ត្រូវកំណត់ក្នុងច្បាប់បោះឆ្នោត ។

**មាត្រា ៧៧.-**

តំណាងរាស្ត្រក្នុងរដ្ឋសភា ជាតំណាងប្រជាជាតិខ្មែរទាំងមូលពុំមែនគ្រាន់តែជាតំណាងប្រជាពលរដ្ឋក្នុងមណ្ឌលរបស់ខ្លួននោះទេ។

អាណត្តិអាជ្ញាបញ្ជាទាំងឡាយត្រូវទុកជាមោឃៈ។

**មាត្រា ៧៨.-**

នីតិកាលរបស់រដ្ឋសភាមានកំណត់ ៥ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលដែលរដ្ឋសភាថ្មីចូលកាន់តំណែង។ រដ្ឋសភាមិនអាចត្រូវបានរំលាយមុនផុតអាណត្តិបានឡើយ វៀរលែងតែក្នុងករណីដែលរាជរដ្ឋាភិបាលត្រូវបានទម្លាក់ពីរដងក្នុងរយៈ ១២ ខែ។

ក្នុងករណីនេះព្រះមហាក្សត្រត្រូវរំលាយរដ្ឋសភា ក្រោយពីព្រះអង្គទ្រង់បានទទួលការស្នើពីនាយករដ្ឋមន្ត្រី និងបន្ទាប់ពីទ្រង់បានការយល់ព្រមពីប្រធានរដ្ឋសភា។

ការបោះឆ្នោតដើម្បីជ្រើសរើសរដ្ឋសភាថ្មី នឹងប្រព្រឹត្តទៅក្នុងរយៈពេល ៦០ ថ្ងៃយ៉ាងយូរ ចាប់តាំងពីថ្ងៃរំលាយរដ្ឋសភាមក។

ក្នុងរយៈកាលនេះ រាជរដ្ឋាភិបាលមានតែភារកិច្ចដឹកនាំការងារប្រចាំថ្ងៃតែប៉ុណ្ណោះ។

ក្នុងពេលមានសង្គ្រាម ឬក្នុងកាលៈទេសៈពិសេសដទៃទៀតដែលមិន អាចធ្វើការបោះឆ្នោតកើត រដ្ឋសភាអាចប្រកាសបន្តនីតិកាលរបស់ខ្លួនមួយដងបានមួយឆ្នាំ តាមសំណើរបស់ព្រះមហាក្សត្រ។

ការប្រកាសបន្តនីតិកាលរបស់រដ្ឋសភា ត្រូវសំរេចដោយមតិយល់ព្រមពីរភាគបីយ៉ាងតិចនៃចំនួនសមាជិករដ្ឋសភាទាំងមូល។

**មាត្រា ៧៩.-**

អាណត្តិនៃសមាជិករដ្ឋសភាមានវិសមិតភាពជាមួយការបំពេញមុខងារសាធារណៈជាសកម្ម និងជាមួយមុខងារជាសមាជិកនៃស្ថាប័នដទៃទៀតដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនេះ វៀរលែងតែទៅបំពេញមុខងារក្នុងគណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល។

ក្នុងករណីនេះ សមាជិករដ្ឋសភារូបនោះ មានឋានៈជាសមាជិករដ្ឋសភាធម្មតា ប៉ុន្តែមិនត្រូវមានមុខតំណែងអ្វីទាំងអស់ក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍ និងក្នុងគណៈកម្មការផ្សេងៗ នៃរដ្ឋសភា។

**មាត្រា ៨០.-**

តំណាងរាស្ត្រមានអភ័យឯកសិទ្ធិសភា។

តំណាងរាស្ត្ររូបណាក៏ដោយ មិនអាចត្រូវបានចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួន ដោយហេតុពីបានសំដែងយោបល់ ឬបញ្ចេញមតិក្នុងការបំពេញមុខងាររបស់ខ្លួនសោះឡើយ។

ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនសមាជិកណាមួយនៃរដ្ឋសភានឹងអាចធ្វើទៅកើត លុះត្រាតែមានការយល់ព្រមពីរដ្ឋសភា ឬពីគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាក្នុងចន្លោះសម័យប្រជុំនៃរដ្ឋសភា វៀរលែងតែក្នុងករណីបទល្មើសព្រហ្មទណ្ឌជាក់ស្តែង។ ក្នុងករណីខាងក្រោយនេះក្រសួងមានសមត្ថកិច្ចត្រូវធ្វើសេចក្តីរាយការណ៍ជូនរដ្ឋសភា ឬជូនគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាជាបន្ទាន់ដើម្បីសំរេច។

សេចក្តីសំរេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា ត្រូវដាក់ជូនសម័យប្រជុំរដ្ឋសភាខាងមុខ ដើម្បីអនុម័តតាមមតិភាគច្រើនពីរភាគបី នៃសមាជិករដ្ឋសភាទាំងមូល។

ក្នុងករណីទាំងអស់ខាងលើនេះ ការឃុំខ្លួន ការចោទប្រកាន់តំណាងរាស្ត្រណាមួយត្រូវផ្អាក ប្រសិនបើរដ្ឋសភាបានបញ្ចេញមតិឲ្យផ្អាកតាមមតិភាគច្រើនបីភាគបួន នៃចំនួនសមាជិករដ្ឋសភាទាំងមូល។

**មាត្រា ៨១.-**

រដ្ឋសភាមានថវិកាស្វយ័ត សំរាប់ដំណើរការ។

តំណាងរាស្ត្រត្រូវទទួលប្រាក់បំណាច់។

**មាត្រា ៨២.- ថ្មី(មួយ)**

រដ្ឋសភាបើកសម័យប្រជុំដំបូង ហុកសិបថ្ងៃយ៉ាងយូរក្រោយពេលបោះឆ្នោត តាមការកោះប្រជុំរបស់ព្រះមហាក្សត្រ។

មុនចាប់ផ្តើមការងាររបស់ខ្លួន រដ្ឋសភាត្រូវប្រកាសសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗ និងត្រូវបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នានូវប្រធាន អនុប្រធានរដ្ឋសភា និងសមាជិកទាំងអស់នៃគណៈកម្មការនានារបស់រដ្ឋសភា ដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល។

ប្រធានរដ្ឋសភា ត្រូវបោះឆ្នោតជ្រើសរើសចេញពីសមាជិករដ្ឋសភា ដែលមានសញ្ជាតិខ្មែរតែមួយគត់។

រដ្ឋសភាត្រូវអនុម័តបទបញ្ជាផ្ទៃក្នុង ដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល។

តំណាងរាស្ត្រទាំងអស់ ត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់តំណែងដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធទី៥ នៃរដ្ឋធម្មនុញ្ញ។

**មាត្រា ៨៣.-**

រដ្ឋសភាប្រជុំជាសាមញ្ញពីរដងក្នុងមួយឆ្នាំ។

សម័យប្រជុំនិមួយៗ មានថិរៈវេលាយ៉ាងតិចបីខែ។ បើមានសំណូមពរពីព្រះមហាក្សត្រ ឬសេចក្តីស្នើសុំពីនាយករដ្ឋមន្ត្រី ឬពីសមាជិករដ្ឋសភាចំនួនមួយភាគបីយ៉ាងតិច គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាកោះប្រជុំរដ្ឋសភាជាវិសាមញ្ញ។

ក្នុងករណីនេះ របៀបវារៈជាក់លាក់នៃសម័យប្រជុំជាវិសាមញ្ញត្រូវផ្សាយ ដល់ប្រជារាស្ត្រជាមួយនឹងថ្ងៃកំណត់ប្រជុំ។

**មាត្រា ៨៤.-**

នៅចន្លោះសម័យប្រជុំរបស់រដ្ឋសភា គណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាទទួលភារកិច្ចចាត់ចែងការងារ។

គណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភារួមមាន : ប្រធានរដ្ឋសភា អនុប្រធានរដ្ឋសភា និងប្រធានគណៈកម្មការទាំងអស់របស់រដ្ឋសភា។

**មាត្រា ៨៥.-**

សម័យប្រជុំរដ្ឋសភាត្រូវធ្វើនៅរាជធានីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងសាលប្រជុំរបស់រដ្ឋសភា លើកលែងតែមានការសំរេចផ្សេង ចុះក្នុងលិខិតកោះប្រជុំដោយកាលៈទេសៈតម្រូវ។

ក្រៅពីករណីខាងលើ និងក្រៅពីកន្លែង និងពីកាលបរិច្ឆេទដែលកំណត់ ក្នុងសេចក្ដីអញ្ជើញ ការប្រជុំណាក៏ដោយរបស់រដ្ឋសភាត្រូវទុកជាខុសច្បាប់ ហើយជាអាសាសូន្យពេញលក្ខណៈ។

**មាត្រា ៨៦.-**

ក្នុងកាលៈទេសៈដែលប្រទេសជាតិស្ថិតក្នុងភាពអាសន្ន រដ្ឋសភាប្រជុំរាល់ថ្ងៃជាប់ជាប្រចាំ។ រដ្ឋសភាមានសិទ្ធិសំរេចបញ្ចប់កាលៈទេសៈពិសេសខាងលើនេះ កាលបើសភាពការណ៍អនុញ្ញាត។

បើរដ្ឋសភាមិនអាចប្រជុំបានទេ ដោយមូលហេតុចាំបាច់ ជាអាទិ៍នៅពេលដែលកម្លាំងបរទេសចូលមកកាន់កាប់ទឹកដី ការប្រកាសភាពអាសន្នត្រូវបន្តទៅមុខជាស្វ័យប្រវត្តិ។

នៅពេលដែលប្រទេសជាតិឋិតក្នុងភាពអាសន្ន រដ្ឋសភាមិនអាចត្រូវរំលាយបានឡើយ។

**មាត្រា ៨៧.-**

ប្រធានរដ្ឋសភាដឹកនាំអង្គប្រជុំរបស់រដ្ឋសភា ទទួលអាញ្ញត្តិច្បាប់និងសេចក្ដីសំរេចចិត្តទាំងឡាយដែលរដ្ឋសភាបានអនុម័ត រ៉ាប់រងការអនុវត្ត បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា និងចាត់ចែងការទាក់ទងអន្តរជាតិទាំងឡាយរបស់រដ្ឋសភា។

ក្នុងករណីដែលប្រធានរដ្ឋសភាមានធុរៈ មិនអាចបំពេញមុខងារបាន ដោយហេតុមកពីមានជម្ងឺ ឬបំពេញមុខងារជាប្រមុខរដ្ឋស្ដីទី ឬជាព្រះរាជានុសិទ្ធិ ឬបំពេញបេសកកម្មនៅបរទេស អនុប្រធានរដ្ឋសភាមួយរូប ត្រូវទទួលភារកិច្ចចាត់ចែងការងារជំនួស។

ក្នុងករណីដែលប្រធាន ឬអនុប្រធានរដ្ឋសភាលាលែងពីមុខតំណែង ឬទទួលអនិច្ចកម្ម រដ្ឋសភាត្រូវបោះឆ្នោតជ្រើសតាំងប្រធាន ឬអនុប្រធានថ្មី។

**មាត្រា ៨៨.-ថ្មី(ពីរ)**

ការប្រជុំរដ្ឋសភាត្រូវធ្វើជាសាធារណៈ។

រដ្ឋសភាអាចប្រជុំជាសម្ងាត់បានតាមការស្នើសុំពីប្រធាន ឬ ពីសមាជិកចំនួនមួយភាគដប់យ៉ាងតិចពីព្រះមហាក្សត្រ ឬ ពីនាយករដ្ឋមន្ត្រី។

ការប្រជុំរដ្ឋសភា នឹងយកជាការបានលុះត្រាតែមាន :

ក-កូរ៉ុមលើសពី ពីរភាគបី នៃចំនួនសមាជិករដ្ឋសភាទាំងមូលសម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឱ្យយកមតិភាគច្រើន ពីរភាគបី នៃចំនួនសមាជិករដ្ឋសភាទាំងមូល។

ខ-កូរ៉ុមលើសពីពាក់កណ្ដាល នៃចំនួនសមាជិករដ្ឋសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឱ្យយកមតិភាគច្រើនដាច់ខាត នៃចំនួនសមាជិករដ្ឋសភាទាំងមូល។

**មាត្រា ៨៩.- ថ្មី**

តាមការសុំពីសមាជិកចំនួនមួយភាគដប់យ៉ាងតិច រដ្ឋសភាអាចអញ្ជើញសមាជិករាជរដ្ឋាភិបាលមួយរូប ឬច្រើនរូប អមដោយឥស្សរជនជាអ្នកជំនាញក្នុងវិស័យណាមួយ មកបំភ្លឺរដ្ឋសភាអំពីបញ្ហាដែលមានសារៈសំខាន់ពិសេស។

**មាត្រា ៩០.- ថ្មី(ពីរ)**

រដ្ឋសភាជាអង្គការ ដែលមានអំណាចនីតិប្បញ្ញត្តិ ហើយបំពេញភារកិច្ចរបស់ខ្លួនដូចបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន។

រដ្ឋសភាអនុម័តថវិកាជាតិ ផែនការរដ្ឋ ការឱ្យរដ្ឋខ្ចីប្រាក់ពីគេ ការឱ្យរដ្ឋឱ្យប្រាក់គេខ្ចី ការសន្យានានាផ្នែកហិរញ្ញវត្ថុ និងការបង្កើត កែប្រែ ឬ លុបចោលពន្ធដារ។

រដ្ឋសភាឱ្យសេចក្ដីយល់ព្រមចំពោះគណនីរដ្ឋបាល។

រដ្ឋសភាអនុម័តច្បាប់ស្ដីពីការលើកលែងទោសជាទូទៅ។

រដ្ឋសភាអនុម័តយល់ព្រម ឬ លុបចោលសន្ធិសញ្ញា ឬ អនុសញ្ញាអន្តរជាតិ។

រដ្ឋសភាអនុម័តច្បាប់ស្ដីពីការប្រកាសសង្គ្រាម។

ការអនុម័តខាងលើនេះប្រព្រឹត្តទៅដោយមតិភាគច្រើនដាច់ខាត នៃចំនួនសមាជិករដ្ឋសភាទាំងមូល។

រដ្ឋសភាបោះឆ្នោតទុកចិត្តដល់រាជរដ្ឋាភិបាលតាមមតិភាគច្រើនដាច់ខាត នៃចំនួនសមាជិករដ្ឋសភាទាំងមូល។

**មាត្រា ៩១.- ថ្មី**

សមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភានិងនាយករដ្ឋមន្ត្រីមានសិទ្ធិផ្ដួចផ្ដើមគំនិតធ្វើច្បាប់។

តំណាងរាស្ត្រមានសិទ្ធិស្នើធ្វើវិសោធនកម្មច្បាប់ ប៉ុន្តែសំណើនេះមិនអាចទទួលយកបានទេ បើវិសោធនកម្មនោះសំដៅបន្ថយប្រាក់ចំណូលសាធារណៈ ឬបន្ថែមបន្ទុកលើប្រជាពលរដ្ឋ។

**មាត្រា ៩២.-**

ការអនុម័តទាំងឡាយរបស់រដ្ឋសភា ដែលផ្ទុយនឹងគោលការណ៍រក្សាការពារ ឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដី នៃព្រះរាជាណាចក្រកម្ពុជា ហើយដែលនាំឲ្យប៉ះពាល់ដល់ឯកភាពនយោបាយ ឬការគ្រប់គ្រងរដ្ឋបាលរបស់ប្រទេសជាតិ នឹងត្រូវចាត់ទុកជាអាសាសូន្យ។ ក្រុមប្រឹក្សាធម្មនុញ្ញជា អង្គការតែមួយគត់ដែលមានសមត្ថកិច្ចសម្រេចពីមោឃភាពនេះ។

## មាត្រា ៩៣.- ថ្មី

ច្បាប់ដែលរដ្ឋសភាបានអនុម័តនិងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់រួចហើយ ហើយត្រូវបានព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាប្រកាសឱ្យប្រើ ត្រូវចូលជាធរមាននៅរាជធានីភ្នំពេញក្នុងរយៈពេលដប់ថ្ងៃគត់ ក្រោយពីថ្ងៃប្រកាសឱ្យប្រើ និងនៅទូទាំងប្រទេសក្នុងរយៈពេលម្ភៃថ្ងៃគត់ ក្រោយពីថ្ងៃប្រកាសឱ្យប្រើ។ ប៉ុន្តែបើច្បាប់នេះបានចែងថាជាការប្រញាប់ ច្បាប់នេះត្រូវចូលជាធរមានភ្លាមនៅទូទាំងប្រទេស ក្រោយថ្ងៃប្រកាសឱ្យប្រើ។

ច្បាប់ដែលព្រះមហាក្សត្រទ្រង់បានឡាយព្រះហស្តលេខាប្រកាសឱ្យប្រើ ត្រូវចុះក្នុងរាជកិច្ចនិងផ្សព្វផ្សាយនៅទូទាំងប្រទេស ឱ្យទាន់តាមពេលកំណត់ខាងលើ។

## មាត្រា ៩៤.-

រដ្ឋសភាបង្កើតគណៈកម្មការផ្សេងៗ ដែលចាំបាច់។ ការរៀបចំនិងការប្រព្រឹត្តទៅ នៃរដ្ឋសភានឹងមានកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា។

## មាត្រា ៩៥.-

ក្នុងករណីមានសមាជិករដ្ឋសភាទទួលអនិច្ចកម្ម លាលែង ឬប្រាសចាក សមាជិកភាព ដែលកើតមានឡើង៦ខែយ៉ាងតិចមុនចប់នីតិកាល ត្រូវចាត់ការជ្រើសតាំងជំនួសសមាជិកនោះ តាមល័ក្ខខ័ណ្ឌកំណត់ក្នុងបទបញ្ជាផ្ទៃក្នុង រដ្ឋសភា និងក្នុងច្បាប់បោះឆ្នោត។

## មាត្រា ៩៦.-

តំណាងរាស្ត្រមានសិទ្ធិដាក់សំណួរដល់រាជរដ្ឋាភិបាល។ សំណួរនេះ ត្រូវសរសេរជាលាយល័ក្ខអក្សរប្រគល់ជូនតាមរយៈប្រធានរដ្ឋសភា។

ចម្លើយអាចធ្វើឡើងដោយរដ្ឋមន្ត្រីមួយរូបឬច្រើនរូប អាស្រ័យដោយបញ្ហាដែលបានចោទឡើងពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់រដ្ឋមន្ត្រីមួយរូប ឬច្រើនរូប។ បើបញ្ហាពាក់ព័ន្ធដល់នយោបាយទូទៅរបស់រាជរដ្ឋាភិបាល នាយករដ្ឋមន្ត្រីត្រូវឆ្លើយផ្ទាល់ខ្លួន។

ចម្លើយរបស់រដ្ឋមន្ត្រីឬរបស់នាយករដ្ឋមន្ត្រី អាចធ្វើដោយផ្ទាល់មាត់ ឬ សរសេរជាលាយល័ក្ខអក្សរ។

ចម្លើយខាងលើនេះ ត្រូវធ្វើឡើងក្នុងរយៈពេលប្រាំពីរថ្ងៃ បន្ទាប់ពីបានទទួលសំណួរ។

ចំពោះចម្លើយផ្ទាល់មាត់ ប្រធានរដ្ឋសភាអាចសំរេចបើកឲ្យមាន ឬមិនឲ្យមានការជជែកដេញដោល។ បើគ្មានការបើកឲ្យជជែកដេញដោលទេ នោះចម្លើយរបស់រដ្ឋមន្ត្រី ឬរបស់នាយករដ្ឋមន្ត្រី នឹងបញ្ចប់សំណួរតែម្តង។

បើមានការបើកឲ្យជជែកដេញដោល ម្ចាស់សំណួរ វាគ្មិនឯទៀត និងរដ្ឋមន្ត្រីពាក់ព័ន្ធឬនាយករដ្ឋមន្ត្រី អាចជជែកប្តូរយោបល់ក្នុងរយៈពេលដែលមិនអាចលើសពីមួយពេលប្រជុំឡើយ។

រដ្ឋសភាកំណត់ទុកពេលមួយថ្ងៃក្នុងមួយសប្តាហ៍ សម្រាប់ការឆ្លើយសំណួរ ។

ទោះបីយ៉ាងណាក៏ដោយ សម័យប្រជុំសំរាប់ឆ្លើយសំណួរខាងលើនេះ មិនអាចបើកលទ្ធភាពឲ្យមានការបោះឆ្នោតប្រភេទណាមួយបានឡើយ។

**មាត្រា ៩៧.-**

គណៈកម្មការទាំងឡាយរបស់រដ្ឋសភា អាចអញ្ជើញរដ្ឋមន្ត្រីមកបំភ្លឺអំពីបញ្ហាអ្វីមួយដែលពាក់ព័ន្ធនឹងវិស័យទទួលខុសត្រូវរបស់ខ្លួន។

**មាត្រា ៩៨.- ថ្មី( មួយ )**

រដ្ឋសភាអាចទម្លាក់សមាជិកគណៈរដ្ឋមន្ត្រី ឬ ទម្លាក់រាជរដ្ឋាភិបាលពីតំណែង ដោយអនុម័តញត្តិបន្ទោស តាមសំឡេងឆ្នោតភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល។ ក្នុងករណីដែលរាជរដ្ឋាភិបាលត្រូវបានទម្លាក់ពីមុខតំណែងដោយរដ្ឋសភា រាជរដ្ឋាភិបាលដែលត្រូវចេញពីមុខតំណែងនេះ មានតែភារកិច្ចដឹកនាំការងារប្រចាំថ្ងៃតែប៉ុណ្ណោះ រហូតដល់មានរាជរដ្ឋាភិបាលថ្មីចូលកាន់តំណែង។

ញត្តិបន្ទោសរាជរដ្ឋាភិបាល ត្រូវបានលើកឡើងជូនរដ្ឋសភាដោយតំណាងរាស្ត្រចំនួនមួយភាគបីនៃចំនួនសមាជិករដ្ឋសភាទាំងមូល ទើបរដ្ឋសភាអាចលើកមកពិភាក្សាបាន។

## ជំពូកទី ៨ ថ្មី
## អំពី
## ព្រឹទ្ធសភា

**មាត្រា ៩៩.- ថ្មី**

ព្រឹទ្ធសភាជាអង្គការដែលមានអំណាចនីតិបញ្ញត្តិ ហើយបំពេញភារកិច្ចរបស់ខ្លួនដូចបានកំណត់ក្នុងរដ្ឋធម្មនុញ្ញនិងច្បាប់ជាធរមាន។

ព្រឹទ្ធសភាមានចំនួនសមាជិកយ៉ាងច្រើនស្មើនឹងពាក់កណ្តាលនៃចំនួនសមាជិករដ្ឋសភាទាំងមូល។

សមាជិកព្រឹទ្ធសភាត្រូវចាត់តាំងខ្លះនិងត្រូវជ្រើសតាំងដោយការបោះឆ្នោតអសកលខ្លះ។

សមាជិកព្រឹទ្ធសភាអាចត្រូវបានចាត់តាំងនិងជ្រើសតាំងសាជាថ្មីបាន។ អ្នកដែលមានសិទ្ធិឈរឈ្មោះជាបេក្ខជនព្រឹទ្ធសភា គឺជាប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានសិទ្ធិបោះឆ្នោតមានអាយុយ៉ាងតិច ៤០ឆ្នាំ មានសញ្ជាតិខ្មែរតាំងពីកំណើត។

**មាត្រា ១០០.- ថ្មី**

សមាជិកព្រឹទ្ធសភាចំនួន ២រូប ត្រូវបានចាត់តាំងដោយព្រះមហាក្សត្រ។

សមាជិកព្រឹទ្ធសភាចំនួន ២រូប ត្រូវបានរដ្ឋសភាជ្រើសតាំងតាមមតិភាគច្រើនដោយប្រៀប។

រីឯសមាជិកព្រឹទ្ធសភាឯទៀត ត្រូវបានជ្រើសតាំងដោយការបោះឆ្នោតអសកល។

**មាត្រា ១០១.- ថ្មី**

ការរៀបចំ បែបបទនិងការប្រព្រឹត្តទៅនៃការចាត់តាំង និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ព្រមទាំងការកំណត់អំពីអ្នកបោះឆ្នោតអង្គបោះឆ្នោតនិងមណ្ឌលបោះឆ្នោត ត្រូវចែងក្នុងច្បាប់មួយ។

**មាត្រា ១០២.- ថ្មី(មួយ)**

នីតិកាលរបស់ព្រឹទ្ធសភាមានកំណត់ ៦ ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលដែលព្រឹទ្ធសភាថ្មីចូលកាន់តំណែង។

ក្នុងពេលមានសង្គ្រាម ឬក្នុងកាលៈទេសៈពិសេសដទៃទៀត ដែលមិនអាចធ្វើការបោះឆ្នោតកើត ព្រឹទ្ធសភាអាចប្រកាសបន្តនីតិកាលរបស់ខ្លួនមួយដងបានមួយឆ្នាំ តាមសំណើរបស់ព្រះមហាក្សត្រ។

ការប្រកាសបន្តនីតិកាលរបស់ព្រឹទ្ធសភា ត្រូវសម្រេចដោយមតិយល់ព្រមពីរភាគបីយ៉ាងតិចនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។

ក្នុងកាលៈទេសៈដូចបានរៀបរាប់ខាងលើ ព្រឹទ្ធសភាប្រជុំរាល់ថ្ងៃជាប់ជាប្រចាំ។ ព្រឹទ្ធសភាមានសិទ្ធិសម្រេចបញ្ចប់កាលៈទេសៈពិសេសខាងលើនេះ កាលបើសភាពការណ៍អនុញ្ញាត។ ប៉ុន្តែ ការសម្រេចបញ្ចប់កាលៈទេសៈពិសេស ដែលប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ព្រឹទ្ធសភាត្រូវសម្រេចរួមគ្នាជាមួយរដ្ឋសភាក្នុងសមាជរដ្ឋសភានិងព្រឹទ្ធសភា វៀរលែងតែការអនុវត្តមាត្រា៨៦ នៃរដ្ឋធម្មនុញ្ញ។

បើព្រឹទ្ធសភាមិនអាចប្រជុំបានទេ ដោយមូលហេតុចាំបាច់ ជាអាទិ៍ នៅពេលដែលកម្លាំងបរទេសចូលមកកាន់កាប់ទឹកដី ការប្រកាសភាពអាសន្នត្រូវបន្តទៅមុខជាស្វ័យប្រវត្តិ។

**មាត្រា ១០៣.- ថ្មី**

អាណត្តិនៃសមាជិកព្រឹទ្ធសភាមានវិសមិតភាពជាមួយការបំពេញមុខងារសាធារណៈជាសកម្ម ជាមួយមុខងារជាតំណាងរាស្ត្រនិងជាមួយមុខងារជាសមាជិកស្ថាប័នដទៃទៀត ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ។

**មាត្រា ១០៤.- ថ្មី**

សមាជិកព្រឹទ្ធសភា មានអភ័យឯកសិទ្ធិសភា។

សមាជិកព្រឹទ្ធសភារូបណាក៏ដោយមិនអាចត្រូវបានចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួនឬឃុំខ្លួន ដោយហេតុពីបានសំដែងយោបល់ឬបញ្ចេញមតិក្នុងការបំពេញមុខងាររបស់ខ្លួនសោះឡើយ។ ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនសមាជិកណាមួយនៃព្រឹទ្ធសភានឹងអាចធ្វើទៅកើត លុះត្រាតែមាន ការយល់ព្រមពីព្រឹទ្ធសភា ឬពីគណៈកម្មាធិការអចិន្ត្រៃយ៍របស់ព្រឹទ្ធសភា ក្នុងចន្លោះសម័យប្រជុំនៃព្រឹទ្ធសភា វៀរលែងតែក្នុងករណីបទល្មើសព្រហ្មទ័ណ្ឌជាក់ស្តែង។ ក្នុងករណីចុងក្រោយនេះ ក្រសួងមានសមត្ថកិច្ច ត្រូវធ្វើសេចក្តីរាយការណ៍ជូនព្រឹទ្ធសភាឬជូនគណៈកម្មាធិការអចិន្ត្រៃយ៍របស់ព្រឹទ្ធសភាជាបន្ទាន់ដើម្បីសំរេច។

សេចក្តីសំរេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍របស់ព្រឹទ្ធសភាត្រូវដាក់ជូនសម័យប្រជុំព្រឹទ្ធសភាខាងមុខ ដើម្បីអនុម័តតាមមតិភាគច្រើនពីរភាគបីនៃសមាជិកព្រឹទ្ធសភាទាំងមូល។

ក្នុងករណីទាំងអស់ខាងលើនេះ ការឃុំខ្លួន ការចោទប្រកាន់សមាជិកព្រឹទ្ធសភាណាមួយត្រូវផ្អាក ប្រសិនបើព្រឹទ្ធសភាបានបញ្ចេញមតិឱ្យផ្អាកតាមមតិភាគច្រើនបីភាគបួននៃសមាជិកព្រឹទ្ធសភាទាំងមូល។

## មាត្រា ១០៥.- ថ្មី

ព្រឹទ្ធសភាមានថវិកាស្វ័យតសំរាប់ដំណើរការ។

សមាជិកព្រឹទ្ធសភាត្រូវទទួលប្រាក់បំណាច់។

## មាត្រា ១០៦.- ថ្មី(ពីរ)

ព្រឹទ្ធសភាបើកសម័យប្រជុំដំបូង ហុកសិបថ្ងៃយ៉ាងយូរក្រោយពេលបោះឆ្នោត តាមការកោះប្រជុំរបស់ព្រះមហាក្សត្រ។

មុនចាប់ផ្តើមការងាររបស់ខ្លួន ព្រឹទ្ធសភាត្រូវប្រកាសសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗ និងត្រូវបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នានូវប្រធាន អនុប្រធានព្រឹទ្ធសភា និងសមាជិកទាំងអស់នៃគណៈកម្មការនានារបស់ព្រឹទ្ធសភា ដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។

ប្រធានព្រឹទ្ធសភា ត្រូវបោះឆ្នោតជ្រើសរើសចេញពីសមាជិកព្រឹទ្ធសភា ដែលមានសញ្ជាតិខ្មែរតែមួយគត់។

សមាជិកព្រឹទ្ធសភាទាំងអស់ ត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់តំណែង ដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធទី៧ នៃរដ្ឋធម្មនុញ្ញ។

## មាត្រា ១០៧.- ថ្មី

ព្រឹទ្ធសភាប្រជុំជាសាមញ្ញពីរដងក្នុងមួយឆ្នាំ។

សម័យប្រជុំនីមួយៗមានថិរៈវេលាយ៉ាងតិចបីខែ។ បើមានសំណូមពរពីព្រះមហាក្សត្រឬសេចក្តីស្នើសុំពីនាយករដ្ឋមន្ត្រី ឬពីសមាជិកព្រឹទ្ធសភាចំនួនមួយភាគបីយ៉ាងតិច ព្រឹទ្ធសភាកោះប្រជុំជាវិសាមញ្ញ។

**មាត្រា ១០៨.- ថ្មី**

នៅចន្លោះសម័យប្រជុំរបស់ព្រឹទ្ធសភា គណៈកម្មាធិការអចិន្ត្រៃយ៍របស់ព្រឹទ្ធសភាទទួលភារកិច្ចចាត់ចែងការងារ។

គណៈកម្មាធិការអចិន្ត្រៃយ៍របស់ព្រឹទ្ធសភារួមមាន : ប្រធានព្រឹទ្ធសភា អនុប្រធាន ព្រឹទ្ធសភា និងប្រធានគណៈកម្មការទាំងអស់របស់ព្រឹទ្ធសភា។

**មាត្រា ១០៩.- ថ្មី**

សម័យប្រជុំព្រឹទ្ធសភាត្រូវធ្វើនៅរាជធានីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងសាលប្រជុំរបស់ព្រឹទ្ធសភា លើកលែងតែមានការសំរេចផ្សេងចុះក្នុងលិខិតកោះប្រជុំដោយកាលៈទេសៈតម្រូវ។

ក្រៅពីករណីខាងលើនិងក្រៅពីកន្លែង និងកាលបរិច្ឆេទដែលកំណត់ក្នុងសេចក្តីអញ្ជើញ ការប្រជុំណាក៏ដោយរបស់ព្រឹទ្ធសភាត្រូវទុកជាខុសច្បាប់ ហើយអសារសូន្យពេញលក្ខណៈ។

**មាត្រា ១១០.- ថ្មី**

ប្រធានព្រឹទ្ធសភាដឹកនាំអង្គប្រជុំរបស់ព្រឹទ្ធសភា ទទួលអាញត្តិច្បាប់និងសេចក្តីសំរេចចិត្តទាំងឡាយដែលព្រឹទ្ធសភាបានអនុម័ត រ៉ាប់រងការអនុវត្តបទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភានិងចាត់ចែងការទាក់ទងអន្តរជាតិទាំងឡាយរបស់ព្រឹទ្ធសភា។

ក្នុងករណីដែលប្រធានព្រឹទ្ធសភាមានធុរៈ មិនអាចបំពេញមុខងារបាន ដោយហេតុមកពីមានជម្ងឺឬបំពេញមុខងារជាប្រមុខរដ្ឋស្តីទី ឬជាព្រះរាជានុសិទ្ធិ ឬបំពេញបេសកកម្មនៅបរទេស អនុប្រធានព្រឹទ្ធសភាមួយរូប ត្រូវទទួលភារកិច្ចចាត់ចែងការងារជំនួស។

ក្នុងករណីដែលប្រធាន ឬអនុប្រធានព្រឹទ្ធសភាលាលែងពីមុខតំណែងឬទទួលអនិច្ចកម្ម ព្រឹទ្ធសភាត្រូវបោះឆ្នោតជ្រើសតាំងប្រធាន ឬអនុប្រធានថ្មី។

**មាត្រា ១១១.- ថ្មី(ពីរ)**

ការប្រជុំព្រឹទ្ធសភាត្រូវធ្វើជាសាធារណៈ។

ព្រឹទ្ធសភាអាចប្រជុំជាសម្ងាត់បានតាមការស្នើសុំពីប្រធាន ឬ ពីសមាជិកចំនួនមួយភាគដប់យ៉ាងតិច ពីព្រះមហាក្សត្រ ពីនាយករដ្ឋមន្ត្រី ឬ ពីប្រធានរដ្ឋសភា។

ការប្រជុំព្រឹទ្ធសភានឹងយកជាការបាន លុះត្រាតែមាន :

ក-កូរ៉ុមលើសពី ពីរភាគបី នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូលសម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឱ្យយកមតិភាគច្រើន ពីរភាគបីនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។

ខ-កូរ៉ុមលើសពីពាក់កណ្តាលនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូលសម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឱ្យយកមតិភាគច្រើនដោយប្រៀប ឬ យកមតិភាគច្រើនដាច់ខាត នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។

ចំនួនសំឡេងដែលតម្រូវសម្រាប់រដ្ឋសភាអនុម័តយល់ព្រម ហើយដែលមានកំណត់ក្នុងរដ្ឋធម្មនុញ្ញត្រូវយកមកប្រើសម្រាប់ព្រឹទ្ធសភាផងដែរ។

## មាត្រា ១១២.- ថ្មី

ព្រឹទ្ធសភាមានភារកិច្ចសម្របសម្រួលការងាររវាងរដ្ឋសភានិងរដ្ឋាភិបាល។

## មាត្រា ១១៣.- ថ្មី

ព្រឹទ្ធសភាពិនិត្យហើយឱ្យយោបល់ក្នុងរយៈពេលមួយខែយ៉ាងយូរ លើសេចក្តីព្រាងច្បាប់ឬសេចក្តីស្នើច្បាប់ដែលរដ្ឋសភាបានអនុម័តយល់ព្រមលើកដំបូងរួចហើយ ព្រមទាំងលើបញ្ហាទាំងពួងដែលរដ្ឋសភាបានដាក់ឱ្យពិនិត្យ។ បើជាការប្រញាប់ រយៈពេលនោះត្រូវបន្ថយមកនៅត្រឹមតែប្រាំថ្ងៃ។

បើព្រឹទ្ធសភាបានឱ្យយោបល់យល់ព្រមឬពុំបានឱ្យយោបល់សោះក្នុងរយៈពេលដែលមានកំណត់ទុកហើយនោះទេ ច្បាប់ដែលរដ្ឋសភាបានអនុម័តយល់ព្រមហើយនោះ នឹងត្រូវបានយកទៅប្រកាសឱ្យប្រើ។

បើព្រឹទ្ធសភាសុំឱ្យកែសំរួលសេចក្តីព្រាងច្បាប់ឬសេចក្តីស្នើច្បាប់នោះ រដ្ឋសភាត្រូវយកមកពិចារណាភ្លាមជាលើកទីពីរ។ រដ្ឋសភាត្រូវពិនិត្យនិងសំរេចតែត្រង់បទប្បញ្ញត្តិ ឬចំណុចណាដែលព្រឹទ្ធសភាសុំឱ្យកែសំរួល ដោយបដិសេធចោលទាំងមូលឬទុកជាបានការខ្លះ។

ការបង្វិលទៅបង្វិលមករវាងព្រឹទ្ធសភានិងរដ្ឋសភា ត្រូវធ្វើតែក្នុងរយៈពេលមួយខែ។ រយៈពេលនេះត្រូវបន្ថយមកត្រឹមដប់ថ្ងៃ បើត្រូវពិនិត្យសំរេចពីថវិកាជាតិ និងហិរញ្ញវត្ថុ ហើយមកត្រឹមតែពីរថ្ងៃ បើជាការប្រញាប់។

បើរដ្ឋសភាទុកឱ្យហួសរយៈពេលកំណត់ ឬពន្យារពេលដែលកំណត់ទុកសំរាប់ពិនិត្យនោះ រយៈពេលជាគោលការណ៍សំរាប់រដ្ឋសភានិងព្រឹទ្ធសភាត្រូវបន្ថែមឱ្យស្មើគ្នាដែរ។

បើព្រឹទ្ធសភាបដិសេធសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នោះជាអសារបង់ រដ្ឋសភាមិនអាចនឹងយកមកពិចារណាជាលើកទីពីរបា មុនរយៈពេលមួយខែទេ។ រយៈពេលនេះត្រូវបន្ថយមកត្រឹមដប់ប្រាំថ្ងៃ បើពិនិត្យពីថវិកាជាតិ និងហិរញ្ញវត្ថុ ហើយមកត្រឹមតែបួនថ្ងៃ បើជាការប្រញាប់។

ក្នុងការពិនិត្យសេចក្តីព្រាងច្បាប់ឬសេចក្តីស្នើច្បាប់ជាលើកទី ២ នេះ រដ្ឋសភាត្រូវអនុម័តដោយវិធីបោះឆ្នោតចំហនិងយកតាមមតិភាគច្រើនដាច់ខាត។

សេចក្តីព្រាងច្បាប់ឬសេចក្តីស្នើច្បាប់ណាដែលបានសំរេចដូចខាងលើនេះហើយនោះ នឹងត្រូវបានយកទៅប្រកាសឱ្យប្រើ។

**មាត្រា ១១៤.- ថ្មី(មួយ)**

ព្រឹទ្ធសភាបង្កើតគណៈកម្មការផ្សេងៗ ដែលចាំបាច់។ ការរៀបចំនិងការប្រព្រឹត្តទៅនៃព្រឹទ្ធសភា នឹងកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភា។ បទបញ្ជាផ្ទៃក្នុងនេះត្រូវអនុម័តយល់ព្រម ដោយសំឡេងភាគច្រើនដាច់ខាតនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។

**មាត្រា ១១៥.- ថ្មី**

ក្នុងករណីមានសមាជិកព្រឹទ្ធសភាទទួលអនិច្ចកម្ម លាលែងឬប្រាសចាកសមាជិកភាពដែលកើតមានឡើងប្រាំមួយខែយ៉ាងតិចមុនចប់នីតិកាល ត្រូវចាត់តាំងឬជ្រើសតាំងជំនួសសមាជិកនោះ តាមល័ក្ខខ័ណ្ឌកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងនៃព្រឹទ្ធសភា និងក្នុងច្បាប់ស្តីពីការចាត់តាំងនិងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។

## ជំពូកទី ៩ ថ្មី
## អំពី
## សមាជរដ្ឋសភានិងព្រឹទ្ធសភា

**មាត្រា ១១៦.- ថ្មី**

ក្នុងករណីចាំបាច់ រដ្ឋសភានិងព្រឹទ្ធសភាអាចប្រជុំរួមគ្នាជាសមាជ ដើម្បីដោះស្រាយបញ្ហាសំខាន់ៗរបស់ប្រទេសជាតិ។

**មាត្រា ១១៧.- ថ្មី**

បញ្ហាសំខាន់ៗរបស់ប្រទេសជាតិដូចមានចែងក្នុងមាត្រា ១១៦ ថ្មី ខាងលើ ព្រមទាំងការរៀបចំនិងការប្រព្រឹត្តទៅនៃសមាជ នឹងត្រូវកំណត់ក្នុងច្បាប់មួយ។

## ជំពូកទី ១០ ថ្មី
## អំពី
## រាជរដ្ឋាភិបាល

**មាត្រា១១៨.- ថ្មី(មួយ)**

គណៈរដ្ឋមន្ត្រីជារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

គណៈរដ្ឋមន្ត្រី ត្រូវបានដឹកនាំដោយនាយករដ្ឋមន្ត្រីមួយរូប អមដោយឧបនាយករដ្ឋមន្ត្រី ព្រមទាំងមានទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រី ជាសមាជិក។

**មាត្រា ១១៩.- ថ្មី (ពីរ)**

តាមសេចក្តីស្នើពីគណបក្សដែលមានអាសនៈច្រើនជាងគេក្នុងរដ្ឋសភាព្រះមហាក្សត្រទ្រង់ចាត់តាំងវរជនមួយរូបជានាយករដ្ឋមន្ត្រី ឱ្យបង្កើតរាជរដ្ឋាភិបាល។ សេចក្តីស្នើពីគណបក្សដែលមានអាសនៈច្រើនជាងគេក្នុងរដ្ឋសភានេះ ត្រូវចម្លងជូនប្រធានរដ្ឋសភា។ វរជនដែលនឹងត្រូវទទួលបានការចាត់តាំងជានាយករដ្ឋមន្ត្រីនេះ ត្រូវតែជាតំណាងរាស្ត្រដែលមានសញ្ជាតិខ្មែរតែមួយគត់ និងដែលត្រូវបានជ្រើសរើសចេញពីគណបក្សដែលមានអាសនៈច្រើនជាងគេក្នុងរដ្ឋសភា។ វរជនដែលត្រូវបានចាត់តាំងនេះ នាំសហការីដែលជាតំណាងរាស្ត្រ ឬជាសមាជិកគណបក្សតំណាងនៅក្នុងរដ្ឋសភាដែលផ្តូផ្តងឱ្យកាន់តំណែងផ្សេងៗក្នុងរាជរដ្ឋាភិបាល ទៅសុំសេចក្តីទុកចិត្តពីរដ្ឋសភា។ ការបោះឆ្នោតផ្តល់សេចក្តីទុកចិត្តនេះ ត្រូវធ្វើលើបញ្ជីសមាសភាពនៃគណៈរដ្ឋមន្ត្រីទាំងមូល។ កាលបើរដ្ឋសភាបានបោះឆ្នោតទុកចិត្តហើយនោះ ព្រះមហាក្សត្រទ្រង់ចេញព្រះរាជក្រឹត្យតែងតាំងគណៈរដ្ឋមន្ត្រីទាំងមូល។

មុនចូលកាន់តំណែង គណៈរដ្ឋមន្ត្រីត្រូវធ្វើសច្ចាប្រណិធានដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធទី៦។

នៅពេលផុតនីតិកាលនីមួយៗរបស់រដ្ឋសភា រាជរដ្ឋាភិបាលដែលត្រូវចេញពីតំណែង មានតែភារកិច្ចដឹកនាំការងារប្រចាំថ្ងៃតែប៉ុណ្ណោះ រហូតដល់មានរាជរដ្ឋាភិបាលថ្មីចូលកាន់តំណែង។

**មាត្រា ១២០.- ថ្មី (មាត្រា ១០១ ចាស់)**

មុខងារនៃសមាជិករាជរដ្ឋាភិបាល មានវិសមិតភាពនិងសកម្មភាពខាងវិជ្ជាជីវៈផ្នែកពាណិជ្ជកម្ម ឬឧស្សាហកម្ម ហើយនិងការកាន់តំណែងណាមួយក្នុងមុខងារសាធារណៈ។

**មាត្រា ១២១.- ថ្មី (មាត្រា ១០២ ចាស់)**

សមាជិកទាំងឡាយនៃរាជរដ្ឋាភិបាលទទួលខុសត្រូវរួមគ្នាចំពោះរដ្ឋសភាអំពីនយោបាយទូទៅរបស់រាជរដ្ឋាភិបាល។

សមាជិកមួយរូបៗនៃរាជរដ្ឋាភិបាលទទួលខុសត្រូវរៀងខ្លួន ចំពោះនាយករដ្ឋមន្ត្រីនិងចំពោះរដ្ឋសភាអំពីការដែលខ្លួនបានប្រព្រឹត្ត។

**មាត្រា ១២២.- ថ្មី (មាត្រា ១០៣ ចាស់)**

សមាជិកទាំងឡាយនៃរាជរដ្ឋាភិបាលមិនអាចយកសំអាងនៃសេចក្តីបង្គាប់ដោយលាយលក្ខអក្សរ ឬដោយវាចាអំពីនរណាមួយ ដើម្បីដោះសាឱ្យរួចខ្លួនពីការទទួលខុសត្រូវរបស់ខ្លួនបានឡើយ។

**មាត្រា ១២៣.- ថ្មី ( មាត្រា ១០៤ ចាស់ )**

គណៈរដ្ឋមន្ត្រីត្រូវប្រជុំរាល់សប្តាហ៍ ជាប្រជុំធំឬជាប្រជុំពិនិត្យស្រាវជ្រាវ។

អង្គប្រជុំធំត្រូវដឹកនាំដោយនាយករដ្ឋមន្ត្រី។ នាយករដ្ឋមន្ត្រីអាចប្រគល់ភារកិច្ចជូនឧបនាយករដ្ឋមន្ត្រីដឹកនាំអង្គប្រជុំពិនិត្យស្រាវជ្រាវបាន។

កំណត់ហេតុនៃអង្គប្រជុំទាំងអស់របស់គណៈរដ្ឋមន្ត្រី ត្រូវធ្វើថ្វាយព្រះមហាក្សត្រទ្រង់ជ្រាប។

**មាត្រា ១២៤.- ថ្មី ( មាត្រា ១០៥ ចាស់ )**

នាយករដ្ឋមន្ត្រីអាចវេរលែកអំណាចរបស់ខ្លួនឱ្យទៅឧបនាយករដ្ឋមន្ត្រី ឬសមាជិកណាមួយនៃរាជរដ្ឋាភិបាលបាន។

**មាត្រា ១២៥.- ថ្មី( មួយ )**

ក្នុងករណីដែលនាយករដ្ឋមន្ត្រីអវត្តមានមួយកាលមួយគ្រា នាយករដ្ឋមន្ត្រីត្រូវចាត់តាំងឧបនាយករដ្ឋមន្ត្រីមួយរូប ឱ្យធ្វើជានាយករដ្ឋមន្ត្រីស្តីទីដើម្បីទទួលភារកិច្ចដឹកនាំគណៈរដ្ឋមន្ត្រីជំនួសជាបណ្តោះអាសន្ន។

បើតំណែងនាយករដ្ឋមន្ត្រីនៅទំនេរជាស្ថាពរ ដោយហេតុជាអាទិ៍មកពីការទទួលអនិច្ចកម្ម ឬការលាលែងពីមុខតំណែង គណៈរដ្ឋមន្ត្រីថ្មីមួយត្រូវតែងតាំងជាបន្ទាន់ ក្នុងលក្ខខណ្ឌដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនេះ។ ប្រធានរដ្ឋសភាត្រូវកោះប្រជុំរដ្ឋសភាជាបន្ទាន់ និងត្រូវធ្វើចំណាត់ការចាំបាច់ដទៃទៀតដោយរួសរាន់ ក្នុងរយៈវេលា ៧ថ្ងៃយ៉ាងយូរបន្ទាប់ពីបានទទួលសំណើពីគណបក្សដែលមានអាសនៈច្រើនជាងគេក្នុងរដ្ឋសភា។

ក្នុងករណីតំណែងនាយករដ្ឋមន្ត្រីនៅទំនេរជាស្ថាពរ ដោយហេតុមកពីការទទួលអនិច្ចកម្ម គណៈរដ្ឋមន្ត្រីដែលត្រូវចេញពីតំណែង ក្រោមការដឹកនាំ របស់ឧបនាយករដ្ឋមន្ត្រីដែលទទួលបានការចាត់តាំងជានាយករដ្ឋមន្ត្រីស្តីទីមានតែភារកិច្ចដឹកនាំការងារប្រចាំថ្ងៃតែប៉ុណ្ណោះ រហូតដល់មានគណៈរដ្ឋមន្ត្រីថ្មីចូលកាន់តំណែង។

ការលាលែងពីមុខតំណែងរបស់នាយករដ្ឋមន្ត្រី ត្រូវធ្វើឡើងតាមលិខិតលាលែងពីមុខតំណែងដែលត្រូវធ្វើថ្វាយព្រះមហាក្សត្រ និងចម្លងជូនប្រធានរដ្ឋសភា។ ក្នុងករណីនេះ គណៈរដ្ឋមន្ត្រីដែលត្រូវចេញពីតំណែង ត្រូវបន្តដឹកនាំការងាររបស់រាជរដ្ឋាភិបាល រហូតដល់គណៈរដ្ឋមន្ត្រីថ្មីចូលកាន់តំណែង។

**មាត្រា ១២៦.- ថ្មី ( មាត្រា ១០៧ ចាស់ )**

សមាជិកមួយរូបៗនៃរាជរដ្ឋាភិបាលត្រូវទទួលទណ្ឌកម្មពីបទឧក្រិដ្ឋ ឬបទមជ្ឈិមដែលខ្លួនបានប្រព្រឹត្តក្នុងការបំពេញការងាររបស់ខ្លួន។

ក្នុងករណីនេះនិងក្នុងករណីធ្វើខុសជាទម្ងន់ ក្នុងការបំពេញការងាររបស់ខ្លួនរដ្ឋសភាអាចសំរេចប្តឹងទៅតុលាការមានសមត្ថកិច្ច។

រដ្ឋសភាសំរេចក្នុងរឿងនេះ ដោយវិធីបោះឆ្នោតជាសម្ងាត់ តាមមតិភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល។

**មាត្រា ១២៧.- ថ្មី** (**មាត្រា ១០៨ ចាស់**)

ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី នឹងត្រូវកំណត់ក្នុងច្បាប់មួយ។

## ជំពូកទី ១១ ថ្មី
## អំពី
## អំណាចតុលាការ

**មាត្រា ១២៨.- ថ្មី** (**មាត្រា ១០៩ ចាស់**)

អំណាចតុលាការជាអំណាចឯករាជ្យ ។

អំណាចតុលាការជានារក្សាអនាគតិនិងការពារសិទ្ធិ សេរីភាពរបស់ប្រជាពលរដ្ឋ។

អំណាចតុលាការគ្របដណ្តប់ទៅលើរឿងក្តីទាំងអស់រួមទាំងរឿងក្តីរដ្ឋបាលផង។

អំណាចនេះ ត្រូវប្រគល់ឱ្យតុលាការកំពូលនិងសាលាជំរះក្តីគ្រប់ផ្នែក និងគ្រប់ជាន់ថ្នាក់។

**មាត្រា ១២៩.- ថ្មី** (**មាត្រា ១១០ ចាស់**)

ការជំរះក្តីផ្តល់យុត្តិធម៌ ត្រូវធ្វើក្នុងនាមប្រជារាស្ត្រខ្មែរ តាមនីតិវិធីនិងច្បាប់ជាធរមាន។

មានតែចៅក្រមទេដែលមានសិទ្ធិជំរះក្តី។ ចៅក្រមត្រូវបំពេញភារកិច្ចនេះ ដោយគោរពច្បាប់យ៉ាងម៉ឺងម៉ាត់និងឱ្យអស់ពីដួងចិត្តនិងសម្បជញ្ញៈរបស់ខ្លួន។

**មាត្រា ១៣០.- ថ្មី** (**មាត្រា ១១១ ចាស់**)

គ្មានអង្គការណាមួយនៃអំណាចនីតិបញ្ញត្តិ ឬនីតិប្រតិបត្តិអាចទទួលអំណាចតុលាការអ្វីបានឡើយ។

**មាត្រា ១៣១.- ថ្មី** (**មាត្រា ១១២ ចាស់**)

មានតែអង្គការអយ្យការទេ ដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា។

**មាត្រា ១៣២.- ថ្មី** (**មាត្រា ១១៣ ចាស់**)

ព្រះមហាក្សត្រទ្រង់ជាអ្នកធានាឯករាជ្យនៃអំណាចតុលាការ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមជួយព្រះមហាក្សត្រក្នុងកិច្ចការនេះ។

**មាត្រា ១៣៣.- ថ្មី (មាត្រា ១១៤ ចាស់)**

ចៅក្រមមិនអាចត្រូវគេដកពីមុខងារបានទេ។ ប៉ុន្តែឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រមសំរេចដាក់វិន័យលើចៅក្រមដែលបានប្រព្រឹត្តខុស។

**មាត្រា ១៣៤.- ថ្មី (មាត្រា ១១៥ ចាស់)**

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនឹងត្រូវបង្កើតដោយច្បាប់រៀបចំអង្គការមួយដែលនឹងកំណត់សមាសភាពនិងមុខងារ។

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមស្ថិតក្រោមព្រះរាជាធិបតីភាពនៃព្រះមហាក្សត្រ។ ព្រះមហាក្សត្រព្រះអង្គទ្រង់អាចចាត់តាំងព្រះរាជតំណាងម្នាក់របស់ព្រះអង្គឱ្យធ្វើជាអធិបតីនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនេះ។

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម លើកសេចក្តីស្នើថ្វាយព្រះមហាក្សត្រអំពីកងតាំងចៅក្រមនិងព្រះរាជអាជ្ញាអមសាលាជំរះក្តីទាំងអស់។

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្នុងមុខការដាក់វិន័យចំពោះចៅក្រម និងព្រះរាជអាជ្ញាក្រោមអធិបតីភាពនៃប្រធានតុលាការកំពូលឬអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល អាស្រ័យដោយករណីទាក់ទងនឹងចៅក្រមឬព្រះរាជអាជ្ញា។

**មាត្រា ១៣៥.- ថ្មី (មាត្រា ១១៦ ចាស់)**

លក្ខន្តិកៈនៃចៅក្រមនិងព្រះរាជអាជ្ញានិងការរៀបចំអង្គការតុលាការនឹងត្រូវកំណត់ក្នុងច្បាប់ដោយឡែកពីគ្នា។

## ជំពូកទី ១២ ថ្មី
## អំពី
## ក្រុមប្រឹក្សាធម្មនុញ្ញ

**មាត្រា ១៣៦.- ថ្មី**

ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចធានាការពារការគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ។

ក្រុមប្រឹក្សាធម្មនុញ្ញមានសិទ្ធិពិនិត្យ និងសំរេចអំពីករណីវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។

**មាត្រា ១៣៧.- ថ្មី(មួយ)**

ក្រុមប្រឹក្សាធម្មនុញ្ញមានសមាជិកប្រាំបួនរូប ដែលទទួលអាណត្តិប្រាំបួនឆ្នាំ។ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញចំនួនមួយភាគបី ត្រូវផ្លាស់ថ្មីក្នុងរយៈពេល បីឆ្នាំម្តង បីឆ្នាំម្តង។ សមាជិកបីរូបត្រូវតែងតាំងដោយព្រះមហាក្សត្រ បីរូបត្រូវជ្រើសតាំងដោយរដ្ឋសភា ហើយបីរូបទៀតត្រូវតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

ប្រធានត្រូវបានជ្រើសតាំងដោយសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ពីក្នុងចំណោមសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ដែលមានសញ្ជាតិខ្មែរពីកំណើត និងមានសញ្ជាតិខ្មែរតែមួយគត់។ ប្រធានមានសំឡេងឧត្តមានុភាពក្នុងករណីបែកសំឡេងជាពីរស្មើគ្នា។

**មាត្រា ១៣៨.- ថ្មី (មាត្រា ១១៩ ចាស់)**

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញត្រូវជ្រើសរើសក្នុងចំណោមឥស្សរជន ដែលមានសញ្ញាប័ត្រចាប់ពីឧត្តមសិក្សាទៅ ខាងច្បាប់ ខាងរដ្ឋបាល ខាងការទូត ឬខាងសេដ្ឋកិច្ច ហើយមានពិសោធន៍ច្រើនក្នុងការងារ។

**មាត្រា ១៣៩.-ថ្មី**

មុខងារសមាជិកក្រុមប្រឹក្សាធម្មនុញ្ញមានវិសមិតភាពនឹងមុខងារ សមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា សមាជិករាជរដ្ឋាភិបាល ចៅក្រមក្នុងតំណែង ការកាន់តំណែងណាមួយក្នុងមុខងារសាធារណៈ ប្រធានឬអនុប្រធានគណបក្សនយោបាយ ប្រធាន ឬអនុប្រធានសហជីព។

**មាត្រា ១៤០.- ថ្មី**

ព្រះមហាក្សត្រ នាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា តំណាងរាស្ត្រចំនួនមួយភាគដប់ ប្រធានព្រឹទ្ធសភាឬសមាជិកព្រឹទ្ធសភាចំនួនមួយភាគបួន អាចបញ្ជូនច្បាប់ដែលរដ្ឋសភាបានអនុម័តទៅឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុននឹងច្បាប់នោះត្រូវប្រកាសឱ្យប្រើ។

បទបញ្ជាផ្ទៃក្នុងរដ្ឋសភា បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភានិងច្បាប់រៀបចំអង្គការទាំងឡាយ ត្រូវតែបញ្ជូនទៅក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ មុននឹងប្រកាសឱ្យប្រើ។ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសំរេចក្នុងរយៈពេលសាមសិប (៣០)ថ្ងៃយ៉ាងយូរ ថាតើច្បាប់ បទបញ្ជាផ្ទៃក្នុងរដ្ឋសភានិងបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភាខាងលើស្របឬមិនស្របនឹងរដ្ឋធម្មនុញ្ញ។

**មាត្រា ១៤១.- ថ្មី**

ក្រោយពីច្បាប់ណាមួយត្រូវបានប្រកាសឱ្យប្រើ ព្រះមហាក្សត្រ ប្រធាន ព្រឹទ្ធសភា ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី សមាជិកព្រឹទ្ធសភាចំនួនមួយភាគបួន តំណាងរាស្ត្រចំនួនមួយភាគដប់ឬតុលាការអាចសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ អំពីធម្មនុញ្ញភាពនៃច្បាប់នោះ។

ប្រជារាស្ត្រមានសិទ្ធិប្ដឹងអំពីធម្មនុញ្ញភាពនៃច្បាប់បាន តាមរយៈតំណាងរាស្ត្រឬប្រធានរដ្ឋសភា ឬសមាជិកព្រឹទ្ធសភាឬប្រធានព្រឹទ្ធសភា ដូចមានចែងក្នុងវាក្យខ័ណ្ឌខាងលើ។

**មាត្រា ១៤២.- ថ្មី** ( **មាត្រា ១២៣ ចាស់** )

បទប្បញ្ញត្តិក្នុងមាត្រាណាដែលក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាមិនស្របនឹងរដ្ឋធម្មនុញ្ញ មិនអាចយកទៅប្រកាសឱ្យប្រើឬយកទៅអនុវត្តបានឡើយ។

សេចក្ដីសំរេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញជាសេចក្ដីសំរេចបិទផ្លូវតវ៉ា។

**មាត្រា ១៤៣.- ថ្មី** ( **មាត្រា ១២៤ ចាស់** )

ព្រះមហាក្សត្រទ្រង់ពិគ្រោះមតិក្រុមប្រឹក្សាធម្មនុញ្ញ ចំពោះសេចក្ដីស្នើទាំងឡាយដែលសុំធ្វើវិសោធនកម្មលើរដ្ឋធម្មនុញ្ញ។

**មាត្រា ១៤៤.- ថ្មី** ( **មាត្រា ១២៥ ចាស់** )

ច្បាប់រៀបចំអង្គការមួយនឹងកំណត់ការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។

## ជំពូកទី ១៣ ថ្មី
## អំពី
## ការគ្រប់គ្រងរដ្ឋបាល

**មាត្រា ១៤៥.- ថ្មី**( **មួយ** )

ទឹកដីនៃព្រះរាជាណាចក្រកម្ពុជាចែកជា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។

**មាត្រា ១៤៦.- ថ្មី**( **មួយ** )

រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ត្រូវគ្រប់គ្រងតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងច្បាប់រៀបចំអង្គការ។

## ជំពូកទី ១៤ ថ្មី
## អំពី
## សមាជជាតិ

**មាត្រា ១៤៧.- ថ្មី** ( **មាត្រា ១២៨ ចាស់** )

សមាជជាតិបើកឱ្យប្រជារាស្ត្រជ្រាបដោយផ្ទាល់ អំពីកិច្ចការផ្សេងៗដែលជាប្រយោជន៍ជាតិនិងលើកបញ្ហា និងសំណូមពរជូនរដ្ឋអំណាចដោះស្រាយ។

ប្រជារាស្ត្រខ្មែរទាំងពីរភេទមានសិទ្ធិទៅចូលរួមក្នុងសមាជជាតិ។

**មាត្រា ១៤៨.- ថ្មី ( មាត្រា ១២៩ ចាស់ )**

សមាជជាតិប្រជុំមួយដងក្នុងមួយឆ្នាំ នៅដើមខែធ្នូ តាមការកោះអញ្ជើញរបស់នាយករដ្ឋមន្ត្រី។

សមាជជាតិប្រព្រឹត្តទៅក្រោមព្រះរាជាធិបតីភាពនៃព្រះមហាក្សត្រ។

**មាត្រា ១៤៩.- ថ្មី**

សមាជជាតិអនុម័តសំណូមពរជូនព្រឹទ្ធសភា ជូនរដ្ឋសភា និងជូនរដ្ឋអំណាចពិចារណា។

ការរៀបចំនិងការប្រព្រឹត្តទៅនៃសមាជជាតិនឹងត្រូវកំណត់ក្នុងច្បាប់មួយ។

## ជំពូកទី ១៥ ថ្មី ( ពីរ )
## អំពី
## អង្គការរៀបចំការបោះឆ្នោត

**មាត្រា ១៥០.- ថ្មី ( ពីរ )**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គឺជាអង្គការដែលមានសមត្ថកិច្ចរៀបចំចាត់ចែង និងគ្រប់គ្រងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ព្រមទាំងការបោះឆ្នោតផ្សេងទៀត តាមការកំណត់នៃច្បាប់។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវអនុវត្តសមត្ថកិច្ចរបស់ខ្លួន ប្រកបដោយឯករាជ្យ និងអព្យាក្រឹត ដើម្បីធានាឲ្យការបោះឆ្នោតប្រព្រឹត្តទៅ ដោយសេរីត្រឹមត្រូវ និងយុត្តិធម៌ ស្របតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស។

មុខងារជាសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានវិសមិតភាពជាមួយការបំពេញមុខតំណែងក្នុងមុខងារសាធារណៈនិងជាមួយមុខងារជាសមាជិកនៃស្ថាប័នដទៃទៀតដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនេះ។ សមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមិនអាចធ្វើជាសមាជិកនៃ គណបក្សនយោបាយ ឬធ្វើជាអ្នកដឹកនាំនៃអង្គការមិនមែនរដ្ឋាភិបាល សមាគម សហជីព ឬក្រុមហ៊ុនពាណិជ្ជកម្មណាមួយបានឡើយ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានថវិកាស្វយ័តសម្រាប់ដំណើរការ។

**មាត្រា ១៥១.- ថ្មី ( ពីរ )**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានសមាសភាពប្រាំបួនរូបដែលទទួលអាណត្តិប្រាំឆ្នាំ។ សមាសភាពបួនរូបត្រូវជ្រើសរើសដោយគណបក្សដឹកនាំរាជរដ្ឋាភិបាល បួនរូបត្រូវជ្រើសរើសដោយគណបក្សមានអាសនៈក្នុងរដ្ឋសភាដែលមិនចូលរួមក្នុងរាជរដ្ឋាភិបាល និងមួយរូប ត្រូវជ្រើសរើសដោយមានការព្រមព្រៀងគ្នារវាងគណបក្សទាំងអស់ដែលមានអាសនៈក្នុងរដ្ឋសភា។

គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ត្រូវដំណើរការរៀបចំឲ្យមានការជ្រើសរើសដោយបើកចំហ និងតម្លាភាព នូវសមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា រៀបចំបញ្ជីសមាសភាព គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដាក់ជូនរដ្ឋសភា ដើម្បីបោះឆ្នោតទុកចិត្តតាមមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល។

សមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវតែងតាំងដោយព្រះរាជក្រឹត្យ។

ក្នុងករណីសមាជិកណាមួយនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបាត់បង់សមាជិកភាពរបស់ខ្លួន គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាត្រូវចាត់ នីតិវិធីជ្រើសរើស សមាសភាពថ្មីជំនួស ក្នុងរយៈពេលយ៉ាងយូរ ១៥ ថ្ងៃ គិតពីថ្ងៃបាត់បង់សមាជិកភាព។ នីតិវិធីលំអិតនៃការជ្រើសរើសសមាសភាពថ្មី ជំនួសត្រូវកំណត់ដោយឡែកក្នុងច្បាប់។

ក្នុងករណីដែលខកខានមិនបានរៀបចំសមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវអនុវត្តការងាររបស់ខ្លួនបន្តទៀត និងមានសមត្ថកិច្ចដើម្បី ចាត់ចែងរៀបចំការបោះឆ្នោតតាមច្បាប់។

ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតនឹងត្រូវកំណត់ក្នុងច្បាប់មួយ។

## ជំពូកទី ១៦ ថ្មី (ពីរ)
## អំពី
## អានុភាព ការសើរើ និងវិសោធនកម្មរដ្ឋធម្មនុញ្ញ

### មាត្រា ១៥២.- ថ្មី (ពីរ មាត្រា ១៥០ ថ្មី)

រដ្ឋធម្មនុញ្ញនេះជាច្បាប់កំពូល នៃព្រះរាជាណាចក្រកម្ពុជា។

ច្បាប់ និងសេចក្ដីសម្រេចទាំងឡាយនៃស្ថាប័ននានារបស់រដ្ឋ ត្រូវស្របនឹងរដ្ឋធម្មនុញ្ញជាដាច់ខាត។

### មាត្រា ១៥៣.- ថ្មី (ពីរ មាត្រា ១៥១ ថ្មី)

ការផ្ដើមគំនិតសើរើ ឬការផ្ដើមគំនិតធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញជាសិទ្ធិរបស់ព្រះមហាក្សត្រ របស់នាយករដ្ឋមន្ត្រី និងរបស់ប្រធានរដ្ឋសភា តាមសេចក្ដីស្នើរបស់តំណាងរាស្ត្រមួយភាគបួននៃចំនួនសមាជិករដ្ឋសភាទាំងមូល។

ការសើរើ ឬវិសោធនកម្មរដ្ឋធម្មនុញ្ញ ត្រូវធ្វើឡើងដោយច្បាប់ធម្មនុញ្ញមួយ ដែលអនុម័តដោយរដ្ឋសភា តាមមតិភាគច្រើនពីរភាគបី នៃចំនួនសមាជិករដ្ឋសភាទាំងមូល។

**មាត្រា ១៥៤.- ថ្មី** ( **ពីរ មាត្រា ១៥២ ថ្មី** )

ការសើរើ ឬវិសោធនកម្មរដ្ឋធម្មនុញ្ញ ត្រូវហាមឃាត់មិនឲ្យធ្វើ នៅពេលប្រទេសជាតិឋិតក្នុងភាពអាសន្ន ដូចមានចែងក្នុងមាត្រា ៨៦។

**មាត្រា ១៥៥.- ថ្មី** ( **ពីរ មាត្រា ១៥៣ ថ្មី** )

ការសើរើ ឬវិសោធនកម្មរដ្ឋធម្មនុញ្ញមិនអាចធ្វើបានឡើយ កាលបើប៉ះពាល់ដល់ប្រព័ន្ធប្រជាធិបតេយ្យសេរីពហុបក្ស និងរបបរាជានិយមអាស្រ័យដោយរដ្ឋធម្មនុញ្ញ។

**មាត្រា ១៥៦.- ថ្មី** ( **ពីរ មាត្រា ១៥៤ ថ្មី** )

រដ្ឋធម្មនុញ្ញនេះ ក្រោយពីទទួលបានការអនុម័ត ត្រូវបានប្រកាស់ឲ្យចូលជាធរមានភ្លាម ដោយព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ១៥៧.- ថ្មី** ( **ពីរ មាត្រា ១៥៥ ថ្មី** )

ក្រោយពេលរដ្ឋធម្មនុញ្ញនេះចូលជាធរមាន សភាធម្មនុញ្ញត្រូវក្លាយជារដ្ឋសភា។

បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភាត្រូវចូលជាធរមាន ក្រោយទទួលបានការអនុម័តពីរដ្ឋសភា។

ក្នុងករណីដែលរដ្ឋសភាមិនទាន់ចាប់ដំណើរការបាន ប្រធាន អនុប្រធានទី១ និងអនុប្រធានទី២ នៃសភាធម្មនុញ្ញ និងចូលរួមបំពេញភារកិច្ចក្នុងក្រុមប្រឹក្សារាជសម្បត្តិ បើសភាពការណ៍ក្នុងប្រទេសទាមទារ។

**មាត្រា ១៥៨.- ថ្មី** ( **ពីរ មាត្រា ១៥៦ ថ្មី** )

ក្រោយរដ្ឋធម្មនុញ្ញនេះចូលជាធរមាន ព្រះមហាក្សត្រជ្រើសតាំងតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ១៣ ថ្មី និង១៤។

**មាត្រា ១៥៩.- ថ្មី** ( **ពីរ មាត្រា ១៥៧ ថ្មី** )

នីតិកាលទី ១ នៃព្រឹទ្ធសភាមានកំណត់ ៥ ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលព្រឹទ្ធសភាថ្មីចូលកាន់តំណែង។

សម្រាប់នីតិកាលទី ១ នៃព្រឹទ្ធសភា :

-សមាជិកព្រឹទ្ធសភាមានចំនួនសរុបចំនួនហុកសិបមួយរូប។

-ព្រះមហាក្សត្រទ្រង់តែងតាំងសមាជិកព្រឹទ្ធសភាពីររូប ព្រមទាំងប្រធាន អនុប្រធានទី ១ អនុប្រធានទី ២ នៃព្រឹទ្ធសភា។

-សមាជិកដទៃទៀតនៃព្រឹទ្ធសភា ត្រូវបានតែងតាំងដោយព្រះមហាក្សត្រ តាមសំណើរបស់ប្រធានព្រឹទ្ធសភា និងប្រធានរដ្ឋសភាក្នុងចំណោមសមាជិកនៃគណបក្សដែលមានអាសនៈនៅក្នុងរដ្ឋសភា។

-កិច្ចប្រជុំជាសមាជនៃរដ្ឋសភា និងព្រឹទ្ធសភា ត្រូវដឹកនាំដោយសហប្រធាន។

**មាត្រា ១៦០.. ថ្មី (ពីរ មាត្រា ១៥៨ ថ្មី)**

ច្បាប់ និងលិខិតបទដ្ឋានទាំងអស់នៅកម្ពុជា ដែលជានាការពារបាននូវទ្រព្យសម្បត្តិរដ្ឋ សិទ្ធិសេរីភាព និងទ្រព្យសម្បត្តិត្រឹមត្រូវតាមច្បាប់របស់បុគ្គល និងដែលសមស្របនឹងប្រយោជន៍ជាតិត្រូវមានអនុភាពអនុវត្តបន្តទៅមុខទៀត រហូតដល់មានអត្ថបទថ្មីមកកែប្រែ ឬលុបចោល លើកលែងតែបទប្បញ្ញត្តិណាដែលផ្ទុយនឹងស្មារតីនៃរដ្ឋធម្មនុញ្ញនេះ។

រដ្ឋធម្មនុញ្ញនេះ ត្រូវបានសភាធម្មនុញ្ញអនុម័ត
នៅភ្នំពេញថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ១៩៩៣ នាសម័យប្រជុំពេញអង្គលើកទី ២

ភ្នំពេញ, ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ១៩៩៣

**ប្រធាន**



**សឺន សាន**

# ឧបសម្ព័ន្ធទី១

## ទង់ជាតិ



# ឧបសម្ព័ន្ធទី២

## ភ្លេងជាតិ នគររាជ

១- សូមពួកទេព្តា រក្សា មហាក្សត្រយើង
ឲ្យ បានរុងរឿង ដោយជ័យមង្គល សិរីសួស្តី
យើងខ្ញុំព្រះអង្គ សូមជ្រកក្រោម ម្លប់ព្រះបារមី
នៃព្រះន-របតី វង្សក្សត្រាដែលសាងប្រាសាទថ្ម
គ្រប់គ្រងដែនខ្មែរ បុរាណថ្កើងថ្កាន ។

២- ប្រាសាទសិលា កំបាំងកណ្តាលព្រៃ
គួរឲ្យស្រមៃ នឹកដល់យសសក្តិ មហានគរ
ជាតិខ្មែរដូចថ្ម គង់វង់នៅល្អ រឹងប៉ឹងជំហរ
យើងសង្ឃឹមពរ ភ័ព្វព្រេងសំណាងរបស់កម្ពុជា
មហារដ្ឋកើតមាន យូរអង្វែងហើយ ។

៣- គ្រប់វត្តអារាម ឮតែសូរស័ព្ទធម៌
សូត្រដោយអំណរ រំឭកគុណពុទ្ធសាសនា
ចូរយើងជាអ្នក ជឿជាក់ស្មោះស្ម័គ្រ តាមបែបដូនតា
គង់តែទេវតា នឹងជួយជ្រោមជ្រែងផ្គត់ផ្គង់ប្រយោជន៍ឲ្យ
ដល់ប្រទេសខ្មែរ ជាមហានគរ ។

# ឧបសម្ព័ន្ធទី៣

## សញ្ញាជាតិ



# ឧបសម្ព័ន្ធទី៤

## សច្ចាប្រណិធាន
## នៃ
## ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា

ខ្ញុំតាំងសច្ចាថានឹងប្រព្រឹត្តតាមរដ្ឋធម្មនុញ្ញ និង ច្បាប់ទាំងឡាយនៃព្រះរាជាណាចក្រ ហើយនឹងតាំងចិត្តធ្វើផលប្រយោជន៍ដល់រដ្ឋ និង ប្រជារាស្ត្រ ។

# ឧបសម្ព័ន្ធទី៥

# សច្ចាប្រណិធាន

ទូលព្រះបង្គំ
យើងខ្ញុំ
ប្រធាន អនុប្រធាន និង សមាជិករដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
សូមធ្វើសច្ចាប្រណិធាន
នៅចំពោះព្រះភ័ក្ត្រព្រះមហាក្សត្រ ព្រះភ័ក្ត្រនៃសម្តេចព្រះសង្ឃរាជ
និងទេវតារក្សាស្វេតច្ឆត្រ
ដូចតទៅ ៖

- ក្នុងពេលប្រតិបត្តិការ តាមមុខតំណែងខ្លួន និងក្នុងការបំពេញបេសកកម្ម ដែលប្រជារាស្ត្រកម្ពុជា បានប្រគល់ជូន ចំពោះទូលព្រះបង្គំយើងខ្ញុំគ្រប់ៗរូប ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញាគោរពរដ្ឋធម្មនុញ្ញ បំរើជានិច្ច ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគត នូវផលប្រយោជន៍របស់ប្រជារាស្ត្រ ប្រជាជាតិ និងមាតិភូមិកម្ពុជា ។ ទូលព្រះបង្គំយើងខ្ញុំ សូមសច្ចាថា មិនកេងប្រវ័ញ្ច នូវផលប្រយោជន៍ជាតិ សំរាប់ផ្ទាល់ខ្លួន ឬសំរាប់គ្រួសារ ឬសំរាប់បក្សពួក ឬសំរាប់ភាគីរៀងៗខ្លួនឡើយ ។

- ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញាប្តូរផ្តាច់ហ៊ានបូជាជីវិត ដើម្បីការពារជានិច្ច ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគត នូវ

• ឯករាជ្យភាពទាំងស្រុង នៃមាតុភូមិកម្ពុជា

• អធិបតេយ្យភាពជាតិពេញបរិបូណ៌

• បូរណភាពទឹកដីដ៏ត្រឹមត្រូវតាមច្បាប់ នៅក្នុងព្រំដែនដីគោក និងព្រំដែនសមុទ្រ ដែលកម្ពុជាធ្លាប់មាន ក្នុងជំនាន់ឆ្នាំ ១៩៦៣ ដល់ ១៩៦៩

• ឯកភាពជាតិ ហើយមិនអនុញ្ញាតឲ្យមានការបែងចែង ឬ ការធ្វើអបគមន៍ណាមួយឡើយ ។

- ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញារក្សាទុកជានិច្ច ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគត នូវអព្យាក្រឹត្យភាព និងភាពមិនចូលបក្សសម្ព័ន្ធ សំរាប់កម្ពុជា ហើយមិនអនុញ្ញាតជាដាច់ខាតឲ្យជនណាក៏ដោយ ដែលចង់ជ្រៀតជ្រែកចូលក្នុងផ្ទៃក្នុង នៃកម្ពុជា ឬមកបង្គាប់បញ្ជាចំពោះគោលនយោបាយជាតិ និងអន្តរជាតិ របស់កម្ពុជាបានឡើយ ។ ទូលព្រះបង្គំយើងខ្ញុំ មិនបំរើជាដាច់ខាត នូវផលប្រយោជន៍បរទេស ហើយធ្វើឲ្យខូចខាតដល់ផលប្រយោជន៍ របស់ប្រជារាស្ត្រប្រជាជាតិ និងមាតុភូមិកម្ពុជាឡើយ ។

- ក្នុងការដោះស្រាយបញ្ហាទាំងឡាយ លើផ្ទៃរាបជាតិ និងអន្តរជាតិ ទូលព្រះបង្គំយើងខ្ញុំ នឹងបំបាត់ចោលទាំងស្រុង នូវអំពើហឹង្សាគ្រប់បែបយ៉ាង ។

ប៉ុន្តែ ព្រះរាជាណាចក្រកម្ពុជា សូមរក្សាទុក នូវសិទ្ធិកាន់អាវុធតស៊ូប្រឆាំងនឹងការរំលោភឈ្លានពានមកពីក្រៅ ដើម្បីការពារជាតិមាតុភូមិខ្លួន ។

- ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញាគោរពជានិច្ច ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគត នូវលទ្ធិប្រជាធិបតេយ្យ សេរីនិយម ដែលមានរបបសភា និងពហុបក្ស ព្រមទាំងមានការគោរពយ៉ាងម៉ឺងម៉ាត់ចំពោះសិទ្ធិមនុស្ស ដូចមានចែងក្នុងសេចក្តីប្រកាសជាសកល ស្តីអំពីសិទ្ធិមនុស្ស ។

- ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញាតស៊ូប្រឆាំង អំពើពុករលួយគ្រប់បែបយ៉ាង ប្រឆាំងអយុត្តិធម៌សង្គម ហើយតស៊ូដើម្បីផ្សះផ្សាជាតិ ដើម្បីឯកភាពជាតិ ដើម្បីសន្តិភាពសង្គម និង សន្តិភាពជាតិ ដើម្បីភាពសម្បូរសប្បាយ នៃប្រជារាស្ត្រកម្ពុជា និងដើម្បីភាពរុងរឿង ថ្កើងថ្កាន នៃមាតុភូមិកម្ពុជា ជាទីគោរពសក្ការៈ និងជាទីស្នេហានៃទូលព្រះបង្គំយើងខ្ញុំគ្រប់រូប ។

# ឧបសម្ព័ន្ធទី៦

# សច្ចាប្រណិធាន

ទូលព្រះបង្គំ
យើងខ្ញុំ
នាយករដ្ឋមន្ត្រី និងសមាជិករាជរដ្ឋាភិបាល
សូមធ្វើសច្ចាប្រណិធាន
នៅចំពោះព្រះភ័ក្ត្រព្រះមហាក្សត្រ ព្រះភ័ក្ត្រនៃសម្តេចព្រះសង្ឃរាជ
និងទេវតារក្សាស្វេតច្ឆត្រ
ដូចតទៅ ៖

- ក្នុងពេលប្រតិបត្តិការ តាមមុខតំណែងខ្លួន និងក្នុងការបំពេញបេសកកម្ម ដែលប្រជារាស្ត្រកម្ពុជា បានប្រគល់ជូន ចំពោះទូលព្រះបង្គំយើងខ្ញុំគ្រប់ៗរូប ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញាគោរពរដ្ឋធម្មនុញ្ញ បំរើជានិច្ច ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគត នូវផលប្រយោជន៍ របស់ប្រជារាស្ត្រ ប្រជាជាតិ និងមាតិភូមិកម្ពុជា ។ ទូលព្រះបង្គំយើងខ្ញុំ សូមសច្ចាថា មិនកេងប្រវ័ញ្ច នូវផលប្រយោជន៍ជាតិ សំរាប់ផ្ទាល់ខ្លួន ឬសំរាប់គ្រួសារ ឬសំរាប់បក្សពួក ឬសំរាប់ភាគីរៀងៗខ្លួនឡើយ ។

- ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញាប្តូរផ្តាច់ហ៊ានបូជាជីវិត ដើម្បីការពារជានិច្ច ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគត នូវ

• ឯករាជ្យភាពទាំងស្រុង នៃមាតុភូមិកម្ពុជា

• អធិបតេយ្យភាពជាតិពេញបរិបូណ៌

• បូរណភាពទឹកដីដ៏ត្រឹមត្រូវតាមច្បាប់ នៅក្នុងព្រំដែនដីគោក និងព្រំដែនសមុទ្រ ដែលកម្ពុជាធ្លាប់មាន ក្នុងជំនាន់ឆ្នាំ ១៩៦៣ ដល់ ១៩៦៩

• ឯកភាពជាតិ ហើយមិនអនុញ្ញាតឲ្យមានការបែងចែង ឬ ការធ្វើអបគមន៍ណាមួយឡើយ ។

- ទូលព្រះបង្គំយើងខ្ញុំ សូមប្ដេជ្ញារក្សាទុកជានិច្ច ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគត នូវអព្យាក្រឹត្យភាព និងភាពមិនចូលបក្សសម្ព័ន្ធ សំរាប់កម្ពុជា ហើយមិនអនុញ្ញាតជាដាច់ខាតឲ្យជនណាក៏ដោយ ដែលចង់ជ្រៀតជ្រែកចូលក្នុងផ្ទៃក្នុង នៃកម្ពុជា ឬមកបង្គាប់បញ្ជាចំពោះគោលនយោបាយជាតិ និងអន្តរជាតិរបស់កម្ពុជាបានឡើយ ។ ទូលព្រះបង្គំយើងខ្ញុំ មិនបំរើជាដាច់ខាត នូវផលប្រយោជន៍បរទេស ហើយធ្វើឲ្យខូចខាតដល់ផលប្រយោជន៍ របស់ប្រជារាស្ត្រប្រជាជាតិ និងមាតុភូមិកម្ពុជាឡើយ ។

- ក្នុងការដោះស្រាយបញ្ហាទាំងឡាយ លើផ្ទៃរាបជាតិ និងអន្តរជាតិ ទូលព្រះបង្គំយើងខ្ញុំ នឹងបំបាត់ចោលទាំងស្រុង នូវអំពើហឹង្សាគ្រប់បែបយ៉ាង ។

ប៉ុន្តែ ព្រះរាជាណាចក្រកម្ពុជា សូមរក្សាទុក នូវសិទ្ធិកាន់អាវុធតស៊ូប្រឆាំងនឹងការរំលោភឈ្លានពានមកពីក្រៅ ដើម្បីការពារជាតិមាតុភូមិខ្លួន ។

- ទូលព្រះបង្គំយើងខ្ញុំ សូមប្ដេជ្ញាគោរពជានិច្ច ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគត នូវលទ្ធិប្រជាធិបតេយ្យ សេរីនិយម ដែលមានរបបសភា និងពហុបក្សព្រមទាំងមានការគោរពយ៉ាងម៉ឹងម៉ាត់ចំពោះសិទ្ធិមនុស្ស ដូចមានចែងក្នុងសេចក្ដីប្រកាសជាសកល ស្ដីអំពីសិទ្ធិមនុស្ស ។

- ទូលព្រះបង្គំយើងខ្ញុំ សូមប្ដេជ្ញាតស៊ូប្រឆាំងអំពើពុករលួយគ្រប់បែបយ៉ាង ប្រឆាំងអយុត្តិធម៌សង្គម ហើយតស៊ូដើម្បីផ្សះផ្សាជាតិ ដើម្បីឯកភាពជាតិ ដើម្បីសន្តិភាពសង្គម និង សន្តិភាពជាតិ ដើម្បីភាពសម្បូរសប្បាយ នៃប្រជារាស្ត្រកម្ពុជា និងដើម្បីភាពរុងរឿង ថ្កើងថ្កាន នៃមាតុភូមិកម្ពុជា ជាទីគោរពសក្ការៈ និងជាទីស្នេហានៃទូលព្រះបង្គំយើងខ្ញុំគ្រប់រូប ។

# ឧបសម្ព័ន្ធទី៧

# សច្ចាប្រណិធាន

**ទូលព្រះបង្គំ**
**យើងខ្ញុំ**
**ប្រធាន អនុប្រធាននិងសមាជិកព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា**
**សូមធ្វើសច្ចាប្រណិធាន**
**នៅចំពោះព្រះភ័ក្ត្រព្រះមហាក្សត្រ ព្រះភ័ក្ត្រនៃសម្តេចព្រះសង្ឃរាជ**
**និងទេវតារក្សាស្វេតច្ឆត្រ**
**ដូចតទៅ :**

- ក្នុងពេលប្រតិបត្តិការ តាមមុខតំណែងខ្លួន និងក្នុងការបំពេញបេសកកម្មដែលប្រជារាស្ត្រកម្ពុជា បានប្រគល់ជូនចំពោះទូលព្រះបង្គំយើងខ្ញុំគ្រប់ៗរូប ទូលព្រះបង្គំយើងខ្ញុំសូមប្តេជ្ញាគោរពរដ្ឋធម្មនុញ្ញ បំរើជានិច្ច ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគតនូវផលប្រយោជន៍របស់ប្រជារាស្ត្រ ប្រជាជាតិនិងមាតុភូមិកម្ពុជា ។ ទូលព្រះបង្គំយើងខ្ញុំ សូមសច្ចាថា មិនកេងប្រវ័ញ្ចនូវផលប្រយោជន៍ជាតិ សំរាប់ផ្ទាល់ខ្លួន ឬសំរាប់គ្រួសារ ឬសំរាប់បក្សពួក ឬសំរាប់ភាគីរៀងៗខ្លួនឡើយ ។

- ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញាប្តូរផ្តាច់ហ៊ានបូជាជីវិត ដើម្បីការពារជានិច្ច ទាំងក្នុងបច្ចុប្បន្នទាំងក្នុងអនាគតនូវ :

  - ឯករាជ្យភាពទាំងស្រុងនៃមាតុភូមិកម្ពុជា
  - អធិបតេយ្យភាពជាតិពេញបរិបូណ៌

• បូរណភាពទឹកដីដ៏ត្រឹមត្រូវតាមច្បាប់ នៅក្នុងព្រំដែនដីគោក និងព្រំដែនសមុទ្រ ដែលកម្ពុជាធ្លាប់មាន ក្នុងជំនាន់ឆ្នាំ១៩៦៣ ដល់១៩៦៩

• ឯកភាពជាតិ ហើយមិនអនុញ្ញាតឱ្យមានការបែងចែក ឬ ការធ្វើអបគមន៍ណាមួយឡើយ ។

- ទូលបង្គំយើងខ្ញុំ សូមប្ដេជ្ញារក្សាទុកជានិច្ច ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគតនូវអព្យាក្រឹត្យភាព និងភាពមិនចូលបក្សសម្ព័ន្ធសំរាប់កម្ពុជា ហើយមិនអនុញ្ញាតជាដាច់ខាតឱ្យជនណាមួយក៏ដោយ ដែលចង់ជ្រៀតជ្រែកចូលក្នុងផ្ទៃក្នុងនៃកម្ពុជា ឬមកបង្គាប់បញ្ជាចំពោះគោលនយោបាយជាតិ និងអន្តរជាតិរបស់កម្ពុជាបានឡើយ ។ ទូលព្រះបង្គំយើងខ្ញុំ មិនបំរើជាដាច់ខាតនូវផលប្រយោជន៍បរទេស ហើយធ្វើឱ្យខូចខាតដល់ផលប្រយោជន៍របស់ប្រជារាស្ត្រប្រជាជាតិ និងមាតុភូមិកម្ពុជាឡើយ ។

- ក្នុងការដោះស្រាយបញ្ហាទាំងឡាយលើផ្ទៃរាបជាតិនិងអន្តរជាតិ ទូលព្រះបង្គំយើងខ្ញុំ នឹងបំបាត់ចោលទាំងស្រុងនូវអំពើហឹង្សាគ្រប់បែបយ៉ាង ។

ប៉ុន្តែ ព្រះរាជាណាចក្រកម្ពុជា សូមរក្សាទុកនូវសិទ្ធិកាន់អាវុធតស៊ូប្រឆាំងនឹងការរំលោភឈ្លានពានមកពីក្រៅ ដើម្បីការពារជាតិមាតុភូមិខ្លួន ។

- ទូលព្រះបង្គំយើងខ្ញុំ សូមប្ដេជ្ញាគោរពជានិច្ចទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគត នូវលទ្ធិប្រជាធិបតេយ្យ សេរីនិយម ដែលមានរបបសភា និងពហុបក្សព្រមទាំងមានការគោរពយ៉ាងម៉ឺងម៉ាត់ចំពោះសិទ្ធិមនុស្ស ដូចមានចែងក្នុងសេចក្ដីប្រកាសជាសកលស្ដីអំពីសិទ្ធិមនុស្ស ។

- ទូលព្រះបង្គំយើងខ្ញុំ សូមប្ដេជ្ញាតស៊ូប្រឆាំងអំពើពុករលួយគ្រប់បែបយ៉ាងប្រឆាំងអយុត្តិធម៌សង្គម ហើយតស៊ូដើម្បីផ្សះផ្សាជាតិ ដើម្បីឯកភាពជាតិ ដើម្បីសន្តិភាពសង្គម និង សន្តិភាពជាតិ ដើម្បីភាពសម្បូរសប្បាយ នៃប្រជារាស្ត្រកម្ពុជា និងដើម្បីភាពរុងរឿងថ្កើងថ្កាន នៃមាតុភូមិកម្ពុជា ជាទីគោរពសក្ការៈ និងជាទីស្នេហានៃទូលព្រះបង្គំយើងខ្ញុំគ្រប់រូប ។

# គណៈកម្មការអចិន្ត្រៃយ៍រៀបរៀងរដ្ឋធម្មនុញ្ញ
## បានអនុម័តដោយសភាធម្មនុញ្ញនាសម័យប្រជុំពេញអង្គលើកទី ១
## ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៩៣

| | | | |
|---|---|---|---|
| ១- | ឯកឧត្តមសម្តេចប្រធានសភាធម្មនុញ្ញឬឯកឧត្តមអនុប្រធានសភាធម្មនុញ្ញ « ករណីសម្តេចប្រធានអវត្តមាន » ជាប្រធាន * | | |
| ២- | ឯកឧត្តម | ចែម ស្ងួន | ជាអនុប្រធាន |
| ៣- | ឯកឧត្តមបណ្ឌិត | តាវ សេងហួរ | ជាអ្នករាយការណ៍ |
| ៤- | ឯកឧត្តម | កាន់ ម៉ន | ជាសមាជិក |
| ៥- | ឯកឧត្តម | គាត ឈន់ | ជាសមាជិក |
| ៦- | ឯកឧត្តម | ឈួរ លាងហួត | ជាសមាជិក |
| ៧- | ឯកឧត្តម | ប៉ោ ប៉េងលាត | ជាសមាជិក |
| ៨- | ឯកឧត្តម | សម រង្ស៊ី | ជាសមាជិក |
| ៩- | អ្នកអង្គម្ចាស់ | ស៊ីសុវត្ថិ សិរីរត្ន | ជាសមាជិក |
| ១០- | ឯកឧត្តម | ស៊ីន ស៊ូប៉ែរ៉្គ | ជាសមាជិក |
| ១១- | ឯកឧត្តម | សោម ចាន់បុត្រ | ជាសមាជិក |
| ១២- | ឯកឧត្តម | អ៊ុន នឹង | ជាសមាជិក |
| ១៣- | ឯកឧត្តម | ឡូយ ស៊ីមឈាង | ជាសមាជិក |
| ១៤- | ឯកឧត្តម | ជាម យៀប | ជាសមាជិកបំរុង |
| ១៥- | ឯកឧត្តម | ប៉ុល ហំម | ជាសមាជិកបំរុង |
| ១៦- | ឯកឧត្តម | ពូ សុធីរៈ | ជាសមាជិកបំរុង |
| ១៧- | ឯកឧត្តម | សរ សាអាត | ជាសមាជិកបំរុង |

| | | |
|---|---|---|
| ១៨- ឯកឧត្តម | អ៊ឹង គៀត | ជាសមាជិកបំរុង |
| ១៩- ឯកឧត្តម | អ៊ុក រ៉ាប៊ុន | ជាសមាជិកបំរុង |
| ២០- ឯកឧត្តម | អ៊ុង ផន | ជាសមាជិកបំរុង |
| ២១- ឯកឧត្តម | ឯក សំអុល | ជាសមាជិកបំរុង |
| ២២- ឯកឧត្តម | សាយ បូរី | ជាអ្នកជំនាញការ |
| ២៣- ឯកឧត្តម | ចាន់ សុខ | ជាអ្នកជំនាញការ |
| ២៤- ឯកឧត្តម | ឈន អៀម | ជាអ្នកជំនាញការ |
| ២៥- ឯកឧត្តម | ហេង វង្សប៊ុនឆាត | ជាអ្នកជំនាញការ |
| ២៦- ឯកឧត្តម | ខៀវ រ៉ាដា | ជាអ្នកជំនាញការ |

<u>**កំណត់សំគាល់**</u> : * យោងជំពូក៧ប្រការ១៨ស្តីពីការគណៈកម្មការ និង ប្រធានគណៈកម្មការសភាធម្មនុញ្ញ

# គណៈកម្មការរៀបរៀង

| ល.រ | ឈ្មោះ | តួនាទី |
|---|---|---|
| ១ | **ឯកឧត្តម លី ច័ន្ទតុលា** | អនុប្រធាន និងជា អគ្គលេខាធិការ គ.ក.ច. |
| ២ | **ឯកឧត្តម ប៉ែន ប៊ុនឈា** | អគ្គលេខាធិការរង គ.ក.ច. |
| ៣ | **ឯកឧត្តម សោម គន្ធា** | អគ្គលេខាធិការរង គ.ក.ច. |
| ៤ | **លោក អៀប សុធានី** | អនុប្រធាននាយកដ្ឋាន |
| ៥ | **លោក ឱន ស៊ីដែន** | អ្នកជំនាញការច្បាប់ |
| ៦ | **លោកស្រី ឡេង ចាន់តួច** | អ្នកជំនាញការច្បាប់ |
| ៧ | **លោក មាឃ សីហា** | អ្នកជំនាញការច្បាប់ |
| ៨ | **លោក ម៉ន សុភ័ណ** | អ្នកជំនាញការច្បាប់ |
| ៩ | **លោក ម៉ិញ សុមេត្តា** | អ្នកជំនាញការច្បាប់ |
| ១០ | **លោក ច័ន្ទតារា រ៉ូម៉ែន** | អ្នកជំនាញការច្បាប់ |
| ១១ | **កញ្ញា តោគ សិរីរតនា** | អ្នកជំនាញការច្បាប់ |
| ១២ | **លោកស្រី ប៉ែន លីនណា** | អ្នកជំនាញការច្បាប់ |
| ១៣ | **លោក នៅ ដានន្ទ** | អ្នកជំនាញការច្បាប់ |
| ១៤ | **លោក ហួរ ម៉ូពិធាន** | អ្នកជំនាញការច្បាប់ |
| ១៥ | **លោក ណោង សីហា** | អ្នកជំនាញការច្បាប់ |

"គ.ក.ច.
ជានិម្មាបនករនៃ
ប្រព័ន្ធច្បាប់និង
វប្បធម៌នីតិរដ្ឋ
ដោយផ្អែកលើ
គុណតម្លៃប្រវត្តិសាស្ត្រ
របស់កម្ពុជា និង
គុណតម្លៃសាកល"

QR CODE បណ្ដាញទំនាក់ទំនង
របស់គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់